ហាមលក់
កម្មសិទ្ធិរបស់រដ្ឋ

ក្រសួងអប់រំ យុវជន និងកីឡា

# អប់រំសុខភាព

## សម្រាប់គ្រូ

# ៦







គំហើញភ្នែកម្ញ៉ុប




គំហើញភ្នែកធម្មតា

នាយកដ្ឋានសុខភាពសិក្សា

## គណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សា

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** លោកជំទាវ **គឹម សេដ្ឋានី**

លោកជំទាវបណ្ឌិត **ស៊ឿ សុជាតា** លោកជំទាវ **ទន់ សារអ៊ីម**

ឯកឧត្តម **ពុត សាមិត្ត** លោកជំទាវវេជ្ជបណ្ឌិត **ឆាយគឹម សុទ្ធាវី**

## គណៈកម្មការនិពន្ធ

លោកស្រី **ពេជ សុគន្ធា** លោកស្រី **ហ៊ុន ហ៊្សីឌីឡា** លោកស្រី **ធឹម លន់**

លោក **ឡឹង ឧុទ្ធី** លោកស្រី **ផៃ សុខសាន្ត**

## គណៈកម្មការរៀបរៀងនិងពិនិត្យ

លោកជំទាវវេជ្ជបណ្ឌិត **ឆាយគឹម សុទ្ធាវី** ឯកឧត្តមវេជ្ជបណ្ឌិត **យង់ គន្ធារិទ្ធ**

លោកជំទាវវេជ្ជបណ្ឌិត **សូ ឆវីរត្ន**

## ជំនួយការបច្ចេកទេស

លោក **គូ ប៊ុនឃាង**

## វិចិត្រករ

លោក **ឡុង សុវណ្ណា**

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ .................. អយក.ប្រក. ចុះថ្ងៃទី.....ខែ........ឆ្នាំ២០២២ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

**ហាមថតចម្លង**

រក្សាសិទ្ធិ ©

**នាយកដ្ឋានសុខភាពសិក្សា**

បោះពុម្ពផ្សាយ ឆ្នាំ២០២២

ចំនួន ........................ច្បាប់

## អ្នកពិគ្រោះយោបល់បច្ចេកទេស

- លោកទន្តបណ្ឌិត **ហាក់ ស៊ីថន** ក្រសួងសុខាភិបាល
- លោកស្រីទន្តបណ្ឌិត **ឆៃ ទេព្វិរូ** ក្រសួងសុខាភិបាល
- លោកស្រីវេជ្ជបណ្ឌិត **ហុក ស៊ីវ៉ាន្នី** ក្រសួងសុខាភិបាល
- លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ដោរ សីហា** ក្រសួងសុខាភិបាល
- លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ម៉ារ អមរិន្ទ** ក្រសួងសុខាភិបាល
- លោកស្រីវេជ្ជបណ្ឌិត **អ៊ុក សុគន្ធ** ក្រសួងសុខាភិបាល
- លោក **ភុត សុធា** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- លោក **វ៉ាត់ សិទ្ធ** ក្រសួងបរិស្ថាន
- លោកសាស្ត្រាចារ្យ **កៅ សុវណ្ណតារា** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- លោកវេជ្ជបណ្ឌិត **ឃឹម សំអាត** អង្គការ WHO
- លោកវេជ្ជបណ្ឌិត **ឃិល ដារ៉ាឌុច** អង្គការ WHO
- លោក **ជុំ ចាន់រ៉ា** អង្គការ UNICEF
- លោកស្រីបណ្ឌិត **ចុង វណ្ណដារ៉ា** អង្គការ UNFPA
- លោកស្រី **សេក ស៊ីសុខុម** អង្គការថែទាំសុខភាពគ្រួសារកម្ពុជា RHAC
- លោកស្រីបណ្ឌិត **សាផន សុមោលីរស្មី** អង្គការថែទាំសុខភាពគ្រួសារកម្ពុជា RHAC
- លោក **តាន់ តីរៈ** អង្គការថែទាំសុខភាពគ្រួសារកម្ពុជា RHAC
- កញ្ញា Eri Kai អង្គការ FIDR
- លោកស្រី **គឹម ចាន់រ៉ាច័យ** អង្គការ FIDR
- លោក **រី ម៉ូរ៉ា** អង្គការ FIDR
- លោកបណ្ឌិត **ភឿន ប៊ុណ្ណា** សមាគម EMDR
- កញ្ញា **ហុង ណៃស៊ីម** សមាគម EMDR
- លោក **ភុល សុភារិទ្ធ** សមាគម EMDR
- លោក **ហែម តា** អង្គការ HAGAR Cambodia

# អារម្ភកថា

សៀវភៅ “អប់រំសុខភាព” សម្រាប់គ្រូថ្នាក់ទី៦ នេះ ត្រូវបានរៀបចំឡើងតម្រូវទៅតាមមេរៀនដែលមាននៅក្នុងសៀវភៅអប់រំសុខភាពសម្រាប់សិស្ស ដោយបានកំណត់ច្បាស់លាស់នូវចំនួនម៉ោងនៃការបង្រៀនមេរៀននីមួយៗ ដែលបានកំណត់នៅក្នុងកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំសុខភាព។ សៀវភៅនេះមានបង្ហាញពីវិធីសាស្ត្របង្រៀន តាមបែបសិស្សមជ្ឈមណ្ឌល ដើម្បីជាជំនួយដល់គ្រូបង្រៀនក្នុងការរិះរកគំនិតច្នៃប្រឌិត បង្កើតសកម្មភាពបង្រៀន ធ្វើឱ្យមានការចូលរួមពីសិស្ស សំដៅឱ្យសិស្សចងចាំបានល្អ។ ការបង្រៀននិងរៀនមុខវិជ្ជាអប់រំសុខភាព មានគោលដៅឱ្យអ្នកសិក្សា មានចំណេះដឹងសុខភាព ស្របតាមការលូតលាស់រាងកាយនិងស្មារតីប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ បំណិនសម្រាប់បង្ការជំងឺ ឆ្លង ជំងឺមិនឆ្លង គ្រោះថ្នាក់ផ្សេងៗ និងវិធីជួយសង្គ្រោះបឋម គុណតម្លៃនិងឥរិយាបថដែលនាំឱ្យពួកគេអភិវឌ្ឍខ្លួនប្រកបដោយភាពពេញលេញទាំងកាយ ប្រាជ្ញាស្មារតីនិងចេះទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន។

គោលដៅនៃមេរៀននីមួយៗ បានកំណត់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាសម្រាប់លោកគ្រូ អ្នកគ្រូរៀបចំសកម្មភាពបង្រៀនតាមវិធីសាស្ត្រចូលរួមទាំងការសិក្សាបែបបញ្ញត្តិ បែបរិះរក និងបែបប្រធានបទ។ លោកគ្រូ អ្នកគ្រូអាចប្រើប្រាស់វិធីសាស្ត្រលាយច្របាច់បញ្ចូលគ្នា ដោយមានភាពទន់ភ្លន់ បត់បែនតាមខ្លឹមសារនៃមេរៀន ធ្វើយ៉ាងណាបង្កើនពុទ្ធិដល់សិស្សក្នុងការប្រកាន់យកនិងអនុវត្តប្រចាំថ្ងៃរបស់ពួកគេដើម្បីបង្ការជំងឺឆ្លង ជំងឺមិនឆ្លង និងគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងបំណិនថែទាំសុខភាពជាប់ជាប្រចាំទាំងពេលបច្ចុប្បន្ននិងទៅអនាគត សំដៅធ្វើឱ្យខ្លួនឯងនិងអ្នកនៅជុំវិញខ្លួនមានសុខភាពល្អកម្លាំងមាំមួន និងមានសុវត្ថិភាពគ្រប់កាលៈទេសៈក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

យើងខ្ញុំជាគណៈកម្មការនិពន្ធ សង្ឃឹមថា សៀវភៅនេះ នឹងក្លាយជាឯកសារគោលដ៏សំខាន់សម្រាប់ការបង្រៀនមុខវិជ្ជាអប់រំសុខភាព។ ព្រមជាមួយគ្នានេះ យើងខ្ញុំរង់ចាំទទួលយកនូវរាល់សំណួរនិងមតិចូលរួមផ្សេងៗ អំពីសំណាក់លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាពីគ្រប់មជ្ឈដ្ឋាន ដើម្បីជួយលើកស្ទួយមុខវិជ្ជាអប់រំសុខភាពកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

**គណៈកម្មការនិពន្ធ**

# បញ្ជីអត្ថបទ


សមាសភាគទី១ : សុខភាពបឋម ........ 1
ជំពូកទី១ : ការលូតលាស់និងអាហាររូបត្ថម្ភ ........ 1
មេរៀនទី ១ : គុណភាពអាហារ ........ 1
មេរៀនទី ២ : ការតាមដានទម្ងន់និងកម្ពស់ ........ 8
មេរៀនទី ២ : ការតាមដានទម្ងន់និងកម្ពស់ (តចប់) ........ 12
៤- ខ្លឹមសារនិងគំនិតសំខាន់ៗ ........ 12
មេរៀនទី ៣ : ទំនាក់ទំនងរវាងរបបអាហារនិងជំងឺ ........ 18
មេរៀនទី ៤ : សុវត្ថិភាពចំណីអាហារ ........ 23
មេរៀនទី ៤ : សុវត្ថិភាពចំណីអាហារ (តចប់) ........ 27
ជំពូកទី ២ : អនាម័យខ្លួនប្រាណនិងអនាម័យទូទៅ ........ 36
មេរៀនទី ១ : ទឹកសុវត្ថិភាព ........ 36
មេរៀនទី ១ : ទឹកសុវត្ថិភាព (តចប់) ........ 40
មេរៀនទី ២ : អនាម័យនៅផ្ទះ ........ 43
ជំពូកទី៣ : ការថែទាំភ្នែកនិងមាត់ធ្មេញ ........ 49
មេរៀនទី ១ : ទំនាក់ទំនងសុខភាពមាត់ធ្មេញនិងសុខភាពទូទៅ ........ 49
មេរៀនទី ១ : ទំនាក់ទំនងសុខភាពមាត់ធ្មេញនិងសុខភាពទូទៅ (តចប់) ........ 53
មេរៀនទី ២ : កំហុសកំណុំរូបភាព ........ 57
មេរៀនទី ២ : កំហុសកំណុំរូបភាព (តចប់) ........ 61
ជំពូកទី៤ : ការបង្ការជំងឺឆ្លង ........ 66
មេរៀនទី ១ : ជំងឺដង្កូវព្រូន ........ 66
មេរៀនទី ១ : ជំងឺដង្កូវព្រូន (តចប់) ........ 69
មេរៀនទី ២ : ជំងឺគ្រុនឈាមផ្តាសាយ ........ 73
សមាសភាគទី២ : សុខភាពផ្លូវចិត្ត ........ 78
មេរៀនទី ១ : សម្ពាធអវិជ្ជមានពីមិត្តភក្តិនិងការគ្រប់គ្រងអារម្មណ៍ ........ 78
មេរៀនទី១ : សម្ពាធអវិជ្ជមានពីមិត្តភក្តិនិងការគ្រប់គ្រងអារម្មណ៍ (តចប់) ........ 81
មេរៀនទី ២ : ទំនាក់ទំនងនៅពេលពេញវ័យ ........ 85
សមាសភាគទី៣ : សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ........ 91
ជំពូកទី១ : ការអប់រំជីវិតផ្លូវភេទ ........ 91
មេរៀនទី ១ : ការប្រើប្រាស់អ៊ីនធើណិត និងបណ្តាញសង្គមទំនាក់ទំនង ........ 91
មេរៀនទី ២ : ការបៀតបៀនផ្លូវភេទ ........ 97

មេរៀនទី ៣ : ចំណាង់ផ្លូវភេទ ........ 102
មេរៀនទី ៤ : អំពើហិង្សា ........ 106
មេរៀនទី ៥ : មិត្តភក្តិមានឥទ្ធិពលទៅលើការសម្រេចចិត្ត ........ 110
មេរៀនទី ៦ : គោលដៅអនាគត ........ 114
**ជំពូកទី២ : សីលធម៌ក្នុងជីវិតផ្លូវភេទ** ........ 118
មេរៀនទី ១ : សិទ្ធសុខភាពផ្លូវភេទនិងបន្តពូជ ........ 118
មេរៀនទី ២ : ការអប់រំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ........ 122
មេរៀនទី ៣ : ការបង្ករោគតាមប្រព័ន្ធបន្តពូជ ........ 127
មេរៀនទី ៣ : ការបង្ករោគតាមប្រព័ន្ធបន្តពូជ (តចប់) ........ 130
មេរៀនទី ៤ : មេរោគអេដស៍និងជំងឺអេដស៍ ........ 133
មេរៀនទី ១ : វិធានការសង្គ្រោះបឋម ........ 138
មេរៀនទី ១ : វិធានការសង្គ្រោះបឋម (ត) ........ 141
មេរៀនទី ១ : វិធានការសង្គ្រោះបឋម (តចប់) ........ 145
មេរៀនទី ២ : ការបំពុលខ្យល់ និងផលប៉ះពាល់សុខភាព ........ 148
មេរៀនទី ៣ : ការរំខានដោយសំឡេងមកលើសុខភាព ........ 152

# មេរៀនទី ១ : តុល្យភាពអាហារ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមានៈ

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យ"តុល្យភាពអាហារ"<br>• រៀបរាប់ពីសារសំខាន់នៃការបរិភោគអាហារមានតុល្យភាព និងផលវិបាកនៃការបរិភោគគ្មានតុល្យភាព។ | • បកស្រាយពីសារៈសំខាន់នៃការបរិភោគអាហារមានតុល្យភាព។<br>• បកស្រាយពីផលវិបាកនៃការបរិភោគអាហារដែលគ្មានតុល្យភាព។ | • មានទម្លាប់បរិភោគអាហារមានតុល្យភាពត្រឹមត្រូវ ដើម្បីសុខភាពល្អ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

និយមន័យ តុល្យភាពអាហារ គឺជាការបរិភោគអាហារចម្រុះមុខនៅក្នុងបរិមាណសមស្រប ដើម្បីទទួលបាន និងរក្សានូវទម្ងន់រាងកាយឱ្យមានសុខភាពល្អ។

អាហារមានតុល្យភាព គឺជាការបរិភោគអាហារចម្រុះមុខក្នុងបរិមាណត្រឹមត្រូវទៅតាមគោលការណ៍ ពីរ៉ាមីតអាហារ។ អាហារគ្មានតុល្យភាព គឺជាការបរិភោគអាហារមិនចម្រុះមុខក្នុងបរិមាណមិនត្រឹមត្រូវទៅតាមគោលការណ៍ពីរ៉ាមីតអាហារ។

សារៈសំខាន់នៃអាហារដែលមានតុល្យភាព មានសារៈសំខាន់រួមជាមួយនិងការធ្វើសកម្មភាពរាងកាយបានទៀងទាត់ យើងនឹងទទួលបានជីវិតពោរពេញដោយសុខភាព។

ផលវិបាកនៃការបរិភោគអាហារគ្មានតុល្យភាព អាចឱ្យ ស្គមស្គាំង គ្មានកម្លាំង លើសទម្ងន់ ធាត់ ឬស្រកទម្ងន់ មិនអាចផ្តោតស្មារតីលើការសិក្សាបានល្អ ការលូតលាស់យឺតយ៉ាវ មានជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម និងជំងឺបេះដូងនៅពេលដែលមានវ័យចំណាស់។

**៥- វិធីសាស្ត្រ**

សំណួរបំផុស សំណួរ ចម្លើយ ពិភាក្សាការងារជាដៃគូ/ក្រុម ពន្យល់ បកស្រាយ សំយោគ ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន  អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូសួរសំណួរបំផុសៈ
  - តើរាល់ថ្ងៃអ្នកបានបរិភោគអាហារអ្វីខ្លះ ? គ្រូហៅសិស្ស២ ឬ៣នាក់ឆ្លើយ
  - តើអ្នកបរិភោគអាហារបានគ្រប់គ្រាន់ដែរឬទេ ? គ្រូហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ។
  - សិស្សឆ្លើយៈ ................
  - គ្រូសម្របសម្រួលនិងសំយោគចម្លើយ។
  - គ្រូសរសេរចំណងជើងមេរៀនដាក់លើក្ដាខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : និយមន័យ**

គ្រូសួរៈ ដូចម្ដេចដែលហៅថា តុល្យភាពអាហារ ? គ្រូហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ។ សិស្សឆ្លើយៈ .....

- គ្រូពន្យល់ ដោយលើយករូបភាពមកបង្ហាញ។

**ចម្លើយ**

តុល្យភាព មានន័យថាភាពស្មើគ្នា ឬភាពមានលំនឹង។

ដូចនេះ នៅពេលដែលយើងនិយាយពីសុខភាពដែលមានតុល្យភាព គឺយើងចង់ឱ្យសុខភាពរបស់យើងមានលំនឹង ឬមានសុខភាពល្អ។ ដើម្បីធ្វើឱ្យយើងមានសុខភាពល្អ នោះគឺយើងត្រូវតែបរិភោគអាហារដែលមានតុល្យភាព។

តុល្យភាពអាហារ គឺជាការបរិភោគអាហារចម្រុះមុខនៅក្នុងបរិមាណសមស្រប ដើម្បីទទួលបាននិងរក្សានូវទម្ងន់រាងកាយឱ្យមានសុខភាពល្អ។



រូបភាពមានតុល្យភាព



អាហារដែលមានតុល្យភាព

**ខ្លឹមសារ : អាហារមានតុល្យភាព**

- គ្រូពន្យល់៖ របបអាហារមានតុល្យភាពមានន័យថាត្រូវបរិភោគអាហារគ្រប់ប្រភេទជាមួយនឹងបរិមាណត្រឹមត្រូវដោយផ្អែកទៅលើពីរ៉ាមីតអាហារ។ តើអ្នកនៅចាំអំពីពីរ៉ាមីតអាហារដែលបានសិក្សានៅថ្នាក់ទី ៤ ដែរឬទេ ?
- គ្រូបង្ហាញពីរ៉ាមីតអាហារ។  ដូច្នេះនៅពេលដែលអ្នកបរិភោគមិនបានត្រឹមត្រូវទៅនឹងការណែនាំនៃពីរ៉ាមីតអាហារនោះមានន័យថាអ្នកកំពុងតែបរិភោគរបបអាហារគ្មានតុល្យភាព។




អាហារដែលមានតុល្យភាព

- គ្រូពន្យល់បន្ត៖

**របបអាហារមានតុល្យភាព = អាហារសុខភាព**

របបអាហារមានតុល្យភាពមានសារៈសំខាន់ ដើម្បីបង្កើតនូវទម្លាប់នៃការបរិភោគអាហារប្រកបដោយសុខភាពល្អ។ ការបរិភោគរបបអាហារមានតុល្យភាពរួមជាមួយនិងការធ្វើសកម្មភាពរាងកាយបានទៀងទាត់ យើងនឹងទទួលបានជីវិតពោរពេញដោយសុខភាព។



បរិភោគអាហារសមស្រប និងចម្រុះមុខ | ហាត់កីឡាជាប្រចាំ | រាងកាយមានសុខភាពល្អ

**ខ្លឹមសារ : អាហារគ្មានតុល្យភាព**

- តើអ្វីទៅជារបបអាហារគ្មានតុល្យភាព ? តើវាមានលក្ខណៈដូចម្តេច ?

- គ្រូពន្យល់ដោយមើលរូបខាងក្រោម៖



អាហារដែលគ្មានតុល្យភាព

**របបអាហារគ្មានតុល្យភាពអាចបណ្តាលទៅជាទម្លាប់នៃការបរិភោគរបបអាហារមិនមានសុខភាព**

នៅពេលយើងបរិភោគរបបអាហារគ្មានតុល្យភាព គឺអាចជាការដឹកនាំខ្លួនយើងទៅរកទម្លាប់នៃការបរិភោគរបបអាហារមិនមានសុខភាព។ ខាងក្រោមជាទម្លាប់នៃការបរិភោគអាហារដែលគ្មានតុល្យភាព៖

- បរិភោគនូវអាហារដែល ផ្អែមខ្លាំង ប្រៃខ្លាំង និងខ្លាញ់ច្រើន
- មិនបរិភោគបន្លែ ឬបរិភោគតែអាហារណាដែលចូលចិត្ត (ជាអ្នករើសចំណីអាហារ)
- បរិភោគច្រើនពេកឬតិចពេក។

ទម្លាប់នៃការបរិភោគអាហារបែបនេះនឹងអាចធ្វើឱ្យអ្នកប្រឈមនឹងបញ្ហាសុខភាពធ្ងន់ធ្ងរទៅថ្ងៃអនាគត។



បរិភោគអាហារ ផ្អែមខ្លាំង ប្រៃខ្លាំង និងខ្លាញ់ច្រើន



មិនបរិភោគបន្លែ ឬបរិភោគតែអាហារណាដែលចូលចិត្ត



បរិភោគច្រើនពេកឬតិចពេក

## ខ្លឹមសារ : សារៈសំខាន់អាហារដែលមានតុល្យភាព និងផលវិបាកនៃការបរិភោគអាហារគ្មានតុល្យភាព

- សកម្មភាព : គ្រូបែងចែកសិស្សជាក្រុមពិភាក្សាពីសារៈសំខាន់អាហារដែលមានតុល្យភាព និងផលវិបាកនៃការបរិភោគអាហារគ្មានតុល្យភាព ដោយបំពេញក្នុងតារាងខាងក្រោម៖

| សារៈសំខាន់អាហារដែលមានគុណភាព | ផលវិបាកនៃការបរិភោគអាហារគ្មានគុណភាព |
|---|---|
| | |

- តំណាងក្រុមឡើងរាយការណ៍និងបកស្រាយ
- គ្រូសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ**

| សារៈសំខាន់អាហារដែលមានគុណភាព | ផលវិបាកនៃការបរិភោគអាហារគ្មានគុណភាព |
|---|---|
| ជួយឱ្យយើងទទួលបាននូវសារធាតុចិញ្ចឹមសំខាន់ៗដែលយើងត្រូវការ។ ការបរិភោគរបបអាហារដែលមានគុណភាពជួយឱ្យ៖<br><br>រាងកាយមានសុខភាពល្អ<br><br>របៀបរស់នៅមានសុខភាពល្អ<br><br>អារម្មណ៍/ផ្លូវចិត្តល្អប្រសើរ ផ្តោតអារម្មណ៍លើការសិក្សា | – ប្រសិនបើយើងបរិភោគអាហារដែលគ្មានគុណភាពជាញឹកញាប់ តើនឹងមានអ្វីកើតឡើង ?<br>– ការបរិភោគអាហារគ្មានគុណភាពអាចឱ្យ ស្គមស្គាំង គ្មានកម្លាំង លើសទម្ងន់ ធាត់ ឬស្រកទម្ងន់ មិនអាចផ្តោតស្មារតីលើការសិក្សាបានល្អ ការលូតលាស់យឺតយ៉ាវ មានជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម និងជំងឺបេះដូងនៅពេលអាយុលើសពី៣០ឆ្នាំឡើងទៅ។<br><br>ស្គមស្គាំង គ្មានកម្លាំង<br><br>ធាត់ឬលើសទម្ងន់<br><br><br>មិនអាចផ្តោតស្មារតីលើការសិក្សាបានល្អ |

**គ្រូពន្យល់បន្ថែមរូបភាពខាងក្រោម**



**ប្រសិនបើ**

មាន

របបអាហារ

ឬ

មាន

សកម្មភាពរាងកាយ

ឬ

ខ្វះទាំងពីរ ➡ **មិនអាចមានជីវិតដែលពោរពេញដោយសុខភាពទេ**

ប្រសិនបើមានតែមួយឬខ្វះទាំងពីរ យើងមិនអាចមានជីវិតដែលពោរពេញដោយសុខភាពទេ។ មានន័យថា អ្នកមិនអាចរក្សាបាននូវសុខភាពល្អទេ។ នេះជាមូលហេតុដែលរបបអាហារមានតុល្យភាពមានសារៈសំខាន់ ពីព្រោះជីវិតដែលពោរពេញដោយសុខភាពគឺពិតជាជួយអ្នកឱ្យមានសុខភាពល្អ។

ទោះយ៉ាងណាក៏ដោយ គឺមិនមានភាពប្រាកដឬជាក់ស្តែងទេ ដែលយើងអាចបរិភោគរបបអាហារមានតុល្យភាព ៣ ដងក្នុងមួយថ្ងៃជារៀងរាល់ថ្ងៃនោះ។ វាមិនអីទេដែលនៅក្នុងឱកាសខ្លះ ជាពិសេសក្នុងអំឡុងពេលមានកម្មវិធីឬថ្ងៃឈប់សម្រាកពិសេស យើងអាចបរិភោគអាហារមិនមានតុល្យភាពឬអាហារមិនមានសុខភាព។ ប៉ុន្តែប្រសិនបើយើងបរិភោគអាហារមិនមានសុខភាពជារៀងរាល់ពេល ហើយបន្តបរិភោគអាហារមិនមានតុល្យភាពក្នុងរយៈពេលយូរ វាអាចប៉ះពាល់ដល់សុខភាពរបស់យើងនិងនាំឱ្យមានបញ្ហាធ្ងន់ធ្ងរនាពេលអនាគត។

**សារគន្លឹះ**

- ✓ លើកទឹកចិត្តដល់សិស្សពិតជាមានសារៈសំខាន់ដើម្បីឱ្យពួកគេអនុវត្ត និងអភិវឌ្ឍន៍នូវទម្លាប់នៃការបរិភោគអាហារដែលធ្វើឱ្យមានសុខភាពល្អ
- ✓ ការបរិភោគអាហារដែលមានតុល្យភាពអាហារជារៀងរាល់ថ្ងៃ និងគ្រប់ពេលគឺពិតជាលំបាកសម្រាប់ការរស់នៅជាក់ស្តែង
- ✓ ការអភិវឌ្ឍទម្លាប់របស់បុគ្គលម្នាក់អាចត្រូវការរយៈពេលយូរ ព្រោះវាមិនអាចកើតឡើងក្នុងរយៈពេលតែមួយថ្ងៃបាននោះទេ!

❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

តុល្យភាពអាហារ គឺការបរិភោគនូវមុខអាហារចម្រុះមុខនៅក្នុងបរិមាណសមស្រប ដើម្បីទទួលបាន និងរក្សានូវទម្ងន់រាងកាយដែលមានសុខភាពល្អ។ ការបរិភោគអាហារដែលមានតុល្យភាព ពិតជាមានសារៈសំខាន់ណាស់ក្នុងការបង្កើតនូវរបៀបរស់នៅប្រកបដោយសុខភាព។ ការបរិភោគអាហារដែលគ្មានតុល្យភាពអាចនាំឱ្យយើងមានទម្លាប់បរិភោគរបបអាហារមិនមានសុខភាព៕

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ចូរឱ្យនិយមន័យ " គុណភាពអាហារ"

២- ចូររៀបរាប់ពីសារសំខាន់នៃការបរិភោគអាហារមានគុណភាព

៣- តើផលវិបាកនៃការបរិភោគអាហារគ្មានគុណភាពមានអ្វីខ្លះ ?

## ៨- លំហាត់ (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរប្អូនបរិភោគអាហារដែលសម្បូរជាតិកាល់ស្យូម ជាតិដែក និងប្រូតេអ៊ីន សម្រាប់ការលូតលាស់និងមានសុខភាពល្អ។

**កិច្ចការផ្ទះ**

ចូរប្អូនកត់ត្រាពីប្រភេទអាហារដែលត្រូវបរិភោគប្រចាំថ្ងៃ។ គ្រូនឹងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពនៅលើកក្រោយ។ ចូរប្អូនមើលមេរៀនបន្ត ការតាមដានទម្ងន់និងកម្ពស់ ។

**ឯកសារយោង៖**


1. Healthy diet (who.int)
2. Eat well - NHS (www.nhs.uk)
3. Food | Head to Health
4. Poor Nutrition | CDC
5. Association of fast food consumption with poor dietary outcomes and obesity among children: is it the fast food or the remainder of the diet? | The American Journal of Clinical Nutrition | Oxford Academic (oup.com)

# មេរៀនទី ២ : ការតាមដានទម្ងន់និងកម្ពស់

## ខ្លឹមសារម៉ោងទី ១ : របៀបថ្លឹងទម្ងន់និងវាស់កម្ពស់

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីរបៀបថ្លឹងទម្ងន់និងវាស់កម្ពស់ | • ពន្យល់បានពីរបៀបថ្លឹងទម្ងន់និងវាស់កម្ពស់ | • មានទម្លាប់តាមដានទម្ងន់និងកម្ពស់ឱ្យបានទៀងទាត់។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

ការថ្លឹងទម្ងន់និងវាស់កម្ពស់របស់សិស្សពិតជាមានសារៈសំខាន់ណាស់ ដើម្បីតាមដានសុខភាពនិងការលូតលាស់។

របៀបថ្លឹងទម្ងន់៖ ១) ជញ្ជីងដាក់នៅលើផ្ទៃរាបស្មើហើយទ្រនិចចង្អុលចំលេខសូន្យ ២) យកសម្ភារៈចេញពីខ្លួន ៣) គ្មានពាក់ស្បែកជើងនិងឈរឱ្យស្ងៀមនៅចំកណ្ដាលផ្ទៃជញ្ជីង។

របៀបវាស់កម្ពស់៖ ១) ដោះស្បែកជើង មួកនិងដង្កៀបចេញ ២) ឈរឱ្យត្រង់ខ្លួន កែងជើងដាក់ទន្ទឹមគ្នាហើយភ្នែកមើលត្រង់ ៣) ប្រើបន្ទាត់ដាក់នៅលើក្បាល ៤) អានលេខកម្ពស់ជាសង់ទីម៉ែត្រ (សម)។

**៥- វិធីសាស្ត្រ**

សំណួរ និងចម្លើយ សំណួរបំផុស ការអនុវត្ត ការធ្វើបទបង្ហាញរបស់សិស្ស ការងារជាដៃគូ/ក្រុម។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
  - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......
  - ៣- តើអ្នកធ្លាប់ថ្លឹងទម្ងន់ និងវាស់កម្ពស់ដែរឬទេ? បើធ្លាប់តើប្អូនមានទម្ងន់ប៉ុន្មានគីឡូ និងកម្ពស់ប៉ុន្មានសង់ទីម៉ែត្រ? គ្រូហៅសិស្ស ២ទៅ៣នាក់ឱ្យឆ្លើយ
  - • គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

## ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)

## ខ្លឹមសារ : របៀបថ្លឹងទម្ងន់

- គ្រូបង្ហាញរូបភាពខាងក្រោម បន្ទាប់មកសួរថា តើអ្នកស្គាល់របស់នេះឬទេ? តើជាអ្វី? សម្រាប់ធ្វើអ្វី? សិស្សឆ្លើយ.............
- គ្រូបង្ហាញជញ្ជីងប្រភេទណាក៏បាន មិនមែនតែដូចក្នុងរូបទេ





- គ្រូសម្របសម្រួលនិងសំយោគចម្លើយសិស្ស

**ចម្លើយ៖**

ឧបករណ៍នេះជាជញ្ជីង គេប្រើវាសម្រាប់ថ្លឹងទម្ងន់។ ថ្ងៃនេះគ្រូនឹងប្រើប្រាស់ឧបករណ៍នេះសម្រាប់ថ្លឹងទម្ងន់របស់ប្អូនៗទាំងអស់គ្នា។

- គ្រូបង្ហាញនិងពន្យល់ពីរបៀបថ្លឹងទម្ងន់តាមជំហាន ដោយឱ្យសិស្សបើកសៀវភៅសិស្ស

| | | |
|---|---|---|
| ១ |  | ជញ្ជីងចាំបាច់ត្រូវដាក់នៅលើដីដែលមានផ្ទៃរាបស្មើហើយទ្រនិចជញ្ជីងចង្អុលចំលេខសូន្យ។ |
| ២ |  | ស្លៀកពាក់ខោអាវស្រាលៗនិងយកសម្ភារៈដែលមានចេញ។ |
| ៣ |  | គ្មានពាក់ស្បែកជើងនិងឈរឱ្យស្ងៀមនៅចំកណ្ដាលផ្ទៃជញ្ជីងដោយគ្មានកាន់របស់អ្វី ឬមានអ្នកជួយទប់។ |

- គ្រូហៅសិស្ស១ ឬ២នាក់ដើម្បីអនុវត្តការថ្លឹងទម្ងន់តាមជំហាននៃការថ្លឹងទម្ងន់ត្រឹមត្រូវ។

- គ្រូប្រាប់សិស្ស៖ ប្រសិនជាអាចទៅរួច អ្នកគួរព្យាយាមថ្លឹងនិងកត់ត្រាទម្ងន់របស់អ្នកឱ្យបានរៀងរាល់ខែ ដូច្នេះអ្នកនិងដឹងពីការលូតលាស់របស់អ្នកហើយ។

**ខ្លឹមសារ : របៀបវាស់កម្ពស់**



- គ្រូបង្ហាញរូបភាពខាងក្រោម (គ្រូអាចបង្ហាញម៉ែត្រប្រភេទណាក៏បាន មិនមែនតែដូចក្នុងរូបទេ)
- បន្ទាប់មកសួរថា តើអ្នកស្គាល់របស់នេះឬទេ? តើជាអ្វី? សម្រាប់ធ្វើអ្វី? សិស្សឆ្លើយ.......

**ចម្លើយ៖**

ឧបករណ៍នេះជាម៉ែត្រ គេប្រើវាសម្រាប់វាស់កម្ពស់។

- គ្រូបង្ហាញនិងពន្យល់ពីរបៀបវាស់កម្ពស់តាមជំហាន ដោយឱ្យសិស្សបើកសៀវភៅសិស្ស

| | | |
|---|---|---|
| ១ |  | ដោះស្បែកជើង មួក និងដង្កៀបចេញ |
| ២ |  | ឈរឱ្យត្រង់ខ្លួន បាតជើងទាំង២ដាក់រាបស្មើលើកម្រាល កែងជើងដាក់ទន្ទឹមគ្នា ហើយភ្នែកមើលត្រង់។ |
| ៣ |  | ប្រើបន្ទាត់ឬបន្ទះលើក្បាល ដាក់នៅផ្នែកខ្ពស់បំផុតរបស់ក្បាល |
| ៤ |  | អានលេខត្រង់ចំណុចបង្ហាញកត់ត្រាប្រវែងកម្ពស់ជាសង់ទីម៉ែត្រ(សម) |

- **កំណត់ចំណាំ៖** សូមព្យាយាមធ្វើការវាស់កម្ពស់ និងកត់ត្រាលទ្ធផលជារៀងរាល់៦ខែម្តង។

❖ គ្រូសង្ខេបមេរៀន និងឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការដឹងពីទម្ងន់និងកម្ពស់គឺមានសារៈសំខាន់ណាស់ សម្រាប់ដឹងពីការលូតលាស់ស្របទៅតាមកម្រិតអាយុ។ របៀបថ្លឹងទម្ងន់ត្រូវ ១) ជញ្ជីងដាក់នៅលើផ្ទៃរាបស្មើហើយទ្រនិចចង្អុលចំលេខសូន្យ ២) យកសម្ភារៈចេញពីខ្លួន ៣) គ្មានពាក់ស្បែកជើងនិងឈរឱ្យស្ងៀមនៅចំកណ្តាលផ្ទៃជញ្ជីង។ របៀបវាស់កម្ពស់ត្រឹមត្រូវ ១) ដោះស្បែកជើង មួកនិងដង្កៀបចេញ ២) ឈរឱ្យត្រង់ខ្លួន កែងជើងដាក់ទន្ទឹមគ្នា ហើយភ្នែកមើលត្រង់ ៣) ប្រើបន្ទាត់ដាក់នៅលើក្បាល ៤) អានលេខកម្ពស់ជាសង់ទីម៉ែត្រ (សម)។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- របៀបថ្លឹងទម្ងន់និងរបៀបវាស់កម្ពស់ត្រឹមត្រូវ

២- គ្រូហៅសិស្ស២ទៅ៣នាក់ឱ្យមកអនុវត្តជាក់ស្តែងពីរបៀបវាស់កម្ពស់។

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ពេលអ្នកទៅផ្ទះវិញ ត្រូវថ្លឹងទម្ងន់ និងវាស់កម្ពស់របស់ខ្លួនឱ្យបានត្រឹមត្រូវ។ គ្រូនឹងប្រមូលចម្លើយនៅលើកក្រោយ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនបន្ត ការតាមដានទម្ងន់និងកម្ពស់(ត) សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការតាមដានទម្ងន់និងកម្ពស់ (តចប់)

## ខ្លឹមសារម៉ោងទី ២ : របៀបមើលតារាងទម្ងន់និងកម្ពស់សមស្រប និងការផ្ដល់ដំបូន្មានពីទម្ងន់និងកម្ពស់ដែលមិនសមស្រប

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| របៀបមើលតារាងទម្ងន់និងកម្ពស់សមស្រប និងការផ្ដល់ដំបូន្មានពីទម្ងន់និងកម្ពស់ដែលមិនសមស្រប | អនុវត្តការផ្ដល់ដំបូន្មានពីទម្ងន់និងកម្ពស់ដែលមិនសមស្រប | • មានទម្លាប់តាមដានទម្ងន់និងកម្ពស់ឱ្យបានទៀងទាត់។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

៤- ខ្លឹមសារនិងគំនិតសំខាន់ៗ

របៀបមើលតារាងទម្ងន់និងកម្ពស់សមស្រប ការអានលទ្ធផលនៃការវាស់ថ្លឹងបានត្រឹមត្រូវមានសារៈសំខាន់ដើម្បីកត់ត្រានូវលទ្ធផលនៃទម្ងន់និងកម្ពស់របស់អ្នក។

ការផ្ដល់ដំបូន្មានពីទម្ងន់និងកម្ពស់ដែលមិនសមស្រប មានទម្ងន់និងកម្ពស់សមស្រប ជាលទ្ធផលល្អ ព្រោះវាបញ្ជាក់ថា អ្នកមានការលូតលាស់និងមានសុខភាពល្អ។

**៥- វិធីសាស្ត្រ**

សំណួរ និងចម្លើយ ការធ្វើបទបង្ហាញ ការងារជាដៃគូ/ក្រុម បកស្រាយ ពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការផ្ទះ

២- តើនៅលើកមុនអ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ។

ចម្លើយសិស្ស : ...

៣. តើអ្នកណាខ្លះបានថ្លឹងទម្ងន់ និងវាស់កម្ពស់របស់ខ្លួន? ចម្លើយសិស្ស : ......

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : របៀបមើលតារាងទម្ងន់និងកម្ពស់សមស្រប**

- គ្រូពន្យល់៖ ការវាស់ថ្លឹងពិតជាសំខាន់សម្រាប់សិស្ស។ ជាមួយគ្នាផងដែរ វាពិតជាមានសារៈសំខាន់នៅក្នុងការអាននូវលទ្ធផលនៃការវាស់ថ្លឹងឱ្យបានត្រឹមត្រូវដើម្បីកត់ត្រានូវលទ្ធផលនៃទម្ងន់ និងកម្ពស់របស់សិស្ស។ អាស្រ័យទៅតាមឧបករណ៍វាស់ថ្លឹង វាអាចមានភាពខុសគ្នាបន្តិចបន្តួចពីឧបករណ៍មួយ ទៅឧបករណ៍ផ្សេងទៀត។
- គ្រូពន្យល់ដោយឱ្យសិស្សមើលលើរូបភាពខាងក្រោម៖
  - ➢ របៀបអានឬមើលលេខលើជញ្ជីងនិងម៉ែត្រ

**<u>ជញ្ជីងថ្លឹងទម្ងន់</u>**

តើអ្នកប្រើជញ្ជីងប្រភេទណាសម្រាប់ថ្លឹងទម្ងន់? (អាស្រ័យលើគ្រូមានជញ្ជីងប្រភេទអ្វី?)




ទ្រនិចជញ្ជីងគឺតែងតែចាប់ផ្តើមពី 0គីឡូក្រាម តាមរូបភាពនៃប្រភេទជញ្ជីងខាងលើ ចន្លោះពីចំណុចមួយទៅចំណុចមួយគឺ៥គីឡូក្រាម (ចំណុចតូចៗគឺ១គីឡូក្រាម)។ ដូច្នេះប្រសិនបើទ្រនិចចង្អុរដូចរូបខាងលើ មានន័យថាទម្ងន់គឺ៥0គីឡូក្រាម។

គ្រូអាចអនុវត្តជាមួយសិស្សដើម្បីឱ្យសិស្សកាន់តែយល់ពីការមើលលេខលើជញ្ជីង។

**<u>ម៉ែត្រវាស់កម្ពស់</u>**

តើអ្នកប្រើម៉ែត្រប្រភេទណាសម្រាប់វាស់កម្ពស់? (អាស្រ័យលើគ្រូមានម៉ែត្រប្រភេទអ្វី?)

តើចន្លោះនេះមាន ប្រវែងប៉ុន្មាន?
= ១០ ស.ម







តើមានកម្ពស់ប៉ុន្មាន?
= ១៤៥ស.ម

ក្រិតលើម៉ែត្រតែងតែចាប់ផ្ដើមពី០សង់ទីម៉ែត្រ តាមរូបភាពនៃប្រភេទម៉ែត្រខាងលើ ចន្លោះពីចំណុចមួយទៅចំណុចមួយគឺ១០សង់ទីម៉ែត្រ (ចំណុចតូចៗគឺ១សង់ទីម៉ែត្រ)។

គ្រូអាចអនុវត្តជាមួយសិស្សដើម្បីឱ្យសិស្សកាន់តែយល់ពីការមើលលេខលើម៉ែត្រ។

➢ របៀបមើលតារាងកម្ពស់និងទម្ងន់សមស្រប

មកដល់ពេលនេះ ក្រសួងសុខាភិបាលមិនទាន់មានតារាងទម្ងន់និងកម្ពស់ជាផ្លូវការណាមួយទេ។ តារាងទម្ងន់និងកម្ពស់សមស្របខាងក្រោម អាចប្រើប្រាស់បានដោយសារតែតារាងនេះបង្កើតឡើងតាមរយៈលទ្ធផលនៃការអង្កេតរបស់សិស្សកម្ពុជា។ សិស្សអាចកំណត់ទម្ងន់និងកម្ពស់តាមលេខនៃតារាងទាំងនេះ ដើម្បីទទួលបានសុខភាពនិងការលូតលាស់ល្អ។ ប្រសិនបើសិស្សមានទម្ងន់និងកម្ពស់តិចជាងនេះ គ្រូអាចជម្រុញឱ្យពួកគេបរិភោគអាហារឱ្យបានត្រឹមត្រូវនិងមានលំហាត់ប្រាណផងដែរ ប៉ុន្តែវាមិនមានន័យថា ពួកគេមិនមានសុខភាពល្អនោះទេ។

| អាយុ (ឆ្នាំ) | កម្ពស់និងទម្ងន់សមស្របក្មេងប្រុស | |
|---|---|---|
| | កម្ពស់ (សង់ទីម៉ែត្រ) | ទម្ងន់ (គីឡូក្រាម) |
| ៦ | ១១៣ - ១១៧ | ១៩ - ២៣ |
| ៧ | ១១៦ - ១២០ | ២០ - ២៣ |
| ៨ | ១២១ - ១២៤ | ២១ - ២៤ |
| ៩ | ១២៤ - ១២៨ | ២២ - ២៥ |
| ១០ | ១២៨ - ១៣២ | ២៥ - ២៨ |
| ១១ | ១៣២ - ១៣៦ | ២៧ - ៣០ |
| ១២ | ១៣៦ - ១៤០ | ២៩ - ៣២ |
| ១៣ | ១៤១ - ១៤៥ | ៣២ - ៣៥ |
| ១៤ | ១៥១ - ១៥៥ | ៣៨ - ៤១ |
| ១៥ | ១៥៧ - ១៦១ | ៤៣ - ៤៦ |

| អាយុ (ឆ្នាំ) | កម្ពស់និងទម្ងន់សមស្របរបស់ក្មេងស្រី | |
|---|---|---|
| | កម្ពស់ (សង់ទីម៉ែត្រ) | ទម្ងន់ (គីឡូក្រាម) |
| ៦ | ១០៩ - ១១៣ | ១៦ - ១៩ |
| ៧ | ១១៦ - ១២០ | ១៩ - ២២ |
| ៨ | ១១៩ - ១២៣ | ២០ - ២៣ |
| ៩ | ១២៣ - ១២៧ | ២២ -២៥ |
| ១០ | ១២៧ - ១៣១ | ២៥ - ២៨ |
| ១១ | ១៣៤ - ១៣៨ | ២៨ - ៣១ |
| ១២ | ១៤២ - ១៤៦ | ៣២ - ៣៥ |
| ១៣ | ១៤៧ - ១៥១ | ៣៥ - ៣៨ |
| ១៤ | ១៥០ - ១៥៤ | ៣៩ - ៤២ |
| ១៥ | ១៥២ - ១៥៦ | ៤៤ - ៤៧ |

យោងតាមសៀវភៅអនុសាសន៍បរិមាណរបបអាហារនិងគោលការណ៍ណែនាំស្ដីពីរបបអាហារសម្រាប់កុមារក្នុងវ័យសិក្សា ២០១៧ របស់ក្រសួងសុខាភិបាល។

➢ របៀបកត់ត្រាកម្ពស់និងទម្ងន់

បន្ទាប់ពីសិស្សបានវាស់ថ្លឹងរួចហើយ សិស្សគួរតែកត់ត្រាទុកនូវលទ្ធផលនៃការវាស់កម្ពស់និងថ្លឹងទម្ងន់របស់ខ្លួនដូចតារាងខាងក្រោម។ ជាអនុសាសន៍ សិស្សគួរកត់ត្រានូវទម្ងន់ និងកម្ពស់របស់ខ្លួនយ៉ាង

ហោចណាស់ឱ្យបាន២ដងក្នុងមួយឆ្នាំ ទោះបីសិស្សបានឡើងថ្នាក់ទៅរៀននៅអនុវិទ្យាល័យក៏ដោយ ដូច្នេះ អាណាព្យាបាលសិស្សអាចមើលពីការលូតលាស់របស់ពួកគេបាន។

| ទម្ងន់/កម្ពស់ | ថ្នាក់ទី៦ | | ថ្នាក់ទី៧ | |
|---|---|---|---|---|
| | កុម្ភៈ | កក្កដា | កុម្ភៈ | កក្កដា |
| ទម្ងន់ | ៣៥ គីឡូក្រាម | | | |
| កម្ពស់ | ១,៤៥ ម៉ែត្រ | | | |

❖ គ្រូហៅសិស្ស២ ឬ៣នាក់ ឡើងមកអនុវត្តពីរបៀបថ្លឹងទម្ងន់ និងវាស់កម្ពស់ របៀបមើលលេខលើជញ្ជីង និងម៉ែត្រ និងរៀបកត់ត្រា។

**ខ្លឹមសារ៣ : ការផ្តល់ដំបូន្មានពីទម្ងន់និងកម្ពស់ដែលមិនសមស្រប**

- គ្រូរំលឹកសិស្សពីតារាងទម្ងន់និងកម្ពស់សមស្របទៅសិស្ស បន្ទាប់មកឱ្យសិស្សយកតួរលេខនៃទម្ងន់ និងកម្ពស់ដែលពួកគេបានវាស់ថ្លឹងក្នុងកិច្ចការផ្ទះមកប្រៀបធៀប។
- គ្រូទុកពេល ៥ ទៅ១០នាទីឱ្យសិស្សដើម្បីប្រៀបធៀបទម្ងន់និងកម្ពស់របស់ពួកគេជាមួយនឹងតារាង ទម្ងន់និងកម្ពស់សមស្រប។
- គ្រូហៅសិស្ស២ ទៅ៣នាក់ដើម្បីឆ្លើយនឹងសំណួរ។ ចម្លើយ៖.............
- ចម្លើយរបស់សិស្សអាចមានអ្នកដែលមានទម្ងន់និងកម្ពស់ទាប ត្រឹមត្រូវ និងខ្ពស់ជាងតារាងទម្ងន់និង កម្ពស់សមស្រប។ គ្រូអាចរំលឹកសិស្សនូវមេរៀនថ្នាក់ទី៤ ដើម្បីឱ្យមានសុខភាពនិងការលូតលាស់ល្អ យើងត្រូវបរិភោគអាហារដែលមានសុខភាព ដេកគ្រប់គ្រាន់ និងធ្វើលំហាត់ប្រាណឱ្យបានទៀងទាត់។

ដូច្នេះគ្រូផ្តល់ដំបូន្មានដល់សិស្សដូចខាងក្រោម៖

| ទម្ងន់និងកម្ពស់ធៀបនឹងតារាងទម្ងន់និងកម្ពស់សមស្រប | ដំបូន្មាន |
|---|---|
| **ទាបជាង** | មិនមែនមានន័យថាសិស្សនោះមិនមានសុខភាពល្អនោះទេ សិស្សអាចនឹងមានការលូតលាស់កាន់តែរហ័សនៅពេលគេឈានដល់វ័យបន្តពូជ។ ដូច្នេះ គ្រូអាចជម្រុញឱ្យពួកគេបរិភោគអាហារសុខភាពគេងឱ្យបានគ្រប់គ្រាន់និងមានលំហាត់ប្រាណឱ្យបានជាប្រចាំ។ |
| **សមស្រប** | សិស្សបែបនេះអាចមានការលូតលាស់ល្អ គ្រូលើកទឹកចិត្តឱ្យសិស្សបន្តទម្លាប់បែបនេះបន្តទៀត។ |
| **ខ្ពស់ជាង** | អាចថាពួកគេមានការលូតលាស់លឿន ដូច្នេះគ្រូជម្រុញឱ្យពួកគេមានលំហាត់ប្រាណឱ្យបានជាប្រចាំ។ |

- គ្រូពន្យល់បន្ថែម៖ ដើម្បីដឹងថា អ្នកបានធ្វើការវាស់ថ្លឹង និងកត់ត្រាបានត្រឹមត្រូវ យើងត្រូវអនុវត្តទាំងអស់គ្នាក្នុងថ្នាក់។
- គ្រូរលឹកពីរបៀបវាស់ថ្លឹង របៀបមើលលេខលើជញ្ជីងនិងម៉ែត្រ និងរបៀបកត់ត្រា។
- គ្រូបែងចែកសិស្សជាគូ ហើយឱ្យពួកគេវាស់ថ្លឹងឱ្យគ្នាទៅវិញទៅមក និងកត់ត្រាដូចតារាងខាងក្រោម៖

| | ថ្នាក់ទី៦ | |
|---|---|---|
| ខែ | | |
| ទម្ងន់ | | |
| កម្ពស់ | | |

- បន្ទាប់មក គ្រូឱ្យសិស្សយកលទ្ធផលដែលពួកគេបានវាស់ថ្លឹងក្នុងថ្នាក់ប្រៀបធៀបនឹងលទ្ធផលដែលពួកគេបានវាស់ថ្លឹងនៅផ្ទះ។ បន្ទាប់មកឱ្យគេយកចម្លើយនោះ ទៅប្រៀបធៀបនឹងតារាងទម្ងន់និងកម្ពស់សមស្របម្តងទៀត។
- គ្រូណែនាំ៖ ប្អូនអាចកត់ត្រាទុកនូវអ្វីដែលប្អូនបានរកឃើញថ្ងៃនេះ ហើយបន្តការវាស់ថ្លឹងឱ្យបានទៀងទាត់ដើម្បីតាមដានការលូតលាស់របស់ប្អូនៗ។ ហើយចែករំលែកលទ្ធផលនេះដល់អាណាព្យាបាលរបស់អ្នក ដើម្បីឱ្យគាត់អាចរួមចំណែកជួយប្អូនក្នុងការទទួលបានការសុខភាពនិងលូតលាស់ល្អ។

**ចំណាំ:** នៅពេលដែលទិន្នន័យរបស់សិស្សទាប មិនត្រូវវិនិច្ឆ័យភ្លាមៗថាពួកគេមានសុខភាពមិនល្អនោះទេ ត្រូវលើកទឹកចិត្តសិស្សថាពួកគេនឹងលូតលាស់បន្ថែមទៀតនៅឆ្នាំខាងមុខៗទៀត។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

របៀបមើលតារាងទម្ងន់និងកម្ពស់សមស្របតាមកម្រិតអាយុ ភេទ និងអាយុ។ របៀបកត់ត្រាទម្ងន់និងកម្ពស់អាចកត់ជារៀងរាល់ខែ។ មានទម្ងន់និងកម្ពស់សមស្របជាលទ្ធផលល្អ ព្រោះវាបញ្ជាក់ថា អ្នកមានការលូតលាស់និងមានសុខភាពល្អ៕

## ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- របៀបមើលតារាងទម្ងន់និងកម្ពស់សមស្រប

២- តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ប្រសិនបើអ្នកមានទម្ងន់ និងកម្ពស់មិនសមស្រប?

**៨- លំហាត់** ( ជំហានទី៥ )

**បណ្ដាំផ្ញើ** : ចូរអ្នកធ្វើថ្លឹងទម្ងន់ និងវាស់កម្ពស់យ៉ាងហោចណាស់ឱ្យបាន២ដង ក្នុងមួយឆ្នាំ ហើយព្យាយាមប្រៀបធៀបលទ្ធផលនៃការវាស់ថ្លឹងដើម្បីតាមដានការលូតលាស់។

**កិច្ចការផ្ទះ** :

១- តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីឱ្យអ្នកមានការលូតលាស់ប្រកបដោយសុខភាព?

២- ចូរអ្នកមើលមេរៀនទំនាក់ទំនងរវាងរបបអាហារ និងជំងឺ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

**ឯកសារយោង៖**


- Measuring Children's Height and Weight Accurately At Home | Healthy Weight, Nutrition, and Physical Activity | CDC

# មេរៀនទី ៣ : ទំនាក់ទំនងរវាងរបបអាហារនិងជំងឺ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យ"របបអាហារ"<br>• រៀបរាប់ពីជំងឺដែលបង្កដោយការបរិភោគអាហារដែលមានរសជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន។ | • បកស្រាយពីផលប៉ះពាល់សុខភាពបណ្តាលពីការបរិភោគអាហារដែលមានរសជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន<br>• ប្រាប់បានពីវិធានការបង្ការជំងឺដែលបង្កដោយការបរិភោគអាហារ។ | • យកចិត្តទុកដាក់កាត់បន្ថយការការបរិភោគអាហារដែលមានរសជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យរបបអាហារ៖ គឺជាអ្វីដែលយើងអាចបរិភោគនិងផឹកបាន ហើយវាផ្តល់ថាមពលនិងសារជាតិចិញ្ចឹមដល់រាងកាយ។

២- ជំងឺដែលបង្កដោយការបរិភោគអាហារដែលមានរសជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន មានដូចជាសម្ពាធឈាមឡើងខ្ពស់ ជំងឺបេះដូង ដាច់សរសៃឈាមខួរក្បាល ជំងឺទឹកនោមផ្អែម ជំងឺមហារីក និងបញ្ហាសុខភាពជាច្រើនទៀត។

៣- វិធានការបង្ការ ដោយកុំបរិភោគអាហារមានជាតិប្រៃពេក ខ្លាញ់ច្រើន និងផ្អែមខ្លាំង បរិភោគបន្លែនិងផ្លែឈើឱ្យបានច្រើន និងហាត់ប្រាណ។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់** (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន** (ជំហានទី២)

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការផ្ទះ។
២- តើនៅលើកមុន អ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ។
ចម្លើយសិស្ស : ...

- គ្រូសួរសំណួរ៖ តើអ្នកចូលចិត្តអាហារសម្រន់ដែរឬទេ? តើអាហារប្រភេទណាខ្លះដែលអ្នកចូលចិត្ត? ហេតុអ្វី?
- គ្រូហៅសិស្ស២ទៅ៣នាក់ឱ្យឆ្លើយ។ ចម្លើយ៖.........(ចម្លើយអាចជាអាហារដែលមានជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន)
- គ្រូសរសេរចំណងជើងមេរៀននៅលើក្ដារខៀន

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យរបបអាហារ**

- គ្រូសួរ: តើអ្វីទៅជារបបអាហារ?
- គ្រូហៅសិស្ស២ទៅ៣នាក់ឱ្យឆ្លើយ។ ចម្លើយ៖.................
- គ្រូសរសេរពាក្យគន្លឹះនៅលើក្ដារខៀន
- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេបតាមខ្លឹមសារនៃមេរៀន។

ចម្លើយ៖

- **របបអាហារ** គឺជាអ្វីដែលយើងអាចបរិភោគនិងផឹកបាន ហើយវាផ្តល់ថាមពលនិងសារជាតិចិញ្ចឹមដល់រាងកាយដើម្បីជួយឱ្យរាងកាយអាចបំពេញមុខងារផ្សេងៗបាន (ក្រសួងសុខាភិបាល)។
- ជំងឺទាក់ទងនឹងរបបអាហារ គឺជាជំងឺដែលកើតមានឡើងបណ្ដាលមកពីការបរិភោគរបបអាហារដែលមិនមានសុខភាព ឬទម្លាប់បរិភោគមិនបានត្រឹមត្រូវ។

**ខ្លឹមសារ : ជំងឺដែលបង្កដោយការបរិភោគអាហារដែលមានរសជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន**

- គ្រូចង្អុលទៅក្ដារខៀនលើចម្លើយសិស្ស (ប្រសិនបើសិស្សនិយាយអំពីអាហារសម្រន់ដែលមានជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន)
- ប៉ុន្តែបើសិនជាសិស្សមិនមានលើកឡើងទេ គ្រូអាចរលើកឡើងវិញពីមេរៀនទី១ នៃថ្នាក់ទី ៣ (អាហារសម្រន់) ឬផ្តល់ឧទាហរណ៍ខ្លះសម្រាប់អាហារដែលមានជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន៖ ទាំងនេះជាអាហារដែលប្អូនចូលចិត្តបរិភោគ៖ ស្ករគ្រាប់ ភេសជ្ជៈមានជាតិស្ករ ប្រហិត គ្រឿងម្ហូរលាយជាមួយអំបិល ចេកចៀន។ ល។ អាហារទាំងនេះភាគច្រើនផ្ទុកនូវជាតិស្ករ អំបិល និងខ្លាញ់។

**របៀបសាមញ្ញពីរយ៉ាងក្នុងការទទួលរងនូវជំងឺទាក់ទងនឹងរបបអាហារ**

➢ **គ្រូឱ្យសិស្សសង្កេតរូបភាពក្នុងសៀវភៅសិស្សរួចពន្យល់ពីការបរិភោគអាហារដែលមានរសជាតិប្រៃពេក**

ប្រសិនបើអ្នកបរិភោគអាហារដែលមានរសជាតិប្រៃពេក អ្នកអាចប្រឈមទៅនឹងបញ្ហាសុខភាពជាច្រើនដូចជា សម្ពាធឈាមឡើងខ្ពស់ ជំងឺបេះដូង និងដាច់សរសៃឈាមខួរក្បាល។




➢ **គ្រូឱ្យសិស្សសង្កេតរូបភាពក្នុងសៀវភៅស័ស្សរួចពន្យល់ពីការបរិភោគអាហារដែលមានរសជាតិផ្អែមខ្លាំង និងខ្លាញ់ច្រើន**

ប្រសិនបើអ្នកបរិភោគរបបអាហារដែលមានរសជាតិផ្អែមខ្លាំងនិងខ្លាញ់ច្រើន បណ្តាលឱ្យអ្នកលើសទម្ងន់និងធាត់។ អ្នកអាចប្រឈមទៅនឹង ជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមបេះដូង ជំងឺមហារីក និងបញ្ហាសុខភាពជាច្រើនទៀត។




**ខ្លឹមសារៈ វិធានការបង្ការ**

- គ្រូសួរៈ ឥឡូវប្អូនដឹងថា អាហារខ្លះនឹងបង្កបញ្ហាដល់សុខភាពរបស់អ្នក។ ដូច្នេះតើប្អូនដឹងទេថា តើយើងអាចការពារបញ្ហាសុខភាពប្រភេទនោះដោយរបៀបណា?
- គ្រូគ្រូហៅសិស្ស២ទៅ៣នាក់ឱ្យឆ្លើយ។ ចម្លើយសិស្សៈ....

**ចម្លើយ**

នៅពេលដែលយើងបរិភោគរបបអាហារមិនត្រឹមត្រូវ ធ្វើឱ្យយើងប្រឈមទៅនឹងជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមបេះដូង ជំងឺមហារីក និងបញ្ហាសុខភាពជាច្រើនទៀត។ ដើម្បីបង្ការជំងឺទាំងនេះ យើងត្រូវអនុវត្តវិធានការដូចខាងក្រោមៈ

| | | |
|---|---|---|
|  |  |  |
| កុំបរិភោគអាហារមានជាតិប្រៃពេក ខ្លាញ់ច្រើន និងផ្អែមខ្លាំង | បរិភោគបន្លែ និងផ្លែឈើ ឱ្យបានច្រើន | ត្រូវប្រាកដថាអ្នកសកម្ម ( ការហាត់កីឡា ឬសកម្មភាពផ្សេងៗទៀត) |

- គ្រូបញ្ជាក់បន្ថែម៖ ការបរិភោគជាតិប្រៃឬអំបិលច្រើនបំផុត ២ ក្រាម/ថ្ងៃ យោងតាមអង្គការសុខភាពពិភពលោក។

• **សកម្មភាពក្នុងថ្នាក់៖** គ្រូគូសតារាង រួចបង្ហាញនូវកាតអាហារដូចរូបខាងក្រោម បន្ទាប់មកបែងចែកសិស្សជាក្រុម ហើយឱ្យសិស្សទាយថាអាហារទាំងអស់នេះមានបរិមាណអំបិលនិងស្ករដែរឬទេ? តំណាងក្រុមនីមួយៗឡើងធ្វើបទបង្ហាញ។

| | | | | | |
|---|---|---|---|---|---|
| |  |  |  |  |  |
| | **ទឹកប៉េងប៉ោះ** | **ទឹកម្ទេស** | **ទឹកត្រី** | **សៀង** | **ទឹកត្រីកោះកុង** |
| **អំបិល** | | | | | |
| **ស្ករ** | | | | | |

• គ្រូផ្តល់ចម្លើយដល់សិស្ស

| | | | | | |
|---|---|---|---|---|---|
| |  |  |  |  |  |
| | **ទឹកប៉េងប៉ោះ** | **ទឹកម្ទេស** | **ទឹកត្រី** | **សៀង** | **ទឹកត្រីកោះកុង** |
| **អំបិល** | **មាន** | **មាន** | **មាន** | **មាន** | **ស្ទើរតែគ្មាន** |
| **ស្ករ** | **មាន** | **មាន** | **ស្ទើរតែគ្មាន** | **មាន** | **មាន** |

- គ្រូពន្យល់បន្ថែមទៅសិស្សថា បរិមាណអំបិលនិងស្ករមានច្រើននិងតិចអាស្រ័យទៅលើការរៀបចំរបស់អ្នកចម្អិន។ សូមចង់ចាំថា អាហារដែលយើងបរិភោគមួយចំនួនគឺអាចមានផ្ទុកទាំងអំបិលនិងស្ករខ្លះផងដែរ។ ពេលខ្លះអាហារមិនមានរសជាតិប្រៃទេ ប៉ុន្តែនៅតែអាចមានផ្ទុកនូវបរិមាណអំបិលខ្លះ ហើយអាហារខ្លះមិនមានជាតិផ្អែមតែក៏មានផ្ទុកនូវបរិមាណស្ករផងដែរ។
- គ្រូសង្ខេបមេរៀនដោយយោងតាមខ្លឹមសារនៃមេរៀនហើយសុំឱ្យសិស្សចម្លងវាចូលសៀវភៅកិច្ចការ។



**មេរៀនសង្ខេប**

**ជំងឺទាក់ទងនឹងរបបអាហារ** គឺជាជំងឺដែលកើតមានឡើងបណ្ដាលមកពីការបរិភោគរបបអាហារដែលមិនមានសុខភាព ឬទម្លាប់បរិភោគមិនបានត្រឹមត្រូវ។ ជំងឺទាំងនោះមានដូចជា សម្ពាធឈាមឡើងខ្ពស់ ជំងឺបេះដូង ដាច់សរសៃឈាមខួរក្បាល ជំងឺទឹកនោមផ្អែម ជំងឺមហារីក និងបញ្ហាសុខភាពជាច្រើនទៀត។ យើងអាចបង្ការជំងឺទាំងនេះបានដោយ កុំបរិភោគអាហារមានជាតិប្រៃពេក ខ្លាញ់ច្រើន និងផ្អែមខ្លាំង ហើយគួរបរិភោគបន្លែនិងផ្លែឈើឱ្យបានច្រើន និងហាត់ប្រាណឱ្យបានទៀងទាត់៕

### ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- កំណត់និយមន័យនៃទំនាក់ទំនងរបបអាហារនិងជំងឺ

២- រៀបរាប់ពីជំងឺដែលបណ្ដាលមកពីការបរិភោគអាហារដែលមានជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន

៣- រៀបរាប់អំពីវិធីការពារ។

### ៨- **លំហាត់** (ជំហានទី៥)

**បណ្ដាំផ្ញើ៖** ចូរអ្នកព្យាយាមកាត់បន្ថយនូវការបរិភោគអាហារដែលមានជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន ហើយបរិភោគបន្លែនិងផ្លែឈើឱ្យបានច្រើន។

**កិច្ចការផ្ទះ៖**

១- ឆ្លុះបញ្ចាំងពីទម្លាប់នៃការបរិភោគរបស់ខ្លួន រួចកំណត់អាហារមួយចំនួនដែលមានអំបិលនិងស្ករច្រើន។

២- សូមអានមេរៀនទី ៤“ សុវត្ថិភាពចំណីអាហារ”  សម្រាប់មេរៀនបន្ទាប់។

# មេរៀនទី ៤ : សុវត្ថិភាពចំណីអាហារ

**ខ្លឹមសារម៉ោងទី ១** : និយមន័យ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ប្រាប់និយមន័យ"សុវត្ថិភាពចំណីអាហារ" | - ពន្យល់បានពីនិយមន័យ "សុវត្ថិភាពចំណីអាហារ" | - យកចិត្តទុកដាក់អនុវត្តតាមគន្លឹះទាំង៥ នៃសុវត្ថិភាពចំណីអាហារដើម្បីសុខភាពល្អប្រសើរ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**សុវត្ថិភាពចំណីអាហារ** សំដៅដល់ការគ្រប់គ្រង ការរៀបចំ ការរក្សាទុក និងការបរិភោពអាហារ ឱ្យចៀសផុតពីជំងឺដែលបង្កឡើងដោយមេរោគនិងសារធាតុគីមី។ វាមានសារៈសំខាន់ចាំបាច់ណាស់ក្នុងការជួយឱ្យអាហារដែលយើងបានបរិភោគមានសារជាតិញ្ចឹមគ្រប់គ្រាន់សម្រាប់ការលូតលាស់និងសុខភាពល្អ។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  ១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការផ្ទះ។
  ២- តើនៅលើកមុន អ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស : ...

៣- តើអ្នកមានធ្លាប់ឈឺពោះឬឈឺបន្ទាប់ពីបរិភោគអាហារដែរឬទេ? គ្រូហៅសិស្ស ២ ទៅ៣នាក់ឱ្យឆ្លើយ។ ចម្លើយសិស្ស៖......................

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យ**

- គ្រូពន្យល់៖ ពេលខ្លះអ្នកឈឺពោះឬឈឺបន្ទាប់ពីបរិភោគអាហារ នេះបណ្តាលមកពីអាហារទាំងនេះគ្មានសុវត្ថិភាព។
- គ្រូសួរ៖ តើអ្នកដឹងថាសុវត្ថិភាពចំណីអាហារមានន័យដូចម្តេចទេ? តើអ្នកត្រូវធ្វើដូចម្តេចដើម្បីការពារខ្លួនឬចៀសពីការពុលអាហារ? (រំលឹកមេរៀននៅថ្នាក់ទី៥)
- គ្រូហៅសិស្ស ២ ទៅ៣នាក់ឱ្យឆ្លើយ។ ចម្លើយ៖....
- គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

**ចម្លើយ**

សុវត្ថិភាពចំណីអាហារ សំដៅដល់ការគ្រប់គ្រង ការរៀបចំ ការរក្សាទុក និងការបរិភោគអាហារ ឱ្យចៀសផុតពីជំងឺដែលបង្កឡើងដោយមេរោគនិងសារធាតុគីមី។

សុវត្ថិភាពចំណីអាហារ មានសារៈសំខាន់ចាំបាច់ណាស់ក្នុងការជួយឱ្យអាហារដែលយើងបានបរិភោគមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ សម្រាប់ការលូតលាស់និងសុខភាពល្អ។

- គ្រូពន្យល់បន្ថែម៖ ដើម្បីការពារខ្លួនឬចៀសពីការពុលអាហារយើងត្រូវ៖
  - លាងសម្អាតដៃ
  - សម្អាតសម្ភារៈប្រើប្រាស់ក្នុងផ្ទះបាយ
  - ចម្អិនបានឆ្អិនល្អ ហើយបរិភោគភ្លាមៗ (កុំទុកឱ្យសល់ ព្យាយាមបរិភោគឱ្យអស់)
  - ធ្វើឱ្យរាងកាយមានសុខភាពល្អ
- គ្រូរំលឹក៖ នៅក្នុងមេរៀនទី៣ យើងបានសិក្សារួចមកហើយពីជំងឺដែលទាក់ទងនឹងអាហារ។ ជំងឺទាក់ទងនឹងរបបអាហារ គឺជាជំងឺដែលផ្សាភ្ជាប់ទៅនឹង ឬបណ្តាលមកពីរបបអាហារដែលមិនមានសុខភាព ឬមកពីទម្លាប់នៃការបរិភោគអាហារមិនល្អ។ ប្រសិនបើយើងបរិភោគអាហារមានជាតិប្រៃពេក ផ្អែមខ្លាំង និងខ្លាញ់ច្រើន នោះយើងនឹងអាចមានហានិភ័យខ្ពស់ក្នុងការវិវត្តទៅជាជំងឺធ្ងន់ធ្ងរ ទាំងនេះមិនមែនជាសុវត្ថិភាពចំណីអាហារទេ ព្រោះជំងឺទាំងនេះនឹងកើតមានឡើងនាពេលអនាគតហើយវាបណ្តាលមកពីទម្លាប់នៃការបរិភោគអាហារមិនល្អ។
- តែបើនិយាយពីសុវត្ថិភាពចំណីអាហារគឺយើងអាចកើតមានបញ្ហាសុខភាពឬការពុលអាហារបន្ទាប់ពីបរិភោគអាហារ។ ខាងក្រោមជាភាពខុសគ្នានៃសុវត្ថិភាពចំណីអាហារនិងជំងឺដែលទាក់ទងនឹងអាហារ៖

➢ **សុវត្ថិភាពចំណីអាហារ**



អាហារនិងទឹកមិនមានសុវត្ថិភាពនិងដៃមិនស្អាត | អាហារនិងទឹកមានការចម្លងមេរោគ | អ្នកឈឺបន្ទាប់ពីបរិភោគអាហារ (ការពុលអាហារ)

- **ជំងឺដែលទាក់ទងនឹងអាហារ**




អាហារដែលមិនមានសុខភាព | ប្រសិនបើបរិភោគច្រើននិងញឹកញាប់ | អ្នកនឹងមានបញ្ហាសុខភាពធ្ងន់ធ្ងរនាពេលអនាគត

- គ្រូរំលឹកបន្ថែម៖ អ្នកបានសិក្សារួចមកហើយនៅថ្នាក់ទី៥ពីការពុលអាហារ។ ការពុលចំណីអាហារ គឺបណ្តាលមកពីអាហារនិងទឹកដែលមានចម្លងរោគដោយសារបាក់តេរី  វីរុស និងសាធាតុពុលដទៃទៀត ហើយតាមរយៈការបរិភោគអាហារនិងផឹកទឹកដែលមានមេរោគទាំងនេះ មនុស្សនឹងអាចឈឺ ឬស្លាប់បានក្នុងករណីពុលអាហារធ្ងន់ធ្ងរ។សុវត្ថិភាពចំណីអាហារគឺផ្សារភ្ជាប់គ្នាទៅនឹងការពុលអាហារ។ ប្រសិនបើអាហារមិនមានសុវត្ថិភាព គឺអាចនឹងមានការពុលអាហារ។
- គ្រូសួរ៖ នៅផ្ទះរបស់អ្នក តើអ្នកគិតថាកន្លែងណាខ្លះដែលជាប្រភពចម្លងរោគទៅលើអាហារ ?
- គ្រូហៅសិស្ស ២ ទៅ៣នាក់ឱ្យឆ្លើយ។ ចម្លើយ៖.......................
- គ្រូសួរ៖ ហេតុអ្វីបានជាយើងត្រូវគិតពីសុវត្ថិភាពចំណីអាហារ ?
- គ្រូហៅសិស្ស ២ ទៅ៣នាក់ឱ្យឆ្លើយ។ ចម្លើយ៖....
- គ្រូសម្របសម្រួលនិងសំយោគចម្លើយ។

**ចម្លើយ៖**

- អាហារដែលមិនមានសុវត្ថិភាពអាចបង្កបញ្ហាសុខភាព (ការពុលអាហារ)
- ជំងឺច្រើនជាង២០០ប្រភេទបង្កឡើងដោយសារអាហារ
- ជំងឺដែលបង្កដោយសារអាហារអាចការពារបានតាមរយៈការគ្រប់គ្រងអាហារ

- គ្រូពន្យល់៖ សុវត្ថិភាពចំណីអាហារមានសារៈសំខាន់ណាស់ព្រោះតាមរយៈការជ្រើសរើសអាហារដែលមានសុវត្ថិភាព អាហារូបត្ថម្ភដែលមានសុខភាព ជាមួយនឹងសកម្មភាពរាងកាយ យើងអាចធ្វើឱ្យជីវិតរបស់យើងមានភាពប្រសើរឡើងពោរពេញដោយសុខភាព។
- គ្រូប្រាប់សិស្ស៖ ដូច្នេះចូរអ្នកប្រាកដថាអាហាររបស់ប្អូនគឺមានសុវត្ថិភាព ជាពិសេសពេលចម្អិន និងរៀបចំអាហារ។ ដើម្បីដឹងថាអាហារយើងមានសុវត្ថិភាពតាមរបៀបណា យើងនឹងពិភាក្សាគ្នានៅម៉ោងបន្ទាប់។
- គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

សុវត្ថិភាពចំណីអាហារ សំដៅដល់ការគ្រប់គ្រង ការរៀបចំ ការរក្សាទុក និងការបរិភោគអាហារ ឱ្យចៀសផុតពីជំងឺដែលបង្កឡើងដោយមេរោគនិងសារធាតុគីមី។

### ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ចូរឱ្យនិយមន័យ សុវត្ថិភាពចំណីអាហារ។

២- បង្ហាញពីភាពខុសគ្នារវាងសុវត្ថិភាពចំណីអាហារនិងជំងឺដែលទាក់ទងនិងអាហារ។

៣. ហេតុអ្វីបានជាសុវត្ថិភាពចំណីអាហារមានសារៈសំខាន់?

### ៨- **លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ** : ចូរអ្នកអានមេរៀនសុវត្ថិភាពចំណីអាហារ យើងនឹងពិភាក្សាគ្នានៅម៉ោងបន្ទាប់ដើម្បីដឹងថារបៀបណាខ្លះដែលធ្វើឱ្យអាហារមានសុវត្ថិភាព។

# មេរៀនទី ៤ : សុវត្ថិភាពចំណីអាហារ ( តចប់ )

**ខ្លឹមសារម៉ោងទី ២** : គន្លឹះទាំង៥ដែលធ្វើឱ្យអាហារមានសុវត្ថិភាព

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ប្រាប់ពីគន្លឹះទាំង៥ដែលធ្វើឱ្យអាហារមានសុវត្ថិភាព។ | - បង្ហាញបានពីគន្លឹះទាំង៥ ដែលធ្វើឱ្យចំណីអាហារមានសុវត្ថិភាព | - យកចិត្តទុកដាក់អនុវត្តតាមគន្លឹះទាំង៥ នៃសុវត្ថិភាពចំណីអាហារដើម្បីសុខភាពល្អប្រសើរ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**គន្លឹះទាំង៥ដើម្បីអាហារមានសុវត្ថិភាព** ៖ ១- រក្សាភាពស្អាត ២- ការទុកដាក់អាហារដាច់ដោយឡែកពីគ្នា ៣- ការចម្អិនអាហារឱ្យបានឆ្អិនល្អ ៤- ការទុកដាក់អាហារក្នុងសីតុណ្ហភាពត្រឹមត្រូវ ៥- ការប្រើប្រាស់ទឹកស្អាតនិងវត្ថុធាតុដើមឆៅល្អ។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត សំណួរនិងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

ទំនាក់ទំនងមេរៀន ( ជំហានទី២ )

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ ដែលគ្រូបានដាក់ឱ្យនៅលើកមុន ? គ្រូប្រមូលកិច្ចការផ្ទះ

  ២- តើនៅលើកមុន អ្នកបានរៀនមេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ។

  ចម្លើយសិស្ស : ...

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )

ខ្លឹមសារ : គន្លឹះទាំង៥ដែលធ្វើឱ្យអាហារមានសុវត្ថិភាព

- គ្រូសួរ៖ តើអ្វីខ្លះដែលអាចការពារអាហាររបស់យើងឱ្យមានសុវត្ថិភាពនៅពេលយើងចម្អិននិងរៀបចំអាហារ? គ្រូហៅសិស្ស ២ ទៅ៣នាក់ឱ្យឆ្លើយ។ ចម្លើយសិស្ស៖...
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន

គ្រូបែងចែកជាក្រុម

- គ្រូបង្ហាញប័ណ្ណរូបភាពនិងឱ្យសិស្សសង្កេតពីខ្លឹមសារនិងសកម្មភាពនៃរូបនីមួយៗ រួចបែងចែកសិស្សជាក្រុមពិភាក្សា។




















- គ្រូចែកសិស្សជា៥ក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ចូលក្នុងតារាងខាងក្រោម ដោយជ្រើសរើសរូបខាងលើទៅដាក់ទៅតាមខ្លឹមសារសម្រាប់ឡើងបង្ហាញ និងអ្នកឡើងរាយការណ៍ម្នាក់។

ក្រុមទី១ : សំណួរ៖ តើការរក្សាភាពស្អាតដែលធ្វើឱ្យអាហារមានសុវត្ថិភាពមានខ្លឹមសារអ្វីខ្លះ? តើមានសកម្មភាពអ្វីខ្លះ? ព្រោះអ្វី?

ក្រុមទី២ : សំណួរ៖ តើការទុកដាក់អាហារដាច់ដោយឡែកពីគ្នាមានខ្លឹមសារអ្វីខ្លះ? តើមានសកម្មភាពអ្វីខ្លះ? ព្រោះអ្វី?

ក្រុមទី៣ : សំណួរ៖ តើការចម្អិនអាហារឱ្យបានឆ្អិនល្អមានខ្លឹមសារអ្វីខ្លះ? តើមានសកម្មភាពអ្វីខ្លះ? ព្រោះអ្វី?

ក្រុមទី៤ : សំណួរ៖ តើការទុកដាក់អាហារក្នុងសីតុណ្ហភាពត្រឹមត្រូវមានខ្លឹមសារអ្វីខ្លះ? តើមានសកម្មភាពអ្វីខ្លះ? ព្រោះអ្វី?

ក្រុមទី៥ : សំណួរ៖ តើការប្រើប្រាស់ទឹកស្អាតនិងវត្ថុធាតុដើមឆៅល្អមានខ្លឹមសារអ្វីខ្លះ? តើមានសកម្មភាពអ្វីខ្លះ? ព្រោះអ្វី?

| កូនសោគន្លឹះ | | |
|---|---|---|
| ខ្លឹមសារ | សកម្មភាព | ព្រោះអ្វី? |
| | | |

- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :**

| កូនសោគន្លឹះ១៖ | រក្សាភាពស្អាត | |
|---|---|---|
| ខ្លឹមសារ | សកម្មភាព | ព្រោះអ្វី? |
|  លាងសម្អាតដៃឱ្យបានស្អាតល្អ ជាមួយទឹកស្អាតនិងសាប៊ូ | ⇨ ត្រូវលាងដៃរបស់អ្នកមុននឹងចាប់កាន់ចំណីអាហារ និងឱ្យបានញឹកញាប់ក្នុងពេលរៀបចំចំណីអាហារ ⇨ ចូរលាងដៃរបស់អ្នកក្រោយពេលចេញពីបន្ទោបង់ | មានមេរោគបង្កគ្រោះថ្នាក់ជាច្រើនត្រូវបានរកឃើញនៅក្នុងធូលីដី ទឹក សត្វ និងមនុស្ស។ មេរោគទាំងនេះបានតោងជាប់នឹងដៃមនុស្ស កំណាត់ជូត និងសម្ភារៈផ្ទះបាយ ជាពិសេសជ្រុញ ទោះជាការ |

| | | |
|---|---|---|
|  លាងសម្អាត សម្ភារៈផ្ទះ បាយ  លាងសម្អាតបន្លែ ផ្លែឈើនិង សាច់ ជាមួយ ទឹកស្អាត   ជូត លាងសម្អាតផ្ទះបាយដើម្បីកម្ចាត់ សត្វកណ្ដុរ កន្លាត ស្រមោច... | ⇨ ចូរលាងសម្អាតនិងធ្វើ<br>⇨ អនាម័យលើផ្ទៃរាបទាំងអស់និងសម្ភារៈ ឧបករណ៍ប្រើប្រាស់សម្រាប់រៀបចំចំណីអាហារ<br>⇨ ការពារផ្ទះបាយនិងចំណីអាហារពីសត្វល្អិត កណ្ដុរនិងសត្វផ្សេងៗ។ | ប៉ះពាល់តិចតួចក៏ដោយ ក៏អាចបញ្ជូនពួកមេរោគទាំងនោះទៅក្នុងចំណីអាហារ រួចបណ្ដាលឱ្យមានជំងឺនៅពេលបរិភោគចំណីអាហារទាំងនេះ។ |

| កូនសោគន្លឹះ១៖ | ទុកដាក់អាហារឆៅនិងឆ្អិន ដាច់ដោយឡែកពីគ្នា | |
|---|---|---|
| **ខ្លឹមសារ** | **សកម្មភាព** | **ព្រោះអ្វី?** |
|  □បន្លែ  □ផ្លែឈើ  □ត្រីឆៅ  សាច់ឆៅ  មឹកឆៅ  បង្គាឆៅ □ទុកដាក់អាហារដាច់ដោយឡែកពីគ្នា | ⇨ ទុកដាក់អាហារដាច់ដោយឡែកពីគ្នានូវសាច់ឆៅ សាច់មាន់ សាច់ទានិងគ្រឿងសមុទ្រពីអាហារផ្សេងៗ។ | អាហារឆៅជាពិសេស សាច់ សាច់សត្វស្លាប ស៊ុត គ្រឿងសមុទ្រ និង ទឹករសរបស់វា អាចមានមេរោគបង្កគ្រោះថ្នាក់ ដែលអាចឆ្លងចូលទៅក្នុងចំណីអាហារផ្សេងទៀត នៅពេលរៀបចំ និង ទុកដាក់អាហារទាំងនោះ។ |

| | | |
|---|---|---|
| <br>ប្រើប្រាស់ឧបករណ៍និងសម្ភារៈផ្ទះបាយដោយឡែកពីគ្នា | ⇨ ប្រើប្រាស់ឧបករណ៍និងសម្ភារៈផ្ទះបាយដោយឡែកពីគ្នា ដូចជាកាំបិត និងជ្រុញសម្រាប់ហាន់អាហារឆៅ។ | |
| <br>ទុកដាក់អាហារតាមកន្លែងនិងប្រភេទរបស់វា | ⇨ ទុកដាក់អាហារក្នុងកន្លែងរបស់វា ដើម្បីចៀសវាងការប៉ះពាល់គ្នារវាងអាហារឆៅនិងអាហារឆ្អិន។ | |

| កូនសោគន្លឹះ៣៖ | **ការចម្អិនអាហារឱ្យបានឆ្អិនល្អ** | |
|---|---|---|
| ខ្លឹមសារ | សកម្មភាព | ព្រោះអ្វី? |
| <br>សាច់មានពណ៌ក្រហមគឺមិនឆ្អិនល្អ<br><br>សាច់មានពណ៌ប្រផេះគឺឆ្អិនបានល្អ | ⇨ ចូរចម្អិនអាហារឱ្យបានឆ្អិនល្អ ជាពិសេស សាច់ សត្វស្លាប ស៊ុត និងគ្រឿង សមុទ្រ | ការចម្អិនត្រឹមត្រូវអាចសម្លាប់មេរោគដែលបង្កគ្រោះថ្នាក់បានស្ទើរតែទាំងអស់។ ការសិក្សាបានបង្ហាញថា ការចម្អិនអាហារដល់សីតុណ្ហភាព ៧០អង្សាសេ អាចជួយធានាថាវាពិតជាមាន |

| | | |
|---|---|---|
| <br>□មួបអាហារត្រូវចម្អិនឱ្យបានឆ្អិនល្អ<br><br>កម្តៅអាហារឡើងវិញ | ⇨ □ចូរចម្អិនអាហារដូចជាស៊ុបនិងសម្ល ទៅដាំឱ្យពុះឡើងវិញនិងបញ្ជាក់ច្បាស់ថា វាក្តៅឡើងដល់៧០អង្សាសេ។ ចំពោះសាច់និងសាច់សត្វស្លាបត្រូវប្រាកដថាទឹករសរបស់វាឡើងថ្លា មិនមែនមានពណ៌ក្រហមព្រឿងៗនោះទេ។<br>⇨ □កំដៅអាហារដែលឆ្អិនរួច ឡើងវិញឱ្យពុះ ឬឡើង ក្តៅដល់៧០ អង្សាសេ។ | សុវត្ថិភាពសម្រាប់បរិភោគចំណីអាហារដែលទាមទារការប្រុងប្រយ័ត្នជាពិសេសមាន សាច់ហាន់ស្តើង សាច់ជំនូចអាំង សាច់ជាប់សន្លាក់ឆ្អឹង និង សាច់សត្វស្លាបទាំងមូល ។ |

| កូនសោគន្លឹះ៤៖ | ទុកដាក់អាហារនៅក្នុងសីតុណ្ហភាពសុវត្ថិភាព | |
|---|---|---|
| **ខ្លឹមសារ** | **សកម្មភាព** | **ព្រោះអ្វី ?** |
| <br>ទុកដាក់អាហារនៅកន្លែងដែលត្រឹមត្រូវ | ⇨ ចូរកុំទុកអាហារឆ្អិនស្រាប់នៅសីតុហ្ហភាពធម្មតាក្នុងបន្ទប់លើសពីពីរម៉ោង<br>⇨ ដាក់ចំណីអាហារដែលងាយស្អុយឬខូចនិងអាហារដែលចម្អិនរួចទៅក្នុងធុងទឹកកក ឬទូទឹកកកភ្លាមក្នុងកម្រិតសីតុណ្ហភាពតិចជាងប្រាំអង្សាសេ។ | មេរោគអាចបំបែកខ្លួនបានយ៉ាងរហ័សបើសិនជាអាហារត្រូវបានរក្សាទុកក្នុងសីតុណ្ហភាពធម្មតា។ ការលូតលាស់របស់មេរោគអាចថយចុះ ឬត្រូវបញ្ឈប់នៅសីតុណ្ហភាពក្រោម ៥អង្សាសេ ឬលើសពី ៦០អង្សាសេ។ មេរោគគ្រោះថ្នាក់មួយចំនួននៅតែអាចលូត |

| | | |
|---|---|---|
| <br> | ➪ ទុកដាក់អាហារឆ្អិនឱ្យនៅក្តៅជានិច្ចក្នុងកម្រិតសីតុណ្ហភាពលើសពី ៦0អង្សាសេ<br><br>➪ ចូរកុំទុកចំណីអាហារយូរពេកទោះបីដាក់ក្នុងធុងទឹកកក ឬទូទឹកកកក៏ដោយ។ | លាស់បានក្រោមសីតុណ្ហភាពទាបជាង ៥ អង្សាសេ។ |
| **កូនសោគន្លឹះ៥៖** | **ប្រើប្រាស់ទឹកស្អាតនិងវត្ថុធាតុដើមឆៅល្អ** | |
| **ខ្លឹមសារ** | **សកម្មភាព** | **ព្រោះអ្វី?** |

| | | |
|---|---|---|
| <br>លាងសាចជាមួយទឹកស្អាត<br><br>ត្រីស្រស់ស្រកីមានពណ៌ក្រហម<br><br>ប្រើប្រាស់ទឹកស្អាតលាងបន្លែ | ➪ ប្រើប្រាស់ទឹកស្អាត ឬកែច្នៃវាឱ្យមានសុវត្ថិភាពមុននឹងប្រើប្រាស់វា<br><br>➪ □ជ្រើសរើសអាហារដែលនៅស្រស់និងនៅទាំងមូលហើយមានការរៀបចំត្រឹមត្រូវនិងមានសុវត្ថិភាពដូចជា ទឹកដោះគោដែលបានធ្វើប៉ាស្ទ័រកម្ម (សម្លាប់មេរោគ) រួចហើយ។<br><br>➪ លាងបន្លែ ផ្លែឈើ ជាពិសេសបើត្រូវរៀបចំញាំឆៅ។ | វត្ថុធាតុដើមឆៅមានទឹក និងទឹកកកអាចចម្លងមេរោគ និងសារជាតិគីមីគ្រោះថ្នាក់។ សារជាតិគីមីពុលអាចកើតមានក្នុងចំណីអាហារខូចឬល្អយ។ ចូរយកចិត្តទុកដាក់ក្នុងការជ្រើសរើសចំណីអាហារឆៅ និងអនុវត្តវិធានការអនាម័យសាមញ្ញ ដូចជាការលាងសម្អាត ការចិតសំបកអាចកាត់បន្ថយ ការប្រឈមមុខ និងគ្រោះថ្នាក់បាន។ |

| | | |
|---|---|---|
|   កុំប្រើប្រាស់ចំណីអាហារហួស ថ្ងៃខែឆ្នាំកំណត់ | ⇨ កុំប្រើប្រាស់ចំណីអាហារដែលហួស ថ្ងៃ ខែ ឆ្នាំកំណត់។ | |

❖ គ្រូសង្ខេបមេរៀនរួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ដើម្បីឱ្យអាហារមានសុវត្ថិភាព យើងត្រូវអនុវត្តនូវគន្លឹះទាំង ៥ រួមមាន ១- រក្សាភាពស្អាត ២- ការទុកដាក់អាហារដាច់ដោយឡែកពីគ្នា ៣- ការចម្អិនអាហារឱ្យបានឆ្អិនល្អ ៤- ការទុកដាក់អាហារក្នុងសីតុណ្ហភាពត្រឹមត្រូវ ៥- ការប្រើប្រាស់ទឹកស្អាតនិងវត្ថុធាតុដើមឆៅល្អ៕

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពី៖

១- គន្លឹះ៥ដែលធ្វើឱ្យអាហារមានសុវត្ថិភាព

២- តើគន្លឹះទាំង៥នេះ គន្លឹះណាខ្លះដែលប្អូនអាចយកទៅអនុវត្តបាន?

៣- ចូរស្វែងរកចំណុចខុសគ្នាក្នុងរូបភាពខាងក្រោម។ គ្រូពន្យល់រូបខាងក្រោមមានចំណុចខុសគ្នា៨ចំណុច។ ចូរប្អូនស្វែងរកចំណុចខុសគ្នា រួចប្រាប់មូលហេតុនៃភាពខុសគ្នាទាំងនេះ។



ចម្លើយៈ




## ៨- លំហាត់ (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកអនុវត្តនិងប្រាប់ពីគន្លឹះទាំងប្រាំដល់ក្រុមគ្រួសាររបស់ប្អូន ដើម្បីឱ្យអាហារមានសុវត្ថិភាព។

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវអ្វីទៅទឹកសុវត្ថិភាព តាមរយៈការមើលមេរៀនបន្ទាប់ ។ គ្រូនឹងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ទឹកសុវត្ថិភាព

## ខ្លឹមសារម៉ោងទី១ : និយមន័យទឹកមានសុវត្ថិភាពឬទឹកសុវត្ថិភាព និងផ្លូវចម្លងរោគផ្សេងៗដែលបណ្តាលមកពីការខ្វះអនាម័យ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា |ចរិយាសម្បទា |
|---|---|---|
| - ប្រាប់និយមន័យ “ទឹកសុវត្ថិភាព”<br>- រៀបរាប់ពីផ្លូវចម្លងរោគផ្សេងៗមកលើទឹក និងវិធានអនាម័យ។ | - ជ្រើសរើសទឹកសុវត្ថិភាពដើម្បីបរិភោគ<br>- វិភាគលើផ្លូវចម្លងរោគផ្សេងៗដែលបណ្តាលមកពីការខ្វះអនាម័យ។ | - យកចិត្តទុកដាក់ថែរក្សា និងទុកដាក់ទឹកឱ្យមានសុវត្ថិភាពសម្រាប់បរិភោគ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- **និយមន័យទឹកមានសុវត្ថិភាពឬទឹកសុវត្ថិភាព** គឺជាទឹកថ្លា មិនមានក្លិន មិនមានរសជាតិ មិនមានបាក់តេរី មិនមានសារធាតុគីមីពុលលើសស្តង់ដាគុណភាពទឹកផឹក។ ការដឹងពីគុណភាពទឹកតាមរយៈការធ្វើតេស្ត ដោយមន្ទីរជំនាញ មានមន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសិប្បកម្ម និងឧស្សាហកម្ម។

២- **ផ្លូវចម្លងរោគផ្សេងៗដែលបណ្តាលមកពីការខ្វះអនាម័យ** ទឹកគឺជាផ្លូវចម្លងរោគផ្សេងៗដែលបណ្តាលមកពីការខ្វះអនាម័យ។ ការប្រើទឹកមិនស្អាតបង្កឱ្យមានជំងឺដូចជា រាក គ្រុនពោះវៀន កើតព្រូន រោគសើស្បែក។ល។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

ទំនាក់ទំនងមេរៀន (ជំហានទី២)

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : .....
៣- តើទឹកស្អាតមានន័យដូចម្តេច? ចម្លើយសិស្ស .........

- គ្រូកត់ពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យទឹកមានសុវត្ថិភាពឬទឹកសុវត្ថិភាព**

- គ្រូពន្យល់ពាក្យ សុវត្ថិភាព គឺជាការមានសួស្តី ការប្រកបដោយសេចក្តីសុខ ។
- គ្រូសួរសិស្ស តើទឹកមានសុវត្ថិភាពមានន័យដូចម្តេច? គ្រូឱ្យសិស្សចាប់ដៃគូ២ៗនាក់ ពិភាក្សាក្នុងរយៈពេលពី ៣ ទៅ ៥នាទី។ បន្ទាប់មកគ្រូហៅតំណាងសិស្ស២ទៅ៣គូឱ្យឆ្លើយ។ គ្រូណែនាំសិស្សឱ្យអ្នកឆ្លើយបន្ទាប់ បន្ថែមលើចម្លើយអ្នកមុនឬអ្វីដែលថ្មី។
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវ

**ចម្លើយ :**

***ទឹកសុវត្ថិភាព*** ជាទឹកថ្លា មិនមានក្លិន មិនមានរសជាតិ មិនមានបាក់តេរី មិនមានសារធាតុពុលគីមីលើសស្តង់ដាគុណភាពទឹកផឹក។ ការដឹងពីគុណភាពទឹកតាមរយៈការធ្វើតេស្ត ដោយមន្ទីរជំនាញមានមន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសិប្បកម្ម និងឧស្សាហកម្ម។

មេរៀននេះផ្តោតលើទឹកមានសុវត្ថិភាព ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់។ ទឹកស្អាតនិងមានសុវត្ថិភាពសម្រាប់ប្រើប្រាស់គឺជាទឹកដែលបានដាំពុះ ឬឆ្លងកាត់ការច្រោះដោយធុងចម្រោះត្រឹមត្រូវ ឬត្រូវបានសម្លាប់មេរោគដោយប្រព្រឹត្តិកម្មសម្អាតទឹកសម្លាប់មេរោគមីក្រូសរីរាង្គ ដោយប្រើប្រាស់ក្លរក្លរីន ឬសារធាតុសម្លាប់មេរោគផ្សេងៗទៀត បានត្រឹមត្រូវ។





ទឹកចម្រោះនិងដាំពុះ

**ខ្លឹមសារ : ផ្លូវចម្លងរោគផ្សេងៗដែលបណ្តាលមកពីការខ្វះអនាម័យ**

- តើអ្នកធ្លាប់ផឹកទឹកឬចឈើនិងចុកពោះ ឬរាកដែរឬទេ? ដោយសារអ្វី?

- ទុកពេលឱ្យសិស្សគិតក្នុងរយៈពេលពី ២ ទៅ ៣នាទី រួចហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស.......
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន

**ចម្លើយ** : ដោយសារមេរោគឆ្លងតាមទឹក

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។
  ១. តើមេរោគចម្លងតាមទឹកបណ្តាលមកពីកត្តាអ្វីខ្លះ?
  ២. តើជំងឺដែលបង្កឡើងដោយការប្រើប្រាស់ទឹកមិនស្អាតមានអ្វីខ្លះ?
- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវដោយលើកយករូបភាពមកបញ្ជាក់។

**ចម្លើយ** :

ទឹកគឺជាផ្លូវចម្លងរោគផ្សេងៗដែលបណ្តាលមកពីការខ្វះអនាម័យ។ ការប្រើទឹកមិនស្អាតបង្កឱ្យមានជំងឺដូចជា រាក គ្រុនពោះវៀន កើតព្រូន រោគសើស្បែក។ល។

គ្រូបញ្ជាក់បន្ថែម៖ ទឹកដែលមើលទៅស្អាត រងថ្លាល្អមិនមែនសុទ្ធតែជាទឹកមានសុវត្ថិភាពទេ។ ទឹកភ្លៀង ទឹកអណ្តូង ទឹកទន្លេ និងទឹកដែលមិនបានលើកឡើងខាងលើមិនមែនជាទឹកមានសុវត្ថិភាពទេ។





**មេរៀនសង្ខេប**

ទឹកមានសុវត្ថិភាពឬទឹកសុវត្ថិភាព គឺជាទឹកថ្លា មិនមានក្លិន មិនមានរសជាតិ មិនមានបាក់តេរី និងគ្មានសារធាតុគីមីពុលលើសស្តង់ដាគុណភាពទឹកផឹក។ ទឹកស្អាតនិងមានសុវត្ថិភាពសម្រាប់ប្រើប្រាស់គឺជាទឹកដែលបានដាំពុះ ឬឆ្លងកាត់ការច្រោះ ឬត្រូវបានសម្លាប់មេរោគ។ ការប្រើទឹកមិនស្អាតបង្កឱ្យមានជំងឺដូចជា រាក គ្រុនពោះវៀន កើតព្រូនរោគសើស្បែក។ល។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពីៈ

១. និយមន័យ “ទឹកសុវត្ថិភាព”

២- តើផ្លូវចម្លងរោគផ្សេងៗមកលើទឹកបានដោយរបៀបណា?

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ**: ចូរអ្នកយកចិត្តទុកដាក់ថែរក្សា និងទុកដាក់ទឹកឱ្យមានសុវត្ថិភាពសម្រាប់បរិភោគ។

**កិច្ចការផ្ទះ** : ចូរអ្នកធ្វើការសួរពីឪពុកម្តាយឬបងប្អូន ពីវិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព គ្រូនឹងប្រមូលកិច្ចការនៅម៉ោងអប់រំសុខភាពលើកក្រោយ។ ចូរអ្នកមើលរៀនបន្តអំពី វិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព។

# មេរៀនទី ១ : ទឹកសុវត្ថិភាព (តចប់)

## ខ្លឹមសារម៉ោងទី២ : វិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| រៀបរាប់ពីវិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព។ | បង្ហាញពីវិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព។ | យកចិត្តទុកដាក់ថែរក្សា និងទុកដាក់ទឹកឱ្យមានសុវត្ថិភាពសម្រាប់បរិភោគ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

**វិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព** ដូចជា ដាំទឹកឱ្យពុះ ក្នុងសីតុណ្ហភាព ១០០ អង្សាសេ ឆ្លងកាត់ការច្រោះដោយធុងចម្រោះត្រឹមត្រូវ ដាក់ក្នុងធុងស្អាតដែលមានគ្របបិទជិត ទុកនៅកន្លែងស្ងួត និងក្នុងម្លប់ ដួសដោយកែវទឹកឬបោយទឹក ដែលទើបតែលាងស្អាតមកដាក់ក្នុងកំសៀវសម្រាប់បរិភោគជាច់ដោយឡែក។

៥- វិធីសាស្ត្រ

សំណួរបំផុសគំនិត សំនួរនិងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់** (**ជំហានទី១**)

- គ្រូពិនិត្យវត្តមាន  អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន** (**ជំហានទី២**)

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ......
  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស :.......
  ៣- តើទឹកស្អាតមានន័យដូចម្ដេច? ចម្លើយសិស្ស :.......
- គ្រូកត់ពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

## ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)

## ខ្លឹមសារ : វិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។ សំណួរៈ តើវិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាពមានអ្វីខ្លះ ?
- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :**

វិធីអនុវត្តដើម្បីឱ្យទឹកប្រើប្រាស់មានសុវត្ថិភាពមានៈ

- ដាំទឹកឱ្យពុះ ក្នុងសីតុណ្ហភាព ១០០ អង្សាសេ
- ឆ្លងកាត់ការច្រោះដោយធុងចម្រោះត្រឹមត្រូវ
- ដាក់ក្នុងធុងស្អាតដែលមានគម្របបិទជិត
- ទុកនៅកន្លែងស្ងួត និងក្នុងម្លប់
- ដួសដោយកែវទឹកឬបោយទឹកដែលទើបតែលាងស្អាតមកដាក់ក្នុងកំសៀវសម្រាប់បរិភោគដាច់ដោយឡែក។




ដំណើរការនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

យើងត្រូវបរិភោគតែទឹកមានសុវត្ថិភាពប៉ុណ្ណោះដើម្បីការពារខ្លួនពីជំងឺរាក និងជំងឺឆ្លងដោយសារទឹកផ្សេងៗ។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

វិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព ត្រូវដាំទឹកឱ្យពុះ ឆ្លងកាត់ការច្រោះ ដាក់នៅក្រោមពន្លឺថ្ងៃយ៉ាងហោចណាស់៦ម៉ោងឬបង់ថ្នាំជាតិក្លរីនចូលក្នុងចំនួនមួយត្រឹមត្រូវ ដាក់ក្នុងធុងស្អាតដែលមានគ្របបិទជិតទុកនៅកន្លែងស្ងួតនិងក្នុងម្លប់ និងដួសដោយកែវទឹកឬបោយទឹក៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពីវិធីអនុវត្តដើម្បីឱ្យទឹកមានសុវត្ថិភាព

**៨- លំហាត់** (ជំហានទី៥)

**បណ្ដាំផ្ញើ**: ចូរអ្នកយកចិត្តទុកដាក់ថែរក្សា និងទុកដាក់ទឹកឱ្យមានសុវត្ថិភាពសម្រាប់បរិភោគ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនអនាម័យនៅផ្ទះ និងធ្វើការសួរពីឪពុកម្ដាយឬបងប្អូនពីអនាម័យនៅផ្ទះមានអ្វីខ្លះ? ។ គ្រូនឹងប្រមូលកិច្ចការនៅម៉ោងអប់រំសុខភាពលើកក្រោយ។

**ឯកសារយោង**


១. ស្តង់ដាគុណភាពទឹកស្អាត, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ឆ្នាំ២០១៥

២. ផែនការសុវត្ថិភាពទឹក, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ឆ្នាំ២០១៥

# មេរៀនទី ២ : អនាម័យនៅផ្ទះ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីអនាម័យនៅចង្ក្រានបាយបង្គន់និងបន្ទប់គេង។ | - បង្ហាញពីសារៈសំខាន់នៃការអនុវត្តអនាម័យនៅផ្ទះ<br>- បកស្រាយវិធានអនាម័យចង្ក្រានបាយ អនាម័យបង្គន់ និងអនាម័យបន្ទប់គេង។ | - យកចិត្តទុកដាក់អនុវត្តអនាម័យនៅផ្ទះ កាត់បន្ថយការប្រើចង្ក្រានបង្ហុយផ្សែងដែលធ្វើឱ្យខូចសុខភាព។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- អនាម័យចង្ក្រានបាយ៖ រួមមាន ការរៀបចំសម្អាតចង្ក្រានបាយនិងសម្ភារៈផ្ទះបាយដូចជា ចាន ឆ្នាំង ខ្ទះ ស្លាបព្រា សម ចង្កឹះ វែក ជ្រុញ កាំបិត កែវ ឬពែងទឹក។ល។ ឱ្យបានស្អាត កុំឱ្យមានខ្លាញ់ ផ្សែងរុំ ឬប្រឡាក់កម្ទេចចំណីអាហារ ទាំងមុនពេលប្រើប្រាស់ និងក្រោយពេលប្រើប្រាស់ម្តងៗ។

២- អនាម័យបង្គន់៖ រួមមាន ការប្រើប្រាស់បង្គន់ឱ្យបានត្រឹមត្រូវតាមប្រភេទបង្គន់នីមួយៗ ការពិនិត្យថាបង្គន់ស្អាតជានិច្ចពេលប្រើប្រាស់រួចម្តងៗ ដោយការចាក់ទឹកសម្អាតនិងធានាថាមិនមានជាប់លាមក ឬទឹកនោមក្នុងចានបង្គន់ ឬក្រៅចានបង្គន់ រួមទាំងការដុសលាងសម្អាតបង្គន់ ទាំងក្នុងចានបង្គន់ ក្រៅចានបង្គន់ និងបរិវេណបង្គន់ទាំងមូល ជាមួយសាប៊ូនិងទឹកឱ្យស្អាតជាប្រចាំ។

៣- អនាម័យបន្ទប់គេង៖ រួមមាន ការរៀបចំឱ្យមានខ្យល់និងពន្លឺចេញចូលគ្រប់គ្រាន់ក្នុងបន្ទប់គេង ពិសេសពេលថ្ងៃត្រូវបើកបង្អួច បើកវាំងនន ដើម្បីកុំឱ្យសត្វល្អិតដូចជាមូសសម្ងំនៅកន្លែងងងឹត ការបោសសម្អាតបន្ទប់គេងឱ្យបានស្អាតជាប្រចាំ កុំឱ្យមានធូលី ស្នាមប្រឡាក់ផ្សេងៗ កម្ចាត់សម្បុកពីងពាងឬសត្វល្អិតជ្រកនៅ ការរៀបចំបន្ទប់គេងឱ្យបានស្អាត ដោយទុកដាក់ មុង ភួយ កន្ទេល និងខ្នើយឱ្យមានរបៀបរៀបរយបន្ទាប់ពីក្រោកពីគេងរៀងរាល់ថ្ងៃ ព្រមទាំងការបោកសម្អាត មុង ភួយ ខ្នើយ ស្រោមពូក ស្រោមខ្នើយ និងហាលថ្ងៃ ដើម្បីកុំឱ្យមានក្លិន និងមានក្អែលលើសម្ភារៈប្រើប្រាស់ទាំងនេះ។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត និងចម្លើយ ការពិភាក្សាក្រុម បកស្រាយក្រុម ការពន្យល់។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

គ្រូពិនិត្យវត្តមាន  អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុសៈ

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ....

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស :

  ៣- តើអ្នកបានជួយធ្វើអនាម័យផ្ទះដែរឬទេ? បើបានមានធ្វើអ្វីខ្លះ? ចម្លើយៈ ...................

  - គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

- គ្រូពន្យល់ៈ អនាម័យមានសារៈសំខាន់សម្រាប់សុខភាពយើងទាំងអស់គ្នា ជាពិសេសការអនុវត្តអនាម័យនៅតាមផ្ទះ ធ្វើឱ្យបរិស្ថានល្អប្រសើរ និងចៀសផុតពីជំងឺឆ្លងបានមួយចំនួនធំ។
- គ្រូចែករូបភាពនិងឱ្យសិស្សសង្កេតរូបភាពខាងក្រោមក្នុងរយៈពេលពី ២ ទៅ ៥នាទី។








- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលព ៥ ទៅ ១០នាទ ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។

  ១. តើការធ្វើអនាម័យនៅចង្ក្រានបាយមានអ្វីខ្លះ?

  ២. តើការធ្វើអនាម័យបង្គន់មានអ្វីខ្លះ?

  ៣. តើការធ្វើអនាម័យបន្ទប់គេងមានអ្វីខ្លះ?

- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :**

## ១- អនាម័យចង្ក្រានបាយ

ចង្ក្រានបាយជាផ្នែកមួយដ៏សំខាន់នៃផ្ទះរបស់យើងរស់នៅ។ ចង្ក្រានបាយជាទីកន្លែងសម្រាប់រៀបចំចម្អិន ទុកដាក់ម្ហូបអាហារ ស្បៀង និងជួនកាលអាចជាទីកន្លែងបរិភោគអាហារផងដែរ។ ហេតុនេះ ចង្ក្រានបាយត្រូវតែរៀបចំឱ្យមានរបៀបរៀបរយ និងមានអនាម័យជាប់ជាប្រចាំ។

សម្ភារៈក្នុងចង្ក្រានបាយរួមមានគ្រឿងឧបភោគ គ្រឿងបរិភោគ ត្រូវរៀបចំទុកដាក់ឱ្យមានរបៀបរៀបរយនៅតាមទីតាំងច្បាស់លាស់ដូចជា លើធ្នើ ក្នុងទូ កញ្ច្រែង ធុង ពាង ឬដប ដើម្បីងាយស្រួលយកមកប្រើប្រាស់ មិនច្រលំ ឬពិបាករកពេលចង់ប្រើប្រាស់ម្តងៗ។ អាហារនិងស្បៀងនៅចង្ក្រានបាយក៏ត្រូវរៀបចំទុកដាក់ឱ្យមានសុវត្ថិភាព ដើម្បីបង្ការការរំខានពីសត្វចង្រៃដូចជា កណ្តុរ កន្លាត ស្រមោច សង្ហារ ពីងពាងឬសត្វល្អិតដទៃទៀតមកស៊ីបំផ្លាញ ថែមទាំងអាចបង្កការចម្លងមេរោគផ្សេងៗដល់អាហារនិងស្បៀងរបស់មនុស្ស។

លើសពីនេះ នៅក្នុងឬក្បែរចង្ក្រានបាយ គួររៀបចំឱ្យមានកន្លែងលាងសម្អាតដៃដោយមានទឹកនិងសាប៊ូជាប់ជាប្រចាំសម្រាប់ប្រើប្រាស់។ បើមានលទ្ធភាព គួររៀបចំបំពង់បង្ហុយផ្សែងពីចង្ក្រានទៅខាងក្រៅផ្ទះដើម្បីកាត់បន្ថយផ្សែង ធូលីធ្យូង ឬក្លិនមិនល្អចូលក្នុងផ្ទះ។ គួរប្រើចង្ក្រានហ្គាស ឬចង្ក្រានជីវឧស្ម័នតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវជំនួសចង្ក្រានឧស ឬធ្យូងសម្រាប់ការចម្អិនអាហារ ដើម្បីចៀសវាងការបង្កហានិភ័យដល់សុខភាពផ្លូវដង្ហើម ឬផលប៉ះពាល់អវិជ្ជមានដល់សុខភាព សមាជិកគ្រួសារ ពិសេសកុមារ និងស្ត្រី។

នៅក្នុងចង្ក្រានបាយត្រូវមានអនាម័យជាប់ជាប្រចាំ តាមរយៈការសម្អាតចង្ក្រានបាយនិងសម្ភារៈផ្ទះបាយដូចជា ចាន ឆ្នាំង ខ្ទះ ស្លាបព្រា សម ចង្កឹះ វែក ជ្រុញ កាំបិត កែវ ឬពែងទឹក។ល។ ឱ្យបានស្អាត កុំឱ្យមានខ្លាញ់ ផ្សិតរុំ ឬប្រឡាក់កម្ទេចចំណីអាហារ ទាំងមុនពេលប្រើប្រាស់ និងក្រោយពេលប្រើប្រាស់ម្តងៗ។

ចង្ក្រានបាយស្អាត មានសោភ័ណភាព មានអនាម័យ ធ្វើឱ្យសមាជិកក្នុងគ្រួសារមានសេចក្តីសុខក្នុងការទទួលទានចំណីអាហារ មិនមានហានិភ័យនៃជំងឺផ្លូវដង្ហើម ឬការចម្លងរោគផ្សេងៗ និងរួមចំណែកធ្វើឱ្យសមាជិកគ្រួសារមានសុខភាពល្អ។





អនាម័យចង្ក្រានបាយ

## ២- អនាម័យបង្គន់

បង្គន់ជាទីកន្លែងដ៏មានសារៈសំខាន់មួយទៀតដែលយើងប្រើប្រាស់ច្រើនដងជារៀងរាល់ថ្ងៃ ពេលនៅផ្ទះ។ ទោះបីបង្គន់ស្ថិតនៅក្នុងផ្ទះ ជាប់ផ្ទះ ឬក្រៅផ្ទះក៏ដោយ បង្គន់ត្រូវតែស្អាតជានិច្ច។ នៅក្នុងឬបរិវេណជុំវិញបង្គន់



ត្រូវតែស្អាត មិនមានក្លិនមិនល្អ មិនមានកម្ទេចចំណីអាហារ ឬកាកសំណល់មិនស្អាត មិនមានសត្វល្អិត ឬសំបុកពីងពាងស្នាក់នៅ។ បង្គន់ត្រូវមានទឹកនិងសាប៊ូជាប់ជាប្រចាំសម្រាប់ប្រើប្រាស់គ្រប់ពេល។

ដើម្បីឱ្យបង្គន់ស្អាតជាប់ជាប្រចាំ យើងចាំបាច់ត្រូវមានវិធានការអនាម័យដូចខាងក្រោម៖

- ប្រើប្រាស់បង្គន់ឱ្យបានត្រឹមត្រូវតាមប្រភេទបង្គន់នីមួយៗ
- ពិនិត្យថាបង្គន់ស្អាតជានិច្ចពេលប្រើប្រាស់រួចម្តងៗ ដោយការចាក់ទឹកសម្អាតនិងធានាថាមិនមានជាប់លាមក ឬទឹកនោមក្នុងចានបង្គន់ ឬក្រៅចានបង្គន់
- ដុសលាងសម្អាតបង្គន់ ទាំងក្នុងចានបង្គន់ ក្រៅចានបង្គន់ និងបរិវេណបង្គន់ទាំងមូល ជាមួយសាប៊ូនិងទឹកឱ្យស្អាតជាប្រចាំ
- ចៀសវាងការចោលកាកសំណល់រឹង ក្រដាសអនាម័យ សំឡីអនាម័យ ឬកម្ទេចកំណាត់ក្នុងចានបង្គន់ ដើម្បីបង្ការការស្ទះបង្គន់
- គួរមានកន្លែងលាងសម្អាតដៃ និងសាប៊ូនៅក្នុងឬក្បែរបង្គន់សម្រាប់លាងដៃក្រោយពេលចេញពីបង្គន់ម្តងៗ
- គួរប្រើប្រាស់សម្ភារៈប្រើប្រាស់សម្អាតបង្គន់ដូចជាច្រាស់ សាប៊ូ ស្រោមដៃ តែមិនគួរដុសសម្អាតចានបង្គន់ជាមួយកម្ទេចដែកទេ ព្រោះវាធ្វើឱ្យមានស្នាមកូតពិបាកក្នុងការសម្អាត ព្រមទាំងជាប់ក្លិនមិនល្អថែមទៀតផង
- បង្គន់គួរមានខ្យល់ចេញចូល ឬឧបករណ៍បឺតខ្យល់**ដើម្បី**កាត់បន្ថយក្លិន ព្រមទាំងគួរមានពន្លឺច្បាស់។





ការសម្អាតបង្គន់

បង្គន់ស្អាត មិនមានក្លិនស្អុះ ឆ្អាប និងមានបរិយាកាសល្អ ធ្វើឱ្យយើងមានទំនុកចិត្តក្នុងការ ប្រើប្រាស់ មិនបង្កហានិភ័យឆ្លងមេរោគផ្សេងៗពីបង្គន់មិនស្អាត និងមានផាសុកភាពក្នុងគ្រួសារ។

## ៣- អនាម័យបន្ទប់គេង

បន្ទប់គេងជាកន្លែងដែលយើងសម្រាកកាយច្រើនម៉ោងជាងគេក្នុងមួយថ្ងៃៗ។ បន្ទប់គេងស្អាតមានអនាម័យល្អធ្វើឱ្យយើងមានអារម្មណ៍ល្អ គេងលក់ស្រួល និងមិនមានជំងឺឆ្លងនានាដូចជាជំងឺសើស្បែក ជំងឺផ្លូវដង្ហើម ឬជំងឺឆ្លងតាមសត្វល្អិតដូចជាមូសជាដើម។ ដើម្បីឱ្យបន្ទប់គេងស្អាតមាន  អនាម័យ យើងត្រូវ៖

- រៀបចំឱ្យមានខ្យល់និងពន្លឺចេញចូលគ្រប់គ្រាន់ក្នុងបន្ទប់គេង ពិសេសពេលថ្ងៃត្រូវបើកបង្អួច បើកវាំងនន ដើម្បីកុំឱ្យសត្វល្អិតដូចជាមូសសម្ងំនៅកន្លែងងងឹត
- បោសសម្អាតបន្ទប់គេងឱ្យបានស្អាតជាប្រចាំ កុំឱ្យមានធូលី ស្នាមប្រឡាក់ផ្សេងៗ កម្ទាត់សម្បុកពីងពាងឬសត្វល្អិតជ្រកនៅ។ លើសពីនេះ បើអាចធ្វើបានមិនត្រូវយកនំចំណី ឬអាហារផ្សេងៗមកបរិភោគក្នុងបន្ទប់គេងទេ ព្រោះកម្ទេចអាហារ ឬនំចំណីផ្សេងៗជាប្រភពនៃការទាក់ទាញសត្វស្រមោច សង្ការ កន្លាត កណ្ដុរ ឬសត្វល្អិតផ្សេងៗ ដែលសុទ្ធតែជាប្រភពនៃការចម្លងរោគដល់មនុស្សបាន។ ក្នុងករណីមិនអាចចៀសវាងបាន ពេលបរិភោគរួច ត្រូវជូតសម្អាតភ្លាមៗតែម្ដង ដើម្បីកុំឱ្យសត្វល្អិតទាំងនោះចូលបន្ទប់គេងបាន។
- រៀបចំបន្ទប់គេងឱ្យបានស្អាត ដោយទុកដាក់ មុង ភួយ កន្ទេល និងខ្នើយឱ្យមានរបៀបរៀបរយបន្ទាប់ពីក្រោកពីគេងរៀងរាល់ថ្ងៃ
- ឧស្សាហ៍បោកសម្អាត មុង ភួយ ខ្នើយ ស្រោមពូក ស្រោមខ្នើយ និងហាលថ្ងៃ ដើម្បីកុំឱ្យមានក្លិន និងមានក្អែលលើសម្ភារៈប្រើប្រាស់ទាំងនេះ។ ខ្នើយ ពូកគួរឧស្សាហ៍ហាលកម្ដៅថ្ងៃដើម្បីសម្លាប់ពពួកមេរោគតូចៗ ( **Dust mites)** ដែលយើងមិនអាចមើលឃើញនឹងភ្នែកជ្រកតោងជាប់ជាមួយសម្ភារៈទាំងនោះ ឬស្ថិតនៅក្នុងបរិយាកាសបន្ទប់គេង។ ពពួកមេរោគទាំងនោះធ្វើឱ្យយើងរលាកស្បែក ឬរលាកច្រមុះ បំពង់ក ឬអាចដល់ផ្លូវដង្ហើមដែលពិបាកក្នុងការព្យាបាល។



ពពួកមេរោគ **Dust mites** ដែលនៅស្រោមពូក ស្រោមខ្នើយដែលមិនមានអនាម័យ

ការរក្សាបន្ទប់គេងឱ្យមានអនាម័យស្អាតល្អ ធ្វើឱ្យយើងមានអារម្មណ៍ស្រស់ស្រាយ គេងលក់ស្រួល និងអាចបង្ការបានរោគឆ្លងផ្សេងៗជាអាទិ៍ ជំងឺសើស្បែក ជំងឺរលាកច្រមុះ បំពង់ក ឬផ្លូវដង្ហើម ដែលរំខានដល់ការសិក្សា ឬជីវិតប្រចាំថ្ងៃរបស់យើង។



រៀបចំពូក ខ្នើយ មុង ភួយ កន្ទេល
ឱ្យមានរបៀបរៀបរយពេកក្រោកពីដំណេរ



សម្អាតបន្ទប់គេងឱ្យបានស្អាត
មានខ្យល់ ពន្លឺចេញ ចូល

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ផ្ទះជាទីកន្លែងដែលសមាជិកគ្រួសារទាំងអស់ជ្រកនៅស្នាក់នៅ ជួបជុំជជែកគ្នា ទទួលទានអាហារ ដំណេក ព្រមទាំងបន្ទោបង់។ ហេតុនេះ ផ្ទះត្រូវតែស្អាតជាប់ជានិច្ចពិសេសត្រូវមានអនាម័យចង្ក្រានបាយ បង្គន់ និងបន្ទប់គេង។ **អនាម័យចង្ក្រានបាយ** គឺត្រូវរៀបចំទុកដាក់គ្រឿងបរិភោគអាហារ ស្បៀង កុំឱ្យមានកណ្ដុរ កន្លាត ឬសត្វល្អិតមករំខាន និងត្រូវបោសជូតសម្អាតបរិវេណ និងគ្រឿងឧបភោគឱ្យបានស្អាតមុននិងក្រោយពេលប្រើប្រាស់។ **អនាម័យបង្គន់** គឺដុសលាងសម្អាតជាប់ជាប្រចាំជាមួយទឹកនិងសាប៊ូឱ្យស្អាតទាំងចានបង្គន់និងបរិវេណបង្គន់ និងត្រូវមានពន្លឺ ឬខ្យល់ចេញចូលដើម្បីកាត់បន្ថយក្លិនមិនល្អនិងបង្ការការឆ្លងមេរោគនានា។ **អនាម័យបន្ទប់គេង** គឺត្រូវរៀបចំសម្ភារៈប្រើប្រាស់ឱ្យមានរបៀប មានខ្យល់និងពន្លឺចេញចូលបានល្អពេលក្រោកពីគេង និងត្រូវឧស្សាហ៍បោកសម្អាត ហាលថ្ងៃ កន្ទេល មុង ភួយ ស្រោមពូក ស្រោមខ្នើយ សម្អាតធូលី សត្វល្អិត ឬស្នាមប្រឡាក់ផ្សេងៗ។ ផ្ទះស្អាតនិងមានអនាម័យធ្វើឱ្យសមាជិកក្នុងគ្រួសារមានជាសុកភាព សុវត្ថិភាព និងអាចបង្ការបានជំងឺឆ្លងផ្សេងៗនៅក្នុងផ្ទះ៕

### ៧- **វាយតម្លៃ** ( ជំហានទី៤ )

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពីៈ

១- តើការធ្វើអនាម័យនៅចង្ក្រានបាយមានអ្វីខ្លះ ?

២- តើការធ្វើអនាម័យបង្គន់មានអ្វីខ្លះ ?

៣- តើការធ្វើអនាម័យបន្ទប់គេងមានអ្វីខ្លះ ?

### ៨- **លំហាត់** ( ជំហានទី៥ )

**បណ្ដាំផ្ញើ**: ចូរអ្នកយកចិត្តទុកដាក់អនុវត្តអនាម័យនៅផ្ទះ កាត់បន្ថយការប្រើចង្ក្រានបង្ហុយផ្សេងដែលធ្វើឱ្យខូចសុខភាព។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនទំនាក់ទំនងសុខភាពមាត់ធ្មេញនិងសុខភាពទូទៅ និងធ្វើការសួរពីឪពុកម្ដាយឬបងប្អូន ពីសារៈសំខាន់នៃសុខភាពមាត់ធ្មេញ។ គ្រូនឹងប្រមូលកិច្ចការនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ :   ទំនាក់ទំនងសុខភាពមាត់ធ្មេញនិងសុខភាពទូទៅ

## ខ្លឹមសារម៉ោងទី១ : ទំនាក់ទំនងសុខភាពមាត់ធ្មេញ និងសុខភាពទូទៅ

**១- រយៈពេល** :  ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ពណ៌នាបានពីទំនាក់ទំនងរវាងសុខភាពមាត់ធ្មេញ និងសុខភាពទូទៅ។ | - បង្ហាញពីការប្រព្រឹត្តមិនល្អដែលប៉ះពាល់ដល់សុខភាពមាត់ធ្មេញ និងសុខភាពទូទៅ។ | - យកចិត្តទុកដាក់ធ្វើអនាម័យមាត់ធ្មេញឱ្យបាន២ដងក្នុងមួយថ្ងៃ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- ទំនាក់ទំនងសុខភាពមាត់ធ្មេញ និងសុខភាពទូទៅ៖ មានការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញថា មានទំនាក់ទំនងរួមគ្នារវាងសុខភាពមាត់និងសុខភាពទូទៅ។ ទំនាក់ទំនងទាំងនោះ គឺមានទាំងផលប៉ះពាល់មានទាំងកត្តាបង្កជំងឺ។ ផលប៉ះពាល់នៃជំងឺមាត់ធ្មេញជាមួយសុខភាពទូទៅ៖ ជំងឺមាត់ធ្មេញដូចជា ជំងឺអញ្ចាញធ្មេញត្រូវបានផ្សារភ្ជាប់ជាមួយនឹងជំងឺរ៉ាំរ៉ៃទូទៅមួយចំនួនដូចជា ជំងឺសរសៃឈាមបេះដូង ជំងឺទឹកនោមផ្អែម ជំងឺផ្លូវដង្ហើម ជំងឺរលាកសន្លាក់រ៉ាំរ៉ៃ ជំងឺលើសសម្ពាធឈាម។ល។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ សំណួរបំផុស ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

គ្រូពិនិត្យវត្តមាន  អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  - ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : .....
  - ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន ? ចម្លើយសិស្ស : .....
  - ៣- តើអ្នកធ្លាប់ឈឺធ្មេញដែរឬទេ ? បើធ្លាប់វាបង្កការលំបាកអ្វីខ្លះ ? ចម្លើយៈ ........

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ទំនាក់ទំនងសុខភាពមាត់ធ្មេញ និងសុខភាពទូទៅ**

- គ្រូពន្យល់៖ មាត់ធ្មេញជាផ្នែកមួយនៃរាងកាយមនុស្សយើង ដូចនេះសុខភាពមាត់ធ្មេញក៏ជាផ្នែកមួយនៃសុខភាពទូទៅរបស់យើងដែរ។ ការថែរក្សាធ្មេញ និងអញ្ចាញធ្មេញបានស្អាតនិងមានសុខភាពល្អ គឺជាប្រការចាំបាច់។ មាត់ធ្មេញក៏ដូចជាសរីរាង្គផ្សេងៗទៀតនៃរាងកាយដែរ ក្នុងមាត់របស់ប្អូនៗមានបាក់តេរី តែបាក់តេរីភាគច្រើនមិនបង្កគ្រោះថ្នាក់អ្វីឡើយ។ ដោយសារមាត់ គឺជាច្រកចូលនៃអាហារនានា ដូចនេះមាត់ជាច្រក នាំបាក់តេរីខ្លះដែលអាចបណ្តាលឱ្យកើតជាជំងឺផ្សេងៗ។



ការថែរក្សាសុខភាពសម្រាប់មាត់ធ្មេញ និងសុខភាពទូទៅមានសារៈសំខាន់ណាស់។ ការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញថា មានទំនាក់ទំនងរួមគ្នារវាងសុខភាពមាត់និងសុខភាពទូទៅ។ ទំនាក់ទំនងទាំងនេះ គឺមានទាំងផលប៉ះពាល់និងកត្តាបង្កជំងឺ។

**ខ្លឹមសារ : ផលប៉ះពាល់នៃជំងឺមាត់ធ្មេញជាមួយសុខភាពទូទៅ**

- គ្រូសួរ : ប្រសិនបើប្អូនឈឺធ្មេញ តើមានផលប៉ះពាល់ដល់អ្វីខ្លះ ?
- គ្រូឱ្យសិស្សចាប់ដៃគូ២ៗនាក់ ពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៣ ទៅ ៥នាទី។ បន្ទាប់មកគ្រូហៅសិស្សតំណាង ២ទៅ៣គូរឱ្យឆ្លើយ។ គ្រូណែនាំសិស្សឱ្យអ្នកឆ្លើយបន្ទាប់បន្ថែមលើចម្លើយអ្នកមុនឬអ្វីដែលថ្មី។
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។
  ១. តើជំងឺអ្វីខ្លះដែលកើតឡើងបណ្តាលមកពីមានបញ្ហាសុខភាពមាត់ធ្មេញ ?
  ២. តើជំងឺមាត់ធ្មេញបង្កផលប៉ះពាល់ដល់អ្វីខ្លះ ?
- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវដោយលើកយករូបភាពមកបញ្ជាក់។

**ចម្លើយ :**

សុខភាពមាត់ធ្មេញផ្សារភ្ជាប់យ៉ាងសំខាន់ទៅនឹងសុខភាពទូទៅ។ ជំងឺមាត់ធ្មេញមួយចំនួន ដូចជា ជំងឺអញ្ចាញធ្មេញត្រូវបានផ្សារភ្ជាប់ជាមួយនឹងជំងឺរ៉ាំរ៉ៃទូទៅមួយចំនួនដូចជា ជំងឺសរសៃឈាមបេះដូង ជំងឺទឹកនោមផ្អែម ជំងឺផ្លូវដង្ហើម ជំងឺរលាកសន្លាក់រ៉ាំរ៉ៃ ជំងឺលើសសម្ពាធឈាម ជំងឺដាច់សរសៃឈាមខួរក្បាល (ស្ត្រូក) ជំងឺវង្វេងស្មារតី ជំងឺតម្រងនោម និងការធ្វើឱ្យប្រព័ន្ធការពាររាងកាយចុះខ្សោយជាដើម។ល។ រីឯជំងឺពុកធ្មេញវិញ ក៏អាចបណ្តាលឱ្យមានការឆ្លង មេរោគចូលទៅសរសៃឈាមខួរក្បាល ឬបេះដូងផងដែរ។




បន្ថែមលើសពីនេះទៅទៀត ពេលអ្នកមានសុខភាពមាត់ធ្មេញមិនល្អ អាចបង្កឱ្យមានផលប៉ះពាល់ដល់សកម្មភាពរស់នៅប្រចាំថ្ងៃរបស់យើងផងដែរ ដូចជាការទទួលទានអាហារ គេងមិនបាន ប៉ះពាល់ដល់ការសិក្សារៀនសូត្រ ការប្រកបរបរចិញ្ចឹមជីវិត និងការទំនាក់ទំនងជាមួយអ្នកដទៃ ។ល។



❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ជំងឺមាត់ធ្មេញដូចជា ជំងឺអញ្ចាញធ្មេញត្រូវបានផ្សារភ្ជាប់ជាមួយនឹងជំងឺរ៉ាំរ៉ៃទូទៅមួយចំនួន ដូចជា ជំងឺសរសៃឈាមបេះដូង ជំងឺទឹកនោមផ្អែម ជំងឺផ្លូវដង្ហើម ជំងឺរលាកសន្លាក់រ៉ាំរ៉ៃ ជំងឺលើសសម្ពាធឈាម។ល។ ពេលអ្នកមានសុខភាពមាត់ធ្មេញមិនល្អ អាចបង្កឱ្យមានផលប៉ះពាល់ ការទទួលទានអាហារ គេងមិនបាន ប៉ះពាល់ដល់ ការសិក្សារៀនសូត្រ ការប្រកបរបរចិញ្ចឹមជីវិត និងការទំនាក់ទំនងជាមួយអ្នកដទៃ។ល។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើការទំនាក់ទំនងរវាងសុខភាពមាត់ធ្មេញនិងសុខភាពទូទៅមានអ្វីខ្លះ?

២- តើកត្តាអ្វីខ្លះដែលជាកត្តារួម បង្កឱ្យមានផលប៉ះពាល់ដល់សុខភាពទូទៅ ក៏ដូចជាសុខភាពមាត់ធ្មេញ?

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ៖** សូមអ្នកយកចិត្តទុកដាក់ធ្វើអនាម័យមាត់ធ្មេញឱ្យបាន២ដង ក្នុងមួយថ្ងៃ

**កិច្ចការផ្ទះ៖** ចូរអ្នកសាកសួរក្រុមគ្រួសាររបស់អ្នក តើការប្រព្រឹត្តមិនល្អប៉ះពាល់ដល់មាត់ធ្មេញនិងសុខភាពទូទៅមានអ្វីខ្លះ? គ្រូនឹងប្រមូលកិច្ចការនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ទំនាក់ទំនងសុខភាពមាត់ធ្មេញនិងសុខភាពទូទៅ (តចប់)

## ខ្លឹមសារម៉ោងទី២ : កត្តាបង្កជំងឺនិងការប្រព្រឹត្តមិនល្អប៉ះពាល់ដល់មាត់ធ្មេញ និងសុខភាពទូទៅ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ពណ៌នាបានពីការប្រព្រឹត្តមិនល្អប៉ះពាល់ដល់មាត់ធ្មេញ និងសុខភាពទូទៅ | - បង្ហាញពីការប្រព្រឹត្តមិនល្អដែលប៉ះពាល់ដល់សុខភាពមាត់ធ្មេញ និងសុខភាពទូទៅ។ | - យកចិត្តទុកដាក់ធ្វើអនាម័យមាត់ធ្មេញឱ្យបាន២ដងក្នុងមួយថ្ងៃ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

កត្តាបង្កជំងឺរួមមាន៖ អាហារឬភេសជ្ជៈដែលមានជាតិផ្អែម ទម្លាប់ជក់បារី ទំពារម្លូស្លា សេពគ្រឿង ស្រវឹង ...នឹងបណ្ដាលឱ្យមានផលប៉ះពាល់ដល់សុខភាពមាត់ធ្មេញ ក៏ដូចជាសុខភាពទូទៅដែរ។

២- ការប្រព្រឹត្តមិនល្អប៉ះពាល់ដល់មាត់ធ្មេញ និង សុខភាពទូទៅ៖ ត្រូវចៀសវាងការប្រព្រឹត្តនិងទម្លាប់មិនល្អមួយចំនួន ដូចជាខាំវត្ថុរឹង ខាំប៊ិច ខ្មៅដៃ ដុំទឹកកក... ដែលអាចបណ្ដាលឱ្យកើតមានបញ្ហាដល់សុខភាពមាត់ធ្មេញ។ ដើម្បីទទួលបានសុខភាពរាងកាយល្អ យើងចាំបាច់ត្រូវថែទាំរក្សា គ្រប់ផ្នែកនៃរូបរាងកាយយើង ដែលក្នុងនោះការថែរក្សាមាត់ធ្មេញបានស្អាតនិងមានសុខភាពល្អ គឺជាប្រការចាំបាច់។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

ទំនាក់ទំនងមេរៀន (ជំហានទី២)

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូកត់ពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : កត្តាបង្កជំងឺ**

- គ្រូសួរ៖ តើកត្តាដែលបង្កជំងឺដល់សុខភាពមាត់ធ្មេញមានអ្វីខ្លះ ? ទុកពេលឱ្យសិស្សគិតក្នុងរយៈពេល ពី ២ ទៅ ៣នាទី រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស៖...
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :** ជំងឺមាត់ធ្មេញ និងជំងឺមិនឆ្លងរ៉ាំរ៉ៃមួយចំនួន បណ្តាលមកពីកត្តាដូចតទៅ៖

- ចំណីអាហារនិងភេសជ្ជៈសម្បូរដោយជាតិផ្អែម គឺជាចំណីអាហារដែលប៉ះពាល់ដល់សុខភាពទូទៅ ក៏ដូចជាសុខភាពមាត់ធ្មេញផងដែរ។ អាហារនិងភេសជ្ជៈផ្អែម បង្កឱ្យកើតមានជំងឺពុកធ្មេញ និងជំងឺទូទៅជាច្រើន ជំងឺទឹកនោមផ្អែម ជំងឺធាត់ ជំងឺមហារីក ជំងឺសរសៃឈាមបេះដូង និងបង្កឱ្យមានការចុះខ្សោយនូវប្រព័ន្ធការពាររាងកាយយើង។
  - ពពួកបារី ថ្នាំជក់ គ្រឿងស្រវឹង ម្លូស្លា...ជាដើម។ល។




**ខ្លឹមសារ : ការប្រព្រឹត្តមិនល្អប៉ះពាល់ដល់មាត់ធ្មេញ និងសុខភាពទូទៅ**

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។

  ១. តើការប្រព្រឹត្តរបស់កុមារមិនល្អប៉ះពាល់ដល់មាត់ធ្មេញនិងសុខភាពទូទៅមានអ្វីខ្លះ ? ចូររៀបរាប់

  ២. តើការប្រព្រឹត្តរបស់មនុស្សធំមិនល្អប៉ះពាល់ដល់មាត់ធ្មេញនិងសុខភាពទូទៅមានអ្វីខ្លះ ?

ចូររៀបរាប់

- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ** : ការប្រព្រឹត្តនិងទម្លាប់មិនល្អរបស់កុមារមួយចំនួន ដែលបណ្ដាលឱ្យមានប៉ះពាល់ដល់សុខភាពមាត់ធ្មេញ ហើយក៏ដូចជាសុខភាពទូទៅដែរនោះរួមមាន៖

ចំពោះក្មេងតូច ឬកុមារ៖

- បៀមដៃ
- បៀមក្បាលដោះជ័រ
- ទម្លាប់ខាំក្រចក ប៊ិក ខ្មៅដៃ...
- ប្រើធ្មេញខាំវត្ថុរឹង ស្វិត ដូចជាដុំទឹកកក គម្របដប ខ្សែអំបោះ...
- ដកដង្ហើមតាមមាត់ (ពេលគេងចំហរមាត់)
- ចំណីអាហារផ្អែមស្អិត និងពពួកភេសជ្ជៈផ្អែម ប៉ូវកម្លាំង...។ សំខាន់គឺការបរិភោគអាហារនិងភេសជ្ជៈបែបនេះញឹកញាប់។




ចំពោះមនុស្សចាស់ មានការប្រព្រឹត្តនិងទម្លាប់មិនល្អមួយចំនួនជាបន្ថែមទៀត ដូចជា៖

- ជក់បារី
- ផឹកគ្រឿងស្រវឹង
- ទំពារម្លូស្លា ចុកថ្នាំ
- អនាម័យមាត់ធ្មេញមិនល្អ សម្អាតធ្មេញមិនទៀងទាត់ ។ល។




ការប្រព្រឹត្តនិងទម្លាប់មិនល្អទាំងអស់ដែលបានរៀបរាប់ខាងលើ អាចបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពទូទៅ ក៏ដូចជាសុខភាពមាត់ធ្មេញដែរ ដូចជា៖ កើតមានជំងឺរ៉ាំរ៉ៃផ្សេងៗ និងធ្វើឱ្យធ្មេញខូចខាតឬផ្លាស់ប្ដូរកំណាំធ្មេញ។

ដូចនេះ ដើម្បីទទួលបានសុខភាពរាងកាយល្អ យើងចាំបាច់ត្រូវថែទាំរក្សាគ្រប់ផ្នែកនៃរូបរាងកាយយើង ដែលក្នុងនោះការថែរក្សាមាត់ធ្មេញបានស្អាតនិងមានសុខភាពល្អ គឺជាប្រការចាំបាច់។

❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

អាហារឬភេសជ្ជៈដែលមានជាតិផ្អែម ទម្លាប់ជក់បារី ទំពារម្លូស្លា សេពគ្រឿងស្រវឹង...នឹងបណ្ដាលឱ្យមានផលប៉ះពាល់ដល់សុខភាពមាត់ធ្មេញ ក៏ដូចជាសុខភាពទូទៅដែរ។ ត្រូវចៀសវាងការប្រព្រឹត្តនិងទម្លាប់មិនល្អមួយចំនួន ដូចជាខាំវត្ថុរឹង ខាំប៊ិក ខ្មៅដៃ ជុំទឹកកក... ដែលអាចបណ្ដាលឱ្យកើតមានបញ្ហាដល់សុខភាពមាត់ធ្មេញ។ ដើម្បីទទួលបានសុខភាពរាងកាយល្អ យើងចាំបាច់ត្រូវថែទាំរក្សា គ្រប់ផ្នែកនៃរូបរាងកាយយើង ដែលក្នុងនោះការថែរក្សាមាត់ធ្មេញបានស្អាតនិងមានសុខភាពល្អ គឺជាប្រការចាំបាច់៕

**៧- វាយតម្លៃ** ( ជំហានទី៤ )

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើកត្តាអ្វីខ្លះដែលជាកត្តារួម បង្កឱ្យមានផលប៉ះពាល់ដល់សុខភាពទូទៅ ក៏ដូចជាសុខភាពមាត់ធ្មេញ ?

២- តើការប្រព្រឹត្តមិនល្អដែលប៉ះពាល់ដល់សុខភាពមាត់ធ្មេញនិងសុខភាពទូទៅមានអ្វីខ្លះ ?

**៨- លំហាត់** ( ជំហានទី៥ )

**បណ្ដាំផ្ញើ៖** ចូរប្អូនយកចិត្តទុកដាក់ធ្វើអនាម័យមាត់ធ្មេញឱ្យបាន២ដងក្នុងមួយថ្ងៃ ជាពិសេសពេលយប់មុនពេលចូលគេង

**កិច្ចការផ្ទះ៖** ចូរប្អូនសាកសួរក្រុមគ្រួសាររបស់ប្អូន តើភ្នែកមើលមិនច្បាស់បណ្ដាលមកពីអ្វី ? ចូរប្អូនមើលមេរៀនកំហុសកំណុំរូបភាព សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : កំហុសកំណុំរូបភាព

## ខ្លឹមសារម៉ោងទី១ : កំណុំរូបភាពភ្នែកធម្មតា និយមន័យកំហុសកំណុំរូបភាពភ្នែកមានបញ្ហាកំហុសកំណុំ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ប្រាប់និយមន័យ"កំហុសកំណុំរូបភាព"<br>- រៀបរាប់ពីប្រភេទនៃបញ្ហាកំហុសកំណុំរូបភាព។ | - បង្ហាញវិធីបង្ការបញ្ហាកំហុសកំណុំរូបភាព។ | - យកចិត្តទុកដាក់ក្នុងការថែរក្សាភ្នែកនិង ស្វែងរកសេវាថែទាំនិងព្យាបាលភ្នែកបានត្រឹមត្រូវ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- កំណុំរូបភាពភ្នែកធម្មតា : ចំពោះភ្នែកធម្មតាពន្លឺនៃវត្ថុត្រូវឆ្លងកាត់តាមកញ្ចក់ភ្នែក កែវភ្នែក រហូតដល់ផ្នែកខាងក្រោយទៅប្រសព្វលើស្រទាប់រ៉េទីន បន្ទាប់មកសរសៃចក្ខុប្រសាទនាំយករូបភាពនេះពីស្រទាប់រ៉េទីនទៅខួរក្បាល ធ្វើឱ្យយើងឃើញរូបភាពច្បាស់។

២- និយមន័យកំហុសកំណុំរូបភាព៖ កំហុសកំណុំ គឺជាការឃើញវត្ថុមិនច្បាស់ដោយសារបាច់ពន្លឺនៃវត្ថុចាំងចូលក្នុងភ្នែកមិនប្រសព្វចំលើស្រទាប់រ៉េទីន អាចប្រសព្វពីខាងមុខ ឬខាងក្រោយ ជាហេតុធ្វើឱ្យមើលវត្ថុឃើញមិនច្បាស់។ កំហុសកំណុំរូបភាពអាចកែតម្រូវបានដោយការពាក់វ៉ែនតានិងព្យាបាល។

៣- ប្រភេទនៃកំហុសកំណុំរូបភាព : ចែកចេញជា៤ ប្រភេទគឺ៖ ម៉្យូប អ៊ីពែមេត្រូប អាស្ទិកម៉ាត និងប្រេសប្ស៊ីត។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បង្ហាញ ពន្យល់ សង្កេត

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )

គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

ទំនាក់ទំនងមេរៀន ( ជំហានទី២ )

- គ្រូរំឭកមេរៀន កែកិច្ចការផ្ទះ និងសំណួរបំផុស៖

១- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ...
២- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ...
៣- តើអ្នក ឬគ្រួសារមានអ្នកពាក់វ៉ែនតាម្ញូបដែរឬទេ? បើមានគាត់មានបញ្ហាភ្នែកដូចម្តេច?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសំយោគចម្លើយសិស្ស និងសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : កំណុំរូបភាពភ្នែកធម្មតា**

- **ពន្យល់ពាក្យ៖ រ៉េទីន** : ស្រទាប់បាតភ្នែក

  **កំហុសកំណុំរូបភាព** : មិនមែនជាជំងឺភ្នែកទេ តែវាខូចទម្រង់នៃគំហើញ

  **បាច់ពន្លឺ** : គឺជាបណ្តុំនៃកាំពន្លឺច្រើនចូលក្នុងភ្នែក។
- គ្រូបង្ហាញរូបភាពរូបផ្តុំនៃគ្រាប់ភ្នែក រួចពន្យល់ ជាពិសេសគ្រូពន្យល់ស្រទាប់រ៉េទីន គឺជាស្រទាប់បាតភ្នែក

**រូបផ្តុំនៃគ្រាប់ភ្នែក(មើលពីចំហៀង)**




ចំពោះភ្នែកធម្មតាពន្លឺនៃវត្ថុត្រូវឆ្លងកាត់តាមកញ្ចក់ផ្នែកខាងមុខដល់កែវភ្នែក ពីផ្នែកខាងក្រោយទៅចំស្រទាប់រ៉េទីន។ បន្ទាប់មកសរសៃចក្ខុប្រសាទនាំយករូបភាពនេះ ពីស្រទាប់រ៉េទីនទៅខួរក្បាល។ ដូចនេះយើងឃើញរូបភាពច្បាស់ អាស្រ័យដោយពន្លឺនៃវត្ថុនោះបញ្ចាំងចំលើស្រទាប់រ៉េទីន។




**ភ្នែកធម្មតា និងតួនាទី៖**

- កញ្ចក់ភ្នែក: បង្វែរបាច់ពន្លឺចូលក្នុងភ្នែក

- កែវភ្នែក: បន្តបង្វែរបាច់ពន្លឺបន្ថែមទៀតឱ្យប្រសព្វទៅលើស្រទាប់រ៉េទីន
- ស្រទាប់រ៉េទីន: បំលែងរូបភាពទៅជាចរន្ត រួចបញ្ជូនទៅខួរក្បាលតាមរយៈសរសៃចក្ខុប្រសាទ
- សរសៃចក្ខុប្រសាទ: បញ្ជូនព័ត៌មានរូបភាព ពីស្រទាប់រ៉េទីន ទៅខួរក្បាលដើម្បីវិភាគ។

**ខ្លឹមសារ : និយមន័យកំហុសកំណុំរូបភាព**

- គ្រូសួរ : តើកំហុសកំណុំរូបភាពមានន័យដូចម្តេច? ទុកពេលឱ្យសិស្សគិត២ទៅ៣នាទី រួចហៅសិស្សឱ្យឆ្លើយ។ ចម្លើយសិស្ស
- គ្រូសម្របសម្រួល សំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារនៃមេរៀន។

**ចម្លើយ:** កំហុសកំណុំរូបភាព គឺជាការមើលឃើញមិនច្បាស់លើវត្ថុ ឬរូបភាព ដោយសារបាច់ពន្លឺនៃវត្ថុចាំងចូលក្នុងភ្នែកមិនប្រសព្វនៅលើស្រទាប់រ៉េទីន។

**ខ្លឹមសារ : ភ្នែកមានបញ្ហាកំហុសកំណុំនិងប្រភេទនៃកំហុសកំណុំរូបភាព**

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរ:
  - តើភ្នែកមានបញ្ហាកំហុសកំណុំមានន័យដូចម្តេច?
  - តើភ្នែកមានបញ្ហាចែកចេញជាប៉ុន្មានប្រភេទ ឬប្រភេទនៃកំហុសកំណុំរូបភាពមានអ្វីខ្លះ?
  - រយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។
- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវ

**ចម្លើយ :**

កំហុសកំណុំ គឺជាការឃើញវត្ថុមិនច្បាស់ដោយសារបាច់ពន្លឺនៃវត្ថុចាំងចូលក្នុងភ្នែកមិនប្រសព្វចំលើស្រទាប់រ៉េទីន អាចប្រសព្វពីខាងមុខ ឬខាងក្រោយ ជាហេតុធ្វើឱ្យមើលវត្ថុឃើញមិនច្បាស់។ កំហុសកំណុំរូបភាពអាចកែតម្រូវបានដោយការពាក់វ៉ែនតានិងព្យាបាល។

កំហុសកំណុំរូបភាពចែកចេញជា៤ ប្រភេទគឺៈ ម៉្យូប អ៊ីពែមេត្រូប អាស្ទិកម៉ាត និងប្រេសប៊្យីត

❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ



**មេរៀនសង្ខេប**

កំហុសកំណុំរូបភាព គឺជាការមើលឃើញមិនច្បាស់លើវត្ថុ ឬរូបភាព ដោយសារបាច់ពន្លឺនៃវត្ថុចាំងចូលក្នុងភ្នែកមិនប្រសព្វនៅលើស្រទាប់រ៉េទីន។ ភ្នែកធម្មតាឃើញរូបភាពច្បាស់ អាស្រ័យដោយពន្លឺនៃវត្ថុនោះបញ្ចាំងចំលើស្រទាប់រ៉េទីន។ កំហុសកំណុំរូបភាពចែកចេញជា៤ ប្រភេទគឺៈ ម៉្យូប អ៊ីពែមេត្រូប អាស្ទិកម៉ាត និងប្រេសប៊្យីត។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- រូបផ្ដុំនៃភ្នែក

២- ដូចម្ដេចហៅថាកំហុសកំណុំរូបភាព

៣- តើប្រភេទនៃកំហុសកំណុំរូបភាពមានអ្វីខ្លះ?

៤- តើមានមូលហេតុអ្វីខ្លះបណ្ដាលឱ្យមានបញ្ហាកំហុសកំណុំរូបភាព?

**៨- លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវនិងរកព័ត៌មានពីប្រភេទកំហុសកំណុំរូបភាពនីមួយៗមានរោគសញ្ញាដូចម្ដេចនិងពីវិធីការពារភ្នែក ដោយសួរពីឪពុកម្ដាយ បងប្អូន ឬមើលនៅក្នុងសៀវភៅសិស្ស។ គ្រូនឹងប្រមូលចម្លើយនៅម៉ោងសិក្សាអប់រំសុខភាពលើកក្រោយ។

**ឯកសារបង្អែក៖**

https://www.iapb.org/learn/knowledge-hub/eye-conditions/refractive-error/

The Ideal Distance for TV Viewing (verywellhealth.com)

# មេរៀនទី ២ : កំហុសកំណុំរូបភាព (តចប់)

## ខ្លឹមសារម៉ោងទី២ : មូលហេតុ រោគសញ្ញា ការបង្ការនិងដំណោះស្រាយ និងការស្វែងរកសេវាព្យាបាល ពេលភ្នែកមានកំហុសរូបភាព

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីមូលហេតុ រោគសញ្ញា ការបង្ការនិងដំណោះស្រាយ និងការស្វែងរកសេវាព្យាបាល ពេលភ្នែកមានកំហុសកុំណុំរូបភាព។ | - បង្ហាញពីមូលហេតុ រោគសញ្ញា ការបង្ការនិងដំណោះស្រាយ និងការស្វែងរកសេវាព្យាបាល ពេលភ្នែកមានកំហុសកុំណុំរូបភាព។ | - យកចិត្តទុកដាក់ក្នុងការថែរក្សាភ្នែកនិង ស្វែងរកសេវាថែទាំនិងព្យាបាលភ្នែកបានត្រឹមត្រូវ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- មូលហេតុកំហុសកំណុំរូបភាព៖ មូលហេតុបណ្តាលឱ្យមានបញ្ហាកំហុសកំណុំរូបភាពមានដូចជា៖ កត្តាពីកំណើត កត្តាតំណពូជ ការប៉ះទង្គិចភ្នែក ឬឈឺភ្នែកញឹកញាប់ ការព្យាបាលភ្នែកមិនបានត្រឹមត្រូវតាមបច្ចេកទេស ទម្លាប់នៃការមើល ឬអាននៅចម្ងាយជិតៗ និងយូរម៉ោងពេក ដូចជា អានសៀវភៅ មើលទូរទស្សន៍ កុំព្យូទ័រ ទូរស័ព្ទដៃ និងគ្រឿងអេឡិចត្រូនិច ....។

២- រោគសញ្ញាកំហុសកំណុំរូបភាព៖ ភ្នែកម្ញូប មើលឆ្ងាយមិនច្បាស់ ប៉ុន្តែមើលជិតច្បាស់។ អ៊ីពែមេត្រូប មើលជិតមិនច្បាស់ មើលឆ្ងាយក៏មិនច្បាស់។ អាស្ទិកម៉ាត មើលឆ្ងាយមិនច្បាស់ បែកជាស្រមោល ឃើញវត្ថុវៀចរលក ឬបែកជាពីរ។ ប្រេសប៊ីត មើលវត្ថុ ឬអក្សរល្អិតៗនៅទីជិតមិនច្បាស់ ចំពោះមនុស្សដែលមានវ័យចាប់ពី ៤0ឆ្នាំឡើងទៅ។

៣- វិធីបង្ការនិងដំណោះស្រាយកំហុសកំណុំរូបភាព៖ អានសៀវភៅនៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់ និងចម្ងាយពី ៣៥ ទៅ៤0សង់ទីម៉ែត្រ មើលទូរទស្សន៍យ៉ាងតិចឱ្យបានចម្ងាយ៥ដងនៃទំហំអេក្រង់ទូរទស្សន៍ កុំមើលចំប្រភពពន្លឺខ្លាំង ឧស្សាហ៍ព្រិចភ្នែកនៅពេលមើលសៀវភៅ កំព្យូទ័រ ឬទូរសព្ទឆ្លាតវៃរយៈពេលយូរ។

៤- ការស្វែងរកសេវាព្យាបាល៖ នៅពេលភ្នែកមានបញ្ហាកំហុសកំណុំរូបភាព ត្រូវប្រញាប់ស្វែងរកសេវាសុខភាពភ្នែកឱ្យទាន់ពេលវេលា នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យ ឬសេវាឯកជន ដែលនៅជិតនិងមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ឬ ស្ថាប័នពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។

## ៥- វិធីសាស្ត្រ

សំណួរ ចម្លើយ ពិភាក្សាក្រុម បង្ហាញ បកស្រាយ ពន្យល់ សង្កេត

## ៦- សកម្មភាពបង្រៀននិងរៀន

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំឭកមេរៀន កែកិច្ចការផ្ទះ និងសំណួរបំផុស៖

  ១- តើនៅលើកមុន អ្នកបានរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ...

  ២- គ្រូប្រមូលកិច្ចការផ្ទះ។ គ្រូហៅសិស្ស២ទៅ៣នាក់ឱ្យឆ្លើយសំណួរកិច្ចការផ្ទះ។ ចម្លើយសិស្ស...

  ៣- តើក្រុមគ្រួសារអ្នកមានបញ្ហាភ្នែកដែរឬទេ? ប្រសិនមាន មូលហេតុអ្វី? ចម្លើយសិស្ស : ...
- គ្រូសំយោគចម្លើយសិស្ស និងសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : មូលហេតុកំហុសកំណុំរូបភាព**

- គ្រូសួរៈ តើមូលហេតុកំហុសកំណុំរូបភាពបណ្តាលមកពីកត្តាអ្វីខ្លះ? គ្រូឱ្យសិស្ស២ ឬ៣ នាក់ឆ្លើយ
- គ្រូសម្របសម្រួល និងសំយោគចម្លើយ

**ចម្លើយៈ** មូលហេតុបណ្តាលឱ្យមានបញ្ហាកុំហុសកំណុំរូបភាពមានដូចជា៖

- ពីកំណើត៖ គ្រាប់ភ្នែក កញ្ចក់ភ្នែក និងកែវភ្នែកមានលក្ខណៈខុសពីធម្មតា
- តំណពូជ៖ ឪពុកម្តាយមានបញ្ហាកំហុសកំណុំ
- ការប៉ះទង្គិចភ្នែក ឬឈ្លីភ្នែកញឹកញាប់
- ការព្យាបាលភ្នែកមិនបានត្រឹមត្រូវតាមបច្ចេកទេស
- ទម្លាប់នៃការមើល ឬអាននៅចម្ងាយជិតៗ និងយូរម៉ោងពេក ដូចជា អានសៀវភៅ មើលទូរទស្សន៍ កុំព្យូទ័រ ទូរស័ព្ទដៃ និងគ្រឿងអេឡិចត្រូនិចផ្សេងៗទៀត។

**ខ្លឹមសារ : រោគសញ្ញានៃកំហុសកំណុំរូបភាព**

- គ្រូចែកសិស្សជា៤ក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។

  សំណួរទី១៖ តើភ្នែកម្ញូបមានរោគសញ្ញាដូចម្តេចខ្លះ?

  សំណួរទី២៖ តើភ្នែកអ៊ីពែមេត្រូបមានរោគសញ្ញាដូចម្តេចខ្លះ?

  សំណួរទី៣៖ តើភ្នែកអាស្ទិកម៉ាតមានរោគសញ្ញាដូចម្តេចខ្លះ?

  សំណួរទី៤៖ តើភ្នែកប្រេសប៊្យុត (មើលជិតមិនច្បាស់)មានរោគសញ្ញាដូចម្តេចខ្លះ?
- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវ

**ចម្លើយ :**

- ភ្នែកម៉្យូប៖
  - មើលឆ្ងាយមិនច្បាស់ ប៉ុន្តែមើលជិតច្បាស់
  - ធ្វើភ្នែកព្រឹមៗ ញី ឬព្រិចភ្នែកញឹកញាប់ ពេលមើលវត្ថុដែលនៅទីឆ្ងាយ
  - ចុករួយគ្រាប់ភ្នែក និងឈឺក្បាល ពេលមើល ឬសម្លឹងទៅឆ្ងាយយូរពេក
  - កាន់សៀវភៅអាននៅជិតភ្នែក។



គំហើញភ្នែកម៉្យូប ពេលអត់ពាក់វ៉ែនតា



គំហើញភ្នែកម៉្យូប ពេលពាក់វ៉ែនតា

- អ៊ីពែមេត្រូប
  - មើលជិតមិនច្បាស់ មើលឆ្ងាយក៏មិនច្បាស់
  - ធ្វើភ្នែកព្រឹមៗ ពេលមើលវត្ថុដែលនៅទីជិត និងទីឆ្ងាយ
  - ចុករួយគ្រាប់ភ្នែក ព្រិចភ្នែកញឹកញាប់ និងឈឺក្បាលពេលសម្លឹងយូរ។

គំហើញភ្នែកអ៊ីពែមេត្រូប



គំហើញភ្នែកធម្មតា



- អាស្ទិកម៉ាត
  - មើលឆ្ងាយមិនច្បាស់ បែកជាស្រមោល (កម្រិតស្រាល) ឃើញវត្ថុវៀច រលក (កម្រិតមធ្យម) ឬបែកជាពីរ (កម្រិតធ្ងន់)។
  - ធ្វើភ្នែកព្រឹមៗ ពេលមើលវត្ថុ ដែលនៅទីឆ្ងាយ
  - ចុករួយគ្រាប់ភ្នែក ព្រិចភ្នែកញឹកញាប់ និងឈឺក្បាលពេលមើល ឬសម្លឹងទៅឆ្ងាយយូរពេក




គំហើញភ្នែកអាស្ទិកម៉ាត




គំហើញភ្នែកធម្មតា

- ប្រេសស្បឹត (មើលជិតមិនច្បាស់)




- មើលវត្ថុ ឬអក្សរល្អិតៗនៅទីជិតមិនច្បាស់ ចំពោះមនុស្សដែលមានវ័យចាប់ពី ៤០ឆ្នាំឡើងទៅ
- ជាញឹកញាប់គាត់កាន់អានឬមើលវត្ថុតូចៗ ដាក់នៅឆ្ងាយពីភ្នែកជាងចម្ងាយធម្មតា លើសពី ៤០ស.ម.
- ឈឺចុករួយគ្រាប់ភ្នែក ឈឺក្បាលនៅពេលដែលគាត់ព្យាយាមអានឬមើលវត្ថុតូចៗរយៈពេលយូរ។

**ខ្លឹមសារ : ការបង្ការនិងដំណោះស្រាយ**

- គ្រូសួរៈ តើការបង្ការនិងដំណោះស្រាយលកំហុសកំណុំរូបភាពមានអ្វីខ្លះ ? គ្រូឱ្យសិស្ស២ ឬ៣ នាក់ឆ្លើយ
- គ្រូសម្របសម្រួល និងសំយោគចម្លើយ

**ចម្លើយៈ** ដើម្បីបង្ការកុំឱ្យមានកំហុសកំណុំរូបភាព ចូរប្រើប្រាស់ភ្នែកឱ្យបានត្រឹមត្រូវៈ

- អានសៀវភៅនៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់ និងចម្ងាយពី ៣៥ ទៅ៤០សង់ទីម៉ែត្រ
- មើលទូរទស្សន៍យ៉ាងតិចឱ្យបានចម្ងាយ ៥ដងនៃទំហំអេក្រង់ទូរទស្សន៍ (ឧទាហរណ៍ ទូរទស្សន៍ទំហំ ៣២អិញ ត្រូវអង្គុយមើលចំងាយ៤ម៉ែត្រ) ប៉ុន្តែកុំឱ្យតិចជាង៣ម៉ែត្រ
- កុំមើលចំប្រភពពន្លឺខ្លាំង (ពន្លឺព្រះអាទិត្យ អំពូលភ្លើង ភ្លើងហ្វា ភ្លើងផ្សារដែក)
- ឧស្សាហ៍ព្រិចភ្នែកនៅពេលមើលសៀវភៅ កំព្យូទ័រ ឬទូរស័ព្ទឆ្លាតវៃរយៈពេលយូរ
- អនុវត្តការសម្រាកភ្នែកតាមគោលការណ៍ ២០-២០-២០ ដែលផ្តល់អនុសាសន៍ដោយអ្នកឯកទេសចក្ខុសាស្ត្រនៅលើពិភពលោក (គោលការណ៍ ២០-២០-២០ មានន័យថា បន្ទាប់ពីធ្វើការងារលើកុំព្យូទ័រ ឬអានរយៈពេល ២០នាទី ត្រូវសម្រាកភ្នែកដោយមើលទៅឆ្ងាយ ចម្ងាយជាង ២០ ហ្វីត ឬ៦ ម៉ែត្រ ឱ្យបានរយៈពេល ២០ វិនាទី យ៉ាងតិច)។
- ក្នុងករណីប្រេសស្បឹត (មើលជិតមិនច្បាស់) ត្រូវទៅពិគ្រោះនិងពិនិត្យព្យាបាលជាមួយគ្រូពេទ្យជំនាញភ្នែក ពេលមានអាយុលើសពី ៤០ឆ្នាំឡើងទៅ។



ពិនិត្យភ្នែកដោយគ្រូពេទ្យភ្នែក

**ខ្លឹមសារ : ការស្វែងរកសេវាព្យាបាល**

- គ្រូណែនាំនិងផ្តាំផ្ញើរ នៅពេលភ្នែកមានបញ្ហាកំហុសកំណុំរូបភាព ត្រូវរួសរាន់ស្វែងរកសេវាសុខភាពភ្នែកឱ្យទាន់ពេលវេលា នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យ ឬសេវាឯកជនដែលនៅជិតនិងមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ឬ ស្ថាប័នពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។

❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

**មូលហេតុ**បណ្តាលឱ្យមានបញ្ហាកុំហុសកំណុំរូបភាពមាន ពីកំណើត តំណពូជ ការប៉ះទង្គិចភ្នែក ការព្យាបាល និងទម្លាប់នៃការមើល ឬអាននៅចម្ងាយជិតៗ។ **រោគសញ្ញា**នៃបញ្ហាកុំហុសកំណុំរូបភាពមាន ភ្នែកម្ញូប អ៊ីពែមេត្រូប អាស្ទិកម៉ាត និងប្រេសស្ប៊ីត ។**វិធីបង្ការ** គឺត្រូវប្រើប្រាស់ភ្នែកឱ្យបានត្រឹមត្រូវដោយអានមានពន្លឺគ្រប់គ្រាន់និងចម្ងាយពី ៣៥ ទៅ៤០សង់ទីម៉ែត្រ មើលទូរទស្សន៍យ៉ាងតិចឱ្យបានចម្ងាយ៥ដងនៃទំហំអេក្រង់ កុំមើលចំប្រភពពន្លឺខ្លាំង ឧស្សាហ៍ព្រិចភ្នែកនៅពេល។ នៅពេលភ្នែកមានបញ្ហាកំហុសកំណុំរូបភាព ត្រូវរួសរាន់ស្វែងរកសេវាសុខភាពភ្នែកឱ្យទាន់ពេលវេលា៕

## ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើរោគសញ្ញាកំហុសកំណុំរូបភាពមានអ្វីខ្លះ ?

២- តើវិធីបង្ការកុំឱ្យមានបញ្ហាកំហុសកំណុំរូបភាពមានអ្វីខ្លះ ?

៣- ចូរអ្នកយកចិត្តទុកដាក់ក្នុងការថែរក្សាភ្នែកនិងស្វែងរកសេវាថែទាំនិងព្យាបាលភ្នែកបានត្រឹមត្រូវ។

## ៨- **លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ**

១- ចូរអ្នកមានបម្រុងប្រយ័ត្ននិងការពារភ្នែកកុំឱ្យមានកំហុសកំណុំរូបភាព

២- ចូរអ្នកមើលមេរៀនជំងឺដង្កូវពូន សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

**ឯកសារបង្អែក**

https://www.iapb.org/learn/knowledge-hub/eye-conditions/refractive-error/
The Ideal Distance for TV Viewing (verywellhealth.com)

# មេរៀនទី ១ : ជំងឺដង្កូវព្រូន

## ខ្លឹមសារម៉ោងទី១ : និយមន័យ និងប្រភេទនៃដង្កូវព្រូន

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ប្រាប់និយមន័យ"ដង្កូវព្រូន"<br>- រៀបរាប់ពីប្រភេទនិងរបៀបឆ្លងនៃដង្កូវព្រូន។ | - បង្ហាញពីប្រភេទនិងរបៀបឆ្លងនៃដង្កូវព្រូន។ | - យកចិត្តទុកដាក់អនុវត្តអនាម័យជាប្រចាំ ហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យ៖ ដង្កូវព្រូនជាសត្វល្អិតតូចៗ ដែលរស់នៅដោយស្រូបយកជីវជាតិពីមនុស្ស ឬសត្វជាអាហារ ដែលហៅថា ប៉ារ៉ាសិត។

២- ប្រភេទនៃដង្កូវព្រូន៖ ដង្កូវព្រូនចែកចេញជា ២ប្រភេទ ដង្កូវព្រូនខ្លួនមូល និងខ្លួនសំប៉ែត។ ដង្កូវព្រូនមូលមាន៖ ព្រូនទម្ពក់ ព្រូនអង្គិលីល ព្រូនចង្កឹះ អៀន និងព្រូនរំពាត់សេះ។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន  អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......

  ៣- តើអ្នកដែលឮនិងឃើញព្រូនដែរឬទេ? បើធ្លាប់តើមានអ្វីខ្លះ? មានរូបរាងដូចម្តេច?
- គ្រូហៅសិស្ស ២ ឬ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្តាខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

## ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )

### ខ្លឹមសារ : និយមន័យជំងឺដង្កូវព្រូន



- គ្រូបង្ហាញរូបដង្កូវព្រូន រួចពន្យល់៖

ដង្កូវព្រូនអាចកើតលើមនុស្សគ្រប់វ័យ ដោយសារការខ្វះអនាម័យ។ ដង្កូវព្រូនជាសត្វល្អិតតូចៗ ដែលរស់នៅដោយស្រូបយកជីវជាតិពីមនុស្ស ឬសត្វជាអាហារ ដែលហៅថា ប៉ារ៉ាសិត។ ព្រូនទាំងនេះមានព្រូនខ្លះអាចមើលឃើញដោយភ្នែកផ្ទាល់  ខ្លះទៀតអាចមើលឃើញដោយមីក្រូទស្សន៍។

### ខ្លឹមសារ : ប្រភេទនៃដង្កូវព្រូន

- គ្រូបែងចែកសិស្សជាក្រុមពិភាក្សា ពីប្រភេទនៃដង្កូវព្រូន និងរៀបរាប់ពីប្រភេទនីមួយៗ។ គ្រូទុកពេលឱ្យឱ្យសិស្សពិភាក្សារយៈពេល ៥ ទៅ១០នាទី។
- តំណាងក្រុមឡើងបកស្រាយ
- គ្រូសម្របសម្រួល និងសំយោគចម្លើយសិស្ស

ចម្លើយ:

| | |
|---|---|
| ក- ព្រូនទម្ពក់ ព្រូនអង្កលីល | |
|  | ជាប្រភេទព្រូនម៉្យាងមានទំហំតូចដែលមិនអាចមើលឃើញដោយភ្នែកទទេ។ វារស់នៅនិងលូតលាស់ក្នុងដីសើមនិងដីភក់។ |
| ខ- ព្រូនចង្កឹះ | |
|  | ជាប្រភេទព្រូនមូលដែលមានទំហំធំជាងគេក្នុងចំណោមព្រូនមូលទាំងអស់។ វាមានប្រវែងពី២០ ទៅ ៣០ សង់ទីម៉ែត្រ។ |
| គ- អៀន | |
|  | អៀនមានប្រវែង ១សង់ទីម៉ែត្រ មានពណ៌ស មានរាងដូចសរសៃអំបោះ។ |
| ឃ- ព្រូនរំពាត់សេះ | |
|  | ជាប្រភេទព្រូនដែលមានប្រវែង ៣៥ ទៅ៥០ មីលីម៉ែត្រ មានពណ៌ស៊ីជម្ពូ ពួកវារស់នៅក្នុងពោះវៀនធំ។ |

| តេញ៉ាគោ និងតេញ៉ាជ្រូក | |
|---|---|
|  | តេញ៉ាគោមានប្រវែង ៤ ទៅ ៧ម៉ែត្រ។ វាមានចុងម្ខាងរាងឆ្មារ និងមានក្បាលកំប៉ោង។ |

❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ដង្កូវព្រូនជាសត្វល្អិតតូចៗ ដែលរស់នៅដោយស្រូបយកជីវជាតិពីមនុស្ស ឬសត្វជាអាហារ ដែលហៅថា ប៉ារ៉ាសិត។ ព្រូនទាំងនេះមានព្រូនខ្លះអាចមើលឃើញដោយភ្នែកផ្ទាល់ ខ្លះទៀតអាចមើលឃើញដោយមីក្រូទស្សន៍។ ដង្កូវព្រូនចែកចេញជា ២ប្រភេទគឺ ដង្កូវព្រូនមូលមាន ព្រូនទម្ពក់ ព្រូនអង្គីលីល ព្រូនចង្កឹះ អៀន ព្រូនរំពាត់សេះ ដង្កូវព្រូនខ្លួនសំប៉ែតមាន តេញ៉ាគោ និងតេញ៉ាជ្រូក។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ដូចម្តេចដែលហៅថា ដង្កូវព្រូន?

២- តើដង្កូវព្រូនមានប៉ុន្មានប្រភេទ?

**៨- លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ៖**

១- ចូរអ្នកសាកសួរក្រុមគ្រួសាររបស់ប្អូន ពីរបៀបឆ្លងដង្កូវព្រូន និងវិធីបង្ការជំងឺដង្កូវព្រូន?

២- ចូរអ្នកមើលមេរៀនពីជំងឺដង្កូវព្រូន សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ជំងឺដង្កូវព្រូន (តចប់)

## ខ្លឹមសារម៉ោងទី២ : របៀបឆ្លងដង្កូវព្រូន អាការៈនៃកុមារមានដង្កូវព្រូន និងការបង្ការជំងឺដង្កូវព្រូន

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីការចម្លងនិងវិធានការបង្ការនៃជំងឺដង្កូវព្រូន។ | - បង្ហាញពីរបៀបឆ្លង អាការៈ និងវិធីបង្ការជំងឺដង្កូវព្រូន។ | - យកចិត្តទុកដាក់អនុវត្តអនាម័យជាប្រចាំ ហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។ |

**៣- សម្ភារៈ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- របៀបឆ្លងដង្កូវព្រូន៖ ដង្កូវព្រូនឆ្លងតាមរយៈការបរិភោគចំណីអាហារដូចជា សាច់ ឬត្រី ដែលមិនឆ្អិនល្អ បរិភោគបន្លែឆៅ ឬផ្លែឈើដែលលាងមិនបានស្អាត ផឹកទឹកមិនស្អាត ឬមានពងព្រូន ដៃមិនស្អាត និង មិនពាក់ស្បែកជើង។

២- អាការៈនៃកុមារមានដង្កូវព្រូន៖ កុមារដែលកើតព្រូនអាចមានអាការៈដូចជា ចុកពោះ រាក ក្អួតស្លេកស្លាំង រមាស់លើស្បែក រមាស់រន្ធគូថ ហូបច្រើនតែមិនធាត់ មិនឃ្លាន និងឆាប់អស់កម្លាំង ដេកមិនសូវលក់។

៣- ការបង្ការជំងឺដង្កូវព្រូន៖ ដើម្បីបង្ការការឆ្លងដង្កូវព្រូនយើងត្រូវ ហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......
- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្តាខៀន

- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : របៀបឆ្លងដង្កូវព្រូន**

- គ្រូសួរសំណួរ៖ តើរបៀបឆ្លងដង្កូវព្រូនមកមនុស្សតាមរបៀបណាខ្លះ ? ចូររៀបរាប់។ ទុកពេលឱ្យសិស្សគិតក្នុងរយៈពេលពី ២ ទៅ ៣នាទី រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ។
- ចម្លើយសិស្ស...
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ** : ដង្កូវព្រូនមាននៅគ្រប់ទីកន្លែងដែលមិនស្អាតដូចជានៅក្នុងទឹក ដី និងក្នុងចំណីអាហារ។ ដង្កូវព្រូនឆ្លងតាមរយៈ៖

- ការបរិភោគបន្លែឆៅ ឬផ្លែឈើដែលលាងមិនបានស្អាត
- ការបរិភោគចំណីអាហារដូចជា សាច់ ឬត្រី ដែលមិនឆ្អិនល្អ
- ផឹកទឹកមិនស្អាត ឬមានពងព្រូន
- ការយកដៃមិនស្អាតដាក់ចូលក្នុងមាត់ ជាពិសេសកុមារតូចៗ
- ការដើរលើដីដោយមិនពាក់ស្បែកជើង ពិសេសលើដីសើម។





**ខ្លឹមសារ : អាការៈនៃកុមារមានដង្កូវព្រូន**

- គ្រូសួរសំណួរ៖ តើអាការៈនៃកុមារមានដង្កូវព្រូនមានដូចម្ដេច ? ទុកពេលឱ្យសិស្សគិតក្នុងរយៈពេលពី ២ ទៅ ៣នាទី រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ។
- ចម្លើយសិស្ស
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ** : កុមារដែលកើតព្រូនអាចមានអាការៈដូចជា៖

- ចុកពោះ រាក ក្អួត
- ស្លេកស្លាំង រមាស់លើស្បែក រមាស់រន្ធគូថ
- ហូបច្រើនតែមិនធាត់
- មិនឃ្លាន និងឆាប់អស់កម្លាំង

- ដេកមិនសូវលក់នៅពេលយប់ដោយសាររមាស់គូទ។

**ខ្លឹមសារ : ការបង្ការជំងឺដង្កូវព្រូន**

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។ សំណួរ តើការបង្ការជំងឺដង្កូវព្រូនមានអ្វីខ្លះ ? ចូររៀបរាប់។
- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :** យើងអាចបង្ការការឆ្លងដង្កូវព្រូនដោយៈ

- ការហូបស្អាតៈ លាងបន្លែ ផ្លែឈើឱ្យស្អាត គ្របចំណីអាហារឱ្យជិត ចម្អិនសាច់ ឬត្រីឱ្យបានឆ្អិនល្អ លាងដៃនឹងសាប៊ូមុនពេលចាប់កាន់ឬបរិភោគចំណីអាហារ
- ផឹកស្អាតៈ ផឹកទឹកដាំពុះ ទឹកចម្រោះ
- រស់នៅស្អាតៈ កាត់ក្រចកដៃឱ្យខ្លី មិនយកដៃកខ្វក់ដាក់ចូលក្នុងមាត់ បន្ទោរបង់ក្នុងបង្គន់ ពាក់ស្បែកជើងជានិច្ច ងូតទឹកសម្អាតខ្លួន។





❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ដង្កូវព្រូនឆ្លងតាមរយៈការបរិភោគចំណីអាហារដូចជា សាច់ ឬត្រី ដែលមិនឆ្អិនល្អបរិភោគបន្លែឆៅ ឬផ្លែឈើដែលលាងមិនបានស្អាត ផឹកទឹកមិនស្អាត ឬមានពងព្រូន ដៃមិនស្អាត និងមិនពាក់ស្បែកជើង។ កុមារដែលកើតព្រូនអាចមានអាការៈដូចជា ចុកពោះ រាក ក្អួត ស្លេកស្លាំង រមាស់លើស្បែក រមាស់រន្ធគូថ ហូបច្រើនតែមិនធាត់ មិនឃ្លាន និងឆាប់អស់កម្លាំង ដេកមិនសូវលក់។ ដើម្បីបង្ការការឆ្លងដង្កូវព្រូនយើងត្រូវ ហូបស្អាត ផឹកស្អាត និងរស់នៅស្អាត៕

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើកុមារដែលមានដង្កូវព្រូន មានអាការៈដូចម្ដេចខ្លះ?

២- ចូររៀបរាប់ពីវិធីបង្ការដង្កូវព្រូន?

**៨- លំហាត់** (ជំហានទី៥)

**បណ្ដាំផ្ញើ៖** ចូរអ្នករស់នៅត្រូវមានអនាម័យដើម្បីបង្ការជំងឺដង្កូវព្រូនឆ្លងចូលក្នុងខ្លួនយើង។

**កិច្ចការផ្ទះ៖**

១- ចូរអ្នកសាកសួរក្រុមគ្រួសាររបស់អ្នក ពីជំងឺផ្ដេសផ្ដាស

២- ចូរអ្នកមើលមេរៀនពីជំងឺផ្ដេសផ្ដាស សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ជំងឺឆ្កែឆ្កួត

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីមូលហេតុ និងស្ថានភាពនៃជំងឺឆ្កែឆ្កួត<br>- ពណ៌នាពីរោគសញ្ញា និងវិធីបង្ការជំងឺឆ្កែឆ្កួត។ | - បកស្រាយពីមូលហេតុ និងវិធីបង្ការជំងឺឆ្កែឆ្កួត។ | - មានបម្រុងប្រយ័ត្នចំពោះសត្វឆ្កែ ចូលរួមបង្ការជំងឺឆ្កែឆ្កួត។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- មូលហេតុនិងស្ថានភាពនៃជំងឺឆ្កែឆ្កួត៖ ជំងឺឆ្កែឆ្កួតអាចឆ្លងតាមសត្វជាច្រើនប្រភេទដូចជា កណ្តុរ ប្រចៀវ ព្រាប ឆ្មា ឆ្កែ។ល។ តែសត្វឆ្កែជាសត្វដែលបង្កការចម្លងរោគនេះជាញឹកញយជាងគេ។ កុមារ និងមនុស្សចាស់ដែលមានចិញ្ចឹម ឬឧស្សាហ៍ប៉ះពាល់សត្វឆ្កែគួរតែចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតខ្លួនឯង និងសត្វឆ្កែរបស់ខ្លួន។ ជនរងគ្រោះភាគច្រើនជាកុមារ ពិសេសកុមារនៅតាមជនបទ។ ជំងឺឆ្កែឆ្កួតអាចបណ្តាលឱ្យស្លាប់បាន បើមិនមានការព្យាបាលទាន់ពេលវេលា។

២- រោគសញ្ញាជំងឺឆ្កែឆ្កួត៖ ចំពោះមនុស្ស៖ ក្តៅខ្លួន ស្ពឹក និងការឈឺចាប់ ឬអារម្មណ៍មោស់ ស្រគារនៅជុំវិញដំបៅដែលសត្វខាំ អត់ឃ្លានចំណីអាហារ ចង្អោរ ក្អួត រាក ឈឺក្បាល វិលមុខ តប់ប្រម៉ល់ក្នុងខ្លួន ដេកមិនលក់ យល់សប្តិវង្វេងវង្វាន់ ខ្លាចទឹកនិងខ្យល់ អ្នកជំងឺនៅមិនស្ងៀមមានចលនាហួត ចេញទឹកមាត់ច្រើន ចេញញើសច្រើន ចេញនោមអត់ដឹងខ្លួនពិបាកលេបចំណីអាហារ និងមានប្រកាច់រហូតដល់សន្លប់។

៣- វិធីបង្ការជំងឺឆ្កែឆ្កួត៖ ត្រូវចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតដល់សត្វចិញ្ចឹម ចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតឱ្យមនុស្ស ចាក់វ៉ាក់សាំងការពារក្រោយពីឆ្កែខាំនិងសត្វផ្សេងៗទៀត និងជៀសវាងកុំឱ្យឆ្កែខាំ ឬឆ្មាខាំ ឬលិឍលើរបួស ឬដំបៅ។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

### ទំនាក់ទំនងមេរៀន ( ជំហានទី២ )

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្ដាខៀន
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

### ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )

**ខ្លឹមសារ : មូលហេតុនិងស្ថានភាពនៃជំងឺឆ្កែឆ្កួត**

- គ្រូបង្ហាញរូបនិងពន្យល់ពីមូលហេតុនិងស្ថានភាពនៃជំងឺឆ្កែឆ្កួត





**ចម្លើយ:** ជំងឺឆ្កែឆ្កួតអាចឆ្លងតាមសត្វជាច្រើនប្រភេទដូចជា កណ្ដុរ ប្រចៀវ ព្រាប ឆ្មា ឆ្កែ។ល។ តែសត្វឆ្កែជាសត្វដែលបង្កការចម្លងរោគនេះជាញឹកញយជាងគេ។ កុមារ និងមនុស្សចាស់ដែលមានចិញ្ចឹម ឬឧស្សាហ៍ប៉ះពាល់សត្វឆ្កែគួរតែចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតខ្លួនឯង និងសត្វឆ្កែរបស់ខ្លួន។ ជនរងគ្រោះភាគច្រើនជាកុមារពិសេសកុមារនៅតាមជនបទ។ ជំងឺឆ្កែឆ្កួតអាចបណ្ដាលឱ្យស្លាប់បាន បើមិនមានការព្យាបាលទាន់ពេលវេលា។

**ខ្លឹមសារ : រោគសញ្ញាជំងឺឆ្កែឆ្កួត**

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។

  ១. តើរោគសញ្ញាជំងឺឆ្កែឆ្កួតដែលកើតឡើងចំពោះឆ្កែមានអ្វីខ្លះ? ចូររៀបរាប់។

  ២. តើរោគសញ្ញាជំងឺឆ្កែឆ្កួតដែលកើតឡើងចំពោះមនុស្សមានអ្វីខ្លះ? ចូររៀបរាប់។

- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :** នៅពេលដែលឆ្កែខាំភ្លាមៗ យើងត្រូវប្រញាប់ទៅចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួត។ នេះជាវិធីតែមួយគត់ដែលជួយសង្គ្រោះជីវិតអ្នករងគ្រោះបាន។ នៅពេលចេញរោគសញ្ញាហើយ នោះនឹងពិបាកក្នុងការជួយសង្គ្រោះជីវិតអ្នករងគ្រោះ។ រោគសញ្ញាជំងឺឆ្កែឆ្កួតមានដូចខាងក្រោម៖

**ចំពោះឆ្កែ៖**

- ស្រក់ទឹកមាត់យ៉ាងខ្លាំង
- លំបាកក្នុងការដើរ និងខាំអ្វីៗទាំងអស់
- ការផ្លាស់ប្តូរសំឡេងព្រុស។

**ចំពោះមនុស្ស៖**

រោគសញ្ញាដំបូង មានរយៈពេលពី២ថ្ងៃទៅ១០ថ្ងៃ៖

- ក្តៅខ្លួន ស្ពឹក និងការឈឺចាប់ ឬអារម្មណ៍រមាស់ ស្រគារនៅជុំវិញដំបៅដែលសត្វខាំ
- អត់ឃ្លានចំណីអាហារ ចង្អោរ ក្អួត រាក
- ឈឺក្បាល វិលមុខ តប់ប្រម៉ល់ក្នុងខ្លួន ដេកមិនលក់ យល់សប្តិ វង្វេងវង្វាន់។

រោគសញ្ញាដំណាក់កាលបន្ទាប់មកទៀត៖ គឺជាដំណាក់កាលដែលរលាកខួរក្បាល និងខួរឆ្អឹងខ្នង ដែលមានរោគសញ្ញាដូចតទៅ៖

- រោគសញ្ញាពិសេសរបស់ឆ្កែឆ្កួតគឺ ខ្លាចទឹក និងខ្យល់
- អ្នកជំងឺនៅមិនស្ងៀមមានចលនារហូត
- ចេញទឹកមាត់ច្រើន ចេញញើសច្រើន ចេញនោមអត់ដឹងខ្លួន
- ពិបាកលេបចំណីអាហារ
- មានប្រកាច់រហូតដល់សន្លប់

ការស្លាប់នឹងកើតឡើងក្នុងរយៈពេល ៥ថ្ងៃ ជាមធ្យម បន្ទាប់ពីចេញរោគសញ្ញាណាមួយខាងលើ។



- គ្រូបញ្ជាក់បន្ថែម៖ នៅពេលដែលមេរោគរីករាលដាលកាន់តែខ្លាំងនៅក្នុងខ្លួន អ្នកជំងឺនឹងមានអាការៈឈឺកាន់តែធ្ងន់ធ្ងរ ហើយបន្ទាប់មកនឹងស្លាប់។

**ខ្លឹមសារ : វិធីបង្ការជំងឺឆ្កែឆ្កួត**

- គ្រូសួរសំណួរ៖ តើវិធីបង្ការជំងឺឆ្កែឆ្កួតមានអ្វីខ្លះ? ទុកពេលឱ្យសិស្សគិតក្នុងរយៈពេលពី ២ ទៅ ៣នាទី រួចគ្រូហៅសិស្ស ២ ឬ ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស:...
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :** ជំងឺឆ្កែឆ្កួតអាចបង្ការបានតាមរយៈការចាក់ថ្នាំបង្ការដល់សត្វចិញ្ចឹមជាពិសេសសត្វឆ្កែនិងចាក់ថ្នាំបង្ការដល់មនុស្ស។ ដើម្បីបង្ការជំងឺឆ្កែឆ្កួតត្រូវ៖

- ចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតដល់សត្វចិញ្ចឹម ជាពិសេសសត្វឆ្កែ
- ចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតឱ្យមនុស្ស
- ចាក់វ៉ាក់សាំងការពារក្រោយពីឆ្កែខាំ និងសត្វផ្សេងៗទៀត
- ចៀសវាងកុំឱ្យឆ្កែខាំ ឬឆ្មាខាំ ឬលិឍលើរបួស ឬដំបៅ។

**កំណត់ចំណាំ៖** ប្រសិនបើលោកអ្នកមានឆ្កែខាំ ឬសត្វដែលចិញ្ចឹមកូនដោយទឹកដោះ ហើយស៊ីសាច់ជាអាហារខាំ សូមរួសរាន់មកពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតដែលនៅជិតផ្ទះ។






❖ គ្រូសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ជំងឺឆ្កែឆ្កួតអាចឆ្លងតាមសត្វជាច្រើនប្រភេទដូចជា កណ្ដុរ ប្រចៀវ ព្រាប ឆ្មា ឆ្កែ។ល។ រោគសញ្ញាជំងឺឆ្កែឆ្កួតកើតមានឡើង ចំពោះឆ្កែ និងមនុស្ស។ ដើម្បីបង្ការជំងឺឆ្កែឆ្កួតត្រូវ ចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតដល់សត្វចិញ្ចឹម ចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតឱ្យមនុស្ស ចាក់វ៉ាក់សាំងការពារក្រោយពីឆ្កែខាំនិងសត្វផ្សេងៗទៀត និងចៀសវាងកុំឱ្យឆ្កែខាំ ឬឆ្មាខាំ ឬលិឍលើរបួស ឬដំបៅ។ ប្រសិនបើអ្នកត្រូវឆ្កែខាំ ឬសត្វដែលចិញ្ចឹមកូនដោយទឹកដោះ ហើយស៊ីសាច់ជាអាហារខាំ សូមរួសរាន់មកពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតដែលនៅជិតផ្ទះ។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើមានមូលហេតុអ្វីដែលបណ្តាលឱ្យកើតជំងឺឆ្កែឆ្កួត?

២- តើរោគសញ្ញាជំងឺឆ្កែឆ្កួតមានដូចម្តេច?

៣- តើវិធីបង្ការជំងឺឆ្កែឆ្កួតមានអ្វីខ្លះ

**៨- លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ៖** ចូរអ្នកមានបម្រុងប្រយ័ត្នចំពោះសត្វឆ្កែ ចូលរួមបង្ការជំងឺឆ្កែឆ្កួត។

**កិច្ចការផ្ទះ៖** ចូរអ្នកមើលមេរៀនពីសម្ពាធអវិជ្ជមានពីមិត្តភក្តិនិងការគ្រប់គ្រងអារម្មណ៍ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : សម្ពាធអវិជ្ជមានពីមិត្តភក្តិនិងការគ្រប់គ្រងអារម្មណ៍

## ខ្លឹមសារម៉ោងទី១ : និយមន័យ និងប្រភេទនៃសម្ពាធ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ប្រាប់និយមន័យ "សម្ពាធ"<br>- រៀបរាប់ពីប្រភេទនិងឥទ្ធិពលនៃសម្ពាធអវិជ្ជមាន។ | - បង្ហាញរបៀបគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភក្តិ។ | - បណ្តុះទម្លាប់ជ្រើសរើសមិត្តភក្តិល្អ និងរក្សាទំនាក់ទំនងល្អ និង ចេះគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភក្តិ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យសម្ពាធអវិជ្ជមានពីមិត្តភក្តិនិងការគ្រប់គ្រងអារម្មណ៍៖ គឺសំដៅលើការប្រើឥទ្ធិពលផ្សេងៗ ដែលមិត្តភក្តិរបស់ខ្លួនប្រើដាក់លើមនុស្សមួយក្រុម ឬ ម្នាក់ ដើម្បីឱ្យធ្វើតាម។ អ្នកដាក់សម្ពាធគេ ប្រើប្រាស់វាដើម្បីផ្លាស់ប្តូរនូវគុណតម្លៃ ឥរិយាបថ ឬ អាកប្បកិរិយារបស់នរណាម្នាក់ (ក្រុម) ទៅតាមអ្វីដែលខ្លួនចង់បាន។

២- ប្រភេទនៃសម្ពាធ៖ ប្រភេទនៃសម្ពាធពីមិត្តភក្តិអាចមានទាំងវិជ្ជមាននិងអវិជ្ជមាន ហើយកើតមានដោយផ្ទាល់និងប្រយោល (បណ្តាញសង្គម) ដោយរួមបញ្ចូលទាំងការនិយាយចេញមកក្រៅ ឬ មិនមាននិយាយចេញមកដែលមានទាំងល្អ និងមិនល្អ។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ពិភាក្សាក្រុម សំណួរនិងចម្លើយ ពន្យល់ បកស្រាយ

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......

៣- តើមានអ្នកណាខ្លះ ធ្លាប់រងសម្ពាធអវិជ្ជមានពីមិត្តភក្តិ? ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ

- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យសម្ពាធអវិជ្ជមានពីមិត្តភក្តិ**

- គ្រូពន្យល់ពាក្យគន្លឹះនៃសម្ពាធអវិជ្ជមាន
  - **សម្ពាធអវិជ្ជមានពីមិត្តភក្តិ៖** គឺសំដៅលើការប្រើឥទ្ធិពលផ្សេងៗ ដែលមិត្តភក្តិរបស់ខ្លួនប្រើដាក់លើមនុស្សមួយក្រុម ឬ ម្នាក់ ដើម្បីឱ្យធ្វើតាម។ អ្នកដាក់សម្ពាធគេ ប្រើប្រាស់វាដើម្បីផ្លាស់ប្តូរនូវគុណតម្លៃ ឥរិយាបថ ឬ អាកប្បកិរិយារបស់នរណាម្នាក់ (ក្រុម) ទៅតាមអ្វីដែលខ្លួនចង់បាន។ មានពេលខ្លះ ជំទង់ក៏អាចនឹងមិនយល់ស្របនូវអ្វីដែលមនុស្សដទៃមានដែរ ដោយឈរលើគោលជំហរស្មើភាពគ្នា និង យុត្តិធម៌។ ជំទង់ក៏រៀនសង្កេតលើ អ្វីជាចំណាប់អារម្មណ៍ និង ការយល់ឃើញរបស់មិត្តភក្តិរបស់ខ្លួនដើម្បី ងាយសម្របខ្លួនចូលរួមសកម្មភាពរបស់ក្រុមផងដែរ។

**ខ្លឹមសារ : ប្រភេទនៃសម្ពាធ**

- គ្រូឱ្យឧទាហរណ៍មួយនៃប្រភេទសម្ពាធវិជ្ជមាននិងអវិជ្ជមាន
- គ្រូបែងចែកសិស្សជាក្រុមធ្វើការពិភាក្សាដោយមានសិស្សពី ៤ ទៅ ៨ នាក់ក្នុងមួយក្រុម ទៅលើសំណួរ៖

  ក្រុមទី១ សំណួរ៖ តើប្រភេទនៃសម្ពាធវិជ្ជមានមានអ្វីខ្លះ ? ចូររៀបរាប់

  ក្រុមទី២ សំណួរ៖ តើប្រភេទនៃសម្ពាធអវិជ្ជមានមានអ្វីខ្លះ ? ចូររៀបរាប់
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍លទ្ធផលពិភាក្សា
- គ្រូសម្របសម្រួលនិងសំយោគចម្លើយសិស្សត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ** : ឥទ្ធិពលពីមិត្តភក្តិអាចមានទាំងវិជ្ជមាន និង អវិជ្ជមាន ហើយកើតមានដោយផ្ទាល់ និង ប្រយោល (បណ្តាញសង្គម) ដោយរួមបញ្ចូលទាំងការនិយាយចេញមកក្រៅ ឬ មិនមាននិយាយចេញមក ដែលមានទាំងល្អ និងមិនល្អ។ មានមិត្តភក្តិខ្លះ គាត់មានលក្ខណៈវិជ្ជមាន និងចាំជួយគាំទ្រយើងដែលអាចជួយគ្នាទៅវិញទៅមក។ មិត្តភិក្តិទាំងនោះ ជួយគ្នាឱ្យរៀននូវអ្វីថ្មី ឬ ជំរុញចូលរួមសកម្មភាពផ្សេងៗ ដូចជាចូលបណ្ណាល័យអានសៀវភៅ សកម្មភាពកីឡា ឬ សកម្មភាពជួយសង្គមជាដើម។

មានមិត្តភក្តិខ្លះ អាចប្រើប្រាស់ឥទ្ធិពល ឬ សម្ពាធជាអវិជ្ជមានលើក្រុមរបស់ខ្លួន ដើម្បីធ្វើរឿងរ៉ាវមិនល្អផ្សេងៗ ដូចជាគេចសាលា លួចរបស់របរ បោកប្រាស់ ប្រើប្រាស់គ្រឿងញៀន (គ្រឿងស្រវឹង ឬ បារីផងដែរ) ចែករំលែកព័ត៌មានមិនសាកសមលើអ៊ីនធើណិត ឬ ធ្វើសកម្មភាពគ្រោះថ្នាក់ផ្សេងៗ។ មានសកម្មភាពអវិជ្ជមានចម្បង ៥ ដែលគេសង្កេតឃើញកើតមានក្នុងចំណោមជំទង់៖

- សាកល្បង គ្រឿងញៀន គ្រឿងស្រវឹង ឬ បារី៖ វាជាអ្វីដែលកើតឡើងញឹកញាប់ និង គួរឱ្យព្រួយបារម្ភជាងគេ កើតចេញពីសម្ពាធអវិជ្ជមានរបស់មិត្តភក្តិ។ អ្វីដែលគួរឱ្យខ្លាចបំផុត គឺការប្រើប្រាស់គ្រឿងស្រវឹង ឬ បារីក្លាយទៅជារឿងមួយកើតឡើងជាទូទៅក្នុងចំណោមជំទង់។ សារជាតិញៀននោះជំទង់នឹងចាប់ផ្តើមប្រើម្តងហើយម្តងទៀត។
- **ការលួចរបស់របរ៖** ការលួចនេះ ពេលខ្លះមិនមែនមកពីការខ្វះខាត ឬ ដើម្បីលុយកាក់ទាំងស្រុងនោះទេ ពេលខ្លះការធ្វើបែបនេះដើម្បីបង្ហាញថាខ្លួនឯងពូកែ ឬ អស្ចារ្យជាងអ្នកដទៃ។ អាចមានហេតុផ្សេងៗ

ទៀតជាច្រើន ដែលបណ្ដាលឱ្យជំទង់ លួចរបស់ពីអ្នកដទៃ។

- **ការធ្វើបាបផ្សេងៗ៖** មានមិត្តភក្តិមួយចំនួន ព្យាយាមធ្វើបាបអ្នកផ្សេង ហើយដើម្បីចៀសផុតពីការធ្វើបាបលើខ្លួនឯង។ ដូចនេះមានតែចូលរួមជាមួយមិត្តភក្តិផ្សេងៗធ្វើបាបអ្នកដទៃ។ តាមពិតទៅ នៅពេលធ្វើបាបអ្នកដទៃចុងបញ្ចប់ទៅវានឹងបង្កជាបញ្ហាមកលើខ្លួនឯងនៅថ្ងៃណាមួយមិនខាន។
- **សកម្មភាពផ្លូវភេទ៖** សកម្មភាពផ្លូវភេទនេះ ជាសម្ពាធមួយយ៉ាងខ្លាំង ដែលអាចកើតមានលើទាំងក្មេងស្រី និងក្មេងប្រុស។ ក្មេងប្រុស ខ្លះរងសម្ពាធពីមិត្តភក្តិដើម្បីមាន សង្សារ (ដៃគូ) ដើម្បីបង្ហាញពីភាពខ្លាំងអស្ចារ្យរបស់ខ្លួន។ ហើយក្មេងស្រីខ្លះ ក៏រងនូវសម្ពាធចិត្តពីមិត្តភក្តិរបស់ខ្លួន ឱ្យជាសង្សារ (ដៃគូ) ដោយសារតែមើលទៅសាកសមគ្នាជាដើម។ មានពេលខ្លះការដាក់សម្ពាធពីមិត្តភក្តិនេះអាចបង្កឱ្យក្មេងខ្លះ ឆាប់ប្រឡូកក្នុងការរួមភេទ
- **អាកប្បកិរិយាគ្រោះថ្នាក់ផ្សេងៗ៖** ដើម្បីបង្ហាញថាខ្លួនឯងអស្ចារ្យ ជំទង់ខ្លះជ្រើសរើស យកការធ្វើរឿងរ៉ាវគ្រោះថ្នាក់ផ្សេងៗ ដូចជាបង្ហោះម៉ូតូ (កង់) បើកបរលើសល្បឿនកំណត់ជាដើម។ ការធ្វើអាកប្បកិរិយាកាន់តែគ្រោះថ្នាក់នឹងបង្ហាញឱ្យអ្នកដទៃឃើញថាខ្លួននឹងមានឋានៈមួយខ្ពស់ក្នុងក្រុមរបស់ខ្លួន។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការចំណាយពេលជាមួយមិត្តភក្តិរបស់ខ្លួន ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលូតលាស់របស់ជំទង់។ ស្របពេលនេះដែរជំទង់ ក៏អាចទទួលរងនូវសម្ពាធពីមិត្តភក្តិរបស់ខ្លួនផងដែរ។ សម្ពាធនេះ អាចមានសម្ពាធវិជ្ជមាន និងអវិជ្ជមាន។

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូសួរសិស្សឱ្យរៀបរាប់ឡើងវិញ៖

១- តើសម្ពាធពីមិត្តភក្តិជាអ្វី?

២- តើសម្ពាធពីមិត្តភក្តិមានប្រភេទអ្វីខ្លះ?

## ៨- លំហាត់ (ជំហានទី៥)

**កិច្ចការផ្ទះ៖**

១- សូមអ្នកស្រាវជ្រាវតាមការសាកសួរពីឪពុកម្ដាយ ឬបងប្អូនពីឥទ្ធិពលនៃសម្ពាធអវិជ្ជមានមកលើផ្លូវអារម្មណ៍។ គ្រូនឹងប្រមូលកិច្ចការនៅម៉ោងសិក្សាបន្ទាប់។

២- ចូរអ្នកមើលមេរៀនសម្ពាធអវិជ្ជមានពីមិត្តភក្តិនិងការគ្រប់គ្រងអារម្មណ៍ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី១ ៖ សម្ពាធអវិជ្ជមានពីមិត្តភក្តិនិងការគ្រប់គ្រងអារម្មណ៍ (តចប់)

## ខ្លឹមសារម៉ោងទី២ ៖ ឥទ្ធិពលនៃសម្ពាធអវិជ្ជមានមកលើផ្លូវអារម្មណ៍ ការប្រឆាំងនឹងសម្ពាធអវិជ្ជមាន និងការគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភក្តិ

**១- រយៈពេល** ៖ ១ ម៉ោងសិក្សា

**២- វត្ថុបំណង** ៖ ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីឥទ្ធិពលនៃសម្ពាធអវិជ្ជមាន និងរបៀប គ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភក្តិ។ | - បង្ហាញពីរបៀបគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភក្តិ។ | - បណ្ដុះទម្លាប់ជ្រើសរើសមិត្តភក្តិល្អ រក្សាទំនាក់ទំនងល្អ និង ចេះគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភក្តិ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារៈផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- ឥទ្ធិពលនៃសម្ពាធអវិជ្ជមានមកលើផ្លូវអារម្មណ៍៖ គឺច្រើនកើតឡើងងាយចំពោះវ័យជំទង់ដោយសារជំទង់ មានភាពមិនប្រាកដប្រជានឹងអត្តសញ្ញាណសង្គមរបស់ខ្លួន (មិនស្គាល់តួនាទីខ្លួនឯងច្បាស់) បង្កើតជាការឱ្យតម្លៃខ្លួនឯងទាប និងឆាប់មានការភ័យខ្លាច និងងាយសម្របខ្លួនធ្វើទៅតាមការដាក់សម្ពាធពីមិត្តភក្តិ ដែលជាកត្តាមិនល្អណាមួយកើតឡើងនៅសាលារៀន ឬគ្រួសាររបស់គេ ដូចជាការវាយតប់គ្នា ឬអំពើហិង្សាក្នុងគ្រួសារជាដើម។

២- ការប្រឆាំងនឹងសម្ពាធអវិជ្ជមាន ដោយនៅឆ្ងាយពីមិត្តភក្តិមិនល្អ រៀននិយាយថា “ទេ” និងពិភាក្សាជាមួយអ្នកដទៃ ជាពិសេសមនុស្សធំដែលអ្នកទុកចិត្តដូចជា ឪពុកម្ដាយ លោកគ្រូ អ្នកគ្រូ ឬអ្នកអាណាព្យាបាលជាដើម។

៣- ការគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភក្តិគឺ ដោយវិធីសាស្ត្របន្ធូរអារម្មណ៍ តាមរយៈការប្រើលំហាត់ដង្ហើម សម្រាកសាច់ដុំជាដំណាក់ៗ .... ក៏អាចមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងអារម្មណ៍មិនល្អផ្សេងៗផងដែរ។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ពិភាក្សាក្រុម សំណួរនិងចម្លើយ

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន  អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុសៈ
  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : ............
  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន ? ចម្លើយសិស្ស : ......
- គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ឥទ្ធិពលនៃសម្ពាធអវិជ្ជមានមកលើផ្លូវអារម្មណ៍**

- គ្រូសួរសំណួរ តើឥទ្ធិពលនៃសម្ពាធអវិជ្ជមានមកលើផ្លូវអារម្មណ៍មានអ្វីខ្លះ ? ចូររៀបរាប់។ ទុកពេលឱ្យសិស្សគិតក្នុងរយៈពេលពី ២ ទៅ ៣នាទី រួចគ្រូហៅសិស្ស ២ ឬ ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្សៈ...
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ : ឥទ្ធិពលនៃសម្ពាធអវិជ្ជមានមកលើផ្លូវអារម្មណ៍ៈ** គឺច្រើនកើតឡើងងាយចំពោះវ័យជំទង់ដោយសារជំទង់ មានភាពមិនប្រាកដប្រជានឹងអត្តសញ្ញាណសង្គមរបស់ខ្លួន (មិនស្គាល់តួនាទីខ្លួនឯងច្បាស់) បង្កើតជាការឱ្យតម្លៃខ្លួនឯងទាប និងឆាប់មានការភ័យខ្លាច និងងាយសម្របខ្លួនធ្វើទៅតាមការដាក់សម្ពាធពីមិត្តភក្តិ ដែលជាកត្តាមិនល្អណាមួយកើតឡើងនៅសាលារៀន ឬគ្រួសាររបស់គេ ដូចជាការវាយតប់គ្នា ឬអំពើហិង្សាក្នុងគ្រួសារជាដើម។

**ខ្លឹមសារ : ការប្រឆាំងនឹងសម្ពាធអវិជ្ជមាន**

- គ្រូបែងចែកសិស្សជាក្រុមធ្វើការពិភាក្សាទៅលើសំណួរ តើការប្រឆាំងនឹងសម្ពាធអវិជ្ជមានត្រូវធ្វើដូចម្តេចខ្លះ ? គ្រូទុករយៈពេល៥ ទៅ ១០ នាទី។
- គ្រូឱ្យតំណាងក្រុមនីមួយៗឡើងរាយការណ៍លទ្ធផលពិភាក្សា
- គ្រូសម្របសម្រួលនិងសំយោគចម្លើយសិស្សត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយៈ** ជំទង់ដែលស្ថិតក្រោមសម្ពាធ ក៏ព្រោះតែពួកគេចង់នៅក្នុងក្រុម ហើយបារម្ភថាខ្លួនឯងនឹងត្រូវបានគេទុកចោល ឬ ត្រូវបានអ្នកដទៃយកទៅលេងសើច។ មានវិធីសាស្ត្រមួយចំនួនក្នុងការជួយឱ្យជំទង់ជំនះនូវការដាក់សម្ពាធអវិជ្ជមានពីក្រុមមិត្តភក្តិរបស់ខ្លួន។

  - នៅឆ្ងាយមិត្តភក្តិមិនល្អ ជាពិសេសនៅជាមួយនឹងក្រុមមិត្តភក្តិ ដែលចូលចិត្តធ្វើនូវរឿងគ្រោះថ្នាក់ផ្សេងៗ ឬ ខុសច្បាប់ជាដើម។
  - រៀននិយាយថា “ទេ” ហើយរៀនពីរបៀបផ្សេងៗគេចចេញពីស្ថានភាពដែលអ្នក មានអារម្មណ៍ថាគ្មានសុវត្ថិភាព

- ចំណាយពេលវេលាជាមួយនឹងក្រុមមិត្តភក្តិដែលប្រឆាំងទល់នឹងសម្ពាធអវិជ្ជមាន។ ជាការប្រសើរបើសិនជាមានមិត្តភក្តិយ៉ាងហោចណាស់ម្នាក់ដែលចេះនិយាយថា "ទេ"។ ដូចពាក្យចាស់ខ្មែរយើងលើកឡើងថា "ចង្កឹះមួយកាច់បាក់ ចង្កឹះមួយបាច់កាច់មិនបាក់"។
- បើសិនជាអ្នកមានអារម្មណ៍ថាទទួលសម្ពាធពីមិត្តភក្តិ សូមយកវាទៅពិភាក្សាជាមួយអ្នកដទៃជាពិសេសមនុស្សធំដែលអ្នកទុកចិត្តដូចជា ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ ឬ អ្នកអាណាព្យាបាលជាដើម។

**ខ្លឹមសារ : ការគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភិក្តិ**

- គ្រូឱ្យសិស្សចាប់ដៃគូ២ៗនាក់ ពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៣ ទៅ ៥នាទី។

សំណួរ៖ តើការគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភិក្តិត្រូវធ្វើដូចម្តេចខ្លះ ?

- បន្ទាប់មកគ្រូហៅតំណាងសិស្ស ២ឬ៣គូឱ្យឆ្លើយ។ គ្រូណែនាំសិស្សឱ្យអ្នកឆ្លើយបន្ទាប់ បន្ថែមលើចម្លើយអ្នកមុនឬអ្វីដែលថ្មី
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ** : អារម្មណ៍ ជាផ្នែកមួយដែលកើតពីធម្មជាតិរបស់មនុស្សយើង ហើយវាជារឿងធម្មតានោះទេ ដែលនៅពេល មនុស្សទទួលរងសម្ពាធ មនុស្សមានអារម្មណ៍តានតឹង ថប់បារម្ភ ភ័យខ្លាច ច្រាស់ច្រាល់ និងអារម្មណ៍អវិជ្ជមានផ្សេងៗទៀត។ នៅពេលមានអារម្មណ៍ទាំងអស់នេះ ប្អូនអាចសាកល្បងប្រើនូវវិធីសាស្រ្តបន្ធូរអារម្មណ៍ ដែលអ្នកធ្លាប់ប្រើពីមុនៗមក។ ក្រៅពីវិធីសាស្រ្តដែលធ្លាប់ប្រើ ការប្រើលំហាត់ដង្ហើម និង សម្រាកសាច់ដុំជាដំណាក់ៗ ក៏អាចមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងអារម្មណ៍មិនល្អ ផ្សេងៗផងដែរ។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

**ឥទ្ធិពលនៃសម្ពាធអវិជ្ជមានមកលើផ្លូវអារម្មណ៍** គឺច្រើនកើតឡើងងាយចំពោះវ័យជំទង់នឹងនាំឱ្យមានកត្តាមិនល្អណាមួយកើតឡើងនៅសាលារៀន ឬគ្រួសាររបស់គេ ដូចជាការវាយតប់គ្នា ឬអំពើហិង្សាក្នុងគ្រួសារជាដើម។ **ការប្រឆាំងនឹងសម្ពាធអវិជ្ជមាន** ដោយនៅឆ្ងាយពីមិត្តភក្តិមិនល្អ រៀននិយាយថា "ទេ" និងពិភាក្សាជាមួយអ្នកដទៃ។ **ការគ្រប់គ្រងអារម្មណ៍នៅពេលមានសម្ពាធអវិជ្ជមានពីមិត្តភក្តិគឺ**ដោយវិធីសាស្រ្តបន្ធូរអារម្មណ៍ តាមរយៈ ការប្រើលំហាត់ដង្ហើម សម្រាកសាច់ដុំជាដំណាក់ៗ .... ក៏អាចមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងអារម្មណ៍មិនល្អផ្សេងៗផងដែរ៕

**៧- ឆ្លុះបញ្ចាំង** (ជំហានទី៤)

គ្រូសួរសិស្សឱ្យរៀបរាប់ឡើងវិញ៖

១- តើសកម្មភាពអវិជ្ជមានអ្វីខ្លះ ដែលជំទង់អាចទទួលរងសម្ពាធពីមិត្តភក្តិដើម្បីឱ្យធ្វើ?

២- តើអ្នកធ្វើយ៉ាងណាដើម្បីតទល់នឹងសម្ពាធអវិជ្ជមាន?

៣- តើអ្នកអាចធ្វើការគ្រប់គ្រងអារម្មណ៍ដោយរបៀបណា?

**៨- សំយោគ** (ជំហានទី៥)

**កិច្ចការផ្ទះ**

១- ចូរអ្នកស្រាវជ្រាវតាមការសាកសួរពីឪពុកម្ដាយ ឬបងប្អូនពីទំនាក់ទំនងនៅពេលពេញវ័យមានអ្វីខ្លះ?
គ្រូនឹងប្រមូលកិច្ចការនៅម៉ោងសិក្សាបន្ទាប់។

២- ចូរអ្នកមើលមេរៀនទំនាក់ទំនងនៅពេលពេញវ័យ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ទំនាក់ទំនងនៅពេលពេញវ័យ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន ៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីប្រភេទនៃទំនាក់ទំនង និងការបង្កើតទំនាក់ទំនង វិជ្ជមាននៅពេលពេញវ័យ។ | - បង្ហាញពីការបង្កើតទំនាក់ទំនងវិជ្ជមាន និងរីករាយ (ទំនាក់ទំនងបែប បាទ/ចាស បែបមានហេតុផល)។ | - ទម្លាប់រស់នៅប្រកបដោយភាពរីករាយតាមរយៈការមានទំនាក់ទំនងល្អ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- ប្រភេទទំនាក់ទំនងពេលពេញវ័យ ៖ ប្រភេទទំនាក់ទំនង មានដូចជា ទំនាក់ទំនងជាមួយនឹងសមាជិកគ្រួសារ មិត្តភក្តិ សហការី អ្នកជិតខាង មនុស្សស្គាល់គ្នា មិត្តប្រុស មិត្តស្រី គ្រូ និងមនុស្សផ្សេងៗទៀតនៅជុំវិញខ្លួនជាដើម។ ទំនាក់ទំនងភេទផ្ទុយគ្នា : ទំនាក់ទំនងភេទផ្ទុយគ្នាអាចជាទំនាក់ទំនងមិត្តភាពឬទំនាក់ទំនងស្នេហា។ ទំនាក់ទំនងមិត្តភក្តិ : គឺជាការរាប់អានមិត្ត ដែលទំនាក់ទំនងមិត្តភាពដ៏ល្អជាមួយគ្នាទៅវិញទៅមក អាចបំពេញតម្រូវការឱ្យគ្នាទៅវិញទៅមកលើកការសិក្សា មនោសញ្ចេតនា សង្គម រាងកាយ បញ្ញា និងសេដ្ឋកិច្ច។ ទំនាក់ទំនងគ្រួសារនិងសង្គម : មានការគោរពគួរសម ការរៀននិយាយដោយមានហេតុផល ការបង្ហាញការយកចិត្តទុកដាក់និងសេចក្តីស្រឡាញ់ដោយបើកចំហ និងឥរិយាបថគោរពគ្នាក្នុងគ្រួសារនិងសង្គម។

២- បង្កើតទំនាក់ទំនងវិជ្ជមាននិងរីករាយ : ការបង្កើតទំនាក់ទំនងដែលមានផលវិជ្ជមាននិងរីករាយ គឺជាការទាក់ទងដល់ផលប្រយោជន៍ទាំងពីរភាគីប្រកបដោយសេចក្តីពេញចិត្ត មានការឱ្យតម្លៃ គោរពគ្នាទៅវិញទៅមក។

**៥- វិធីសាស្ត្រ**

សំណួរបំផុស ពិភាក្សាក្រុម សំណួរនិងចម្លើយ បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន រួចសួរសិស្ស ២ ឬ៣នាក់ ឱ្យឆ្លើយ

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ប្រភេទទំនាក់ទំនងពេលពេញវ័យ**

- គ្រូសួរសំណួរបំផុស : តើអ្នកមានទំនាក់ទំនងជាមួយនណាខ្លះ សព្វថ្ងៃ? ប្រសិនបើធ្លាប់? ចូររៀបរាប់។ ចម្លើយសិស្ស...។
- គ្រូកត់ត្រាចម្លើយលើក្តារខៀន
- គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

ចម្លើយ : "ទំនាក់ទំនង គឺជាដំណើរការនៃការបញ្ជូនព័ត៌មាននិងការយល់ដឹងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ការបញ្ជូនសារនេះ ជាដំណើរការនៃការចែករំលែកគំនិតយោបល់ ពីមនុស្សម្នាក់ទៅម្នាក់ ឬពីក្រុមមួយទៅក្រុមមួយទៀត។ ប្រភេទទំនាក់ទំនង មានដូចជា ទំនាក់ទំនងជាមួយនឹងសមាជិកគ្រួសារ មិត្តភក្តិ សហការី អ្នកជិតខាង មនុស្សស្គាល់គ្នា មិត្តប្រុស មិត្តស្រី គ្រូ និងមនុស្សផ្សេងៗទៀតនៅជុំវិញខ្លួនជាដើម។

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។
  ១- សំណួរ តើទំនាក់ទំនងភេទផ្ទុយគ្នាមានអ្វីខ្លះ? ចូររៀបរាប់។
  ២- សំណួរ តើទំនាក់ទំនងទំនាក់ទំនងមិត្តភក្តិមានអ្វីខ្លះ? ចូររៀបរាប់។
  ៣- សំណួរ តើទំនាក់ទំនងគ្រួសារនិងសង្គមមានអ្វីខ្លះ? ចូររៀបរាប់។
- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :**

### ១.១- ទំនាក់ទំនងភេទផ្ទុយគ្នា

ទំនាក់ទំនងភេទផ្ទុយគ្នាអាចជាទំនាក់ទំនងមិត្តភាពឬទំនាក់ទំនងស្នេហា។ ទំនាក់ទំនងមិត្តភាព គឺជាការរាប់អានមិត្ត។ ក្មេងស្រី និងក្មេងប្រុសអាចមានទំនាក់ទំនងមិត្តភាពដ៏ល្អជាមួយគ្នាទៅវិញទៅមក ដោយមិនមានទំនាក់ទំនងខាងផ្លូវភេទឡើយ។ ទំនាក់ទំនងអាចបំពេញតម្រូវការផ្នែកការសិក្សា មនោសញ្ចេតនា សង្គម រាងកាយ បញ្ញា និងសេដ្ឋកិច្ច។ ចំណែកទំនាក់ទំនងស្នេហាគឺជាសេចក្តីស្រឡាញ់ដែលចេញពីអារម្មណ៍ប្រកបដោយមនោសញ្ចេតនា។ វាផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយអារម្មណ៍ចេញពីបេះដូងរវាងបុគ្គលម្នាក់ចំពោះបុគ្គលម្នាក់ទៀត។

### ១.២- ទំនាក់ទំនងមិត្តភក្តិ

**ទំនាក់ទំនងមិត្តភាព** គឺជាការរាប់អានមិត្ត។ ទំនាក់ទំនងនៅពេលពេញវ័យរបស់យុវវ័យ អាចមានទំនាក់ទំនងមិត្តភាពដ៏ល្អជាមួយគ្នាទៅវិញទៅមក អាចបំពេញតម្រូវការឱ្យគ្នាទៅវិញទៅមក

លើកការសិក្សា មនោសញ្ចេតនា សង្គម រាងកាយ បញ្ញា និងសេដ្ឋកិច្ច។

ក្នុងការទំនាក់ទំនងមិត្តភក្តិ គឺកើតចេញពីទំនុកចិត្តដែលយើងមានទៅលើមិត្តនោះ។ ធាតុសំខាន់របស់ទំនុកចិត្តលើមិត្តភក្តិ គឺការអាចទុកចិត្តបាន អាចពឹងពាក់បាន អាចជួយយកអាសាគ្នាទៅវិញទៅមកបាន និងជួយអ្នកបានពេលត្រូវការជាដើម។ ដូចគ្នានឹងការមានទំនុកចិត្តលើខ្លួនឯង ការមានទំនុកចិត្តលើមិត្តភក្តិកើតចេញពីភាពជោគជ័យនៃទំនាក់ទំនងបន្តិចម្តងៗ។ ការមានទំនុកចិត្តលើនរណាម្នាក់ ឬមិត្តភក្តិរបស់យើង នឹងជួយបង្កើតឱ្យមានទំនាក់ទំនងល្អជាមួយគ្នា ហើយការធ្វើការងារជាមួយគ្នានឹងកាន់តែប្រសើរ។

ការធ្វើការងារជាក្រុម ជាពិសេសជាមួយមិត្តភក្តិ នឹងជួយយើងឱ្យសម្រេចការងារបានងាយស្រួល និងដោះស្រាយនូវការលំបាក ដែលការធ្វើការងារម្នាក់ឯងមិនអាចធ្វើបាន។ ដូចសុភាសិតខ្មែរលើកឡើងថា "ចង្កឹះមួយបាច់ កាច់មិនបាក់"។

## ១.៣- ទំនាក់ទំនងគ្រួសារនិងសង្គម

### ក. ទំនាក់ទំនងគ្រួសារ

ដើម្បីសេចក្តីសុខសាន្តនៅក្នុងគ្រួសារ ការគោរពគ្នាមានសារៈសំខាន់ណាស់ដែលសមាជិកគ្រួសារម្នាក់ៗត្រូវអនុវត្ត។ ការគោរពមានន័យថា សមាជិកគ្រួសារត្រូវរៀនស្តាប់គ្នាទៅវិញទៅមក ទោះបីមានការមិនពេញចិត្ត និងរៀនផ្តល់យោបល់ប្រកបដោយហេតុផល។ មានវិធីបួនយ៉ាងដែលបង្ហាញពីការគោរពនៅក្នុងគ្រួសារគឺ ការគោរពគួរសម ការរៀននិយាយ ដោយមានហេតុផល ការបង្ហាញការយកចិត្តទុកដាក់និងសេចក្តីស្រឡាញ់ដោយបើកចំហ និងឥរិយាបថគោរពគ្នាក្នុងគ្រួសារ។

#### ក- ការគោរពគួរសម

ដើម្បីជៀសវាងរាល់ការមិនពេញចិត្តនិងទំនាស់ ត្រូវប្រកាន់ខ្ជាប់ឥរិយាបថគោរពនិងគួរសម ដូចជា៖

- ប្រើពាក្យ "សូមអធ្យាស្រ័យ..." ឬ"សុំទោស" និង "អរគុណ"
- ប្រើកាយវិការ ភាសា និងសំឡេងឱ្យបានសមរម្យ មិនគំហ៊ក មិនស្រែក មិនច្រងេងច្រងាង។

#### ខ- រៀននិយាយដោយមានហេតុផល

- ស្តាប់អត្ថន័យការនិយាយរបស់ដៃគូសន្ទនាដោយប្រុងប្រយ័ត្ន
- រៀនដកដង្ហើមវែងៗនៅពេលដែលអ្នកមានភាពតានតឹង មុននឹងនិយាយស្តី
- ឆ្លើយតបដោយនិយាយមានហេតុផល
- រាល់ការឆ្លើយតបមិនត្រូវស្រែកតតាំងភ្លាមៗ ដោយមិនទាន់យល់ពីអត្ថន័យច្បាស់លាស់ជាមុនឡើយ
- និយាយទទួលកំហុស ទោះតូចតាចក្តី
- បង្ហាញពីអារម្មណ៍របស់អ្នក ជាជាងបន្ទោសទៅដៃគូសន្ទនា ឧទាហរណ៍ "ខ្ញុំមានអារម្មណ៍ថាខ្ញុំមិនទទួលបានការគោរព..." ឬ "ខ្ញុំមិនសប្បាយចិត្ត ព្រោះ..."។

#### គ- ការបង្ហាញការយកចិត្តទុកដាក់និងសេចក្តីស្រឡាញ់ដោយបើកចំហ

- យកចិត្តទុកដាក់ជួយការងារធូន់ស្រាលក្នុងគ្រួសារ

- ជួយលើកទឹកចិត្តនៅពេលមានទុក្ខព្រួយជាដើម
- យកចិត្តទុកដាក់ចំពោះសមាជិកគ្រួសារគ្រប់រូបទោះមានពិការភាព ព៌ណសម្បុរ និងភេទខុសគ្នាក៏ដោយ
- ចំណាយពេលនៅជាមួយគ្នា ជជែក និងពិភាក្សា ដើម្បីយល់គ្នាឱ្យបានច្រើន។

**ឃ- ឥរិយាបថគោរពគ្នាក្នុងគ្រួសារ**

- ប្រើពាក្យថា "កូនស្រឡាញ់ម៉ែ ពុក ឬ ម៉ែ ពុកស្រឡាញ់កូន"
- លើកសរសើរគ្នាទៅវិញទៅមកនៅពេលសមាជិកណាម្នាក់ធ្វើអ្វីមួយបានល្អ
- គោរពឯកជនភាព របស់សមាជិកគ្រួសារម្នាក់ៗ ឧទាហរណ៍ មុនចូលបន្ទប់ត្រូវជូនដំណឹងឬសញ្ញា
- រៀនអត់ធ្មត់ តស៊ូប្រឈមនឹងបញ្ហាដែលកើតឡើង ហាត់ពត់ចិត្តឱ្យរក្សានូវភាពស្ងប់ នឹងមិនរំជើបរំជួលតាមស្ថានភាព
- គោរពតួនាទីរបស់ខ្លួនដោយមិនប្រើឋានៈនៅក្នុងគ្រួសារមកដាក់សម្ពាធ ឧទាហរណ៍ បងបង្ខំឱ្យប្អូនធ្វើអ្វីមួយជំនួសខ្លួន។

## ខ. ទំនាក់ទំនងសង្គម

- **សិទ្ធិស្មើគ្នាក្នុងទំនាក់ទំនង** : រវាងបុគ្គលនិងបុគ្គលត្រូវមានសិទ្ធិស្មើគ្នា គ្មាននរណាម្នាក់មានឥទ្ធិពលលើទំនាក់ទំនងនេះបានឡើយ។ អ្នកធ្វើការសម្រេចចិត្តរួមគ្នាជាមួយដៃគូអ្នកក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាផ្សេងៗដែលអ្នកទាំងពីរបានព្រមព្រៀងគ្នា មានតុល្យភាពរវាងការផ្តល់ ការទទួល ចែករំលែក និងការទទួលខុសត្រូវ ក្នុងការបំពេញភារកិច្ចដោយស្មើភាព។
- **ការគោរពក្នុងទំនាក់ទំនង** : គឺបង្ហាញការយកចិត្តទុកដាក់ ឱ្យតម្លៃ និងរាប់អានទៅដៃគូឬភាគីម្ខាងទៀតប្រកបដោយការយកចិត្តទុកដាក់ដោយគ្មានការវិនិច្ឆ័យ និងចាត់ទុកដៃគូជាមនុស្សសំខាន់ទោះជាស្ថិតនៅក្នុងស្ថានភាពសង្គមខុសគ្នាក៏ដោយ។
- **ទំនុកចិត្តក្នុងទំនាក់ទំនង** : គឺជាការជឿជាក់ចំពោះទង្វើ កាយវិការ ពាក្យសម្តីរបស់ដៃគូ ដែលផ្តល់ឱ្យគ្នាទៅវិញទៅមកនូវសេរីភាពនិងពេលវេលាផ្ទាល់ខ្លួន។ ដើម្បីមានឱកាសក្នុងការភ្ជាប់ចំណងមិត្តភាពជាមួយអ្នកដទៃផ្សេងទៀតនិងមិនមានអារម្មណ៍សង្ស័យចំពោះដៃគូ។
- **ភាពស្មោះត្រង់ក្នុងទំនាក់ទំនង** : គឺជាការបើកចិត្តឱ្យទូលាយក្នុងការប្រាស្រ័យទាក់ទងគ្នាប្រាប់ការពិត ចែករំលែករឿងរ៉ាវ និងបញ្ហាផ្សេងៗក៏ដូចជា សារភាពនៅពេលមានកំហុស "ចេះសូមអភ័យទោស" ប្រកបដោយការទទួលខុសត្រូវលើគ្រប់ទង្វើរបស់ខ្លួន។
- **ការគាំទ្រក្នុងទំនាក់ទំនង** : គឺជាការផ្តល់កម្លាំងចិត្តដល់ដៃគូដោយសម្តែងទឹកចិត្តមេត្តានិងករុណា។ ផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមកនៅពេលនរណាម្នាក់ក្នុងចំណោមដៃគូមានបញ្ហាអ្វីមួយកើតឡើង។

**ខ្លឹមសារ : បង្កើតទំនាក់ទំនងវិជ្ជមាន និងរីករាយ**

- គ្រូសួរសំណួរ និងទុកពេលឱ្យសិស្សឆ្លើយ

- តើការបង្កើតទំនាក់ទំនងវិជ្ជមាន និងរីករាយមានអ្វីខ្លះ? ចូររៀបរាប់។
- គ្រូកត់ត្រាចម្លើយសិស្សលើក្តារខៀន
- គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ** : ការបង្កើតទំនាក់ទំនងដែលមានផលវិជ្ជមាននិងរីករាយ គឺជាការទាក់ទងដល់ផលប្រយោជន៍ទាំងពីរភាគីប្រកបដោយសេចក្តីពេញចិត្ត មានការឱ្យតម្លៃ គោរពគ្នាទៅវិញទៅមក ដែលមានដូចខាងក្រោម៖

- ញញឹមនិងបង្ហាញឥរិយាបថវិជ្ជមានក្នុងការនិយាយរកគ្នា
- ការសន្ទនា គឺចាប់ផ្តើមជាមួយនឹងអ្វីដែលអ្នកទាំងពីរមានរួមគ្នា ដូចជាចូលចិត្តលេងកីឡាដូចគ្នា ចូលចិត្តមុខវិជ្ជាគណិតវិទ្យាដូចគ្នា ចូលចិត្តអាហារដែលមានបន្លែច្រើនដូចគ្នាជាដើម
- រក្សាការសន្ទនាបន្តឱ្យបានយូរតាមតែអាចធ្វើបាននិងស្តាប់ឱ្យបានច្រើន។

ដើម្បីបង្កើតទំនាក់ទំនងវិជ្ជមាននិងរីករាយ អ្នកត្រូវចេះធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព តាមរយៈ៖

- ការស្តាប់ដោយយកចិត្តទុកដាក់ ការប្រើភ្នែក ងក់ក្បាល សំពះ
- និយាយឆ្លើយតប បាទ ចាស ឬពន្យល់តបវិញដោយមានហេតុផល
- មានឥរិយាបថសមរម្យ មានក្រមសីលធម៌ គោរពនូវគំនិតរបស់បុគ្គលឬក្រុម
- បើកចិត្តទូលាយទទួលយកនូវគំនិតយោបល់ពីភាគីម្ខាងទៀត
- គោរពពេលវេលា ជំនឿ ទំនៀមទម្លាប់ ប្រពៃណី ទៅតាមតំបន់នីមួយៗ។

❖ សំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

សម្ពាធអវិជ្ជមាន អាចធ្វើឱ្យជំទង់ធ្វើទង្វើមិនគួរគប្បីមួយចំនួនដូចជាប្រើប្រាស់គ្រឿងញៀន លួចរបស់របរ ធ្វើបាបអ្នកដទៃ សកម្មភាពផ្លូវភេទ និងរឿងគ្រោះថ្នាក់ផ្សេងៗទៀត។បើសិនជាអ្នកទទួលរងនូវសម្ពាធអវិជ្ជមានណាមួយខ្លាំងពេក សូមជជែកជាមួយមនុស្សធំដែលអ្នកទុកចិត្ត។ លំហាត់ដង្ហើម និងសម្រាកសាច់ដុំជាដំណាក់ៗ អាចជួយក្នុងការគ្រប់គ្រងនូវអារម្មណ៍មិនល្អផ្សេងៗបាន៕

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូសួរសិស្សឱ្យរៀបរាប់ឡើងវិញ៖

១- តើប្រភេទនៃទំនាក់ទំនងពេលពេញវ័យមានអ្វីខ្លះ?

២- តើទំនាក់ទំនងភេទផ្ទុយគ្នាមានអ្វីខ្លះ?

៣- តើទំនាក់ទំនងជាមិត្តភក្តិមានអ្វីខ្លះ?

៤- តើទំនាក់ទំនងគ្រួសារនិងសង្គមមានអ្វីខ្លះ?

៥- តើត្រូវធ្វើដូចម្តេច ដើម្បីបង្កើតទំនាក់ទំនងវិជ្ជមាននិងរីករាយ?

## ៨- លំហាត់ (ជំហានទី៥)

**កិច្ចការផ្ទះ**

១- សូមអ្នកស្រាវជ្រាវតាមការសាកសួរពីឪពុកម្តាយ ឬបងប្អូនពីការប្រើប្រាស់អ៊ីនធើណិតនិងបណ្តាញសង្គមមានអ្វីខ្លះ ?គ្រូនឹងប្រមូលកិច្ចការនៅម៉ោងសិក្សាបន្ទាប់។

២- ចូរអ្នកមើលមេរៀនការប្រើប្រាស់អ៊ីនធើណិតនិងបណ្តាញសង្គម សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : ការប្រើប្រាស់អ៊ីនធើណិត និងបណ្តាញសង្គមទំនាក់ទំនង

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមានៈ

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់បានពីអត្ថប្រយោជន៍ និងគ្រោះថ្នាក់ដែលអាចកើតមានក្នុងការប្រើប្រាស់បណ្តាញសង្គម។ | • បង្ហាញពីអត្ថប្រយោជន៍ និងគ្រោះថ្នាក់ដែលអាចកើតមានពេលប្រើប្រាស់បណ្តាញសង្គមនានាដែលឆ្លុះបញ្ចាំងពីរឿងផ្លូវភេទ។ | • ប្រុងប្រយ័ត្នចំពោះការប្រើប្រាស់បណ្តាញសង្គមដែលឆ្លុះបញ្ចាំងពីរឿងផ្លូវភេទ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗទៀត ដែលទាក់ទងនឹងមេរៀននេះ។

## ៤- ខ្លឹមសារនិងគំនិតសំខាន់ៗ

### ១- អត្ថប្រយោជន៍ និងគ្រោះថ្នាក់ដែលអាចកើតមាន

អ៊ីនធើណិតមានអត្ថប្រយោជន៍ ជាច្រើនដូចជា ផ្តល់ដល់មនុស្សភាគច្រើននូវលទ្ធភាពធ្វើការភ្ជាប់ទំនាក់ទំនងទៅកាន់ពិភពលោកដូចជា ការស្វែងរកព័ត៌មាន ទំនាក់ទំនងបុគ្គល ទំនាក់ទំនងការងារ ការប្រជុំ ជាដើម។ បន្ទុប្បន្នការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានិងសារគមនាគមន៍ កាន់តែមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីឱ្យដំណើរការងារប្រព្រឹត្តិទៅប្រកបដោយសុវត្ថិភាព និងប្រសិទ្ធិភាព។

ការប្រើប្រាស់អ៊ីនធើណិតក៏មានគ្រោះថ្នាក់ដល់សុខភាព ដូចជា ឈឺចង្កេះ រៀចឆ្អឹងខ្នង ខូចភ្នែក ខូចប្រព័ន្ធប្រសាទ អាចកើតជំងឺបាក់ទឹកចិត្ត និងងាយរងនូវការលួច និងបោកប្រាស់តាម អ៊ីនធើណិត ឬបណ្តាញសង្គម។

២. បណ្តាញសង្គមដែលឆ្លុះបញ្ចាំងពីរឿងផ្លូវភេទ វាអាចជាបណ្តុំនៃរឿង ឬរូបភាព និងវីដេអូ ទាក់ទងនឹងរឿងផ្លូវភេទ ដែលគេបានបង្ហោះនៅក្នុងបណ្តាញសង្គម។

៣- អារម្មណ៍ចំពោះបណ្តាញសង្គមដែលឆ្លុះបញ្ចាំងពីរឿងផ្លូវភេទ អារម្មណ៍ចំពោះរឿងភេទ រួមមាន ការទទួលយកព័ត៌មានអប់រំរឿងភេទ ឬទទួលបាននូវភាពរំភើប ភាពអស្ចារ្យ អរ សប្បាយ ស្រៀវស្រើប មានសេចក្តីសុខជាដើម នៅពេលដែលបានមើលឃើញនូវខ្លឹមសារអប់រំ ឬសកម្មភាពផ្លូវភេទ ដែលបានបញ្ចាំងតាមបណ្តាញសង្គម។

## ៥- វិធីសាស្ត្រ

ករណីសិក្សា សំណួរបំផុសគំនិត ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល ការងារជាក្រុម ការពិភាក្សា។

## ៦- សកម្មភាពបង្រៀននិងរៀន

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......

  ៣- តើអ្នកស្គាល់ឬធ្លាប់ឮអ៊ីនធើណិតដែរឬទេ?

  ៤- តើក្នុងគ្រួសារប្អូនមានប្រើប្រាស់អ៊ីនធើណិតដែរឬទេ?

- គ្រូហៅសិស្ស ២ ឬ៣នាក់ឱ្យឆ្លើយ
- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្ដារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន និងគោលបំណងមេរៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : អត្ថប្រយោជន៍ និងគ្រោះថ្នាក់ដែលអាចកើតមាន**

- គ្រូសួរសំណួរ តើអ៊ីនធើណិតមានអត្ថប្រយោជន៍ដូចម្ដេច? ទុកពេល១ទៅ២នាទីរួចហៅសិស្ស ២ ឬ៣ នាក់ ឱ្យឆ្លើយ។ សិស្សឆ្លើយ : ....
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

  **ចម្លើយ**

  អ៊ីនធើណិតមានអត្ថប្រយោជន៍ជាច្រើន ដូចជា ផ្ដល់ដល់មនុស្សភាគច្រើននូវលទ្ធភាពធ្វើការភ្ជាប់ទំនាក់ទំនងទៅកាន់ពិភពលោកដូចជា ការស្វែងរកព័ត៌មាន ទំនាក់ទំនងបុគ្គល ទំនាក់ទំនងការងារ ការប្រជុំជាដើម។ បច្ចុប្បន្នការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានិងសារគមនាគមន៍ កាន់តែមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីឱ្យដំណើរការងារប្រព្រឹត្តិទៅប្រកបដោយសុវត្ថិភាព និងប្រសិទ្ធិភាព។ អ៊ីនធើណិតក៏មានអត្ថប្រយោជន៍ជាច្រើនទៀតដូចជា៖

  - ការស្វែងរកព័ត៌មាននិងចំណេះដឹងគ្រប់វិស័យ
  - ការស្រាវជ្រាវនិងចែករំលែកព័ត៌មានដែលមានប្រយោជន៍
  - ការសិក្សាកាន់តែមានភាពងាយស្រួល ទទួលបានចំណេះដឹងតាមរយៈការសិក្សាពីចម្ងាយ
  - ការបង្កើតឱកាសកំសាន្តសប្បាយតាមរយៈល្បែង ចម្រៀង ..
  - ការស្វែងរកព័ត៌មានផ្សេងៗ រកការងារធ្វើ
  - ទាញយកចំណេះគ្រប់ផ្នែកនិងបានទូលំទូលាយគ្រប់ជ្រុងជ្រោយ
  - ស្វែងរកបាននូវរាល់ដំណោះស្រាយលើបញ្ហាផ្សេងៗដូចជា ទាញយកឯកសារសម្រាប់អាន សម្ភារៈឧបទេសសម្រាប់រៀននិងបង្រៀនទាក់ទងនឹងការសិក្សា

- អាចធ្វើការទំនាក់ទំនងគ្នាបានយ៉ាងងាយស្រួលពាក់ព័ន្ធនឹងការសិក្សា និងមិត្តភាពដោយប្រើប្រាស់បណ្ដាញសង្គម
- ការបង្កើននូវកេរ្តិ៍ឈ្មោះបោះសម្លេង តាមរយៈការផលិត និងស្រាវជ្រាវលើប្រធានបទដែលមានប្រយោជន៍ដល់ការអភិវឌ្ឍន៍សង្គមជាដើម។

- គ្រូសួរសំណួរ : ក្រៅពីអត្ថប្រយោជន៍ តើអ៊ីនធើណិតផ្ដល់ផលគ្រោះថ្នាក់អ្វីខ្លះ ? ទុកពេល១ទៅ២នាទីរួចហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ។ សិស្សឆ្លើយ : .....
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយៈ**

ទន្ទឹមនឹងអត្ថប្រយោជន៍ខាងលើ ការប្រើប្រាស់អ៊ីនធើណិតក៏អាចនាំមកនូវហានិភ័យ និងមានគ្រោះថ្នាក់ផងដែរ។ ចំណុចអវិជ្ជមានទាំងនោះ មានដូចជាៈ

- នាំឱ្យមានភាពទាក់ទាញហួសហេតុ ក្លាយទៅជាញៀនក្នុងការលេងហ្គេម ដែលធ្វើឱ្យប៉ះពាល់ដល់ការសិក្សានិងសុខភាព
- ងាយរងគ្រោះពីការលួចនិងកេងប្រវ័ញ្ច បោកប្រាស់តាមប្រព័ន្ធអ៊ីនធើណិត ឬបណ្ដាញសង្គម
- ងាយធ្លាក់ចូលក្នុងការអូសទាញពីក្រុមកេងប្រវ័ញ្ចផ្លូវភេទ តាមរយៈការផ្សព្វផ្សាយ រឿងនិងរូបភាពអាសអាភាសជាដើម
- យល់ខុសទៅតាមព័ត៌មានមិនពិតដែលផ្សព្វផ្សាយក្នុងប្រភពមិនច្បាស់លាស់
- បង្កឱ្យមានផលប៉ះពាល់ដែលអាចជះឥទ្ធិពលដល់សុខភាពភ្នែក រាងកាយ និងផ្លូវចិត្តជាដើម។




**ក្រៅពីហានិភ័យ ការប្រើប្រាស់អ៊ីនធើណិតក៏អាចបណ្ដាលឱ្យមានផលប៉ះពាល់ដល់សុខភាពដូចជាៈ**

- អង្គុយឬសម្លឹងមើលក្នុងពន្លឺខ្លាំងឬខ្សោយរបស់កុំព្យូទ័រ ឬទូរស័ព្ទធ្វើឱ្យភ្នែកមានគំហើញមិនច្បាស់ ឈឺចង្កេះ រៀចឆ្អឹងខ្នងដោយសារការអង្គុយយូរ
- កើតក្ដីស្រមើស្រមៃតែរឿងអាក្រក់ៗដូចជា រឿងខ្មោច រឿងឧក្រិដ្ឋកម្ម ឬឃាតកម្ម នាំឱ្យខូចប្រព័ន្ធប្រសាទ

- អាចកើតជំងឺបាក់ទឹកចិត្ត ស្រងូតស្រងាត់ ឯកោ ហើយយូរទៅគឺផ្ដាច់ខ្លួនពីទំនាក់ទំនងក្នុងគ្រួសារនិងសង្គម។

**ខ្លឹមសារ : បណ្ដាញសង្គមដែលផ្សះបញ្ជាំងពីរឿងផ្លូវភេទ**

- គ្រូចែកសិស្សជាក្រុមឱ្យពិភាក្សា និងឆ្លើយសំណួរទាក់ទងទៅនឹងករណីសិក្សារបស់រក្សា ក្នុងរយៈពេល ១០ ទៅ១៥ នាទី
- **ករណីសិក្សារបស់រក្សា** ជាសិស្សថ្នាក់ទី៦។ ក្រោយទទួលបានទូរស័ព្ទថ្មី ក៏បានបង្កើតគណនីរបស់ខ្លួននៅក្នុងបណ្ដាញសង្គម និងបានផុសរូបដ៏ស្រស់ស្អាតរបស់ខ្លួនជាញឹកញាប់។ ថ្ងៃមួយនាងបានទទួលសារពីក្មេងប្រុសម្នាក់ដែលនាងស្គាល់ច្បាស់។ ទំនាក់ទំនងនេះ បានកើនឡើងនិងកាន់តែជិតស្និទ្ធ។ រក្សា ជាក្មេងស្លូតត្រង់មិនបានយល់នូវកិច្ចកល កេងជំរិតតាមប្រព័ន្ធអ៊ីនធើណិតឡើយ។ ថ្ងៃមួយនាងកំពុងងូតទឹក ក៏ទទួលបានសារពីក្មេងប្រុស សួរនាងថា កំពុងធ្វើអ្វី ? នាងឆ្លើយថានាងកំពុងងូតទឹក ក្មេងប្រុសក៏ថា សុំបើកកាំមេរ៉ាមើលបន្ទប់ទឹកបន្តិច។ ដោយលង់នឹងពាក្យផ្អែមល្ហែម នាងក៏យល់ព្រមបើកកាមេរ៉ា។ នាងគិតថាមើលបន្ទប់ទឹកមិនជាអ្វី នាងក៏ធ្វើតាម បន្ទាប់មកក្មេងប្រុសនោះ ក៏សុំមើលមុខនាងបន្តិច ដោយពោលថា នឹកណាស់។ នាងក៏ធ្វើតាម ក្មេងប្រុសនោះចេះតែសុំឱ្យវិលកាមេរ៉ាចុះក្រោមបន្តិចៗ រហូតដល់ដើមទ្រូង។ បន្ទាប់ពីនោះមក រក្សាត្រូវក្មេងប្រុសនោះសំឡុតយកប្រាក់ប្រសិនបើនាងមិនចង់ឱ្យរូបរបស់នាងត្រូវបង្ហោះជាសាធារណៈ។ល។

**សំណួរ៖**

១. តើរក្សាប្រើប្រាស់បណ្ដាញសង្គមមានសកម្មភាពអ្វីខ្លះ ?

២. តាមរយៈករណីសិក្សា តើរក្សាបានផលវិជ្ជមាននិងអវិជ្ជមានអ្វីខ្លះ បន្ទាប់ពីបានបង្កើតគណនី រួចមក?

- គ្រូហៅសិស្សតំណាងក្រុមឱ្យឆ្លើយ។ សិស្សឆ្លើយ : ..........................
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវ

**ចម្លើយ:**

បណ្ដាញសង្គមដែលបានបង្ហោះនិងដាក់បញ្ជាំងអំពីរឿងផ្លូវភេទ វាអាចជាបណ្ដុំនៃរឿង ឬរូបភាព និងវិដេអូ ទាក់ទងនឹងរឿងផ្លូវភេទ ការអប់រំរឿងផ្លូវភេទ ដែលគេបានបង្ហោះនៅក្នុងបណ្ដាញសង្គម។ ការដាក់បង្ហោះ ឬបញ្ជាំងរឿងផ្លូវភេទតាមបណ្ដាញសង្គម អាចជះឥទ្ធិពលជាវិជ្ជមាន ឬអវិជ្ជមានដល់អ្នកចូលរួមក្នុងបណ្ដាញសង្គម។ ក្មេងជំទង់ជាវ័យមួយដែលឆាប់ទទួលរងឥទ្ធិពលពី ទំនោរនិងទំនាក់ទំនងផ្លូវភេទតាមរយៈបណ្ដាញសង្គម។ ក្មេងជំទង់ ឬយុវវ័យអាចបង្ហាញពីទំនោរផ្លូវភេទរបស់ខ្លួន ហើយទំនោរនេះក៏ក្លាយជាការប្រព្រឹត្តមិនប្រយ័ត្ន ឬមិនមានការទទួលបានការការពារពីអ្នកអាណាព្យាបាល។ ពួកគេក៏អាចទទួលនូវឥទ្ធិពលអវិជ្ជមាន ដោយសារការបញ្ជាំងរឿងផ្លូវភេទ ក្នុងបណ្ដាញសង្គម ជារួមការប្រើប្រាស់បណ្ដាញសង្គមរបស់ក្មេងជំទង់ក្រោមអាយុ១៨ឆ្នាំ ត្រូវមានការគ្រប់គ្រងពីអ្នកអាណាព្យាបាល ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើទំនាក់ទំនងផ្លូវភេទក្នុងក្រុមមនុស្សអាយុស្របាលគ្នា ឬពីមនុស្សចាស់ ដែលបណ្ដាលឱ្យមានការកើនឡើងនៃការកេងប្រវ័ញ្ចនិងជួញដូរផ្លូវភេទ។

បច្ចុប្បន្នជាសម័យបច្ចេកវិទ្យាទំនើបគេអាចស្វែងរកមិត្តឬដៃគូស្នេហាតាមរយៈអ៊ីនធើណិតបាន។ មានករណីនៃការស្វែងរកមិត្តឬគូសង្សាតាមបណ្តាញសង្គមជាច្រើន ដែលភាគីទាំងសងខាងក្លែងបន្លំ ឬអាចលាក់អត្តសញ្ញាណបាន។

**ខ្លឹមសារ : អារម្មណ៍ចំពោះបណ្តាញសង្គមដែលផ្សះបញ្ចាំងពីរឿងផ្លូវភេទ**

- គ្រូសួរសំណួរ៖ តើប្អូនមានអារម្មណ៍ដូចម្តេច ចំពោះបណ្តាញសង្គមដែលឆ្លុះបញ្ចាំងពីរឿងផ្លូវភេទ ? គ្រូទុកពេល ២ ទៅ ៣ នាទី ឱ្យឆ្លើយ។ សិស្សឆ្លើយ : ...........
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ:**

អារម្មណ៍ គឺកើតឡើងដោយការរំញោចពីញ្ញាណណាមួយក្នុងចំណោមញ្ញាណទាំងប្រាំ។ អារម្មណ៍ចំពោះរឿងផ្លូវភេទ អាចកើតមានឡើងនៅពេលដែលមានការទទួលបានព័ត៌មាន រឿងផ្លូវភេទដែលទាក់ទងនឹងសេចក្តីរំភើប ត្រេកត្រអាល ភាពអស្ចារ្យ ស្រៀវស្រើប មនោរសញ្ចេតនាស្នេហាដែលនាំឱ្យមានសេចក្តីសុខជាដើម។ នៅក្នុងបណ្តាញសង្គម នឹងមានព័ត៌មានទាំងរឿងផ្លូវភេទ និងការអប់រំរឿងផ្លូវភេទ។

ហេតុដូច្នេះ ការយល់ដឹង វិភាគ ឬការជ្រើសរើសព័ត៌មាន ឬចំណេះដឹងតាមបណ្តាញសង្គម គឺជារឿងសំខាន់ណាស់សម្រាប់ក្មេងជំទង់ ឬយុវវ័យ ព្រោះវាអាចជារឿងផ្លូវភេទដែលជាព័ត៌មានទាក់ទាញ ឬបង្កើនអារម្មណ៍ផ្លូវភេទ ឬជាការអប់រំរឿងផ្លូវភេទ ដែលផ្តល់ចំណេះដឹង គុណតម្លៃ សុវត្ថិភាព និងការត្រិះរិះពិចារណា ដែលអាចចៀសផុតនូវរាល់ហានិភ័យដែលអាចកើតមាន និងត្រៀមខ្លួនសម្រាប់វ័យបន្ទាប់។ រឿងផ្លូវភេទដែលបង្ហាញមានការជះឥទ្ធិពលតិចឬច្រើនទៅលើអារម្មណ៍របស់អ្នកមើលក្នុងកំឡុងពេលបញ្ចាំងនិងក្រោយពេលបញ្ចាំង។ ឥទ្ធិពលនៃរឿងផ្លូវភេទបានផ្សារភ្ជាប់ទៅនឹងការពិត និងការប្រឌិតដែលមើលទៅហាក់ដូចជាមានភាពអស្ចារ្យ ឬធ្វើឱ្យមានការឆ្ងល់ ការចង់ដឹង និងអាចទាក់ទាញអ្នកមើលឱ្យមានអារម្មណ៍ទៅតាមការអូញទាញទាំងនោះ។

ការស្តាប់ មើល ឬអានរឿងផ្លូវភេទតាមបណ្តាញសង្គមញឹកញាប់ អាចនឹងមានឥទ្ធិពលផ្នែកអារម្មណ៍ ផ្នត់គំនិត ការគិត និងការប្រព្រឹត្ត ដែលយុវវ័យមានជំនឿថា អាចធ្វើតាមបាននូវសកម្មភាពទាំងនោះ។ វាហាក់ដូចជាការដក់អារម្មណ៍ជាប់នឹងភាពអស្ចារ្យនៃការប្រណាំងម៉ូតូរបស់តួឯករឿងម្នាក់ដែលមិនមានអ្នកណាឈ្នះឡើយ។ វាជាភាពរំភើប និងការកោតសរសើរ ហើយប៉ុនប៉ងធ្វើត្រាប់តាមដូចបែបនោះដែរ។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

អ៊ីនធើណិតមានអត្ថប្រយោជន៍ជាច្រើនដូចជា ផ្តល់ដល់មនុស្សភាគច្រើននូវលទ្ធភាពធ្វើការងារនៅទីកន្លែងណាក៏បានដូចជា ការងារសហការ ការភ្ជាប់ទំនាក់ទំនងនៅទូទាំងពិភពលោក ឱ្យតែមានអ៊ីនធើណិត។ ចំពោះអ្នកសិក្សាដូចជា ពង្រីកចំណេះដឹងរបស់ខ្លួនតាមរយៈ ការសិក្សាស្រាវជ្រាវ និងការសិក្សាពីចម្ងាយជាដើម។ ទន្ទឹមនឹងអត្ថប្រយោជន៍ខាងលើ ការប្រើប្រាស់អ៊ីនធើណិតដែលមិនមានការគិតពិចារណាលើប្រភព និងព័ត៌មានច្បាស់លាស់ គឺអាចនាំឱ្យមានហានិភ័យទៅដល់សុវត្ថិភាពនិងមានគ្រោះថ្នាក់ដល់សុខភាពជាពិសេសនៅតាមគេហទំព័រ និងបណ្តាញសង្គមទាំងឡាយណាដែលបង្ហោះ និងបញ្ចាំងរឿងផ្លូវភេទ៕

## ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ដូចម្តេចដែលហៅថា អ៊ីនធើណិតនិងបណ្តាញសង្គម?

២- តើអ៊ីនធើណិតនិងបណ្តាញសង្គមមានអត្ថប្រយោជន៍និងត្រូវការពារបែបណា?

៣- តើបណ្តាញសង្គមដែលឆ្លុះបញ្ចាំងរឿងភេទមានឥទ្ធិពលយ៉ាងដូចម្តេច?

## ៨- **លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ** :

១- ចូរអ្នកស្រាវជ្រាវពីករណីបៀតបៀនផ្លូវភេទនៅសាលានិងក្នុងសហគមន៍ប្អូនរស់នៅមានអ្វីខ្លះ?

២- ចូរអ្នកមើលមេរៀនត្រង់ចំណងជើងការបៀតបៀនផ្លូវភេទ

គ្រូនឹងសួរនិងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

## **ឯកសារយោង**


១- https://aspe.hhs.gov/basic-report/influence-new-media-adolescent-sexual-health-evidence-and-opportunities

២- http://journals.sagepub.com/doi/full/10.1177/2056305117738992

៣- https://www.google.com/search?q=How+feeling+reflecting+social+media+related+sexuality&oq=How+feeling+reflecting+social+media+related+sexuality&aqs=chrome..69i57.18489j0j1&sourceid=chrome&ie=UTF-8

# មេរៀនទី ២ : ការបៀតបៀនផ្លូវភេទ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីនិយមន័យ"ការបៀតបៀនផ្លូវភេទ"<br>- កំណត់ពីទម្រង់ និងវិធីបង្ការការបៀតបៀនផ្លូវភេទ។ | - បង្ហាញពីជនដែលអាចបង្ក និងវិធីបង្ការការបៀតបៀនផ្លូវភេទ។ | - បណ្ដុះទម្លាប់រកវិធីដោះស្រាយបញ្ហាដែលកើតឡើងនៅពេលមានការបៀតបៀនផ្លូវភេទ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យ៖ ការបៀតបៀនផ្លូវភេទ ជាសកម្មភាពទាំងឡាយណាដែលមិនអាចទទួលយកបានក្នុងរឿងផ្លូវភេទពីជនរណាម្នាក់ទៅលើបុគ្គលម្នាក់ទៀត។

២- ទម្រង់នៃការបៀតបៀនផ្លូវភេទ៖ អាចធ្វើឡើងតាមរយៈការគំរាម ឬការដាក់សម្ពាធ ការស្នើសុំ ឬពាក្យសម្ដីនិយាយ ឬពាក្យសម្ដី ជាលាយលក្ខណ៍អក្សរ រូបភាព ឬការប៉ះពាល់រាងកាយ។

៣- ជនដែលអាចបង្កការបៀតបៀនផ្លូវភេទ៖ ជនបង្កការបៀតបៀនផ្លូវភេទ អាចជាជនប្លែកមុខ អ្នកមានវ័យប្រហាក់ប្រហែលគ្នាឬចាស់ជាង អ្នកមានអំណាច ឬឥទ្ធិពល មិត្តភក្តិ គ្រូបង្រៀន សមាជិកគ្រួសារ សាច់ញាតិ អ្នកមើលថៃ។ល។

៤- ជនងាយរងគ្រោះ ៖ ជនណាក៏អាចរងការបៀតបៀនផ្លូវភេទបានដែរ ភាគច្រើនការបៀតបៀនផ្លូវភេទកើតមានឡើងលើមនុស្សទន់ខ្សោយ មានជាក្មេងស្រី ក្មេងប្រុស អ្នកដែលពិការភាព មនុស្សប្រុសមានអាកប្បកិរិយាដូចមនុស្សស្រី មនុស្សស្រឡាញ់ភេទដូចគ្នា។

៥- វិធីបង្ការការបៀតបៀនផ្លូវភេទ៖ ដើម្បីបង្ការការបៀតបៀនផ្លូវភេទត្រូវ□ ចេះគោរពគ្នាទៅវិញទៅមកនិងស្វែងយល់ពីសិទ្ធិផ្លូវភេទ ចេះពីវិធីដោះសារនិងឆ្លើយតប ប្រុងប្រយ័ត្នពីសុវត្ថិភាពផ្ទាល់ខ្លួន កុំសេពគប់មនុស្សដែលមិនស្គាល់និងមិនអាចទុកចិត្តបាន កុំទទួលអំណោយ ឬវត្ថុអនុស្សាវរីយ៍ពីអ្នកមិនទុកចិត្ត បើនរណាម្នាក់បៀតបៀនផ្លូវភេទអ្នក អ្នកត្រូវប្រាប់ពួកគេឱ្យឈប់ធ្វើ ចៀសចេញឱ្យបានឆាប់ពីជនដែលបង្កការបៀតបៀនផ្លូវភេទរបស់អ្នក ប្រាប់ឬរាយការណ៍ដល់គ្រូបង្រៀន នាយកសាលា អាជ្ញាធរដែនដី ឬបុគ្គលិកសង្គមកិច្ច។

## ៥- វិធីសាស្ត្រ

សំណួរបំផុសគំនិត ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល ការងារជាក្រុម ការពិភាក្សា។

## ៦- សកម្មភាពបង្រៀននិងរៀន

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ..........

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុនរួចសួរ តើការបៀតបៀនផ្លូវភេទមានអ្វីខ្លះ?
- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន និងគោលបំណងមេរៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យនៃការបៀតបៀនផ្លូវភេទ**

- គ្រូសួរសំណួរ : ដូចម្ដេចដែលហៅថា កាបៀតបៀនផ្លូវភេទ?
- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្ដាខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ: ការបៀតបៀនផ្លូវភេទ** ជាសកម្មភាពទាំងឡាយណាដែលមិនអាចទទួលយកបានក្នុងរឿងផ្លូវភេទពីជនណាម្នាក់ទៅលើបុគ្គលម្នាក់ទៀត។ ឧទាហរណ៍ការបៀតបៀន ដូចជា ស្ទាបគូថ ប៉ះអវយវៈភេទ អង្អែលថ្ពាល់។ល។

**ខ្លឹមសារ : ទម្រង់នៃការបៀតបៀនផ្លូវភេទ ជនដែលអាចបង្កការបៀតបៀនផ្លូវភេទ និងជនងាយរងគ្រោះ**

- គ្រូចែកសិស្សជាក្រុមឱ្យពិភាក្សានិងឆ្លើយសំណួរក្នុងរយៈពេល ១០ ទៅ១៥ នាទី ឆ្លើយទៅនឹងសំណួរខាងក្រោម ដោយបំពេញចូលក្នុងតារាង៖

| ទម្រង់នៃការបៀតបៀនផ្លូវភេទ | មនុស្សឬជនប្រភេទណាខ្លះ ដែលអាចបង្កការបៀតបៀន ផ្លូវភេទ | មនុស្សឬអ្នកណាជាអ្នកងាយរងគ្រោះពីការបៀតបៀនផ្លូវភេទ |
|---|---|---|
| | | |

១- តើទម្រង់នៃការបៀតបៀនផ្លូវភេទមានអ្វីខ្លះ ?
២- តើមនុស្សឬជនប្រភេទណាខ្លះ ដែលអាចបង្កការបៀតបៀនផ្លូវភេទ ?
៣- តើមនុស្សឬអ្នកណាជាអ្នកងាយរងគ្រោះពីការបៀតបៀនផ្លូវភេទ ?

- គ្រូហៅសិស្សតំណាងក្រុមឱ្យឡើងបង្ហាញ
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវ

**ចម្លើយ**

| **ទម្រង់នៃការបៀតបៀនផ្លូវភេទ** | **មនុស្សឬជនប្រភេទណាខ្លះ ដែលអាចបង្កការបៀតបៀន ផ្លូវភេទ** | **មនុស្សឬអ្នកណាជាអ្នកងាយរងគ្រោះពីការបៀតបៀន ផ្លូវភេទ** |
|---|---|---|
| ការបៀតបៀនផ្លូវភេទ អាចធ្វើឡើងតាមរយៈការគំរាម ឬការដាក់សំពាធ ការស្នើសុំ ឬពាក្យសម្ដីនិយាយ ឬពាក្យសម្ដីជាលាយលក្ខណ៍អក្សរ រូបភាព ឬការប៉ះពាល់រាងកាយ។ ការបៀតបៀនផ្លូវភេទមានបីប្រភេទគឺ ៖<br>**១. ការបៀតបៀនផ្លូវភេទដោយពាក្យសម្ដី** គឺការប្រើពាក្យ និយាយ ឬបញ្ចេញមតិក្នុងលក្ខណៈផ្លូវភេទអំពីនរណាម្នាក់ការផ្សព្វផ្សាយពាក្យចចាមអារ៉ាមផ្លូវភេទ ការស្នើសុំដែលមានលក្ខណៈភេទ និងការនិយាយរឿងកំប្លែងផ្លូវភេទ សំណួរពីរឿងផ្លូវភេទ បន្លឺសម្លេងផ្លូវភេទ។ល។<br>**២. ការបៀតបៀនផ្លូវភេទជាសារ សញ្ញា និងរូបភាព** គឺការសរសេរមតិយោបល់អំពីនរណាម្នាក់ ការផ្ញើសារដែលមានលក្ខណៈផ្លូវភេទនៅក្នុងគេហទំព័រឬប្រព័ន្ធផ្សព្វផ្សាយសង្គម ការបញ្ជូនសារស្នេហាងប់ងល់ និងការបញ្ជូនរូបភាពដែលមានលក្ខណៈផ្លូវភេទ។ | ជនបង្កការបៀតបៀនផ្លូវភេទអាចជាជនប្លែកមុខ អ្នកមានវ័យប្រហាក់ប្រហែលគ្នាឬចាស់ជាង អ្នកមាន អំណាចឬឥទ្ធិពល មិត្តភក្តិ គ្រូបង្រៀន សមាជិកគ្រួសារ សាច់ញាតិ អ្នកមើលថែ។ | ជនណាក៏អាចរងការបៀតបៀនផ្លូវភេទបានដែរ ភាគច្រើនការបៀតបៀនផ្លូវភេទកើតមានឡើងលើមនុស្សទន់ខ្សោយ មានជាក្មេងស្រី ក្មេងប្រុស អ្នកដែលពិការភាព មនុស្សប្រុសមានអាកប្បកិរិយាដូចមនុស្សស្រី មនុស្សស្រឡាញ់ភេទដូចគ្នា។ |

| | | |
|---|---|---|
| **៣. ការបៀតបៀនផ្លូវភេទដោយការប៉ះពាល់រាងកាយ** គឺជាការប៉ះ ឬចាប់ផ្នែកណាមួយនៃរាងកាយរបស់នរណាម្នាក់  ដូចជា ការលាត់ ទាញ ឬស្រាតសម្លៀកបំពាក់ ការប៉ះពាល់ ឱប ថើប ដែលគេមិនពេញចិត្ត។ | | |

**ខ្លឹមសារ : វិធីបង្ការការបៀតបៀនផ្លូវភេទ**

- គ្រូសួរសំណួរ : ដើម្បីបង្ការការបៀតបៀនផ្លូវភេទ តើត្រូវធ្វើអ្វីខ្លះ ?
- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្ដាខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ:** ដើម្បីបង្ការការបៀតបៀនផ្លូវភេទត្រូវ៖

- យល់ដឹងនិងគោរពគ្នាទៅវិញទៅមកអំពីសិទ្ធិផ្លូវភេទ
- ចេះពីវិធីដោះសារនិងឆ្លើយតប ដូចជាខ្ញុំមានការត្រូវទៅហើយ ខ្ញុំមិនចូលចិត្តអ្នកធ្វើសកម្មភាពនេះដាក់ខ្ញុំទេ
- ប្រុងប្រយ័ត្នពីសុវត្ថិភាពផ្ទាល់ខ្លួន ជាពិសេសកុំទៅកន្លែងស្ងាត់តែពីរនាក់ កន្លែងដែលមិនមានសុវត្ថិភាព
- កុំសេពគប់មនុស្សដែលមិនស្គាល់និងមិនអាចទុកចិត្តបាន
- កុំទទួលអំណោយ ឬវត្ថុអនុស្សាវរីយ៍ពីអ្នកមិនទុកចិត្ត។

ប្រសិនបើនរណាម្នាក់បៀតបៀនផ្លូវភេទអ្នក អ្នកត្រូវ៖

- ប្រាប់ពួកគេឱ្យ ឈប់ធ្វើដូច្នេះ
- ចៀសចេញឱ្យបានឆាប់ពីជនដែលបង្កការបៀតបៀនផ្លូវភេទរបស់អ្នក
- ប្រាប់មនុស្សមានវ័យចាស់ជាងដែលអ្នកទុកចិត្តអំពីរឿងនេះ ប្រសិនបើរឿងនេះកើតនៅសាលារៀន សូមប្រាប់ឬរាយការណ៍ដល់គ្រូបង្រៀន នាយកសាលា អាជ្ញាធរដែនដី ឬបុគ្គលិកសង្គមកិច្ច
- អាចសរសេរពាក្យបណ្ដឹងដោយរៀបរាប់អំពីរឿងរ៉ាវដែលបានកើតឡើងជាក់ស្ដែងទាំងនោះដោយឆ្លើយតបជាមួយសំណួរ : តើនរណា ? នៅទីណា ? ពេលណា ? អ្វី ? តើនរណាបានឃើញ ?



**មេរៀនសង្ខេប**

ការបៀតបៀនផ្លូវភេទ

## ៧- **វាយតម្លៃ** ( ជំហានទី៤ )

គ្រូសួរសំណួរ៖

១- តើអ្នកត្រូវធ្វើដូចម្ដេចខ្លះនៅពេលអ្នកឃើញមានគេបៀតបៀនផ្លូវភេទមិត្តអ្នកឬអ្នកដទៃ ?

២- បន្ទាប់ពីសិក្សាមេរៀននេះរួចតើអ្នកមានទំនួលខុសត្រូវក្នុងការបៀតបៀនផ្លូវភេទអ្នកដទៃដែរឬទេ ?

## ៨- **លំហាត់** ( ជំហានទី៥ )

**កិច្ចការផ្ទះ**

១- ចូរប្អូនមើលវិដេអូ **លីអូ៧ពណ៌** ហើយឆ្លើយសំណួរ : តើអ្នកត្រូវធ្វើដូចម្ដេច ក្រោយពីមើលវិដេអូ ?

២- ចូរប្អូនមើលមេរៀនត្រង់ចំណាងជើងចំណង់ផ្លូវភេទ។ គ្រូនឹងសួរនិងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

**ឯកសារយោង** : បន្ទាប់ពីបានមើលវិដេអូ លីអូ៧ពណ៌ហើយ ចូរប្អូនឆ្លើយសំណួរ : តើអ្នកត្រូវធ្វើដូចម្ដេច ក្រោយពីមើលវិដេអូ ?



Video Lio 7 Colors.mov

# មេរៀនទី ៣ : ចំណង់ផ្លូវភេទ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីការយល់ឃើញផ្សេងៗរបស់បុរស និងស្ត្រីអំពីចំណង់ផ្លូវភេទ<br>- ពណ៌នាពីគុណសម្បត្តិ និងគុណវិបត្តិនៃការពន្យារពេលរួមភេទ ឬជ្រើសរើសការរួមភេទ។ | - ប្រៀបធៀបគុណសម្បត្តិ និងគុណវិបត្តិនៃការពន្យារពេលរួមភេទ ឬជ្រើសរើសការរួមភេទ<br>- បង្ហាញពីការតម្រួមភេទ និងពេលវេលាដែលត្រូវសម្រេចចិត្តរួមភេទ។ | - បណ្តុះស្មារតីស្វែងយល់ពីការតម្រួមភេទ និងពេលវេលាដែលត្រូវសម្រេចចិត្តរួមភេទ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- ការឆ្លើយតបរបស់បុរសនិងស្ត្រីអំពីចំណង់ផ្លូវភេទ៖ គឺមានរូបភាពផ្សេងៗ និងខុសៗគ្នាទៅតាមរាងកាយបុរស និងរាងកាយរបស់ស្ត្រី ជាមួយនឹងអារម្មណ៍នៃទំនោរផ្លូវភេទរបស់ខ្លួន ហើយពេលខ្លះ វាមានលក្ខណៈស៊ាំញ៉ាំដោយផ្អែកលើបុគ្គល ពេលវេលានិងទីកន្លែង។

២- គុណសម្បត្តិ និងគុណវិបត្តិនៃការពន្យារពេលរួមភេទ ឬជ្រើសរើសការរួមភេទ៖ គុណសម្បត្តិនៃការពន្យារពេលរួមភេទមាន៖ មិនមានការឆ្លងរោគ (ជំងឺអេដស៍/កាមរោគ) មិនមានផ្ទៃពោះដែលមិនចង់បាន មិនមានបញ្ហាដល់ការសិក្សា ...។

៣- ការតម្រួមភេទ/ការសម្រេចចំណង់ដោយខ្លួនឯង គឺសំដៅលើការបបោសអង្អែលរាងកាយដោយខ្លួនឯងដើម្បីសម្រេចចំណង់ផ្លូវភេទ។ ការសម្រេចបំណងដោយខ្លួនឯង គឺជាវិធីសាស្ត្រដែលមានសុវត្ថិភាពបំផុត ហើយមិនប៉ះពាល់ដល់សុខភាពឡើយ។ ការសម្រេចចំណង់ដោយខ្លួនឯង គឺអាចប្រព្រឹត្តបានទាំងរាងកាយស្ត្រី និងរាងកាយបុរស។

**៥- វិធីសាស្ត្រ**

សំណួរបំផុសគំនិត ការឆ្លុះបញ្ចាំងជាលក្ខណៈបុគ្គល ការងារជាក្រុម ការពិភាក្សា។

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន រួចសួរ តើអ្វីទៅជាចំណង់ផ្លូវភេទ?

- គ្រូហៅសិស្ស ២ ឬ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្តាខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ការឆ្លើយតបរបស់បុរសនិងស្ត្រីអំពីចំណង់ផ្លូវភេទ**

- គ្រូពន្យល់ថា៖ មនុស្សគ្រប់រូបមានចំណង់ផ្លូវភេទដែលជាលក្ខណៈធម្មជាតិ ជាពិសេសនៅពេលពេញវ័យ។ ការមានចំណង់ផ្លូវភេទជារឿងធម្មតារបស់មនុស្ស។ ប៉ុន្តែការសម្តែងចេញនូវចំណង់ផ្លូវភេទ ឬសេចក្តីស្នេហារបស់បុគ្គលម្នាក់ៗគឺអាចមានលក្ខណៈខុសគ្នាដោយផ្អែកលើកត្តាយេនឌ័រ និងកត្តារួមផ្សំជាច្រើនទៀត។ មនុស្សគ្រប់រូប ទាំងបុរស ទាំងស្ត្រី ទាំងអ្នកប្លែងភេទ/យេនឌ័រ ឬអ្នកស្រលាញ់ភេទដូចគ្នា អាចមានចំណង់ផ្លូវភេទជាមួយមនុស្សម្នាក់ទៀត ដែលមានភេទដូចគ្នាឬភេទផ្សេងគ្នា។
- គ្រូសួរ តើការឆ្លើយតបរបស់បុរសនិងស្ត្រីអំពីចំណង់ផ្លូវភេទកើតឡើងដូចម្តេច? គ្រូហៅសិស្ស ២ ឬ ៣នាក់ឱ្យឆ្លើយ។ ចម្លើយសិស្ស.......
- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្តារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវដាក់លើក្តារខៀន

**ចម្លើយ:** រាងកាយរបស់យើង មានសរីរាង្គជាច្រើនដែលអាចឆ្លើយតបទៅនឹងរំញោចផ្លូវភេទ។ ឧទាហរណ៍៖ បុគ្គលម្នាក់អាចមានអារម្មណ៍ផ្លូវភេទ និងសុខស្រួល ដោយការប៉ះពាល់លើផ្ទៃមុខ ក្បាលពោះ ចុងសុដន់ ត្រចៀក ដៃ ជើង ចង្កេះ ប្រដាប់ភេទ ជាដើម។ ការទទួលបានអារម្មណ៍នេះ គឺចាប់ផ្តើមចេញពីខួរក្បាល ដែលជាសរីរាង្គដ៏សំខាន់ក្នុងការឆ្លើយតបទៅនឹងរំញោចផ្លូវភេទដើម្បីទទួលបានភាពសុខស្រួល។ ជាទូទៅ បុគ្គលម្នាក់ៗមានការយល់ឃើញ និងឆ្លើយតបទៅនឹងចំណង់ផ្លូវភេទរបស់ខ្លួនតាមរូបភាព ផ្សេងៗ និងខុសៗគ្នាទៅតាមរាងកាយបុរស និងរាងកាយរបស់ស្ត្រី ជាមួយនឹងអារម្មណ៍នៃទំនោរផ្លូវភេទរបស់ខ្លួន ហើយពេលខ្លះ វាក៏ត្រូវបានផ្លាស់ប្តូរទៅតាមពេលវេលាផងដែរ។ យោងតាមការសិក្សាស្រាវជ្រាវមួយបាន លើកឡើងថា ការយល់ឃើញ និងឆ្លើយតបអំពីចំណង់ផ្លូវភេទរបស់បុគ្គលគឺមានលក្ខណៈស្មុំគ្រស្មាញដោយផ្អែកលើបុគ្គល ពេលវេលានិងទីកន្លែង។ ឧទាហរណ៍៖ រាងកាយរបស់បុរស អាចសម្តែងចេញនូវចំណង់ផ្លូវភេទងាយៗ ដែលផ្ទុយពីរាងកាយរបស់ស្ត្រី។ គេសង្កេតឃើញថា ស្ត្រីដែលមានទំនាក់ទំនងនឹងសាសនា មានទំនោរបិទបាំងច្រើនទៅលើការសម្តែងចំណង់ផ្លូវភេទ។ បុគ្គលដែលមានរាងកាយជាស្រី អាចទទួលឥទ្ធិពលកាន់តែខ្លាំងពីឥរិយាបថរបស់ក្រុមមិត្តភក្តិ ក្នុងការសម្រេចចិត្តអំពីការរួមភេទ។ មានភាគរយនៃស្ត្រីច្រើនជាងបុរស បង្ហាញភាពមិនស៊ីចង្វាក់គ្នារវាងការឱ្យតម្លៃអំពីសកម្មភាពផ្លូវភេទ ដូចជាការរួមភេទមុនពេលរៀបការ និងអាកប្បកិរិយាជាក់ស្តែងរបស់ពួកគេដែលបានប្រព្រឹត្ត។ ប៉ុន្តែការជះឥទ្ធិ

ពលទាំងនេះ មិនមែនជារឿងដែលត្រឹមត្រូវនោះទេ ព្រោះបុគ្គលម្នាក់ៗ មានសិទ្ធិស្មើគ្នាក្នុងការសម្តែងនូវទំនោរ និងអារម្មណ៍ផ្លូវភេទរបស់ខ្លួន។ នេះគឺជាចំណុចសំខាន់ដែលសិស្សានុសិស្សត្រូវយល់ដឹងអំពីសិទ្ធិផ្លូវភេទ និងសិក្សាបន្ថែមដើម្បីពិចារណាដោយខ្លួនឯងនៅពេលដែលមានការសម្រេចចិត្តរឿងផ្លូវភេទ។

**ខ្លឹមសារ : គុណសម្បត្តិ និងគុណវិបត្តិនៃការពន្យារពេលរួមភេទ ឬជ្រើសរើសការរួមភេទ**

- គ្រូចែកជាក្រុមពិភាក្សានិងរកចម្លើយសំណួរខាងក្រោម ក្នុងរយៈពេល ១០នាទី ដោយសរសេរចម្លើយក្នុងក្រដាសសម្រាប់ឡើងរាយការណ៍។
  - ១- តើគុណសម្បត្តិនៃការពន្យារពេលរួមភេទមានអ្វីខ្លះ ?
  - ២- តើគុណវិប្បត្តិនៃការពន្យារពេលរួមភេទមានអ្វីខ្លះ ?
- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សា
- គ្រូកត់ពាក្យគន្លឹះដាក់លើក្តារខៀននូវចម្លើយរបស់សិស្ស
- គ្រូសំយោគចម្លើយតាមខ្លឹមសារមេរៀន បន្ទាប់ពីតំណាងក្រុមធ្វើបទបង្ហាញរួច

**ចម្លើយ:** នៅក្នុងយុវវ័យ ការសម្រេចចិត្តរឿងផ្លូវភេទគឺជារឿងសំខាន់ខ្លាំងណាស់សម្រាប់ខ្លួនឯង ពីព្រោះវាអាចមានការជះឥទ្ធិពលខ្លាំងទាំងទៅលើរាងកាយនិងផ្លូវចិត្ត។ យុវវ័យត្រូវធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ដោយផ្អែកលើជំហ៊ាននៃការសម្រេចចិត្ត មុនពេលដែលខ្លួនសម្រេចចិត្តធ្វើការរួមភេទជាលើកដំបូង។ ត្រូវចងចាំថា យើងអាចពន្យារពេលការរួមភេទរបស់ខ្លួនតាមរយៈការគោរពលើការសម្រេចចិត្តរបស់ខ្លួន និងអនុវត្តជាសកម្មភាពដទៃក្រៅពីការរួមភេទ។ យុវវ័យអាចពិភាក្សាជាមួយនឹងដៃគូរបស់ខ្លួនអំពីគុណសម្បត្តិនៃការពន្យារពេលការរួមភេទ ដោយផ្អែកលើចំណុចដែលបានរៀបរាប់ត្រួសៗដូចខាងក្រោម៖

**ក. គុណសម្បត្តិនៃការពន្យារពេលរួមភេទ៖**

- មិនមានការឆ្លងរោគ ( ជំងឺអេដស៍/កាមរោគ )
- មិនមានផ្ទៃពោះដែលមិនចង់បាន
- មិនមានបញ្ហាដល់ការសិក្សា
- សប្បាយរីករាយនឹងកីឡា ការអានសៀវភៅ និងការកម្សាន្តផ្សេងៗទៀត
- មានមិត្តភក្តិកាន់តែច្រើន
- យុវវ័យត្រូវចងចាំថា ប្រសិនបើខ្លួនចង់ប្រឡូកនឹងការរួមភេទ យើងត្រូវស្វែងយល់ឱ្យបានលម្អិតមុនធ្វើការសម្រេចចិត្តដូចជា៖
  - អ្នកត្រូវស្វែងយល់ពីដៃគូរួមភេទឱ្យបានច្បាស់លាស់
  - យល់ដឹងអំពីការបង្ការការចម្លងរោគតាមការរួមភេទ
  - ស្វែងយល់អំពីការប្រើប្រាស់ស្រោមអនាម័យដើម្បីបង្ការការចម្លងរោគ និងការមានផ្ទៃពោះដោយមិនចង់បាន
  - វិធីការពារការមានផ្ទៃពោះដោយចៃដន្យ
  - សេវាសុខភាពមិត្តភាពសម្រាប់យុវវ័យ

ក្រៅពីនេះយុវវ័យក៏អាចពិភាក្សាជាមួយដៃគូទៅលើការសម្តែងមនោសញ្ចេតនាទៅលើដៃគូ ដោយគ្រាន់តែឱប ថើប ឬការសម្រេចចំណង់ដោយខ្លួនឯងជាដើម។

**ខ្លឹមសារ : ការសម្រេចចំណង់ដោយខ្លួនឯង**

**គ្រូពន្យល់:** ការសម្រេចចំណង់ដោយខ្លួនឯង គឺសំដៅលើការបបោសអង្អែលរាងកាយដោយខ្លួនឯងដើម្បីសម្រេចចំណង់ផ្លូវភេទ។ ការសម្រេចបំណងដោយខ្លួនឯង គឺជាវិធីសាស្ត្រដែលមានសុវត្ថិភាពបំផុត ហើយមិនប៉ះពាល់ដល់សុខភាពឡើយ។ វាអាចជួយឱ្យយើងមានសុខមាលភាពខាងផ្លូវភេទ និងជាឱកាសក្នុងការស្វែងយល់ពីតម្រូវការផ្លូវភេទ និងស្គាល់ពីរាងកាយរបស់ខ្លួនកាន់តែច្បាស់។ ការសម្រេចចំណង់ដោយខ្លួនឯង គឺអាចប្រព្រឹត្តបានទាំង រាងកាយស្ត្រី និងរាងកាយបុរស។ វិធីនេះក៏អាចឱ្យយុវវ័យជួយពន្យារពេលនៃការរួមភេទជាមួយដៃគូរបស់ខ្លួនផងដែរ។ យុវវ័យត្រូវចងចាំថា ការទទួលបានភាពស្រណុកសុខស្រួលខាងផ្លូវភេទមិនសំដៅតែការទទួលបានអារម្មណ៍ពីដៃគូរួមភេទដោយការរួមភេទនោះទេ យុវវ័យអាចសម្រេចចំណង់ផ្លូវភេទដោយខ្លួនឯងបាន ពីព្រោះចំណង់ផ្លូវភេទគឺជាអារម្មណ៍ដែលបុគ្គលអាចរីករាយ និងស្រណុកសុខស្រួល ដោយមិនកំណត់ពីវិធីនៃការទទួលបានអារម្មណ៍នោះឡើយ។

- គ្រូឱ្យសិស្សកត់មេរៀនសង្ខេបចូលក្នុងសៀវភៅកិច្ចការសិស្ស។



**មេរៀនសង្ខេប**

ការឆ្លើយតបរបស់បុរសនិងស្ត្រីអំពីចំណង់ផ្លូវភេទតាមរូបភាពផ្សេងៗ និងខុសៗគ្នាទៅតាមរាងកាយបុរស និងរាងកាយរបស់ស្ត្រី ជាមួយនឹងអារម្មណ៍នៃទំនោរផ្លូវភេទរបស់ខ្លួន ហើយពេលខ្លះ វាមានលក្ខណៈស្មុគស្មាញដោយផ្អែកលើបុគ្គល ទីកន្លែង និងពេលវេលា។ គុណសម្បត្តិនៃការពន្យារពេលរួមភេទមាន មិនមានការឆ្លងរោគ (ជំងឺអេដស៍/កាមរោគ) មិនមានផ្ទៃពោះដែលមិនចង់បាន មិនមានបញ្ហាដល់ការសិក្សា ...។ ការសម្រេចចំណង់ដោយខ្លួនឯង គឺជាវិធីសាស្ត្រដែលមានសុវត្ថិភាពបំផុត ហើយមិនប៉ះពាល់ដល់សុខភាពឡើយ។

**៧- វាយតម្លៃ** (ជំហានទី៤)

- គ្រូឱ្យសិស្សសរុបឡើងវិញពីការយល់ឃើញផ្សេងៗរបស់បុរស និងស្ត្រីអំពីចំណង់ផ្លូវភេទ គុណសម្បត្តិ និងគុណវិបត្តិនៃការពន្យារពេលរួមភេទ ឬជ្រើសរើសការរួមភេទ។

**៨- លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ:**

១- ចូរអ្នកស្រាវជ្រាវអំពីហិង្សាមានអ្វីខ្លះ

២- ចូរអ្នកមើលមេរៀនអំពីហិង្សា សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

សមាសភាគទី៣ : សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ

ជំពូកទី១ : ការអប់រំជីវិតផ្លូវភេទ

# មេរៀនទី ៤ : អំពើហិង្សា

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីនិយមន័យ មូលហេតុ និងប្រភេទនៃអំពើហិង្សា។ | • បកស្រាយពីផលប៉ះពាល់និង វិធីបញ្ចៀសអំពើហិង្សា។ | • បណ្តុះស្មារតីឱ្យចេះស្រឡាញ់ សមាជិកគ្រួសារនិងសហគមន៍។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យ៖ អំពើហិង្សាមានច្រើនប្រភេទរាប់បញ្ចូលទាំងការបង្ខំលើរូបរាងកាយ ការគំរាមកំហែង ការបំភិតបំភ័យខាងផ្លូវចិត្ត ផ្លូវភេទ និងខាងផ្នែកសេដ្ឋកិច្ច។ អំពើហិង្សា គឺនៅពេលមនុស្សម្នាក់ប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីគាបសង្កត់ ធ្វើបាប ទៅលើជនដទៃទៀត ធ្វើឱ្យពួកគេមានអារម្មណ៍ឈឺចាប់និងភ័យខ្លាច។

២- មូលហេតុនិងប្រភេទនៃអំពើហិង្សា៖ មូលហេតុអំពើហិង្សាដោយសាអ្នកប្រព្រឹត្តិអំពើហិង្សាមួយចំនួនចងសម្រេចបំណង ប្រកាន់ទស្សនៈរៀងៗខ្លួន ខ្វះការគោរពគ្នា ចង់ឈ្នះ ចង់ធ្វើជាអ្នកខ្លាំង ដោយមិនយកហេតុផលមកជជែក មិនគ្រប់គ្រងកំហឹងរបស់ខ្លួន និងខ្វះការពិចារណានិងអធ្យាស្រ័យឱ្យគ្នា។ ប្រភេទនៃអំពើហិង្សាមានបួនប្រភេទគឺ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវចិត្ត ឬផ្លូវអារម្មណ៍ និងអំពើហិង្សាដោយការបំភ្លេចនិងការបដិសេធឱកាស។

៣- ផលប៉ះពាល់នៃអំពើហិង្សា៖ អំពើហិង្សាផ្តល់ផលប៉ះពាល់អវិជ្ជមាន ដល់ផ្នែករាងកាយ ផ្លូវចិត្តឬស្មារតី គ្រួសារ និងសង្គម។

៤- វិធីបញ្ចៀសអំពើហិង្សាមាន៖ និយាយឆ្លើយតបដោយសន្តិវិធី ប្រាប់អ្នកដែលទុកចិត្តនិងអាចជួយបាន ចេះគោរពនិងស្វែងយល់ពីគ្នាទៅវិញទៅមក ត្រូវចេះគ្រប់គ្រងកំហឹងរបស់ខ្លួន និងចេះពិចារណាអធ្យាស្រ័យឱ្យគ្នា៕

**៥- វិធីសាស្ត្រ**

សំណួរបំផុស ធ្វើបទបង្ហាញ ធ្វើការជាដៃគូ

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .....
  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......
  ៣- តើអ្នកធ្លាប់ឮឬឃើញអំពើហិង្សាអ្វីខ្លះ?
- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្តារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យអំពើហិង្សា**

- គ្រូសួរសំណួរ៖ តើអំពើហិង្សាមានន័យដូចម្តេច? ទុកពេល១-២នាទី រួចហៅសិស្ស ២-៣នាក់ឱ្យឆ្លើយ។ ចម្លើយសិស្ស : .............
- គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ:** អំពើហិង្សាមានច្រើនប្រភេទរាប់បញ្ចូលទាំងការបង្ខំលើរូបរាងកាយ ការគំរាមកំហែង ការបំភិតបំភ័យខាងផ្លូវចិត្ត ផ្លូវភេទ និងខាងផ្នែកសេដ្ឋកិច្ច។ អំពើហិង្សា គឺនៅពេលមនុស្សម្នាក់ប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីគាបសង្កត់ ធ្វើបាប ទៅលើជនដទៃទៀត ធ្វើឱ្យពួកគេមានអារម្មណ៍ឈឺចាប់និងភ័យខ្លាច។

**ខ្លឹមសារ : មូលហេតុនិងប្រភេទនៃអំពើហិង្សា**

- គ្រូបែងចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេល៥ ទៅ ១០នាទី។
  ១. តើមូលហេតុនៃអំពើហិង្សាមានអ្វីខ្លះ? ចូររៀបរាប់
  ២. តើអំពើហិង្សាមានប៉ុន្មានប្រភេទ? ចូររៀបរាប់
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល និងសំយោគចម្លើយដែលត្រឹមត្រូវត្រឹមត្រូវដូចក្នុងខ្លឹមសារមេរៀន។

**ចម្លើយ៖**

| មូលហេតុនៃអំពើហិង្សា | ប្រភេទនៃអំពើហិង្សា |
|---|---|
| - អ្នកប្រព្រឹត្តិអំពើហិង្សាមួយចំនួនចង់សម្រេចបំណង និងប្រើប្រាស់អំណាចដើម្បីត្រួតត្រាលើនរណាម្នាក់<br>- អំពើហិង្សាមួយចំនួនមានប្រភពមកពីការប្រកាន់ទស្សនៈឬមានគំនិតខុសៗគ្នា ខ្វះការគោរពគ្នា មិនស្វែងយល់ពីគ្នាទៅវិញទៅមក<br>- ចិត្តមានៈ ចង់ឈ្នះ ចង់ធ្វើជាអ្នកខ្លាំង ដោយមិនយកហេតុផលមកជជែក<br>- ខ្វះវិធីគ្រប់គ្រងកំហឹងរបស់ខ្លួន | - អំពើហិង្សាផ្លូវភេទ ជាការបង្កការឈឺចាប់ដែលពាក់ព័ន្ធនឹងផ្លូវភេទ និងខូចសរីរាង្គបន្តពូជ ។ ឧទាហរណ៍ : ការចាប់បង្ខំនរណាម្នាក់រួមភេទ។<br>- អំពើហិង្សាផ្លូវកាយ ជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ផ្នែករាងកាយ ទោះមានស្លាកស្នាម ឬគ្មានស្លាកស្នាមក៏ដោយ។ ឧទាហរណ៍៖ ការវាយ ការច្រាន ការធាក់ ឬប្រើវត្ថុអ្វីមួយដូចជា ដំបង ឬឧបករណ៍ផ្សេងៗ ក្នុងការធ្វើឱ្យនរណាម្នាក់មានការឈឺចាប់។ |

| | |
|---|---|
| - ខ្វះការពិចារណានិងអធ្យាស្រ័យឱ្យអ្នកដទៃ។ | - អំពើហិង្សាផ្លូវចិត្ត ឬផ្លូវអារម្មណ៍ ជាការគំរាម ការនិយាយ ឬធ្វើអ្វីម៉្យាង ដែលបង្កភាពភ័យខ្លាច និងតានតឹង អារម្មណ៍ដល់នរណាម្នាក់ ឬក្រុមមនុស្ស ដើម្បីត្រួតត្រាលើពួកគេ ។ ឧទាហរណ៍៖ ការគំរាមថានឹងវាយសម្លាប់នរណាម្នាក់ ការប្រាប់នរណាម្នាក់ថាពួកគេជាមនុស្សភ្លីភ្លើ ឬគ្មានប្រយោជន៍ ឬការបញ្ឈប់ពួកគេកុំឱ្យជួបសមាជិកគ្រួសារ ឬមិត្តភក្តិរបស់គេ។<br>- អំពើហិង្សាដោយការបំភ្លេច និងការបដិសេធឱកាស ការរារាំងនរណាម្នាក់ មិនឱ្យទទួលបានសេចក្តីត្រូវការជាមូលដ្ឋានរបស់ខ្លួន មិនឱ្យទទួលបានអត្ថប្រយោជន៍ពីឱកាសណាមួយដោយចេតនា។ ឧទាហរណ៍៖ ការមិនផ្តល់ទឹក ឬអាហារគ្រប់គ្រាន់ដល់នរណាម្នាក់ ឬការមិនផ្តល់ឱកាសឱ្យក្មេងស្រីទទួលបានការអប់រំជាដើម។ |

**ខ្លឹមសារ : ផលប៉ះពាល់នៃអំពើហិង្សា**

- **ការងារជាដៃគូ** : ចាប់ដៃគូរកខ្លឹមសារពីផលប៉ះពាល់នៃអំពើហិង្សា ក្នុងរយៈពេល២ទៅ៣នាទី។ បន្ទាប់មកគ្រូឱ្យសិស្សឡើងចែករំលែកពីលទ្ធផលនៃការពិភាក្សាដល់ក្រុមធំតាមការស្ម័គ្រចិត្ត។
- គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។

**ចម្លើយ:** អំពើហិង្សាផ្តល់ផលប៉ះពាល់អវិជ្ជមាន ដល់ជនរងគ្រោះ ទាំងផ្នែករាងកាយ ផ្លូវចិត្តឬស្មារតី ដល់មនុស្ស គ្រួសារ និងសង្គម។ **អំពើហិង្សាផ្នែករាងកាយ** អាចបណ្តាលឱ្យរបួស បាក់ឆ្អឹង ពិការភាព ឬអាចបណ្តាលឱ្យស្លាប់, **ផ្នែកផ្លូវចិត្តឬស្មារតី**មានដូចជា ការភ័យខ្លាច ស្រ្តេស ថប់បារម្ភ ធ្លាក់ទឹកចិត្ត។ មានអារម្មណ៍ថាខ្លួនគ្មានតម្លៃ ឯកោ ជំងឺផ្លូវចិត្ត ឬធ្វើអត្តឃាត, **គ្រួសារ**៖ គ្រួសារអត់មានសេចក្តីសុខ បែកបាក់គ្រួសារ បាត់បង់ពេលវេលារកចំណូល បាត់បង់ កិត្តិយស ជះឥទ្ធិពលដល់កូននិងសមាជិកគ្រួសារ។ **សង្គម**៖ អំពើហិង្សាជាបន្ទុកនិងបង្កអសន្តិសុខ គ្មានសណ្តាប់ធ្នាប់ដល់សង្គម។

**ខ្លឹមសារ : វិធីបញ្ចៀសអំពើហិង្សា**

- តើវិធីបញ្ចៀសអំពើហិង្សាមានអ្វីខ្លះ? ទុកពេល១ទៅ២នាទីរួច ហៅសិស្ស ២-៣នាក់ ឱ្យឆ្លើយ
  ចម្លើយសិស្ស : .......
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយៈ** ក្នុងករណីមានការឈ្លោះប្រកែកគ្នា យើងអាចប្រើវិធីផ្សេងៗដើម្បីបញ្ចៀសអំពើហិង្សា ដូចជា៖

- និយាយឆ្លើយតបដោយសន្តិវិធី រួចដើរចេញ ដើម្បីរកវិធីដោះស្រាយបន្ទាប់
- ប្រាប់អ្នកដែលទុកចិត្តនិងអាចជួយបាន ឬអាចប្រាប់ទៅគ្រូ នាយក ឪពុកម្ដាយ បង មេភូមិ ប៉ូលីស ក្រុមប្រឹក្សាឃុំ ឬអង្គការ
- មិនត្រូវប្រកាន់ទស្សនៈឬគំនិតខ្លួនឯងពេកទេ និងត្រូវចេះគោរពនិងស្វែងយល់ពីគ្នាទៅវិញទៅមក
- មិនត្រូវយកឈ្នះ ចាញ់ ចេះពិភាក្សានិងពិចារណាហើយអធ្យាស្រ័យអត់ឱនឱ្យគ្នាទៅវិញទៅមក
- ត្រូវចេះគ្រប់គ្រងកំហឹងរបស់ខ្លួន។



**មេរៀនសង្ខេប**

**អំពើហិង្សា**មានច្រើនប្រភេទរាប់បញ្ចូលទាំងការបង្ខំលើរូបរាងកាយ ការគំរាមកំហែង ការបំភិតបំភ័យខាងផ្លូវចិត្ត ផ្លូវភេទ និងខាងផ្នែកសេដ្ឋកិច្ច។ មូលហេតុអំពើហិង្សាដោយសាអ្នកប្រព្រឹត្តិអំពើហិង្សាមួយចំនួនចង់សម្រេចបំណង ប្រកាន់ទស្សនៈរៀងៗខ្លួន ...។ ប្រភេទនៃអំពើហិង្សាមានបួនប្រភេទគឺ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវចិត្ត ឬផ្លូវអារម្មណ៍ និងអំពើហិង្សាដោយការបំភ្លេចនិងការបដិសេធឱកាស។ វិធីបញ្ចៀសអំពើហិង្សាមាន និយាយឆ្លើយតបដោយសន្តិវិធី ប្រាប់អ្នកដែលទុកចិត្តនិងអាចជួយបាន ចេះគោរពនិងស្វែងយល់ពីគ្នាទៅវិញទៅមក ត្រូវចេះគ្រប់គ្រងកំហឹងរបស់ខ្លួន និងចេះពិចារណាអធ្យាស្រ័យឱ្យគ្នា៕

### ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ចូរឱ្យនិយមន័យអំពើហិង្សា ?

២- មូលហេតុអ្វីខ្លះដែលនាំឱ្យមានអំពើហិង្សា ?

៣- ចូររៀបរាប់ពីផលប៉ះពាល់និងវិធីបញ្ចៀសនៃអំពើហិង្សាក្នុងគ្រួសារនិងសង្គម។

### ៨- **លំហាត់** (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកយកចំណេះដឹងពីមេរៀននេះ ទៅចែករំលែកដល់សមាជិកគ្រួសារនិងមិត្តភក្តិ

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនមិត្តភក្តិមានឥទ្ធិពលទៅលើការសម្រេចចិត្ត សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៥ : មិត្តភក្តិមានឥទ្ធិពលនៅលើការសម្រេចចិត្ត

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - រៀបរាប់ពីឥទ្ធិពលវិជ្ជមាននិងអវិជ្ជមានទៅលើការសម្រេច ចិត្ត និងអាកប្បកិរិយារបស់ក្មេងជំទង់ទាក់ទងនឹងរឿងផ្លូវភេទ។ | - បង្ហាញពីវិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងសម្ពាធអវិជ្ជមាន និងគាំទ្រការបង្កើតមិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមាន។ | - យកចិត្តទុកដាក់បង្កើតមិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមាន កាត់បន្ថយការសេពគប់មិត្ត ដែលផ្តល់សម្ពាធអវិជ្ជមាន។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- ឥទ្ធិពលវិជ្ជមាននិងអវិជ្ជមានទៅលើការសម្រេចចិត្ត និងអាកប្បកិរិយារបស់ក្មេងជំទង់ទាក់ទងនឹងរឿងផ្លូវភេទ

- ឥទ្ធិពលវិជ្ជមាន មានដូចជា៖ មិត្តភក្តិបានឱ្យគំរូល្អៗ ឱ្យគ្នាទៅវិញទៅមក ផ្តល់មតិនិងដំបូន្មានល្អ ជួយការលើកទឹកចិត្ត និងផ្តល់បទពិសោធន៍ថ្មី។
- ឥទ្ធិពលអវិជ្ជមានទៅលើការសម្រេចចិត្ត មានដូចជា៖ ការបង្ខិតបង្ខំពីមិត្តភក្តិឱ្យធ្វើអ្វីមួយដែលអាចបង្កឱ្យមានគ្រោះថ្នាក់ឬផលវិបាកធ្ងន់ធ្ងរ ការដាក់សម្ពាធលើការស្លៀកពាក់មិនសមរម្យ ការបង្ខំឱ្យសេពគប់ជាមួយមនុស្សពាលាអាវ៉ាសែ ការបង្ខំមិត្តភក្តិឱ្យបោះបង់ការសិក្សាឱ្យប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន។

២- វិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងសម្ពាធអវិជ្ជមាននិងគាំទ្រការបង្កើតមិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមាន

- ត្រូវមានភាពក្លាហាននិងទំនុកចិត្ត និងចេះរៀបចំផែនការទប់ទល់នឹងសម្ពាធ ចេះពីរបៀបដែលត្រូវដោះស្រាយបញ្ហាប្រឈម និងត្រូវស្វែងរកមនុស្សល្អនិងមានឥទ្ធិពល ដើម្បីជួយដោះស្រាយ។
- គាំទ្រការបង្កើតមិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមាន ត្រូវមានអាកប្បកិរិយា និងការប្រព្រឹត្ត៖ គោរពនិងឱ្យតម្លៃគ្នាទៅវិញទៅមក គោរពពេលវេលា ពាក្យសន្យានិងរក្សាការសម្ងាត់ ផ្តល់ការលើកទឹកចិត្ត ចូលរួមពិភាក្សានិងដោះស្រាយបញ្ហា ផ្តល់មតិយោបល់និងដំបូន្មានល្អៗ និងចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក។

**៥- វិធីសាស្ត្រ**

ការងារជាដៃគូ សំណួរនិងចម្លើយ បទបង្ហាញ បកស្រាយ ពន្យល់ ការបំផុសគំនិត

## ៦- សកម្មភាពបង្រៀននិងរៀន

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព ? ចម្លើយសិស្ស : .......

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន ? ចម្លើយសិស្ស : ......

  ៣- តើកន្លងមកមិត្តភក្តិរបស់អ្នកដែលមានឥទ្ធិពលទៅលើការសម្រេចចិត្តអ្នកដែរឬទេ ? បើមានដូចម្តេច ?

- គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ
- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្តារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : ឥទ្ធិពលវិជ្ជមាននិងអវិជ្ជមានទៅលើការសម្រេចចិត្ត និងអាកប្បកិរិយារបស់ក្មេងជំទង់ទាក់ទងនឹងរឿងផ្លូវភេទ**

- គ្រូចែកសិស្សជាក្រុមតូចៗ ពិភាក្សាលើសំណួរខាងក្រោមក្នុងរយៈពេល៥ ទៅ១០នាទី៖

  ១- តើឥទ្ធិពលវិជ្ជមានលើការសម្រេចចិត្តមានអ្វីខ្លះ ? ចូររៀបរាប់

  ២- តើឥទ្ធិពលអវិជ្ជមានលើការសម្រេចចិត្តមានអ្វីខ្លះ ? ចូររៀបរាប់

- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សំយោគ និងសង្ខេបចម្លើយ តាមខ្លឹមសារនៃមេរៀន

**ចម្លើយៈ ឥទ្ធិពលវិជ្ជមាន មានដូចជា៖**

- **មិត្តភក្តិបានឱ្យគំរូល្អៗ ឱ្យគ្នាទៅវិញទៅមក** ប្តេជ្ញាធ្វើកិច្ចការឱ្យបានល្អនៅសាលារៀន ប្រឹងប្រែងឱ្យអស់ពីសមត្ថភាពក្នុងការងារ មានចិត្តសប្បុរស គុណសម្បត្តិ និងមានឥទ្ធិពលទៅលើការសម្រេចចិត្តលើគោលដៅច្បាស់លាស់។
- **មតិនិងដំបូន្មាន៖** មិត្តរបស់យើងស្តាប់និងផ្តល់មតិយោបល់ឱ្យយើង នៅពេលដែលយើងចង់រកគំនិតថ្មី និងដោះស្រាយបញ្ហា។ មិត្តភក្តិល្អអាចជួយអប់រំ ទូន្មាន ដល់យើង នៅពេលពួកគេគិតថា យើងកំពុងធ្វើកំហុស ឬធ្វើអ្វីមួយដែលមានគ្រោះថ្នាក់។
- **ការលើកទឹកចិត្ត៖** មិត្តភក្តិលើកទឹកចិត្តឱ្យយើងខិតខំដើម្បីទទួលបានលទ្ធផលល្អ ជួយយើងក្នុងសិក្សារៀនសូត្រ គាំទ្រយើងនៅពេលយើងមានការខកចិត្ត ឬមានបញ្ហា និងយល់ស្របជាមួយយើងនៅពេលពួកគេជួបប្រទះការលំបាកស្រដៀងគ្នា។
- **បទពិសោធន៍ថ្មី៖** មិត្តភក្តិរបស់យើងអាចនាំយើងចូលរួមក្នុងក្លឹបសិក្សា ក្រុមកីឡា ក្រុមរបាំ ការងារមនុស្សធម៌ និងការងារសង្គម។

## ខ. ឥទ្ធិពលអវិជ្ជមានទៅលើការសម្រេចចិត្ត

នៅពេលខ្លះមិត្តភក្តិបានដាក់សម្ពាធ ឬបង្កភាពតានតឹងនៅក្នុងជីវិតរបស់យើង។ ពួកគេអាចដាក់សម្ពាធ ឱ្យយើងធ្វើអ្វីមួយដែលយើងយល់ថាមិនត្រឹមត្រូវ ដូចជា ការទិញអីវ៉ាន់ ការសេពគ្រឿងញៀន ការប្រថុយគ្រោះថ្នាក់នៅពេលបើកបររថយន្ត ឬបបួលចូលរួមក្នុងការរួមភេទ ...។ ការដាក់សម្ពាធនេះអាចត្រូវបានបង្ហាញដោយចំហរ ដូចជា៖

- ការបង្ខិតបង្ខំពីមិត្តភក្តិឱ្យធ្វើអ្វីមួយដែលអាចបង្កឱ្យមានគ្រោះថ្នាក់ ឬផលវិបាកធ្ងន់ធ្ងរ។
- ការដាក់សម្ពាធលើការស្លៀកពាក់មិនសមរម្យ
- ការបង្ខំឱ្យសេពគប់ជាមួយមនុស្សពាលា អាវ៉ាសែ ដូចជា អ្នកផឹក ស្រា ឬសេពគ្រឿងញៀន
- ការបង្ខំមិត្តភក្តិឱ្យបោះបង់ការសិក្សា ឱ្យប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន។

**ខ្លឹមសារ : វិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងសម្ពាធអវិជ្ជមាន និងគាំទ្រការបង្កើតមិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមាន**

- គ្រូចែកសិស្សជាក្រុមតូចៗ ពិភាក្សាលើសំណួរខាងក្រោមក្នុងរយៈពេល១០នាទី៖
  - ១- តើវិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងសម្ពាធអវិជ្ជមានមានអ្វីខ្លះ ? ចូររៀបរាប់
  - ២- តើការគាំទ្រការបង្កើតមិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមាន មានអ្វីខ្លះ ? ចូររៀបរាប់
- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សំយោគ និងសង្ខេបចម្លើយ តាមខ្លឹមសារនៃមេរៀន

**ចម្លើយ:** មិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមានមានលក្ខណសម្បត្តិ ដូចជា៖ ចេះគោរពគ្នាទៅវិញទៅមក ផ្តល់យោបល់ល្អ គាំទ្រនិងលើកទឹកចិត្ត រួមសុខទុក្ខ ជួយយកអាសារគ្នាទៅវិញទៅមក។ គាំទ្រការបង្កើតមិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមាន ត្រូវមានអាកប្បកិរិយា និងការប្រព្រឹត្ត ដូចខាងក្រោម៖

- គោរពនិងឱ្យតម្លៃគ្នាទៅវិញទៅមក
- គោរពពេលវេលា ពាក្យសន្យា និងរក្សាការសម្ងាត់
- ផ្តល់ការលើកទឹកចិត្ត
- ចូលរួមពិភាក្សានិងដោះស្រាយបញ្ហា
- ផ្តល់មតិយោបល់ ដំបូន្មានល្អៗ និងចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក។
- គ្រូសម្របសម្រួលនិងបង្ហាញមេរៀនសង្ខេប



**មេរៀនសង្ខេប**

មិត្តមានតួនាទីសំខាន់ក្នុងជីវិតរបស់យើងដូចជា ការជួយយកអាសារគ្នា ជួយការសិក្សាគ្នា ជួយពិភាក្សានិងផ្ដល់យោបល់ក្នុងការសម្រេចចិត្ត ព្រមទាំងយល់ថា ពួកគេដូចជាគ្រួសាររបស់យើង។ ប៉ុន្តែមិត្តភក្តិខ្លះអាចបង្កឱ្យមានគ្រោះថ្នាក់ដែរ ដូចជាការដាក់សម្ពាធលើការស្លៀកពាក់មិនសមរម្យ ការបង្ខំឱ្យសេពគប់ជាមួយមនុស្សមិនល្អ បង្ខំមិត្តភក្តិឱ្យបោះបង់ការសិក្សាឱ្យប្រើប្រាស់គ្រឿងស្រវឹងឬគ្រឿងញៀន។ វិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងសម្ពាធអវិជ្ជមានមានដូចជា ត្រូវមានភាពក្លាហាននិងទំនុកចិត្ត និងចេះរៀបចំផែនការទប់ទល់នឹងសម្ពាធ ចេះពីរបៀបដែលត្រូវដោះស្រាយបញ្ហាប្រឈម និងត្រូវស្វែងរកមនុស្សល្អនិងមានឥទ្ធិពល ដើម្បីជួយដោះស្រាយ។ដោះស្រាយបញ្ហាប្រឈម និងត្រូវស្វែងរកមនុស្សល្អនិងមានឥទ្ធិពល ដើម្បីជួយដោះស្រាយ។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្ស២ឬ៣នាក់ឆ្លើយឡើងវិញនឹងសំណួរ:

១- ចូររៀបរាប់ពីឥទ្ធិពលវិជ្ជមាននិងអវិជ្ជមានទៅលើការសម្រេចចិត្តនិងអាកប្បកិរិយារបស់ក្មេងជំទង់ទាក់ទងនឹងរឿងផ្លូវភេទ។

២- ចូររៀបរាប់ពីវិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងសម្ពាធអវិជ្ជមាននិងគាំទ្រការបង្កើតមិត្តភក្តិដែលមានឥទ្ធិពលវិជ្ជមាន។

**៨- លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនគោលដៅអនាគត សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៦ : គោលដៅអនាគត

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| រៀបរាប់ពីគោលដៅ ផែនការអនាគតនិងកត្តាជួយសម្រេចគោលដៅអនាគត។ | បង្ហាញពីផែនការសម្រាប់អនុវត្តនិងកត្តាដែលជួយសម្រេចគោលដៅអនាគត។ | បណ្ដុះទម្លាប់ចេះរៀបចំផែនការដើម្បីសម្រេចគោលដៅអនាគត។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- ការកំណត់គោលដៅសម្រាប់ផែនការអនាគត៖ ការកំណត់គោលដៅ និងការធ្វើផែនការដើម្បីសម្រេចបានគោលដៅ មានសារៈសំខាន់ ចង់ឱ្យអនាគតរបស់យើងទៅជាបែបណា និងត្រូវខិតខំប្រឹងប្រែងចាប់ពីពេលឥឡូវនេះ ដើម្បីឈានទៅសម្រេចគោលដៅនោះ ត្រូវមានផែនការទៅតាមជំហានចំនួនប្រាំមួយ ៖ (១) ការកំណត់គោលដៅ, (២) ការកំណត់កាលបរិច្ឆេទគោលដៅ, (៣) ការធ្វើផែនការ, (៤)ការកំណត់រកការលំបាកនិងឧបសគ្គរាំង, (៥) ការកំណត់រកដំណោះស្រាយចំពោះការលំបាកនិងឧបសគ្គរាំង, និង (៦) ការកំណត់រកធនធានមនុស្ស និងទីកន្លែងដើម្បីទទួលបានជំនួយ។

២- កត្តាដែលជួយសម្រេចគោលដៅអនាគត៖ កត្តាដែលជួយឱ្យសម្រេចគោលដៅអនាគត មាន៖ កំណត់គោលដៅសមហេតុផលនិងអាចសម្រេចបាន, កំណត់ពេលវេលាច្បាស់លាស់និងសមស្រប, បំបែកគោលដៅធំៗឱ្យទៅជាជំហានតូចៗ, រក្សាកំណត់ត្រាអំពីវឌ្ឍនភាពនិងកែសម្រួលគោលដៅព្រមទាំងតារាងពេលវេលា ប្រសិនបើចាំបាច់, និងត្រូវចៀសវាងនិងបង្ការបញ្ហានានា។

**៥- វិធីសាស្ត្រ**

សន្លឹកកិច្ចការ ការធ្វើបទបង្ហាញ បកស្រាយ ការងារជាក្រុម ពន្យល់ សំណួរ និងចម្លើយ។

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......
៣- តើប្អូនចង់ធ្វើអ្វីទៅអនាគត?។ គ្រូហៅសិស្ស ២ ឬ ៣នាក់ឱ្យឆ្លើយ

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ការកំណត់គោលដៅនិងផែនការអនាគត**

- គ្រូពន្យល់ពីខ្លឹមសារនៃជំហានសំខាន់ៗក្នុងការកំណត់គោលដៅនិងផែនការអនាគត៖ (១) ការកំណត់គោលដៅ, (២) ការកំណត់កាលបរិច្ឆេទគោលដៅ, (៣) ការធ្វើផែនការ, (៤)ការកំណត់រកការលំបាកនិងឧបសគ្គរាំង, (៥) ការកំណត់រកដំណោះស្រាយចំពោះការលំបាកនិងឧបសគ្គរាំង, និង (៦) ការកំណត់រកធនធានមនុស្ស និងទីកន្លែងដើម្បីទទួលបានជំនួយ។
- គ្រូឱ្យសិស្សចាប់ដៃគូពិភាក្សានិងកំណត់គោលដៅនិងផែនការអនាគតម្នាក់ៗ ក្នុងរយៈពេល ៥ទៅ១០ នាទី។ គ្រូប្រាប់សិស្សថា គ្រូហៅសិស្សឱ្យឡើងបង្ហាញផែនការរបស់ដៃគូគ្នាទៅវិញទៅមក។
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសង្ខេបនិងសំយោគចម្លើយត្រឹមត្រូវដូចក្នុងខ្លឹមសារមេរៀនសៀវភៅសិស្ស។

**ចម្លើយ:** ដើម្បីឈានទៅដល់ការសម្រេចគោលដៅ ត្រូវមានផែនការទៅតាមជំហានចំនួនប្រាំមួយសំខាន់ៗ ដូចខាងក្រោម៖

- **ការកំណត់គោលដៅ:** សូមគិតពីគោលដៅមួយ ហើយគោលដៅនោះអាចជាអ្វីម៉្យាងដែលយើងសុបិន និងចង់បានសម្រេចនាពេលអនាគត។ គោលដៅនោះត្រូវសមស្របនិងសមត្ថភាពរបស់ខ្លួន អាចជាគោលដៅប្រភេទណាមួយក៏បាន ដូចជាគោលដៅក្នុងការសិក្សា ផ្ទាល់ខ្លួន ផ្នែកហិរញ្ញវត្ថុ ផ្នែកការច្នៃប្រឌិត ឬគោលដៅបែបអត្តពលកម្ម។ សូមសរសេរគោលដៅ ទាំងនោះ ហើយត្រូវមានលក្ខណៈជាក់លាក់។
- **ការកំណត់កាលបរិច្ឆេទគោលដៅ៖** តើយើងចង់សម្រេចគោលដៅរបស់យើងនៅត្រឹមពេលណា? ត្រូវប្រាកដថា កាលបរិច្ឆេទដែលយើងកំណត់នោះ ជាកាលបរិច្ឆេទដែលមានលក្ខណៈជាក់ស្តែង ។
- **ការធ្វើផែនការ:** តើត្រូវការមានជំហានអ្វីខ្លះ ដើម្បីឈានទៅដល់គោលដៅរបស់យើង? សូមបំបែកគោលដៅរបស់យើងទៅជាផ្នែកៗ។ បន្ទាប់មកសូមសរសេរជំហានទាំងនោះឱ្យបានលម្អិត ហើយយើងអាចសម្រេចចិត្តក្នុងការកំណត់កាលបរិច្ឆេទនៃគោលដៅសម្រាប់ជំហាននីមួយៗ ដើម្បីរក្សាឱ្យយើងដើរនៅលើផ្លូវត្រឹមត្រូវ។
- **ការកំណត់រកការលំបាក និងឧបសគ្គរាំង៖** តើអ្វីខ្លះដែលអាចរាំងយើងមិនឱ្យសម្រេចគោលដៅរបស់យើងបាន? សូមគិតជាមុនអំពីអ្វីដែលនឹងកើតមាន ឬអ្វីដែលអាចធ្វើឱ្យយើងមានភាពយឺតយូរ ឬអ្វីដែលអាចមករាំងផ្លូវយើង។ យើងពិតជាពុំអាចព្យាករណ៍អ្វីបានគ្រប់យ៉ាងនោះទេ។ សូមសរសេរចំណុចទាំងអស់នេះចេញមកផងដែរ។

- **ការកំណត់រកដំណោះស្រាយចំពោះការលំបាក និងឧបសគ្គរាំងទាំងនោះ** តើយើងធ្វើអ្វីបានខ្លះដើម្បីជំនះការលំបាកទាំងនេះ? សូមបង្កើតដំណោះស្រាយដើម្បីជំនះលើឧបសគ្គដែលអាចកើតមានទាំងអស់ ដែលយើងគិតឃើញ ប៉ុន្តែត្រូវមានលក្ខណៈច្នៃប្រឌិតខ្ពស់។
- **ការកំណត់រកធនធានមនុស្ស និងទីកន្លែងដើម្បីទទួលបានជំនួយៈ** តើអ្នកណា ឬមានអ្វីខ្លះដែលជួយយើងឱ្យសម្រេចគោលដៅរបស់យើងបាន? តើអ្នកណាអាចជួយលើកទឹកចិត្តយើង? តើយើងអាចទទួលបានព័ត៌មានបន្ថែមអំពីវិធី ដើម្បីទទួលបានការគាំទ្រនៅទីណា ?

**ខ្លឹមសារ : កត្តាដែលជួយសម្រេចគោលដៅអនាគត**

- គ្រូបែងចែកសិស្សជាក្រុមពិភាក្សាលើសំណួរៈ តើកត្តាដែលជួយយើងសម្រេចបានគោលដៅអនាគតមានអ្វីខ្លះ? រយៈពេល៥ទៅ១០នាទី ដោយសរសេរលទ្ធផលដាក់លើក្រដាសទុកឡើងបង្ហាញ។
- តំណាងក្រុមឡើងរាយការណ៍
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសង្ខេបនិងសំយោគចម្លើយត្រឹមត្រូវដូចក្នុងខ្លឹមសារមេរៀនសៀវភៅសិស្ស។

**ចម្លើយៈ** កត្តាដែលជួយឱ្យសម្រេចគោលដៅអនាគតមានៈ

- កំណត់គោលដៅសមហេតុផលនិងអាចសម្រេចបាន
- កំណត់ពេលវេលាច្បាស់លាស់និងសមស្រប ដើម្បីឈានទៅដល់គោលដៅបាន
- បំបែកគោលដៅធំៗឱ្យទៅជាជំហានតូចៗ និងឈានទៅសម្រេចជំហានទាំងនោះម្តងមួយៗ។
- រក្សាកំណត់ត្រាអំពីវឌ្ឍនភាពរបស់យើង និងកែសម្រួលគោលដៅ ព្រមទាំងតារាងពេលវេលាប្រសិនបើចាំបាច់។
- ត្រូវចៀសវាង និងបង្ការបញ្ហានានាដូចជា ការមានផ្ទៃពោះនៅវ័យជំទង់ ឬការផឹកគ្រឿងស្រវឹង ... ដែលអាច ធ្វើឱ្យប៉ះពាល់ដល់ផែនការរបស់អ្នក។
- សូមកុំបោះបង់គោលដៅរបស់អ្នក។

**ចំណុចគន្លឹះដែលត្រូវចងចាំៈ**

- ការកំណត់គោលដៅ គឺជាវិធីដ៏ល្អដើម្បីឱ្យគេអាចផ្តោតថាមពល និងកិច្ចខិតខំ។
- គោលដៅរយៈពេលខ្លីអាចសម្រេចបានដោយងាយស្រួលជាងគោលដៅរយៈពេលវែង។ គោលដៅរយៈពេលវែងទាមទារការធ្វើផែនការកាន់តែច្រើន។
- ត្រូវមានភាពបត់បែនក្នុងការធ្វើផែនការ ហេតុនេះប្រសិនបើមានអ្វីម៉្យាងមិនដំណើរការបានត្រឹមត្រូវទេ យើងអាចកែសម្រួលផែនការរបស់យើង ឬផ្តោតការយកចិត្តទុកដាក់លើគោលដៅមួយផ្សេងទៀត។ យើងអាចមានផែនការសម្រាប់ជាជម្រើសជំនួសបាន។
- នៅពេលយើងធំឡើង យើងកាន់តែអាចគ្រប់គ្រងជីវិតរបស់យើងបានប្រសើរឡើងថែមទៀត។
- យើងអាចកំណត់គោលដៅរបស់ខ្លួន និងខិតខំដើម្បីឱ្យឈានទៅសម្រេចបានគោលដៅនោះ។

- ប្រសិនបើយើងអាចគិតឃើញអំពីឧបសគ្គដែលអាចកើតមានឡើង យើងអាចបង្ការកុំឱ្យឧបសគ្គទាំងនោះ កើតមាន ឬធ្វើផែនការថា តើយើងនឹងធ្វើអ្វីខ្លះប្រសិនបើឧសគ្គទាំងនោះកើតមាន។

❖ គ្រូសម្របសម្រួលនិងបង្ហាញមេរៀនសង្ខេប



**មេរៀនសង្ខេប**

ការកំណត់គោលដៅ និងការធ្វើផែនការដើម្បីសម្រេចបានគោលដៅ មានសារៈសំខាន់ ចង់ឱ្យអនាគតរបស់យើងទៅជាបែបណា និងត្រូវខិតខំប្រឹងប្រែងចាប់ពីពេលឥឡូវ កត្តាដែលជួយឱ្យសម្រេចគោលដៅអនាគតមានដូចជា កំណត់គោលដៅសមហេតុផលនិងអាចសម្រេចបាន កំណត់ពេលវេលាច្បាស់លាស់និងសមស្រប បំបែកគោលដៅធំៗឱ្យទៅជាជំហានតូចៗ រក្សាកំណត់ត្រាអំពីវឌ្ឍនភាពនិងកែសម្រួលគោលដៅព្រមទាំងតារាងពេលវេលាប្រសិនបើចាំបាច់ ត្រូវចៀសវាងនិងបង្ការបញ្ហានានា៕

## ៧- ខ្សែយតម្លៃ (ជំហានទី៤)

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ចូររៀបការកំណត់គោលដៅសម្រាប់និងផែនការអនាគត

២- ចូររៀបរាប់ពីកត្តាដែលជួយសម្រេចគោលដៅអនាគត

## ៨- លំហាត់ (ជំហានទី៥)

**កិច្ចការផ្ទះ**

១- ចូរអ្នករៀបចំគោលដៅអនាគត ដោយមានជំនួយពី ឪពុក ម្តាយរបស់ប្អូន។

២- ចូរអ្នកមើលមេរៀនការស្វែងយល់ពីសុខភាពផ្លូវភេទនិងបន្តពូជ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : សិទ្ធសុខភាពផ្លូវភេទនិងបន្តពូជ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់បានពីសិទ្ធិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទទាំង១០ | • សិក្សានិងវិភាគសិទ្ធិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទទាំង១០។ | • ប្រកាន់ខ្ជាប់សិទ្ធិខ្លួនឯង និងអ្នកដទៃ។ |

**៣- សម្ភា**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

សិទ្ធិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទទាំង១០មាន៖ ១- សិទ្ធិបានទទួលការប្រព្រឹត្តដោយស្មើភាព និងដោយសេចក្តីថ្លៃថ្នូរ, ២- សិទ្ធិមិនត្រូវបានគេរើសអើងដោយហេតុផលណាមួយ, ៣- សិទ្ធិមានអារម្មណ៍សុវត្ថិភាព និងទទួលបានការការពារ, ៤- សិទ្ធិចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ជីវិត, ៥- សិទ្ធិទទួលបានឯកជនភាព និងទទួលបានការរក្សារការសម្ងាត់, ៦- សិទ្ធិរៀបអាពាហ៍ពិពាហ៍, ៧- សិទ្ធិទទួលបានព័ត៌មាន, ៨- សិទ្ធិមានសុខភាពល្អ, ៩- សិទ្ធិទទួលបានការអប់រំ, និង ១០- ចំណុចគន្លឹះដែលត្រូវចងចាំ។

**៥- វិធីសាស្ត្រ**

បំផុសគំនិត ករណីសិក្សា សំណួរ និងចម្លើយ

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖
  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............
  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......
  ៣- តើសិទ្ធិមនុស្សមានសិទ្ធិអ្វីខ្លះ?
- គ្រូហៅសិស្ស ២ ឬ ៣នាក់ឱ្យឆ្លើយ
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

## ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)

## ខ្លឹមសារ : សិទ្ធិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទទាំង១០

- គ្រូពន្យល់ពីខ្លឹមសារសំខាន់ៗសិទ្ធិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទទាំង១០។ បន្ទាប់មកគ្រូបែងចែកសិស្សជាក្រុម ពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេល៥ទៅ១០នាទី ដោយសរសេរលទ្ធផលដាក់លើក្រដាសទុកឡើងបង្ហាញ។
  - ក្រុមទី១ : តើសិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើភាពនិងដោយសេចក្តីថ្លៃថ្នូរមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី២ : តើសិទ្ធិមិនត្រូវបានគេរើសអើងដោយហេតុផលណាមួយមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី៣ : តើសិទ្ធិមានអារម្មណ៍សុវត្ថិភាព និងទទួលបានការការពារមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី៤ : តើសិទ្ធិចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ជីវិតមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី៥ : តើសិទ្ធិទទួលបានឯកជនភាព និងទទួលបានការរក្សាការសម្ងាត់មានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី៦ : តើសិទ្ធិរៀបអាពាហ៍ពិពាហ៍មានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី៧ : តើសិទ្ធិទទួលបានព័ត៌មានមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី៨ : តើសិទ្ធិមានសុខភាពល្អមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី៩ : តើសិទ្ធិទទួលបានការអប់រំអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
  - ក្រុមទី១០ : តើចំណុចគន្លឹះដែលត្រូវចងចាំមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍
- តំណាងក្រុមឡើងបង្ហាញ
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសង្ខេបនិងសំយោគចម្លើយត្រឹមត្រូវដូចក្នុងខ្លឹមសារមេរៀនសៀវភៅសិស្ស។

**ចម្លើយ:** សិទ្ធិសំខាន់ៗដែលជួយការពារសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ មានដូចជា៖

- **សិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើភាព និងដោយសេចក្តីថ្លៃថ្នូរ៖** យើងទាំងអស់សុទ្ធតែមានតម្លៃសក្តិសម ទទួលបានការគោរព និងមានសិទ្ធិដូចគ្នា តាំងតែពីកំណើតមកម្ល៉េះ។
- **សិទ្ធិមិនត្រូវបានគេរើសអើងដោយហេតុផលណាមួយ៖** យើងពុំគួរទទួលបានការប្រព្រឹត្តមកលើយើងខុសប្លែកពីអ្នកដទៃដោយសារហេតុផលណាមួយឡើយ ដូចជា ជាតិសាសន៍ ពណ៌សម្បុរ ភេទ អត្តសញ្ញាណយេនឌ័រ និន្នាការផ្លូវភេទ។ល។
- **សិទ្ធិមានអារម្មណ៍សុវត្ថិភាព និងទទួលបានការការពារ៖** សិទ្ធិនេះត្រូវបានផ្តល់ការការពារពិសេសចំពោះមុខច្បាប់ រួចផុតពីអំពើហិង្សា និងការភ័យខ្លាច។ កុមារដែលគ្មានក្រុមគ្រួសារ កុមារភៀសខ្លួនមិនឱ្យមានអំពើទារុណកម្ម ការរំលោភពាក់ព័ន្ធនិងច្បាប់ ការបង្ខំឱ្យធ្វើពលកម្ម និងប្រើប្រាស់គ្រឿង

ញៀន គ្រឿងស្រវឹង  ការថែទាំកុមារ ការធ្វើបាបផ្នែករាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ឬកេងប្រវ័ញ្ច ការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទជាដើម។

- **សិទ្ធិចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ជីវិត៖** នៅពេលមានការសម្រេចចិត្ត ត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងជីវិត  អ្នកមានសិទ្ធិចូលរួមធ្វើការសម្រេចចិត្ត ទាំងផ្នែកអារម្មណ៍ និងទស្សនៈរបស់អ្នក គួរត្រូវបានគេស្តាប់ និងយកទៅពិចារណា រាងកាយរបស់អ្នកជាកម្មសិទ្ធិរបស់អ្នក គ្មាននរណាម្នាក់មានសិទ្ធិវិនិច្ឆ័យជីវិតយើងទេ ប្រសិនបើយើងពុំយល់ព្រម។
- **សិទ្ធិទទួលបានឯកជនភាព និងទទួលបានការរក្សាការសម្ងាត់៖** ប្រសិនបើយើងប្រាប់បុគ្គលិកសុខាភិបាល ឬគ្រូបង្រៀនអំពីអ្វីម៉្យាងដែលយើងពុំចង់ឱ្យនរណាម្នាក់ផ្សេងទៀតបានដឹង ពួកគេគួរគោរពភាពឯកជនភាពរបស់អ្នក។ ប្រសិនបើអ្នកត្រូវបានគេរំលោភបំពាន អ្នកត្រូវប្រាប់អ្នកផ្សេងទៀតដែលអាចជួយ ឬការពារអ្នកមិនឱ្យជួបគ្រោះថ្នាក់បាន។
- **សិទ្ធិរៀបអាពាហ៍ពិពាហ៍៖** នៅពេលយើងមានអាយុច្រើនគ្រប់គ្រាន់តាមផ្លូវច្បាប់ និងមានគ្រួសារក្នុងអាពាហ៍ពិពាហ៍មនុស្សទាំងពីរនាក់មានសិទ្ធិដូចគ្នា។ គ្មាននរណាម្នាក់មានសិទ្ធិបង្ខំយើងឱ្យរៀបការ ឬជ្រើសរើសដៃគូសម្រាប់យើងឡើយ។ យើងអាចសម្រេចចិត្តមានកូន ឬពុំមានកូន ត្រូវមានកូនប៉ុន្មាននាក់ និងពេលណាដែលយើងចង់មានកូន។
- **សិទ្ធិទទួលបានព័ត៌មាន៖** យើងអាចសុំព័ត៌មាន ឬ ទទួលបានព័ត៌មាន និងចែករំលែកព័ត៌មានលើប្រធាន បទណាមួយ រួមទាំងប្រធានបទអំពីសុខភាព និងផ្លូវភេទផងដែរ។
- **សិទ្ធិមានសុខភាពល្អ៖** ការថែទាំសុខភាពល្អ ដែលអាចធ្វើបាន យើងអាចទៅកាន់ មន្ទីពេទ្យ ឬគ្លីនិកដើម្បីទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ មធ្យោបាយពន្យារកំណើតផ្សេងៗការប្រើស្រោមអនាម័យ និងដំបូន្មានត្រឹមត្រូវស្តីពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។
- **សិទ្ធិទទួលបានការអប់រំ៖** កុមារទាំងអស់គួរបានទៅសាលារៀន ទទួលបានពីការអប់រំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការសិក្សាអំពីរាងកាយ ការមានផ្ទៃពោះ ការពន្យារកំណើត (វិធីសាស្ត្រដើម្បីបង្ការការមានផ្ទៃពោះ) និងជំងឺកាមរោគ។ល។

ចំណុចគន្លឹះដែលត្រូវចងចាំ៖

- សិទ្ធិគឺជាអ្វីទាំងឡាយដែលមនុស្សត្រូវតែទទួលបាននិងមានសេរីភាព។
- យើងទាំងអស់គ្នាមានសិទ្ធិ សេរីភាព និងការទទួលខុសត្រូវដូចៗគ្នា។
- ស្ត្រី និងបុរសគ្រប់អាយុទាំងអស់ មានសិទ្ធិទទួលបទពិសោធន៍ផ្លូវភេទរបស់ខ្លួនក្នុងលក្ខណៈប្រកបដោយសុវត្ថិភាព សុខភាពល្អ មានការទទួលខុសត្រូវ មានការគោរព និងមានក្តីរីករាយ។
- យើងមានការទទួលលខុសត្រូវក្នុងការគោរព និងការពារសិទ្ធិរបស់ជនដទៃ។
- ពុំមាននរណាម្នាក់អាចដកហូតសិទ្ធិមនុស្សរបស់យើងបានឡើយ។

## មេរៀនសង្ខេប



សិទ្ធិមនុស្ស គឺការទទួលបានសិទ្ធិជាមូលដ្ឋាន ការការពារពីគ្រោះថ្នាក់ និងមានសេរីភាពក្នុងជីវិតរស់នៅប្រចាំថ្ងៃ មនុស្សគ្រប់រូបមានសិទ្ធិដូចៗគ្នា។ សិទ្ធិសំខាន់ៗដែលជួយការពារសុខភាពផ្លូវភេទ និងសុខភាពបន្តពូជមាន ១- សិទ្ធិបានទទួលការប្រព្រឹត្តដោយស្មើភាព និងដោយសេចក្ដីថ្លៃថ្នូរ ២- សិទ្ធិមិនត្រូវបានគេរើសអើងដោយហេតុផលណាមួយ ៣- សិទ្ធិមានអារម្មណ៍សុវត្ថិភាព និងទទួលបានការការពារ ៤- សិទ្ធិចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ជីវិត ៥- សិទ្ធិទទួលបានឯកជនភាព និងទទួលបានការរក្សាការសម្ងាត់ ៦- សិទ្ធិរៀបអាពាហ៍ពិពាហ៍ ៧- សិទ្ធិទទួលបានព័ត៌មាន ៨- សិទ្ធិមានសុខភាពល្អ ៩- សិទ្ធិទទួលបានការអប់រំនិង១០- ចំណុចគន្លឹះដែលត្រូវចងចាំ។

**៧- វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញពីសិទ្ធិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទទាំង១០។

**៨- លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនការអប់រំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការអប់រំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
| --- | --- | --- |
| -រៀបរាប់ពីនិយមន័យ"សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ<br>-ពណ៌នាពីការថែទាំសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ។ | បង្ហាញបានពីការថែទាំសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ។ | មានស្មារតីទទួលខុសត្រូវលើសុខភាពផ្លូវភេទនិងសុខភាពបន្តពូជរបស់ខ្លួន។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យ៖ **សុខភាពផ្លូវភេទ**ល្អមានន័យថា ជាការមានសុខុមាលភាពពេញលេញ ពាក់ព័ន្ធជាមួយផ្លូវភេទរបស់ខ្លួន។ **សុខភាពបន្តពូជ** គឺជាសុខុមាលភាពទាំងស្រុងទាក់ទងជាមួយការបន្តពូជ។

២- សមាសភាពសុខភាពបន្តពូជ៖ រួមមានការរក្សាសរីរាង្គបន្តពូជរបស់យើងឱ្យមានសុខភាពល្អ មានផ្ទៃពោះ រក្សាសុខភាពល្អក្នុងពេលមានផ្ទៃពោះ ពេលសម្រាល និងការរក្សាសុខភាពល្អ ចាប់ផ្តើមពីផ្ទះរបស់អ្នក។

៣- ការថែទាំសុខភាពផ្លូវភេទនិងសុខភាពបន្តពូជរួមមាន ការថែទាំសុខុមាលភាពផ្នែកផ្លូវកាយ ផ្នែកផ្លូវចិត្ត និងផ្នែកសង្គមទាក់ទងជាមួយការបន្តពូជ។

**៥- វិធីសាស្ត្រ**

បំផុសគំនិត ករណីសិក្សា សំណួរ និងចម្លើយ

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

២- តើមានអ្នកណាដឹងការអប់រំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជមានអ្វីខ្លះ?

- គ្រូហៅសិស្ស ២ ឬ៣នាក់ឱ្យឆ្លើយ
- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្ដារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យការអប់រំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ**

- គ្រូសួរសំណួរ៖ តើការអប់រំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជមានន័យដូចម្ដេច? គ្រូហៅសិស្ស ២ឬ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស : ..........
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ:** សុខភាពផ្លូវភេទល្អមានន័យថា ជាការមានសុខុមាលភាពពេញលេញ ពាក់ព័ន្ធជាមួយផ្លូវភេទរបស់ខ្លួន។ ដើម្បីមានសុខភាពផ្លូវភេទល្អ មនុស្សចាំបាច់ត្រូវមានទំនាក់ទំនងផ្លូវភេទវិជ្ជមាន និងមានការគោរពព្រមទាំងមានបទពិសោធន៍ផ្លូវភេទដែលមានសុវត្ថិភាពគួរជាទីពេញចិត្ត និងពុំមានអំពើហិង្សា។ អ្នកប្រហែលជានៅចាំថា ការបន្តពូជ គឺទាក់ទងជាមួយការមានកូន។

សុខភាពបន្តពូជ គឺជាសុខុមាលភាពទាំងស្រុងទាក់ទងជាមួយការបន្តពូជ។ សុខភាពបន្តពូជ រួមមានការរក្សាសរីរាង្គបន្តពូជរបស់យើងឱ្យមានសុខភាពល្អ មានផ្ទៃពោះ (ឬបណ្ដាលឱ្យគេមានផ្ទៃពោះ) តែនៅពេលដែលយើងចង់ឱ្យមាន រក្សាសុខភាពល្អក្នុងពេលមានផ្ទៃពោះ ពេលសម្រាល និងការរក្សាសុខភាពល្អចាប់ផ្ដើមពីផ្ទះរបស់អ្នក។

**ខ្លឹមសារ : សមាសភាពសុខភាពបន្តពូជ (សេវាសុខភាពបន្តពូជ)**

- គ្រូសួរសំណួរ៖ តើសមាសភាពសុខភាពបន្តពូជ (សេវាសុខភាពបន្តពូជ)មានអ្វីខ្លះ? គ្រូហៅសិស្ស ២ឬ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស : ...
- គ្រូកត់ត្រាចម្លើយសិស្សនិងពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសម្របសម្រួលនិងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀន

**ចម្លើយ: សមាសភាពសុខភាពបន្តពូជមាន៖**

- សុខភាពផ្លូវភេទ គឺជាសុខុមាលភាពផ្នែកផ្លូវកាយ ផ្នែកផ្លូវចិត្ត និងផ្នែកសង្គមទាក់ទងជាមួយផ្លូវភេទ។
- ដើម្បីមានសុខភាពផ្លូវភេទល្អ មនុស្សចាំបាច់ត្រូវមានទំនាក់ទំនងផ្លូវភេទជាវិជ្ជមាន និងមានការគោរពព្រមទាំងមានបទពិសោធន៍ផ្លូវភេទ ដែលមានសុវត្ថិភាព គួរជាទីពេញចិត្ត និងពុំមានអំពើហិង្សា។
- សុខភាពបន្តពូជ រួមមានការរក្សាសរីរាង្គបន្តពូជរបស់យើងឱ្យមានសុខភាពល្អ មានផ្ទៃពោះតែនៅពេលដែលយើងចង់មានផ្ទៃពោះ រក្សាសុខភាពល្អក្នុងពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាល និងត្រូវមានជីវិតផ្លូវភេទប្រកបដោយការទទួលខុសត្រូវ គួរជាទីពេញចិត្ត និងមានសុវត្ថិភាព។

**សេវាសុខភាពសម្រាប់យុវវ័យមាន ៨ ចំណុចសំខាន់ៗ (យោងតាមឯកសាររបស់អង្គការសុខភាពពិភពលោក)៖**

១- មាតុភាពគ្មានគ្រោះថ្នាក់ រួមមាន៖ ការពិនិត្យផ្ទៃពោះ ការសម្រាល ការពិនិត្យក្រោយសម្រាល និងសុខភាពទារក

២- មធ្យោបាយពន្យារកំណើត

៣- ការការពារនិងការគ្រប់គ្រងការរំលូតដែលមានបញ្ហា

៤- ការបង្ករោគតាមផ្លូវបន្តពូជ រួមមានជំងឺកាមរោគ ជំងឺអេសដ៍

៥- ការការពារនិងការគ្រប់គ្រងការមិនមានកូន (ភាពអារ)

៦- សុខភាពបន្តពូជរបស់យុវវ័យ

៧- បញ្ហាសុខភាពរបស់ស្ត្រីដែលមានវ័យចំណាស់

៨- អំពើហិង្សាផ្អែកលើយេនឌ័រ

**ខ្លឹមសារ : ការថែទាំសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ**

- គ្រូបែងចែកសិស្សជាក្រុម ពិភាក្សាលើសំណួរ៖ តើការថែទាំសុខភាពផ្លូវភេទនិងសុខភាពបន្តពូជមានអ្វីខ្លះ? រយៈពេល៥ទៅ១០នាទី ដោយសរសេរលទ្ធផលដាក់លើក្រដាសទុកឡើងបង្ហាញ។
- តំណាងក្រុមឡើងរាយការណ៍
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសង្ខេបនិងសំយោគចម្លើយត្រឹមត្រូវដូចក្នុងខ្លឹមសារមេរៀនសៀវភៅសិស្ស។

**ចម្លើយ:** ដើម្បីបង្ការបញ្ហាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ដែលអាចកើតមានអ្នកគួរយល់ដឹងនិងអនុវត្តតាមដូចខាងក្រោម៖

**ក្មេងស្រីនិងស្ត្រី៖** គួរលាងសម្អាតតែទ្វារមាស (ប្រដាប់ភេទផ្នែកខាងក្រៅ) ប៉ុណ្ណោះ។ អ្នកពុំចាំបាច់ត្រូវលាងសម្អាតរន្ធយោនីទេ ព្រោះថា រន្ធយោនីនឹងធ្វើការសម្អាតដោយខ្លួនឯង។ ការព្យាយាមលាងសម្អាត អាចបង្កឱ្យមានបញ្ហាសុខភាព។ ទឹករំអិលទ្វារមាស តាមធម្មតាពុំមានក្លិនខ្លាំងទេ ហើយពុំរមាស់ ឬក្រហាយនោះឡើយ។ ប្រសិនបើអ្នកសង្កេតឃើញមានការប្រែប្រួលមិនប្រក្រតីចំពោះទឹករំអិល ឬមានរមាស់ ឬក្រហាយ សូមទៅគ្លីនិកជំនាញនិងឯកទេស។ នៅពេលប្រើប្រាស់បង្គន់ ជានិច្ចជាកាលត្រូវជូតពីមុខទៅក្រោយ។ ការជូតពីក្រោយមកមុខ អាចនាំមេរោគចូលទៅក្នុងរន្ធបង្ហួរនោម និងរន្ធយោនី។

**ក្មេងប្រុសនិងបុរស៖** លាងសម្អាតក្បាលលិង្គ ស្បែកចុងលិង្គ និងថង់ពងស្វាស ប្រសិនបើ ពុំបានកាត់ស្បែកគ្របលិង្គទេ។ តាមធម្មតាលិង្គមិនមានការចេញទឹករំអិលទេ។ ប្រសិនបើសង្កេតឃើញមានការចេញទឹករំអិលពីលិង្គ (ក្រៅពីទឹករំអិលមុនពេលបាញ់ទឹកកាម ឬទឹកកាម) ឬមានពងទឹកផ្លូត ឬដំបៅនៅលើប្រដាប់ភេទ ឬមានការឈឺចាប់ពេលបត់ជើងតូច សូមទៅមណ្ឌលសុខភាព មន្ទីរពេទ្យ ឬគ្លីនិកឯកទេស ដើម្បីពិនិត្យ ពិគ្រោះយោបល់ និងព្យាបាល។

## សារគន្លឹះត្រូវចងចាំ

| អាយុ ១០ដល់ ១៤ឆ្នាំ | អាយុ ១៥ដល់ ១៩ឆ្នាំ | អាយុ ២០ដល់ ២៤ឆ្នាំ |
|---|---|---|
| យល់ដឹងពីព័ត៌មានទាក់ទងនឹង៖ | | |
| អនាម័យនិងការថែទាំសុខភាពបឋម | អានាម័យនិងការថែទាំសុខភាពបឋម | អានាម័យនិងការថែទាំសុខភាពបឋម |
| វីរុសអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ | ការពិភាក្សាមុនពេលរៀបការ (ផែនការគ្រួសារ) និងសុវត្ថិភាពនៃការរួមភេទ | ការពិភាក្សាមុនពេលរៀបការ (ផែនការគ្រួសារ) និងសុវត្ថិភាពនៃការរួមភេទ |
| អាហារូបត្ថម្ភ និងជំងឺស្លេកស្លាំង | អាហារូបត្ថម្ភ និងជំងឺស្លេកស្លាំង | អាហារូបត្ថម្ភ និងជំងឺស្លេកស្លាំង |
| ការការពារមហារីកមាត់ស្បូន (អាយុ៩ដល់១៣ឆ្នាំ) | ពន្យារកំណើត និងការការពារកំណើតបន្ទាន់ | ពន្យារកំណើត និងការការពារកំណើតបន្ទាន់ |
| | ការធ្វើតេស្តពិនិត្យមើល ការមានផ្ទៃពោះ | ការធ្វើតេស្តពិនិត្យមើល ការមានផ្ទៃពោះ |
| | ការថែទាំពេលមានផ្ទៃពោះនិងក្រោយសម្រាល | ការថែទាំពេលមានផ្ទៃពោះនិងក្រោយសម្រាល |
| សុខភាពផ្លូវចិត្ត | វីរុសអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ | វីរុសអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ |
| យេនឌ័រ អំពើហិង្សាផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ | ការ រលូត និងរំលូត | ការរលូត និងរំលូត |
| គ្រឿងញៀន និងស្រា | ការការពារមហារីកមាត់ស្បូននិងមហារីកដោះ | ការការពារមហារីកមាត់ស្បូននិងមហារីកដោះ |
| | សុខភាពផ្លូវចិត្ត | សុខភាពផ្លូវចិត្ត |
| | យេនឌ័រ អំពើហិង្សាផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ | យេនឌ័រ អំពើហិង្សាផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ |
| | គ្រឿងញៀន និងស្រា | គ្រឿងញៀន និងស្រា |

គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

**សុខភាពផ្លូវភេទ**ល្អមានន័យថា ជាការមានសុខុមាលភាពពេញលេញ ពាក់ព័ន្ធជាមួយផ្លូវភេទរបស់ខ្លួន។ **សុខភាពបន្តពូជ** គឺជាសុខុមាលភាពទាំងស្រុងទាក់ទងជាមួយការបន្តពូជ។ **សេវាសុខភាពសម្រាប់យុវវ័យ**មាន ការផ្តល់មាតុភាពគ្មានគ្រោះថ្នាក់ មធ្យោបាយពន្យារកំណើត ការការពារនិងការគ្រប់គ្រងការរំលូតដែលមានបញ្ហា ការបង្ករោគតាមផ្លូវបន្តពូជ ការការពារនិងការគ្រប់គ្រងការមិនមានកូន សុខភាពបន្តពូជរបស់យុវវ័យ បញ្ហាសុខភាពរបស់ស្ត្រីដែលមានវ័យចំណាស់ និងអំពើហិង្សាផ្អែកលើយេនឌ័រ។ **ការថែទាំសុខភាពផ្លូវភេទ** រួមមានអនាម័យប្រដាប់ភេទសម្រាប់យុវវ័យ។**ការថែទាំសុខភាពបន្តពូជ** គឺជាសុខុមាលភាពផ្នែកផ្លូវកាយ ផ្នែកផ្លូវចិត្ត និងផ្នែកសង្គមទាក់ទងជាមួយការបន្តពូជ។

## ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើអ្វីជាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ?

២- តើសេវាសុខភាពយុវវ័យមានអ្វីខ្លះ? ចូររៀបរាប់

៣- តើការថែទាំសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ សម្រាប់ក្មេងប្រុសនិងក្មេងស្រីមានអ្វីខ្លះ?

## ៨- **លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវពីការបង្ករោគតាមប្រព័ន្ធបន្តពូជ តាមរយៈការសាកសួរពីចាស់ទុំក្នុងគ្រួសារ សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : ការបង្ករោគតាមប្រព័ន្ធបន្តពូជ

## ខ្លឹមសារម៉ោងទី១ : និយមន័យ និងរបៀបឆ្លងការបង្ករោគតាមប្រព័ន្ធបន្តពូជ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ប្រាប់និយមន័យ" ការបង្ករោគតាមប្រព័ន្ធបន្តពូជ"<br>• ពណ៌នាពីរបៀបឆ្លងរោគតាមប្រព័ន្ធបន្តពូជ។ | • បកស្រាយពីរបៀបឆ្លងរោគតាមប្រព័ន្ធបន្តពូជ។ | • មានស្មារតីទទួលខុសត្រូវលើសុខភាពបន្តពូជរបស់ខ្លួន។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យ៖ **ការបង្ករោគតាមប្រព័ន្ធបន្តពូជ** កើតឡើង៖ (១) ឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតតាមរយៈ ការរួមភេទ, (២) តាមរយៈឧបករណ៍ពេទ្យដែលមិនមានអនាម័យនិងសម្លាប់មេរោគ, និង (៣) កើតឡើងដោយសាបាក់តេរីនៅយោនីកើនឡើងខុសប្រក្រតី។

២- របៀបឆ្លងការបង្ករោគតាមប្រព័ន្ធបន្តពូជ៖ មានតាមរយៈខាងក្រៅនិងខាងក្នុង។ ការបង្ករោគតាមប្រព័ន្ធបន្តពូជខាងក្រៅ អាចឆ្លងបានតាមរយៈ ៖ ការខ្វះអនាម័យលើប្រដាប់ភេទ ការរួមភេទជាមួយដៃគូក្រៅដែលមានជំងឺកាមរោគ ការចម្លងដោយការប៉ះពាល់ជាមួយស្បែកដែលមានជំងឺ ការប្រើប្រាស់របស់រួមជាមួយអ្នកមានជំងឺ ឆ្លងពីម្តាយទៅទារកក្នុងផ្ទៃ ឧបករណ៍ពេទ្យខ្វះការសំលាប់មេរោគ។ ការបង្ករោគតាមប្រព័ន្ធបន្តពូជខាងក្នុង គឺសំដៅទៅលើជំងឺកាមរោគ ដែលឆ្លងតាមការរួមភេទ។

**៥- វិធីសាស្ត្រ**

បំផុសគំនិត ករណីសិក្សា សំណួរ និងចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការផ្ទះពីម៉ោងមុនរួចសួរសំណួរ

៣- តើការបង្ករោគតាមប្រព័ន្ធបន្តពូជមានអ្វីខ្លះ? គ្រូហៅសិស្ស ២ឬ៣នាក់ឱ្យឆ្លើយ

- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្ដារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

- គ្រូពន្យល់ពីនិយមន័យនៃការបង្ករោគតាមប្រព័ន្ធបន្តពូជ៖ ការបង្ករោគតាមប្រព័ន្ធបន្តពូជ កើតឡើង៖ (១) ឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត តាមរយៈ ការរួមភេទ ដោយពុំប្រើស្រោមអនាម័យជាមួយដៃគូដែលមានជំងឺ, (២) តាមរយៈឧបករណ៍ពេទ្យដែលមិនមានអនាម័យនិងសម្លាប់មេរោគបានល្អ, និង (៣) កើតឡើងដោយសាបាក់តេរីនៅយោនីកើនឡើងខុសប្រក្រតី។
- គ្រូបែងចែកសិស្សជាក្រុម ពិភាក្សាសំណួរ តើរបៀបឆ្លងការបង្ករោគតាមប្រព័ន្ធបន្តពូជមានអ្វីខ្លះ? កើតឡើងដូចម្ដេច? ចូរបកស្រាយនិងឱ្យឧទាហរណ៍។ គ្រូទុករយៈពេល៥ទៅ១០នាទី ដោយសរសេរលទ្ធផលដាក់លើក្រដាសទុកឡើងបង្ហាញ។
- តំណាងក្រុមឡើងបង្ហាញ
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសង្ខេបនិងសំយោគចម្លើយត្រឹមត្រូវដូចក្នុងខ្លឹមសារមេរៀនសៀវភៅសិស្ស។

**ចម្លើយ: របៀបឆ្លងការបង្ករោគតាមប្រព័ន្ធបន្តពូជ៖** ការបង្ករោគតាមប្រព័ន្ធបន្តពូជ ខាងក្រៅ អាចឆ្លងបានតាមរយៈ

- ការខ្វះអនាម័យលើប្រដាប់ភេទ រួមបញ្ចូលទាំងរបៀបលាងពេលបន្ទោរបង់ហើយ
- ការរួមភេទជាមួយដៃគូក្រៅដែលមានជំងឺកាមរោគ ដោយមិនបានប្រើស្រោមអនាម័យ
- ការចម្លងដោយការប៉ះពាល់ជាមួយស្បែកដែលមានជំងឺ ដូចជា ដំបៅ ឬផ្លូត នៅលើប្រដាប់ភេទ ដែលជាមេរោគបង្កឱ្យមានជំងឺកាមរោគ
- ការប្រើប្រាស់របស់រួមជាមួយអ្នកមានជំងឺ ដូចជា កន្សែង ខោក្នុង
- ឆ្លងពីម្ដាយទៅទារកក្នុងផ្ទៃ នៅពេលសម្រាល និងពេលបំបៅដោះ
- ឧបករណ៍ពេទ្យខ្វះការសម្លាប់មេរោគ។
- ការបង្ករោគតាមប្រព័ន្ធបន្តពូជ ខាងក្នុង គឺសំដៅទៅលើជំងឺកាមរោគ ដែលឆ្លងតាមការរួមភេទ។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ការបង្ករោគតាមប្រព័ន្ធបន្តពូជគឺជា ការឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត តាមរយៈ ការរួមភេទ ដោយពុំប្រើស្រោមអនាម័យជាមួយដៃគូដែលមានជំងឺ ឧបករណ៍ពេទ្យដែលមិនមានអនាម័យនិងសម្លាប់មេរោគបានល្អ និងកើតឡើងដោយសាបាក់តេរីនៅយោនីកើនឡើងខុសប្រក្រតី។ **ការបង្ករោគតាមប្រព័ន្ធបន្តពូជ** មានតាមរយៈផ្នែកខាងក្រៅនិងខាងក្នុង។

### ៧- វាយតម្លៃ ( ជំហានទី៤ )

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ដូចម្តេចហៅថាការបង្ករោគតាមប្រព័ន្ធបន្តពូជ ?

២- តើរបៀបឆ្លងជំងឺកាមរោគមានអ្វីខ្លះ ?

### ៨- លំហាត់ ( ជំហានទី៥ )

**បណ្តាំផ្ញើ** : ចូរអ្នកយកចំណេះដឹងពីមេរៀននេះទៅប្រើក្នុងសកម្មភាពប្រចាំថ្ងៃ ដើម្បីការពារកុំឱ្យមានជំងឺកាមរោគ។

**កិច្ចការផ្ទះ** : ចូរអ្នកមើលមេរៀនការបង្ករោគតាមប្រព័ន្ធបន្តពូជ និងស្រាវជ្រាវពីរោគសញ្ញានិងវិធានការបង្ការរោគតាមប្រព័ន្ធបន្តពូជ តាមរយៈការសាកសួរពីចាស់ទុំក្នុងគ្រួសារឬនៅក្នុងសហគមន៍សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : ការបង្ករោគតាមប្រព័ន្ធបន្តពូជ (តចប់)

## ខ្លឹមសារម៉ោងទី២ : រោគសញ្ញា និងវិធានការបង្ការការរោគតាមប្រព័ន្ធបន្តពូជ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមានៈ

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • ពណ៌នាពី រោគសញ្ញា និងការបង្ការការបង្ករោគតាមប្រព័ន្ធបន្តពូជ។ | • បកស្រាយពីវិធានការបង្ការការបង្ករោគតាមប្រព័ន្ធបន្តពូជ។ | • មានស្មារតីទទួលខុសត្រូវលើសុខភាពបន្តពូជរបស់ខ្លួន។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- រោគសញ្ញានៃរោគតាមប្រព័ន្ធបន្តពូជ មានដូចជាៈ ដំបៅផ្លូត កន្ទួល ដុំរឹង ឡើងកូនកណ្ដុរ ឬមាស់ក្រហមនៅលើប្រដាប់ភេទ។ ការរមាស់ ឬការមានអារម្មណ៍មិនស្រួលនៅប្រដាប់ភេទ ក្រហាយ ឬឈឺនៅពេលបត់ជើង (នោម) មានសារធាតុរាវ ឬទឹករំអិលមិនប្រក្រតីចេញពីលិង្គ ឬយោនីដែលអាចមានពណ៌ស លឿង ឬបៃតង ឬអាចមានក្លិនខ្លាំង និង ហើមពងស្វាស ឬក្រពេញ។

២- វិធានការបង្ការការបង្ករោគតាមប្រព័ន្ធបន្តពូជ មានដូចជាៈ កុំឆាប់រួមភេទនៅវ័យក្មេងពេក ស្មោះត្រង់ប្ដី១ប្រពន្ធ១ ប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវគ្រប់ពេលរួមភេទជាមួយដៃគូ ធ្វើការអប់រំទៅមិត្តភ័ក្រញាតិមិត្តបន្ត។

**៥- វិធីសាស្ត្រ**

បំផុសគំនិត ករណីសិក្សា សំណួរ និងចម្លើយ ពិភាក្សាក្រុម ពន្យល់ បកស្រាយ

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុសៈ

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការផ្ទះពីម៉ោងមុនរួចសួរសំណួរ

៣- តើការបង្ករោគតាមប្រព័ន្ធបន្តពូជមានអ្វីខ្លះ? គ្រូហៅសិស្ស ២ ទៅ ៣នាក់ឱ្យឆ្លើយ

- គ្រូកត់ចម្លើយត្រឹមត្រូវដាក់លើក្តារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

- គ្រូបែងចែកសិស្សជាក្រុម ពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេល៥ទៅ១០នាទី ដោយសរសេរលទ្ធផលដាក់លើក្រដាសទុកឡើងបង្ហាញ។

  ១ : តើរោគសញ្ញានៃការបង្ករោគតាមប្រព័ន្ធបន្តពូជមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍

  ២ : តើវិធានការបង្ការនៃការបង្ករោគតាមប្រព័ន្ធបន្តពូជមានអ្វីខ្លះ? ចូរបកស្រាយនិងឱ្យឧទាហរណ៍

- តំណាងក្រុមឡើងបង្ហាញ
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសង្ខេបនិងសំយោគចម្លើយត្រឹមត្រូវដូចក្នុងខ្លឹមសារមេរៀនសៀវភៅសិស្ស។

**ចម្លើយ: រោគសញ្ញានៃការបង្ករោគតាមប្រព័ន្ធបន្តពូជមានដូចជា៖**

- ដំបៅផ្លូត កន្ទួល ដុំរឹង ឡើងកូនកណ្តុរ ឬរមាស់ក្រហមនៅលើប្រដាប់ភេទ។
- ការរមាស់ ឬការមានអារម្មណ៍មិនស្រួលនៅប្រដាប់ភេទ ក្រហាយ ឬឈឺនៅពេលបត់ជើង (នោម) មានសារធាតុរាវ ឬទឹករំអិលមិនប្រក្រតីចេញពីលិង្គ ឬយោនីដែលអាចមានពណ៌ស លឿង ឬបៃតង ឬអាចមានក្លិនខ្លាំង និង ហើមពងស្វាស ឬក្រពេញ។

**វិធានការបង្ការនៃការបង្ករោគតាមប្រព័ន្ធបន្តពូជ៖**

- កុំឆាប់រួមភេទនៅវ័យក្មេងពេក
- ស្មោះត្រង់ប្តី១ប្រពន្ធ១
- ប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវគ្រប់ពេលរួមភេទជាមួយដៃគូ
- ធ្វើការអប់រំទៅមិត្តភ័ក្រ ញាតិមិត្តបន្ត។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

**រោគសញ្ញានៃរោគតាមប្រព័ន្ធបន្តពូជ** មានដូចជា ដំបៅ កន្ទួល ដុំរឹង ឡើងកូនកណ្តុរ ឬរមាស់ក្រហមនៅលើប្រដាប់ភេទ។ **វិធានការបង្ការការបង្ករោគតាមប្រព័ន្ធបន្តពូជ មានដូចជា** កុំឆាប់រួមភេទនៅវ័យក្មេងពេក ស្មោះត្រង់ប្តី១ប្រពន្ធ១ ប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវគ្រប់ពេលរួមភេទជាមួយដៃគូ ធ្វើការអប់រំទៅមិត្តភក្តិ ញាតិមិត្តបន្ត៕

**៧- ខ្វាយតម្លៃ** ( ជំហានទី៤ )

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើជំងឺកាមរោគមានរោគសញ្ញាដូចម្តេចខ្លះ ?

២- តើវិធីបង្ការជំងឺកាមរោគមានអ្វីខ្លះ ?

**៨- សំហាត់** ( ជំហានទី៥ )

**បណ្តាំផ្ញើ** : ចូរអ្នកយកចំណេះដឹងពីមេរៀននេះទៅប្រើក្នុងសកម្មភាពប្រចាំថ្ងៃ ដើម្បីការពារកុំឱ្យមានជំងឺកាមរោគ។

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវពីមេរោគអេដស៍និងជំងឺអេដស៍ តាមរយៈការសាកសួរពីចាស់ទុំក្នុងគ្រួសារឬនៅក្នុងសហគមន៍សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៤ : មេរោគអេដស៍និងជំងឺអេដស៍

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីនិយមន័យ របៀបឆ្លង និងវិធានការបង្ការមេរោគអេដស៍ ជំងឺអេដស៍។ | • បកស្រាយពីរបៀបឆ្លងនិងវិធានការបង្ការមេរោគអេដស៍និងជំងឺអេដស៍។ | • បណ្តុះស្មារតីថែរក្សាសុខភាពបង្ការការឆ្លងមេរោគអេដស៍និងជំងឺអេដស៍។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យ

- **មេរោគអេដស៍**(HIV) ជាវីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំ (ប្រព័ន្ធការពាររាងកាយ) របស់មនុស្សចុះខ្សោយ។
- **ជំងឺអេដស៍** (AIDS) ជាបណ្តុំរោគសញ្ញាដែលកើតក្រោយពី ប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ។

២- របៀបឆ្លងមេរោគអេដស៍និងជំងឺអេដស៍៖ ការរួមភេទដោយមិនបានប្រើស្រោមអនាម័យត្រឹមត្រូវ តាមរយៈការប៉ះពាល់ឈាម (ដោយការប្រើប្រាស់ម្ជុលរួមគ្នា ឬមុតនឹងវត្ថុមុតស្រួចដទៃទៀត) និងពីម្តាយដែលមានផ្ទុកមេរោគទៅទារកក្នុងពេលមានផ្ទៃពោះ ពេលឆ្លងទន្លេ និងពេលបំបៅដោះ។

៣- វិធានការបង្ការ៖ ការមិនរួមភេទឬតមការរួមភេទ ប្រើប្រាស់ស្រោមអនាម័យឱ្យបានត្រឹមត្រូវរៀងរាល់ពេលដែលអ្នកមានការរួមភេទ ត្រូវស្មោះត្រង់ប្តីមួយប្រពន្ធមួយ មិនត្រូវប្រើប្រាស់ម្ជុលឬវត្ថុមុតស្រួចដែលមានឈាមរួមគ្នា ឬប្រើប្រាស់ម្ជុលដែលគេប្រើរួចហើយទេ៕

**៥- វិធីសាស្ត្រ**

សំណួរបំផុស សំនួរចម្លើយ ពិភាក្សាក្រុម ធ្វើការងារជាដៃគូ

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

ទំនាក់ទំនងមេរៀន (ជំហានទី២)

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុសៈ

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យស្រាវជ្រាវនៅលើកមុន?
- គ្រូហៅសិស្ស ២ ឬ ៣នាក់ឱ្យឆ្លើយ។ ចម្លើយសិស្ស
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : និយមន័យមេរោគអេដស៍និងជំងឺអេដស៍**

- គ្រូបង្ហាញរូបភាពនិងពន្យល់តើអ្វីទៅជាជំងឺជំងឺអេដស៍




ខ្លឹមសារ : និយមន័យៈ

- **មេរោគអេដស៍** (HIV = Human Immunodeficiency Virus) ជាមេរោគដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំនៃរាងកាយរបស់មនុស្សចុះខ្សោយ។ ប្រសិនបើ អ្នកផ្ទុកមេរោគអេដស៍ពុំបានទទួលការព្យាបាលទេ នោះនឹងក្លាយទៅជាអ្នកជំងឺអេដស៍។
- **ជំងឺអេដស៍** (AIDS = Acquired Immun Deficency Symdrome) គឺជាបណ្តុំរោគសញ្ញាដែលកើតឡើងក្រោយពីប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ។

ខ្លឹមសារ : របៀបឆ្លងមេរោគអេដស៍និងជំងឺអេដស៍និងវិធានការបង្ការ

- គ្រូចែកសិស្សជាក្រុមពិភាក្សាលើសំណួរខាងក្រោម រយៈពេល៥ ទៅ១០នាទី៖
  - ១- តើរបៀបឆ្លងមេរោគអេដស៍និងជំងឺអេដស៍កើតឡើងដូចម្ដេចខ្លះ ?
  - ២- ចូររៀបរាប់ពីវិធានការបង្ការនៃការឆ្លងមេរោគអេដស៍និងជំងឺអេដស៍
- តំណាងក្រុមឡើងបង្ហាញលទ្ធផល
- គ្រូសម្របសម្រួល សំយោគចម្លើយ និងសង្ខេបតាមខ្លឹមសារនៃមេរៀន ។

**ចម្លើយ**

**របៀបឆ្លងមេរោគអេដស៍និងជំងឺអេដស៍មាន៖**

**ក. ការរួមភេទ៖** ជាមួយដៃគូតាមយោនីឬតាមរន្ធគូថ ដែលមានផ្ទុកមេរោគអេដស៍ ដោយពុំបានប្រើស្រោមអនាម័យឬប្រើមិនបានត្រឹមត្រូវ។

**ខ. ឈាម៖** ការប៉ះពាល់ឈាមនិងទឹករងៃដោយផ្ទាល់របស់អ្នកផ្ទុកមេរោគអេដស៍ តាម រយៈការប្រើប្រាស់សម្ភារៈមុតស្រួច ទម្លុះស្បែករួមគ្នា ឧទាហរណ៍៖ ម្ជុលប្រើរួចហើយយកទៅចាក់ ឬយកទៅសាក់ ឬឡាមដែលប្រើរួច។

**គ. ពីម្ដាយទៅកូន៖** មេរោគអេដស៍អាចឆ្លងពីម្ដាយទៅកូនក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល និងពេលបំបៅដោះ។



វិធីដែលមេរោគអេដស៍ឆ្លងច្រើនជាងគេបំផុត គឺតាមរយៈការរួមភេទដោយមិនប្រើស្រោមអនាម័យ។ មេរោគអេដស៍ពុំឆ្លងតាមរយៈទំនាក់ទំនងសង្គម ដូចជា ការរស់នៅក្នុងផ្ទះជាមួយគ្នា ការកាន់ដៃគ្នា ការឱប ការថើបថ្ពាល់ ការប្រើប្រាស់បង្គន់រួមគ្នា ការហែលទឹកនៅអាងជាមួយគ្នា ការញ៉ាំអាហារ និងភេសជ្ជៈជាមួយគ្នា ការប្រើប្រាស់សម្លៀកបំពាក់ជាមួយគ្នា ការកណ្ដាស់ និងក្អក ឬតាមរយៈមូសខាំឡើយ។ សកម្មភាពទាំងអស់នេះពុំចម្លងមេរោគអេដស៍ឡើយ ព្រោះនៅពេលអ្នកធ្វើសកម្មភាពទាំងនេះ ពុំមានសារធាតុរាវនៃរាងកាយណាមួយក្នុងចំណោមសារធាតុរាវទាំង ៥ ដែលមានផ្ទុកមេរោគអេដស៍នៅក្នុងនោះ អាចចូលទៅក្នុងខ្លួនអ្នកបានឡើយ។

**វិធានការបង្ការ៖** ដើម្បីចៀសវាងកុំឱ្យកើតជំងឺអេដស៍ អ្នកចាំបាច់ត្រូវបង្ការកុំឱ្យសារធាតុរាវនៃរាងកាយដែលមានមេរោគអេដស៍នៅក្នុងនោះអាចចូលមកក្នុងខ្លួនអ្នកបាន។ អ្នកអាចការពារខ្លួនអ្នកតាមរយៈ៖

- ត្រូវស្មោះត្រង់ប្ដីមួយប្រពន្ធមួយ
- ប្រសិនបើអ្នករួមភេទ ត្រូវប្រើស្រោមអនាម័យឱ្យបានត្រឹមត្រូវរៀងរាល់ពេលដែលអ្នករួមភេទ
- មិនត្រូវប្រើប្រាស់ម្ជុលឬវត្ថុមុតស្រួចដែលមានឈាមរួមគ្នា ឬប្រើប្រាស់ម្ជុលដែលគេប្រើរួចហើយទេ
- ប្រសិនបើមានចំណង់ផ្លូវភេទ អាចប្រើប្រាស់វិធីសម្រេចកាមដោយខ្លួនឯង។

**ចំណាំ៖**មានតែការធ្វើ តេស្តឈាមតាមក្បួនវេជ្ជសាស្ត្រទេ ទើបដឹងថាមានឬគ្មានផ្ទុកមេរោគអេដស៍។





**មេរៀនសង្ខេប**

**មេរោគអេដស៍**(HIV) ជាវីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំ(ប្រព័ន្ធការ ពាររាងកាយ)របស់មនុស្សចុះខ្សោយ។ **ជំងឺអេដស៍** (AIDS) ជាបណ្តុំរោគសញ្ញាដែលកើតក្រោយពី ប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ។ **មេរោគអេដស៍ចម្លងតាមរយៈ៖** ការរួមភេទដោយមិនបានប្រើស្រោមអនាម័យត្រឹមត្រូវ ប៉ះពាល់ឈាម និងពីម្តាយទៅកូន (ពេលមានផ្ទៃពោះ ពេលឆ្លងទន្លេ និងពេលបំបៅដោះ)។ **យើងអាចបង្ការមេរោគអេដស៍បានតាមរយៈ** ការមិនរួមភេទ ប្រើប្រាស់ស្រោមអនាម័យឱ្យបានត្រឹមត្រូវ ត្រូវស្មោះត្រង់ប្តីមួយប្រពន្ធមួយ មិនត្រូវប្រើប្រាស់ម្ជុលឬវត្ថុមុតស្រួចដែលមានឈាមរួមគ្នា ឬប្រើប្រាស់ម្ជុលដែលគេប្រើរួចហើយទេ៕

## ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូសួរសំណួរឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- ចូររៀបរាប់ពីនិយមន័យមេរោគអេដស៍ និងជំងឺអេដស៍?

២- តើមេរោគអេដស៍ចម្លងតាមរយៈអ្វីខ្លះ?

៣- តើការបង្ការមេរោគអេដស៍មានអ្វីខ្លះ?

៤- តើអ្នកមានវិធានការអ្វីខ្លះ ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍?

## ៨- **លំហាត់** (ជំហានទី៥)

**កិច្ចការផ្ទះ៖**

១. ចូរអ្នកស្រាវជ្រាវពីវិធានការសង្គ្រោះបឋមសម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

២. ចូរអ្នកមើលមេរៀនវិធានការសង្គ្រោះបឋម សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : វិធានការសង្គ្រោះបឋម

## ខ្លឹមសារម៉ោងទី១ : និយមន័យ និងគោលបំណងនៃការសង្គ្រោះបឋម

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| រៀបរាប់ពីនិយមន័យ គោលបំណងនៃការសង្គ្រោះបឋម។ | មានបំណិនងាយៗក្នុងការសង្គ្រោះបឋមពេលមានការចាំបាច់។ | យកចិត្តទុកដាក់ស្វែងយល់ពីជំនាញសង្គ្រោះបឋមងាយៗ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- និយមន័យ៖ ការសង្គ្រោះបឋម គឺជាការជួយដំបូងនិងបន្ទាន់ដល់ជនរងគ្រោះ ដើម្បីរក្សាជនរងគ្រោះឱ្យមានជីវិតនិងការពារកុំឱ្យស្ថានភាពជំងឺ ឬរបួសកាន់តែធ្ងន់ មុននឹងបញ្ជូនទៅរកសេវាវេជ្ជសាស្ត្រត្រឹមត្រូវ

២- គោលបំណងនៃការសង្គ្រោះបឋម៖ ដើម្បីសង្គ្រោះជីវិត បង្ការកុំឱ្យរបួសកាន់តែធ្ងន់ធ្ងរថែមទៀត ឱ្យជនរងគ្រោះមានអារម្មណ៍ធូរស្រាល រក្សាភាពរឹងមាំ និងកាត់បន្ថយភាពឈឺចាប់ និង ដើម្បីឱ្យជនរងគ្រោះអាចទទួលបាននូវការថែទាំផ្នែកវេជ្ជសាស្ត្របានយ៉ាងឆាប់រហ័ស ។

**៥- វិធីសាស្ត្រ**

សំណួរបំផុស សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ ( ជំហានទី១ )**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន ( ជំហានទី២ )**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : .............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? ចម្លើយសិស្ស : ......
- គ្រូទុកពេល២នាទីឱ្យសិស្សគិត រួចហៅសិស្ស ២ ឬ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្ដារខៀន
- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី ( ជំហានទី៣ )**

**ខ្លឹមសារ : និយមន័យ**

- គ្រូសួរសំណួរ៖ តើវិធានការសង្គ្រោះបឋមមានន័យដូចម្ដេច? ទុកពេលឱ្យសិស្សគិតក្នុងរយៈពេលពី ២ ទៅ ៣នាទី រួចគ្រូហៅសិស្ស ២ ឬ ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស:....
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ** : ការសង្គ្រោះបឋម គឺជាការជួយដំបូងនិងបន្ទាន់ដល់ជនរងគ្រោះ ដើម្បីរក្សាជនរងគ្រោះឱ្យមានជីវិត និងការពារកុំឱ្យស្ថានភាពជំងឺ ឬរបួសកាន់តែធ្ងន់ មុននឹងបញ្ជូនទៅរកសេវាវេជ្ជសាស្ត្រត្រឹមត្រូវ។

**ខ្លឹមសារ : គោលបំណងនៃការសង្គ្រោះបឋម**

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរ តើគោលបំណងនៃការសង្គ្រោះបឋម មានអ្វីខ្លះ? រយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។
- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ** : គោលបំណងនៃការសង្គ្រោះបឋមគឺ៖

  - ដើម្បីសង្គ្រោះជីវិត
  - ដើម្បីបង្ការកុំឱ្យរបួសកាន់តែធ្ងន់ធ្ងរថែមទៀត
  - ដើម្បីឱ្យជនរងគ្រោះមានអារម្មណ៍ធូរស្រាល រក្សាភាពរឹងមាំ និងកាត់បន្ថយភាពឈឺចាប់
  - ដើម្បីឱ្យជនរងគ្រោះអាចទទួលបាននូវការថែទាំផ្នែកវេជ្ជសាស្ត្របានយ៉ាងឆាប់រហ័ស ។

❖ គ្រូសម្របសម្រួលនិងបង្ហាញមេរៀនសង្ខេប



**មេរៀនសង្ខេប**

**ការសង្គ្រោះបឋម** គឺជាការជួយដំបូងនិងបន្ទាន់ដល់ជនរងគ្រោះ ដើម្បីរក្សាជនរងគ្រោះឱ្យមានជីវិតនិងកាពារកុំឱ្យស្ថានភាពជំងឺ ឬរបួសកាន់តែធ្ងន់ មុននឹងបញ្ជូនទៅរកសេវាវេជ្ជសាស្ត្រត្រឹមត្រូវ។ **គោលបំណងនៃការសង្គ្រោះបឋម** គឺដើម្បីសង្គ្រោះជីវិត

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើការសង្គ្រោះបឋមមានន័យដូចម្ដេច?

២- តើគោលបំណងនៃការសង្គ្រោះបឋមមានអ្វីខ្លះ?

**៨- លំហាត់** ( ជំហានទី៥ )

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវពីវិធីសង្គ្រោះបឋមតាមរយៈការសួរពីឪពុកម្ដាយនិងបងប្អូន ? គ្រូនឹងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : វិធានការសង្គ្រោះបឋម (ត)

## ខ្លឹមសារម៉ោងទី២ : វិធីសង្គ្រោះបឋម( ការមុតនិងរបួសតិចតួច និងវិធីសង្គ្រោះការរលាក ការឈាមច្រមុះ និងការស្លាក់អាហារ។)

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| រៀបរាប់ពីវិធីសង្គ្រោះបឋមរួមមានការមុតនិងរបួសតិចតួច វិធីសង្គ្រោះការរលាកនិងការឈាមច្រមុះ ការស្លាក់។ | មានបំណិនងាយៗក្នុងការសង្គ្រោះបឋមពេលមានការចាំបាច់ ទៅតាមវិធីសាស្ត្រត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ | យកចិត្តទុកដាក់ស្វែងយល់ពីជំនាញសង្គ្រោះបឋមងាយៗ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀននេះ។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១. វិធីសង្គ្រោះបឋម៖

- វិធីសង្គ្រោះការមុតនិងរបួសតិចតួច៖ អ្នកសង្គ្រោះត្រូវលាងដៃនឹងសាប៊ូមុននឹងប៉ះពាល់មុខរបួសលាងរបួសនឹងទឹកសាប៊ូ ឬទឹកស្អាត ឬទឹកថ្នាំសម្លាប់មេរោគ (បេតាឌីន) ធ្វើការរុំរបួស។
- វិធីសង្គ្រោះការរលាក៖ ត្រូវយកជនរងគ្រោះចេញពីកន្លែងកើតហេតុ ត្រាំទឹកត្រជាក់ឬស្ដំ ប្រសិនបើផ្ទៃរលាកមានទំហំតូច បើរលាកឡើងពងទឹកត្រូវលាងជាមួយនឹងសាប៊ូជូតឱ្យស្អាតរួចរុំវាទុកក្នុងរយៈពេលមួយសប្តាហ៍។ ប្រសិនបើមានធុំក្លិនស្អុយ ឬមានហូរទឹកត្រូវលាងជាមួយទឹកអំបិលក្តៅអ៊ុនៗ រួចទុករបួសឱ្យចំហរធ្វើយ៉ាងណា កុំឱ្យរុយរោម។
- វិធីសង្គ្រោះការឈាមច្រមុះ៖ ឱ្យអ្នករបួសអង្គុយចុះ ហើយឱ្យច្របាច់រន្ធច្រមុះជាប់ឱនខ្លួនទៅមុខ ហើយដកដង្ហើមតាមមាត់ អ្នករបួសត្រូវនៅក្នុងលក្ខណៈនេះ ១០ នាទី ។ ប្រាប់ឱ្យអ្នករបួសខ្ពុរទឹក ឬឈាមចេញតាមមាត់។
- **វិធីសង្គ្រោះការស្លាក់អាហារ៖** យកកំទេចកំទីចេញពីមាត់ ជម្រុញឱ្យជនរងគ្រោះក្អក ឱនក្បាលទៅមុខ ហើយត្រូវតប់ថ្មមៗលើចន្លោះឆ្អឹងស្លាប្រចៀវ ដោយប្រើគល់បាតដៃចំនួន ៥ដង គួរតប់ល្មមៗដែលអាចនាំឱ្យជនរងគ្រោះក្អកចេញមកវិញនូវវត្ថុដែលស្ទះនោះ។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ សំណួរបំផុស ពិភាក្សាក្រុម បកស្រាយ ពន្យល់

## ៦- សកម្មភាពបង្រៀននិងរៀន

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន។ គ្រូហៅសិស្ស ២ឬ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្តារខៀន។

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : វិធីសង្គ្រោះការមុតនិងរបួសតិចតួច**

- គ្រូឱ្យសិស្សចាប់ដៃគូ២ៗនាក់ ពិភាក្សាសំណួរ តើវិធីសង្គ្រោះការមុតនិងរបួសតិចតួចមានអ្វីខ្លះ? រយៈពេលពី ៣ ទៅ ៥នាទី។ បន្ទាប់មកគ្រូហៅតំណាងសិស្ស ២ឬ៣គូឱ្យអនុវត្តសាកល្បង។ គ្រូណែនាំសិស្សដែលត្រូវឆ្លើយបន្ទាប់ បន្ថែមលើចម្លើយអ្នកមុនឬអ្វីដែលថ្មី
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :**

- អ្នកសង្គ្រោះត្រូវលាងដៃនឹងសាប៊ូមុននឹងប៉ះពាល់មុខរបួស
- លាងរបួសនឹងទឹកសាប៊ូ ឬទឹកស្អាតដោយប្រើស្បៃស្អាតគ្មានមេរោគសម្អាតពីខាងក្នុងចេញមកក្រៅ
- លាងរបួសនឹងទឹកថ្នាំសម្លាប់មេរោគ (បេតាឌីន)
- ធ្វើការរុំរបួសជាមួយនឹងស្បៃរុំរបួសដែលគ្មានមេរោគមានសភាពទន់ មានទំហំធំល្មមដែលអាចរុំជុំវិញមុខរបួសបានត្រឹមត្រូវ ឬបិទមុខរបួសតូចដោយប្រើបង់ស្អិត
- ប្រសិនបើជនរងគ្រោះមិនទាន់បានចាក់ថ្នាំតេតាណូសត្រូវប្រាប់ជនរងគ្រោះឱ្យទៅមណ្ឌលសុខភាព ដើម្បីចាក់ថ្នាំ
- ដុត ឬកប់កាកសំណល់ រួចត្រូវលាងដៃនឹងសាប៊ូ។

**ខ្លឹមសារ : វិធីសង្គ្រោះការរលាក ការឈាមច្រមុះ និងការស្លាក់អាហារ**

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។

  ១. តើវិធីសង្គ្រោះការរលាកមានអ្វីខ្លះ? ចូររៀបរាប់។

  ២. តើវិធីសង្គ្រោះការឈាមច្រមុះមានអ្វីខ្លះ? ចូររៀបរាប់។

  ៣. តើវិធីសង្គ្រោះការស្លាក់អាហារមានអ្វីខ្លះ? ចូររៀបរាប់។

- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម

- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :**

វិធីសង្គ្រោះការរលាក៖ ត្រូវយកជនរងគ្រោះចេញពីកន្លែងកើតហេតុ ត្រាំទឹកត្រជាក់ឬស្ពំ ប្រសិនបើផ្ទៃរលាកមានទំហំតូច៖បើរលាកឡើងពងទឹកត្រូវលាងជាមួយនឹងសាប៊ូជូតឱ្យស្អាតរួចរុំវាទុកក្នុងរយៈពេលមួយសប្ដាហ៍។ ប្រសិនបើមានធុំក្លិនស្អុយ ឬមានហូរទឹកត្រូវលាងជាមួយទឹកអំបិលក្ដៅអ៊ុនៗ រួចទុករបួសឱ្យចំហរធ្វើយ៉ាងណាកុំឱ្យរុយរោម។ ប្រសិនបើផ្ទៃរលាកមានទំហំធំ៖ ត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាពជាដំបូងត្រូវ៖ ដាក់ជនរងគ្រោះឱ្យដេក គ្របផ្នែករលាកដោយកំណាត់ស្អាត និងឱ្យផឹកទឹកបានច្រើន។

វិធីសង្គ្រោះការឈាមច្រមុះ៖ ឱ្យអ្នករបួសអង្គុយចុះ ហើយឱ្យច្របាច់រន្ធច្រមុះជាប់ឱនខ្លួនទៅមុខ ហើយដកដង្ហើមតាមមាត់ អ្នករបួសត្រូវនៅក្នុងលក្ខណៈនេះ ១០ នាទី ។ ប្រាប់ឱ្យអ្នករបួសខ្ពុរទឹក ឬឈាមចេញតាមមាត់។ ក្រោយពីជាហើយ ណែនាំឱ្យជនរងគ្រោះចៀសវាងការប៉ះទង្គិចច្រមុះ ២ ទៅ ៣ ម៉ោង។ បើឈាមហូរមិនឈប់ គួរបញ្ជូនទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យ ។

វិធីសង្គ្រោះការស្លាក់អាហារ៖ យកកំទេចកំទីចេញពីមាត់ ជម្រុញឱ្យជនរងគ្រោះក្អក ឱនក្បាលទៅមុខ ហើយត្រូវតប់ថ្នមៗលើចន្លោះឆ្អឹងស្លាបប្រចៀវ ដោយប្រើគល់បាតដៃចំនួន ៥ដង គួរតប់ល្មមៗដែលអាចនាំឱ្យជនរងគ្រោះក្អកចេញមកវិញនូវវត្ថុដែលស្ទះនោះ។ ត្រូវប្រាប់ឬបញ្ជូនដំណឹងទៅអ្នកជួយដែលអាចសង្គ្រោះបាន។

❖ គ្រូសម្របសម្រួលនិងបង្ហាញមេរៀនសង្ខេប



**វិធីសង្គ្រោះការមុតនិងរបួសតិចតួច៖** អ្នកសង្គ្រោះត្រូវលាងដៃនឹងសាប៊ូមុននឹងប៉ះពាល់មុខរបួសលាងរបួសនឹងទឹកសាប៊ូ ឬទឹកស្អាត ឬទឹកថ្នាំសម្លាប់មេរោគ (បេតាឌីន) ធ្វើការរុំរបួស។ **វិធីសង្គ្រោះការរលាក**

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើវិធីសង្គ្រោះការមុតនិងរបួសតិចតួចមានអ្វីខ្លះ ?

២- តើវិធីសង្គ្រោះការរលាកមានអ្វីខ្លះ ?

៣- តើវិធីសង្គ្រោះការឈាមច្រមុះមានអ្វីខ្លះ ?

៤- តើវិធីសង្គ្រោះការស្លាក់អាហារមានអ្វីខ្លះ ?

## ៨- លំហាត់ (ជំហានទី៥)

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវពីវិធីសង្គ្រោះឈឺក្បាល វិធីសង្គ្រោះឈឺធ្មេញ វិធីសង្គ្រោះឈឺរាករូស វិធីសង្គ្រោះសត្វល្អិតទិចឬខាំ តាមរយៈការសួរពីឪពុកម្តាយនិងបងប្អូន ? គ្រូនឹងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ១ : វិធានការសង្គ្រោះបឋម (តចប់)

## ខ្លឹមសារម៉ោងទី៣ : វិធីសង្គ្រោះឈឺក្បាល វិធីសង្គ្រោះឈឺធ្មេញ វិធីសង្គ្រោះឈឺរាករូស វិធីសង្គ្រោះសត្វល្អិតទិចឬខាំ

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| • រៀបរាប់ពីវិធីសង្គ្រោះឈឺក្បាល វិធីសង្គ្រោះឈឺធ្មេញ វិធីសង្គ្រោះឈឺរាករូស វិធីសង្គ្រោះសត្វល្អិតទិចឬខាំ។ | • មានបំណិនងាយៗក្នុងការសង្គ្រោះបឋមពេលមានការចាំបាច់ទៅតាមវិធីសាស្ត្រត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ | • យកចិត្តទុកដាក់ស្វែងយល់ពីជំនាញសង្គ្រោះបឋមងាយៗ។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

វិធីសង្គ្រោះឈឺក្បាល៖ យកកំណាត់ត្រជាក់ដាក់នៅលើក្បាលនិងត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ដើម្បីពិនិត្យព្យាបាល។

វិធីសង្គ្រោះឈឺធ្មេញ៖ ស្ពំទឹកក្តៅដែលទ្រាប់កំណាត់កន្លែងឈឺ មិនត្រូវញាំុអាហារដែលក្តៅ ឬត្រជាក់ពេកទេ។ ក្នុងករណីហើមជុំវិញ ឬសធ្មេញ អញ្ចាញ ហើមមុខ ក្តៅខ្លួន ត្រូវទៅពិនិត្យនិងពិភាក្សាជាមួយទន្តពេទ្យ។ ត្រូវដុសធ្មេញឱ្យបានរៀងរាល់ថ្ងៃ ដើម្បីកាត់បន្ថយរោគពុកធ្មេញ និងជំងឺអញ្ចាញធ្មេញ។

វិធីសង្គ្រោះឈឺរាករូស៖ ត្រូវញាំុទឹកឱ្យបានច្រើន ឱ្យបាន១.៥លីត្រ ទៅ២លីត្រ ក្នុងមួយថ្ងៃ ញាំុទឹកអូរ៉ាលីត (មួយកញ្ចប់លាយទឹក១លីត្រ) យកអំបិលមួយស្លាបព្រាបាយស្មើលាយទឹកមួយលីត្រ។ បើអ្នកជំងឺឃ្លានត្រូវឱ្យអាហារដែលងាយរំលាយរក្សាអនាម័យឱ្យបានល្អ។

វិធីសង្គ្រោះសត្វល្អិតទិចឬខាំ៖ ប្រសិនបើមានទ្រនិចកប់ជាប់ក្នុងស្បែក ហាមច្របាច់ចង់ពិស ប្រើទឹកកកស្ពំ និងដកយកទ្រនិចចេញ ប្រសិនបើជនរងគ្រោះពិបាកដកដង្ហើម ដាក់ជនរងគ្រោះក្នុងដំណេកដូចក្នុងរូបភាព។ ប្រសិនបើចាំបាច់ត្រូវបញ្ជូនអ្នករងគ្រោះទៅកាន់មន្ទីរពេទ្យ។

**៥- វិធីសាស្ត្រ**

សំណួរបំផុស សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្ដាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំលឹកមេរៀន ឬកែកិច្ចការផ្ទះ ឬសួរសំណួរបំផុស៖

  ១- តើនៅលើកមុនអ្នកបានរៀន មេរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............

  ២- តើមានអ្នកណាខ្លះបានធ្វើសំណួរកិច្ចការផ្ទះ គ្រូដាក់ឱ្យនៅលើកមុន? គ្រូប្រមូលកិច្ចការស្រាវជ្រាវពីម៉ោងមុន។ គ្រូហៅសិស្ស ២ ឬ ៣នាក់ឱ្យឆ្លើយ គ្រូកត់ពាក្យគន្លឹះដាក់លើក្ដារខៀន។

- គ្រូសរសេរចំណងជើងដាក់លើក្ដារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : វិធីសង្គ្រោះឈឺក្បាល វិធីសង្គ្រោះឈឺធ្មេញ វិធីសង្គ្រោះឈឺរាករូស វិធីសង្គ្រោះសត្វល្អិតទិចឬខាំ**

- គ្រូចែកសិស្សជាក្រុមពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៥ ទៅ ១០នាទី ដោយមានអ្នកសម្របសម្រួលម្នាក់ អ្នកកត់ត្រាម្នាក់ និងអ្នកឡើងរាយការណ៍ម្នាក់។

  ១. តើវិធីសង្គ្រោះឈឺក្បាលមានអ្វីខ្លះ? ចូររៀបរាប់។

  ២. តើវិធីសង្គ្រោះឈឺធ្មេញមានអ្វីខ្លះ? ចូររៀបរាប់។

  ៣. តើវិធីសង្គ្រោះឈឺរាករូសមានអ្វីខ្លះ? ចូររៀបរាប់។

  ៤. តើវិធីសង្គ្រោះសត្វល្អិតទិចឬខាំមានអ្វីខ្លះ? ចូររៀបរាប់។

- តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សាក្រុម
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្ដារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ :**

- វិធីសង្គ្រោះឈឺក្បាល៖ យកកំណាត់ត្រជាក់ដាក់នៅលើក្បាលនិងត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ដើម្បីពិនិត្យព្យាបាល។
- វិធីសង្គ្រោះឈឺធ្មេញ៖ ស្ពំទឹកក្ដៅដែលទ្រាប់កំណាត់កន្លែងឈឺ មិនត្រូវញ៉ាំអាហារដែលក្ដៅ ឬត្រជាក់ពេកទេ។ ក្នុងករណីហើមជុំវិញ ឬសធ្មេញ អញ្ចាញ ហើមមុខ ក្ដៅខ្លួន ត្រូវទៅពិនិត្យនិងពិភាក្សាជាមួយទន្តពេទ្យ។ ត្រូវដុសធ្មេញឱ្យបានរៀងរាល់ថ្ងៃ ដើម្បីកាត់បន្ថយរោគពុកធ្មេញ និងជំងឺអញ្ចាញធ្មេញ។
- វិធីសង្គ្រោះឈឺរាករូស៖ ត្រូវញ៉ាំទឹកឱ្យបានច្រើន ឱ្យបាន១.៥លីត្រ ទៅ២លីត្រ ក្នុងមួយថ្ងៃ ញ៉ាំទឹកអូរ៉ាលីត (មួយកញ្ចប់លាយទឹក១លីត្រ) យកអំបិលមួយស្លាបព្រាបាយស្មើលាយទឹកមួយលីត្រ។ បើអ្នកជំងឺឃ្លានត្រូវឱ្យអាហារដែលងាយរំលាយរក្សាអនាម័យឱ្យបានល្អ។
- វិធីសង្គ្រោះសត្វល្អិតទិចឬខាំ៖ ប្រសិនបើមានទ្រនិចកប់ជាប់ក្នុងស្បែក ហាមច្របាច់ចង់ពិស ប្រើទឹកកកស្អំ និងដកយកទ្រនិចចេញ ប្រសិនបើជនរងគ្រោះពិបាកដកដង្ហើម ដាក់ជនរងគ្រោះក្នុងដំណេកដូចខាងលើ។ ប្រសិនបើចាំបាច់ត្រូវបញ្ជូនអ្នករងគ្រោះទៅកាន់មន្ទីរពេទ្យ។

❖ គ្រូសម្របសម្រួលនិងបង្ហាញមេរៀនសង្ខេប



**មេរៀនសង្ខេប**

**វិធីសង្គ្រោះឈឺក្បាល** យកកំណាត់ត្រជាក់នៅលើក្បាលនិងត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ដើម្បីពិនិត្យព្យាបាល។ **វិធីសង្គ្រោះឈឺធ្មេញ** ស្អំទឹកក្តៅដែលទ្រាប់កំណាត់កន្លែងឈឺ មិនត្រូវញុំាអាហារដែលក្តៅ ឬត្រជាក់ពេកទេ។ **វិធីសង្គ្រោះឈឺរាករូស** ត្រូវញុំាទឹកឱ្យបានច្រើន ឱ្យបាន១.៥លីត្រ ទៅ២លីត្រ ក្នុងមួយថ្ងៃ ញុំាទឹកអូរ៉ាលីត។ **វិធីសង្គ្រោះសត្វល្អិតទិចឬខាំ**

**៧- វាយតម្លៃ** ( ជំហានទី៤ )

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើវិធីសង្គ្រោះឈឺក្បាលមានអ្វីខ្លះ ?

២- តើវិធីសង្គ្រោះឈឺធ្មេញមានអ្វីខ្លះ ?

៣- តើវិធីសង្គ្រោះឈឺរាករូសមានអ្វីខ្លះ ?

៤- តើវិធីសង្គ្រោះសត្វល្អិតទិចឬខាំមានអ្វីខ្លះ ?

**៨- លំហាត់** ( ជំហានទី៥ )

**កិច្ចការផ្ទះ** : ចូរអ្នកស្រាវជ្រាវពីការបំពុលខ្យល់និងផលប៉ះពាល់សុខភាព តាមរយៈការសួរពីឪពុកម្តាយ និងបងប្អូន ? គ្រូនឹងប្រមូលចម្លើយនៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ២ : ការបំពុលខ្យល់ និងផលប៉ះពាល់សុខភាព

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ពណ៌នាពីមូលហេតុ និងផលប៉ះពាល់សុខភាព និងវិធានការកាត់បន្ថយការបំពុលខ្យល់។ | - បកស្រាយពីមូលហេតុ ផលប៉ះពាល់សុខភាព និងវិធានការកាត់បន្ថយការបំពុលខ្យល់។ | - យកចិត្តទុកដាក់ចូលរួមកាត់បន្ថយការបំពុលខ្យល់។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- ប្រភពនៃការបំពុលខ្យល់ ការបំពុលខ្យល់មានការបំពុលនៅក្នុងនិងក្រៅផ្ទះ។ ប្រភពចម្បងៗនៃការបំពុលខ្យល់ គឺមកពីចំហេះឥន្ធនៈផូស៊ីល ការដុតជីវម៉ាស និងការដុតកាកសំណល់នៅតាមលំនៅឋាន។

ការបំពុលខ្យល់នៅក្នុងលំនៅឋាន អាចកើតឡើងពីការប្រើចង្ក្រានអុស ធ្យូងសម្រាប់ការដាំស្ល ផ្សែងបារី ផ្សែងធូប ដែលបង្កជាផ្សែងហុយនៅក្នុងផ្ទះ។

ការបំពុលខ្យល់នៅក្រៅផ្ទះ៖ កើតឡើងដោយសារផ្សែងម៉ូតូ រថយន្ត រថភ្លើង រោងចក្រ ការដុតសំរាមនៅទីវាល ក្លិនលាមកមនុស្សនិងសត្វដែលមិនបានជីកកប់ ឬទុកដាក់បានល្អ។ល។

២- ផលប៉ះពាល់ដល់សុខភាពពីការបំពុលខ្យល់ អាចបង្កឱ្យមានជំងឺផ្លូវដង្ហើម និងជំងឺផ្សេងៗ។ ជំងឺដែលបង្កដោយការបំពុលខ្យល់ មានដូចជា ជំងឺផ្លូវដង្ហើម ជំងឺភ្នែក ជំងឺសើស្បែក ជំងឺសរសៃឈាមបេះដូង ជំងឺមហារីកសួត និងជំងឺផ្លូវចិត្ត។ល។

៣- វិធានការកាត់បន្ថយបំពុលខ្យល់ ៖ កាត់បន្ថយឬបញ្ឈប់ការជក់បារី កាត់បន្ថយការដុតសំណល់ កាកសំណល់សរីរាង្គអាចយកទៅកែច្នៃឡើងវិញសម្រាប់ប្រើប្រាស់ដូចជាជីកំប៉ុស ជីករណ្ដៅ ឬធ្វើឡដុតកាកសំណល់ សាងសង់ចង្ក្រានបាយនៅក្រៅផ្ទះ ដាំដើមឈើជុំវិញបរិវេណផ្ទះ ប្រើចង្ក្រានហ្គាស ឬចង្ក្រានជីវឧស្ម័ន ជំនួសចង្ក្រានអុសធ្យូង យើងត្រូវហ៊ាននិយាយប្រាប់ឪពុកម្ដាយនិងអ្នកជុំវិញខ្លួន ឱ្យកាត់បន្ថយការបំពុលខ្យល់នៅក្នុងផ្ទះ ដើម្បីសុខភាព។

**៥- វិធីសាស្ត្រ**

សំណួរបំផុស សំណួរ ចម្លើយ ពិភាក្សាក្រុម បកស្រាយ ពន្យល់

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់ (ជំហានទី១)**

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន (ជំហានទី២)**

- គ្រូរំឭកមេរៀន កែកិច្ចការផ្ទះ និងសំណួរបំផុស៖

  ១- គ្រូប្រមូលកិច្ចការផ្ទះ។ គ្រូហៅសិស្ស២ឬ៣នាក់ឱ្យឆ្លើយសំណួរកិច្ចការផ្ទះ។ ចម្លើយសិស្ស:....

  ២- តើនៅលើកមុន អ្នកបានរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ......

  ៣- តើខ្យល់គឺជាអ្វី? តើខ្យល់មានសារៈប្រយោជន៍អ្វីខ្លះ? ចម្លើយសិស្ស : ......

- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារ : ប្រភពនៃការបំពុលខ្យល់**

- គ្រូពន្យល់: ខ្យល់គឺជាល្បាយនៃឧស្ម័ន ធូលី និងអតិសុខុមប្រាណ
- គ្រូឱ្យសិស្សសង្កេតរូបភាពខាងក្រោមនិងពន្យល់ពីប្រភពនៃការបំពុលខ្យល់









- ប្រភពចម្បងៗនៃការបំពុលខ្យល់ គឺមកពីចំហេះឥន្ធនៈផូស៊ីល ការដុតជីវម៉ាស និងការដុតកាកសំណល់នៅតាមលំនៅឋាន។ ខ្យល់អាចត្រូវបានបំពុលដោយការដុតសំរាមជុំវិញផ្ទះ ការចម្អិនអាហារ ផ្សែងបារី ការដុតព្រៃ ការដុតសំណល់តាមលំនៅឋាននិងតាមសាធារណៈ និងពីយានយន្ត ទាំងនេះគឺជាប្រភពទូទៅនៃការបំពុលខ្យល់។
- គ្រូចែកសិស្សជាបួនក្រុមពិភាក្សារយៈពេល៥ទៅ១០នាទី លើសំណួរខាងក្រោម៖

  ១. តើការបំពុលខ្យល់នៅក្នុងលំនៅឋានមានអ្វីខ្លះ?

  ២. តើការបំពុលខ្យល់នៅក្រៅលំនៅឋាន ឬតាមទីធ្លាសាធារណៈមានអ្វីខ្លះ?

- តំណាងក្រុមឡើងបង្ហាញលទ្ធផល

- គ្រូសម្របសម្រួល និងសំយោគចម្លើយត្រឹមត្រូវ

ចម្លើយ: **ប្រភពចម្បងៗនៃការបំពុលខ្យល់** គឺមកពីចំហេះឥន្ធនៈផូស៊ីល ការដុតជីវម៉ាស និងការដុតកាកសំណល់នៅតាមលំនៅឋាន។

**ការបំពុលខ្យល់នៅក្នុងលំនៅឋាន** ការបំពុលខ្យល់នៅក្នុងលំនៅឋានអាចកើតឡើងពីការប្រើចង្ក្រានអុស ធ្យូងសម្រាប់ការដាំស្ល ផ្សែងបារី ផ្សែងធូប ដែលបង្កជាផ្សែងហុយនៅក្នុងផ្ទះដែលធ្វើឱ្យអ្នកស្នាក់នៅរងគ្រោះភាគច្រើនជាស្ត្រី និងកុមារដែលចំណាយពេលច្រើននៅផ្ទះ។ កុមារគួរហ៊ាននិយាយប្រាប់ ឪពុកម្តាយឱ្យកាត់បន្ថយការបំពុលខ្យល់នៅក្នុងផ្ទះដើម្បីសុខភាពខ្លួន និងសមាជិកក្នុងគ្រួសារ។

**ការបំពុលខ្យល់នៅក្រៅផ្ទះនិងទីសាធារណ**: អាចកើតឡើងដោយសារផ្សែងម៉ូតូ រថយន្ត រថភ្លើង រោងចក្រ ការដុតសំរាមនៅទីវាល ក្លិនលាមកមនុស្សនិងសត្វដែលមិនបានជីកកប់ ឬទុកដាក់បានល្អ។ ការបំពុលខ្យល់នៅក្រៅផ្ទះជាបញ្ហាសុខភាពសាធារណៈមួយព្រោះវាអាចបង្កជាជំងឺដ៏ធ្ងន់ធ្ងរដូចជាការបំពុលខ្យល់នៅក្នុងផ្ទះដែរ។

**ខ្លឹមសារ : ផលប៉ះពាល់សុខភាពបណ្តាលមកពីការបំពុលខ្យល់**

- គ្រូសួរសំណួរ៖ តើមានផលប៉ះពាល់សុខភាពអ្វីខ្លះពីការបំពុលខ្យល់? ទុកពេលឱ្យសិស្សគិតក្នុងរយៈពេលពី ២ ទៅ ៣នាទី រួចគ្រូហៅសិស្ស ២ ឬ ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្ស:...
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវ

**ចម្លើយ** : **ខ្យល់ដែលត្រូវបានបំពុលទាំងនៅក្នុងនិងក្រៅផ្ទះ** ខ្យល់ទាំងក្នុងនិងក្រៅផ្ទះ ដែលសំបូរដោយជាតិពុល ចូលទៅក្នុងខ្លួនពេលមនុស្សដកដង្ហើម អាចបង្កឱ្យមានជំងឺផ្លូវដង្ហើម និងជំងឺផ្សេងៗ បណ្តាលឱ្យស្លាប់ភ្លាមៗបានដោយសារការថប់ដង្ហើម។ ជំងឺដែលបង្កដោយខ្យល់ពុលមាន ជំងឺផ្លូវដង្ហើម ជំងឺភ្នែក ជំងឺសើស្បែក ជំងឺសសៃឈាមបេះដូង ជំងឺមហារីកសួត និងជំងឺផ្លូវចិត្ត។ល។

**ខ្លឹមសារ : វិធានការកាត់បន្ថយការបំពុលខ្យល់**

- គ្រូឱ្យសិស្សចាប់ដៃគូ២ៗនាក់ ពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៣ ទៅ ៥នាទី។
  សំណួរ៖ តើមានវិធានការកាត់បន្ថយការបំពុលខ្យល់មានអ្វីខ្លះ? ចូររៀបរាប់
- បន្ទាប់មកគ្រូហៅតំណាងសិស្ស ២ឬ៣គូឱ្យឆ្លើយ។ គ្រូណែនាំសិស្ស ឱ្យអ្នកឆ្លើយបន្ទាប់បន្ថែមលើចម្លើយរបស់អ្នកមុនឬអ្វីដែលថ្មី។
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះលើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស។

**ចម្លើយ** : វិធានការកាត់បន្ថយការបំពុលខ្យល់មានដូចជា៖

**ក- ក្នុងលំនៅឋាន**

- កាត់បន្ថយឬបញ្ឈប់ការជក់បារី

- កាត់បន្ថយការដុតសំណល់ ដោយហាមដុតពពួកកាកសំណល់សរីរាង្គដែលយើងអាចយកទៅកែច្នៃឡើងវិញសម្រាប់ប្រើប្រាស់ដូចជាជីកំប៉ុសជាដើម និងជីករណ្ដៅ ឬធ្វើឡដុតកាកសំណល់
- សាងសង់ចង្ក្រានបាយនៅក្រៅផ្ទះ ដើម្បីកាត់បន្ថយការហុយចូលនៃផ្សែងទៅក្នុងផ្ទះ
- ដាំដើមឈើជុំវិញបរិវេណផ្ទះ
- ប្រើចង្ក្រានហ្គាស ឬចង្ក្រានជីវឧស្ម័ន ជំនួសចង្ក្រានអុសធ្យូង ប្រសិនបើមានលទ្ធភាព
- យើងត្រូវហ៊ាននិយាយប្រាប់ឪពុកម្ដាយ និងអ្នកជុំវិញខ្លួន ឱ្យកាត់បន្ថយការបំពុលខ្យល់នៅក្នុងផ្ទះ ដើម្បីសុខភាព។

**ខ- ក្រៅលំនៅឋាន និងទីសាធារណៈ**

- ដាំដើមឈើជុំវិញផ្ទះ រោងចក្រ សហគ្រាស និងតាមកន្លែងទីសាធារណៈ
- កាត់បន្ថយការប្រើប្រាស់ថាមពលផូស៊ីលឥន្ធនៈ
- បំពាក់បច្ចេកទេសដើម្បីកាត់បន្ថយឧស្ម័នពុលចូលក្នុងបរិស្ថាន
- យើងត្រូវហ៊ាននិយាយប្រាប់អ្នកជុំវិញខ្លួនឱ្យកាត់បន្ថយការបំពុលខ្យល់នៅក្នុងទីសាធារណៈ ដើម្បីសុខភាព។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

ប្រភពនៃការបំពុលខ្យល់ កើតចេញពីក្នុងលំនៅឋាន ក្រៅលំនៅឋាន និងទីសាធារណៈ។ ផលប៉ះពាល់សុខភាពពីការបំពុលខ្យល់អាចបង្កឱ្យមានជំងឺផ្លូវដង្ហើម និងជំងឺផ្សេងៗ។ ជំងឺដែលបង្កដោយខ្យល់ពុលមាន ជំងឺផ្លូវដង្ហើម ជំងឺភ្នែក ជំងឺស្បែក ជំងឺសរសៃឈាមបេះដូង ជំងឺមហារីកសួត និងជំងឺផ្លូវចិត្ត។ល។ វិធានការកាត់ បន្ថយការបំពុលខ្យល់ កាត់បន្ថយឬបញ្ឈប់ការជក់បារី ដុតសំណល់ ដាំដើមឈើជុំវិញបរិវេណផ្ទះ ប្រើចង្ក្រានហ្គាស ឬចង្ក្រានជីវឧស្ម័ន ៕

## ៧- វាយតម្លៃ (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើប្រភពនៃការបំពុលខ្យល់បណ្ដាលមកពីអ្វីខ្លះ?

២- តើការបំពុលខ្យល់មានផលប៉ះពាល់ដល់សុខភាពអ្វីខ្លះ?

៣- តើអ្នកមានវិធានអ្វីខ្លះ ដើម្បីកាត់បន្ថយការបំពុលខ្យល់?

## ៨- លំហាត់ (ជំហានទី៥)

**បណ្ដាំផ្ញើ** : ចូរអ្នកយកចិត្តទុកដាក់ចូលរួមកាត់បន្ថយការបំពុលខ្យល់។

**កិច្ចការផ្ទះ** : ចូរ មើលមេរៀនការបំពុលសំឡេងនិងផលប៉ះពាល់សុខភាព សម្រាប់រៀននៅម៉ោងអប់រំសុខភាពលើកក្រោយ។

# មេរៀនទី ៣ : ការរំខានដោយសំឡេងមកលើសុខភាព

**១- រយៈពេល** : ១ ម៉ោងសិក្សា

**២- វត្ថុបំណង** : ក្រោយពេលរៀនចប់សិស្សនឹងមាន៖

| វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|
| - ពណ៌នាពីមូលហេតុ ផលប៉ះពាល់សុខភាព និងវិធានការកាត់បន្ថយសំឡេង។ | - វិភាគពីមូលហេតុ ផលប៉ះពាល់សុខភាព និងវិធានការកាត់បន្ថយសំឡេង។ | - ចូលរួមអប់រំពីផលប៉ះពាល់សុខភាពដោយសារសំឡេង និងកាត់បន្ថយសំឡេងដើម្បីសុខភាពទាំងអស់គ្នា។ |

**៣- សម្ភារ**

សៀវភៅអប់រំសុខភាពសិស្សនិងគ្រូ រូបភាព និងសម្ភារផ្សេងៗ ទៀតដែលទាក់ទងនឹងមេរៀន។

**៤- ខ្លឹមសារនិងគំនិតសំខាន់ៗ**

១- មូលហេតុនៃការបំពុលដោយសំឡេង៖ កើតឡើងដោយសារសូរសំឡេងឬរំញ័រខ្លាំងៗ និងមានភាពញឹកញាប់ ពីយានយន្ត គ្រឿងចក្រ យន្តហោះ រទេះភ្លើង រថយន្តធំៗ ម៉ាស៊ីនភ្លើង រោងចក្រ ការស្ដាប់សំឡេងខ្លាំងជាញឹកញាប់ ពីកាសប្រព័ន្ធចាក់ផ្សាយនិងឧបករណ៍បំពងសំឡេង ដូចជាទូរទស្សន៍ ម៉ាញ៉េ មេក្រូ ធុងបាស ជាដើម។

២- ផលប៉ះពាល់សុខភាពនៃការបំពុលដោយសំឡេង៖ បង្កឱ្យរំខានដល់ ដំណេក ការសិក្សា ការបំពេញការងារ ដែលធ្វើឱ្យថយចុះសមត្ថភាពប្រមូលផ្តុំអារម្មណ៍ រំខានភាពសុខនៃអារម្មណ៍ ។ល។ ការទទួលរងនូវសំឡេងខ្លាំងៗ (លើសពី ៦៥dB) ជាញឹកញាប់បណ្តាលឱ្យចុះខ្សោយសោតវិញ្ញាណ ឈឺចាប់ក្នុងត្រចៀក ទៅជាថ្លង់ក៏មាន និងអាចស្លាប់បាន។

៣- វិធានការកាត់បន្ថយសំឡេង៖ កុំបើកទូរទស្សន៍ ឬម៉ាញ៉េខ្លាំងៗ ដាក់ម៉ាស៊ីនភ្លើងឱ្យឆ្ងាយពីកន្លែងមនុស្សនិងសត្វរស់នៅ ប្រើកាសបិទត្រចៀក ពន្លត់ម៉ាស៊ីនរថយន្ត និងម៉ូតូ បើមិនចាំបាច់ យើងអាចប្រាប់ទៅឪពុកម្តាយ ឬគ្រូឱ្យមានវិធានការជួយដោះស្រាយបញ្ហា បើសិនជាមានការបំពុលដោយសំឡេង។

**៥- វិធីសាស្ត្រ**

សំណួរ ចម្លើយ ពិភាក្សាក្រុម បង្ហាញ ពន្យល់ សង្កេត

**៦- សកម្មភាពបង្រៀននិងរៀន**

**គ្រូធ្វើលំនឹងថ្នាក់** (**ជំហានទី១**)

- គ្រូពិនិត្យវត្តមាន អនាម័យ និងពង្រឹងសណ្តាប់ធ្នាប់។

**ទំនាក់ទំនងមេរៀន** (**ជំហានទី២**)

- គ្រូរំឭកមេរៀន កែកិច្ចការផ្ទះ និងសំណួរបំផុសៈ
  ១- គ្រូប្រមូលកិច្ចការផ្ទះ។ គ្រូហៅសិស្ស២ឬ៣នាក់ឱ្យឆ្លើយសំណួរកិច្ចការផ្ទះ។ ចម្លើយសិស្ស
  ២- តើនៅលើកមុន អ្នកបានរៀនអ្វីក្នុងមុខវិជ្ជាអប់រំសុខភាព? ចម្លើយសិស្ស : ............
- គ្រូសរសេរចំណងជើងដាក់លើក្តារខៀន។

**ខ្លឹមសារមេរៀនថ្មី (ជំហានទី៣)**

**ខ្លឹមសារទី១៖ មូលហេតុនៃការបំពុលដោយសំឡេង**



កម្រិតសំឡេងពីប្រភពផ្សេងៗ

- គ្រូពន្យល់ពីមូលហេតុនៃការបំពុលដោយសំឡេង៖ ការបំពុលដោយសំឡេងកើតឡើងដោយសារស្នូរសំឡេងឬរំញ័រខ្លាំងៗ និងមានភាពញឹកញាប់ ដែលមិនមែនជាស្នូរសំឡេងធម្មជាតិ មានប្រភពពីយានយន្ត ពិសេសគ្រឿងចក្រ យន្តហោះ រទេះភ្លើង រថយន្តធំៗ ម៉ាស៊ីនភ្លើង រោងចក្រ ការស្តាប់សំឡេងខ្លាំងៗជាញឹកញាប់ពីកាស ប្រព័ន្ធចាក់ផ្សាយនិងឧបករណ៍បំពងសំឡេង ដូចជាទូរទស្សន៍ ម៉ាញ៉េ មេក្រូ ផុងបាស ជាដើម។ ខ្នាតនៃសំឡេងគឺដេស៊ីបែល (dB) និងខ្នាតនៃរំញ័រគឺ ហែក្ស (Hz)។"។

**ខ្លឹមសារ : ផលប៉ះពាល់សុខភាពនៃការបំពុលដោយសំឡេង**

- គ្រូសួរសំណួរ៖ តើមានផលប៉ះពាល់សុខភាពនៃការបំពុលដោយសំឡេងមានអ្វីខ្លះ? ទុកពេលឱ្យសិស្សគិតក្នុងរយៈពេលពី ២ ទៅ ៣នាទី រួចគ្រូហៅសិស្ស ២ ទៅ ៣នាក់ ឱ្យឆ្លើយ។ ចម្លើយសិស្សៈ...
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស។

**ចម្លើយ** : ការបំពុលដោយសំឡេងបង្កឱ្យរំខានដល់ ដំណេក ការសម្រាក ការអាននិងសិក្សា ការបំពេញការងារ ដែលធ្វើឱ្យថយចុះសមត្ថភាពប្រមូលផ្តុំអារម្មណ៍ រំខានភាពសុខនៃអារម្មណ៍ ។ល។ ការទទួលរងនូវសម្លេងខ្លាំងៗ (លើសពី ៦៥dB) ជាញឹកញាប់ រយៈពេលវែងអាចបណ្តាលឱ្យ ចុះខ្សោយសោតវិញ្ញាណ ឈឺចាប់ក្នុងត្រចៀក ទៅជាថ្លង់ក៏មាន និងអាចស្លាប់បាន។

**ខ្លឹមសារ : វិធានការកាត់បន្ថយសំឡេង**

- គ្រូឱ្យសិស្សចាប់ដៃគូ២ៗនាក់ ពិភាក្សាសំណួរខាងក្រោមក្នុងរយៈពេលពី ៣ ទៅ ៥នាទី។
  សំណួរ៖ តើមានវិធានការកាត់បន្ថយការបំពុលសំឡេងអ្វីខ្លះ? ចូររៀបរាប់
- បន្ទាប់មកគ្រូហៅតំណាងសិស្ស ២ឬ៣គូឆ្លើយ។ គ្រូណែនាំសិស្សឱ្យអ្នកឆ្លើយបន្ទាប់ បន្ថែមលើចម្លើយអ្នកមុនឬអ្វីដែលថ្មី
- គ្រូកត់ត្រាចម្លើយនិងពាក្យគន្លឹះដាក់លើក្តារខៀន
- គ្រូសម្របសម្រួល សង្ខេប និងសំយោគចម្លើយត្រឹមត្រូវតាមខ្លឹមសារមេរៀនសៀវភៅសិស្ស

**ចម្លើយ** : វិធានការកាត់បន្ថយសំឡេង៖

- កុំបើកសំឡេងទូរទស្សន៍ ឬម៉ាញ៉េ ឬឧបករណ៍បំពងសំឡេងឮខ្លាំងៗនៅក្នុងផ្ទះនិងនៅទីសាធារណៈ
- ដាក់ម៉ាស៊ីនភ្លើងឱ្យឆ្ងាយពីកន្លែងមនុស្ស និងសត្វរស់នៅ
- បន្ថយសំឡេងមេក្រូឬធុងបាស់ និងបែរមេក្រូនិងធុងបាស់ចេញពីកន្លែងមានមនុស្ស
- នៅទីសាធារណៈគួរប្រើកាសបិទត្រចៀក ដើម្បីកុំឱ្យរំខានអ្នកដទៃ។ ប្រើកាសស្តាប់ចម្រៀងឬសំឡេងផ្សេងៗក្នុងកម្រិត សមស្រប ដើម្បីកុំឱ្យខូចសោតវិញ្ញាណ
- គួរប្រើកាសបិទត្រចៀកនៅទីសាធារណៈ ដើម្បីការពារពីសំឡេងរំខានខាងក្រៅ (ឧទាហរណ៍ អ្នកធ្វើការនៅព្រលានយន្តហោះ ជាដើម)
- ពន្លត់ម៉ាស៊ីនរថយន្ត និងម៉ូតូ បើមិនចាំបាច់
- កុមារអាចប្រាប់ទៅឪពុកម្តាយ ឬគ្រូឱ្យមានវិធានការជួយដោះស្រាយបញ្ហា បើសិនជាមានការបំពុលដោយសំឡេងនៅជុំវិញផ្ទះ ឬសាលារៀន ដោយពន្យល់ប្រាប់ពីការរំខាន និងផលវិបាកចំពោះខ្លួន
- ការដាំដើមឈើ និងបង្កើតទីធ្លាបៃតងក្នុងទីក្រុង មានដូចជាសួនច្បារ ឧទ្យាន ជាដើម ក៏អាចចូលរួមក្នុងការកាត់បន្ថយសំឡេងផងដែរ។

❖ គ្រូសំយោគចម្លើយនិងសង្ខេបមេរៀន រួចឱ្យសិស្សកត់ត្រាចូលក្នុងសៀវភៅ។



**មេរៀនសង្ខេប**

**មូលហេតុនៃការបំពុលដោយសំឡេង** កើតឡើងដោយសារសូរសំឡេងឬរំញ័រ ពីយានយន្ត គ្រឿងចក្រ យន្តហោះ រថភ្លើង រថយន្តធំៗ ម៉ាស៊ីនភ្លើង រោងចក្រ ការស្តាប់សំឡេងខ្លាំងៗ។ **ផលប៉ះពាល់សុខភាពនៃការបំពុលដោយសំឡេង** បង្កឱ្យរំខានដល់ ដំណេក ការសម្រាក ការអាន សិក្សា ការបំពេញការងារ ដែលធ្វើឱ្យថយចុះសមត្ថភាពប្រមូលផ្តុំអារម្មណ៍ រំខានភាពសុខនៃអារម្មណ៍។ល។ **វិធានការកាត់បន្ថយសំឡេង** គឺកុំបើកទូរទស្សន៍ ឬម៉ាញ៉េខ្លាំងៗ ដាក់ម៉ាស៊ីនភ្លើងឱ្យឆ្ងាយពីកន្លែងមនុស្សនិងសត្វរស់នៅ ប្រើកាសបិទត្រចៀក ពន្លត់ម៉ាស៊ីនរថយន្តនិងម៉ូតូ៕

## ៧- **វាយតម្លៃ** (ជំហានទី៤)

គ្រូឱ្យសិស្សរៀបរាប់ឡើងវិញ៖

១- តើមូលហេតុនៃការបំពុលដោយសំឡេងមានអ្វីខ្លះ?

២- តើផលប៉ះពាល់ដល់សុខភាពនៃការបំពុលដោយសំឡេងមានអ្វីខ្លះ?

៣- តើវិធានការកាត់បន្ថយសំឡេងត្រូវធ្វើដូចម្តេចខ្លះ?

## ៨- **លំហាត់** (ជំហានទី៥)

**បណ្តាំផ្ញើ** : ចូរអ្នកចូលរួមអប់រំពីផលប៉ះពាល់សុខភាពដោយសារសំឡេង និងកាត់បន្ថយសំឡេងដើម្បីសុខភាពទាំងអស់គ្នា។